**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Économiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការអនុវត្តច្បាប់ព្រហ្មទណ្ឌ
# អន្តរជាតិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ៖
និស្សិតឈ្មោះ **លោក តាន់គង់ លីហួរ**
**លោក ថេង សុខហេង**

ណែនាំដោយ៖
**បណ្ឌិត អ៊ឹង រដ្ឋា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី **២៤**

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **តាន់គង់ លីហួរ** និងខ្ញុំបាទឈ្មោះ **ថេង សុខហេង** ដែលជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រជំនាន់ទី ២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០២០-២០២៤។

សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោកអ្នកមានគុណទាំងពីរ** ដែលបានខិតខំប្រឹងប្រែង និងតស៊ូចិញ្ចឹមបីបាច់ថែរក្សាកូនប្រកបទៅ ដោយព្រហ្មវិហារធម៌ ផ្តល់នូវការស្រឡាញ់ ព្រមទាំងទូន្មានប្រៀនប្រដៅ ដោយគ្មានខ្លាចភាពនឿយហត់ និងចង់ឃើញ កូនទទួលបាននូវចំណេះដឹងខ្ពង់ខ្ពស់ ក៏ដើម្បីជាស្ពានសម្រាប់អនាគតកូននឹងជាធនធានសម្រាប់ប្រទេសជាតិ។ ទំហំនៃសេចក្តីស្រឡាញ់ និងការតស៊ូរបស់លោកអ្នកមានគុណទាំងពីរពុំអាចកាត់ថ្លៃបានឡើយ និងជាកាតាលីករជំរុញឆន្ទៈ និងស្មារតីរបស់កូនក្នុងការជម្នះគ្រប់ឧបសគ្គដើម្បីសម្រេចដល់គោលដៅដែលកូនចង់ប្រាថ្នា។ រាល់ពាក្យទូន្មានប្រៀនប្រដៅរបស់លោកអ្នកមានគុណ បានស្រោចស្រពដល់កូនឱ្យបានក្លាយជា កូនល្អ សិស្សល្អ ពលរដ្ឋល្អនៅក្នុងសង្គម លើសពីនេះទៀតក៏បានធ្វើឱ្យកូនចេះត្រិះរិះពិចារណាស្គាល់ខុសស្គាល់ត្រូវរហូតមកដល់សព្វថ្ងៃ។ យើងទាំងពីរសូមថ្លែងអំណរគុណលោកទាំងពីរចំពោះការយកចិត្តទុកដាក់ និងការផ្តល់កម្លាំងចិត្តកន្លងមក។

យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះ **ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង សាស្ត្រាចារ្យ និងលោកគ្រូ អ្នកគ្រូទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានអនុញ្ញាតព្រមទាំងផ្តល់ឱកាសឱ្យក្រុមយើងខ្ញុំបាន ធ្វើការស្រាវជ្រាវលើប្រធានបទមួយនេះ ពិសេសព្រមទាំងលោកគ្រូ **បណ្ឌិត អ៊ឹង រដ្ឋា** ដែលលោកគ្រូជាអ្នកណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់ក្រុមយើងខ្ញុំ ហើយលោកគ្រូបានចំណាយពេលវេលាផ្ទាល់ខ្លួនយ៉ាងមានតម្លៃក្នុងការតម្រង់ទិសសម្រាប់ស្រាវជ្រាវ និងការផ្តល់យោបល់ព្រមទាំងធ្វើការកែលម្អចំពោះចំណុចខ្វះខាត ក្នុងការសរសេរសារណា។ ទោះបីជាមានការជួបនៅឧបសគ្គជាច្រើន ក្នុងការសរសេរ លោកគ្រូតែងតែលើកទឹកចិត្ត និងណែនាំអំពីចំណុចខ្វះខាត ដោយផ្តល់ការពន្យល់យ៉ាង ក្បោះក្បាយ និងច្បាស់លាស់ដល់ក្រុមយើងខ្ញុំ។ ខ្ញុំទាំងពីរពិតជាមានសេចក្តីសោមនស្សរីករាយដែលមានលោកគ្រូ ជាអ្នកណែនាំក្នុងការសរសេរសារណាសម្រាប់ក្រុមយើងខ្ញុំ។

ជាអវសានកថា ក្រុមយើងខ្ញុំមានតែលើកដៃសូមប្រសិទ្ធពរជ័យ សិរីមង្គល និងពុទ្ធពរទាំងបួនប្រការនោះគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ជូនចំពោះលោកអ្នកមានគុណ ថ្នាក់ដឹកនាំ សាស្ត្រាចារ្យទាំងអស់ ព្រមទាំងលោកគ្រូ អ្នកគ្រូ និងមិត្តភក្តិទាំងអស់ដែលបានផ្តល់កម្លាំងចិត្ត រួមទាំងសមាជិកក្រុមក្នុងការសម្រេចនូវសារណាដើម្បីបញ្ចប់ការសិក្សាមួយនេះ។

# អារម្ភកថា

បន្ទាប់ពីយើងខ្ញុំបានឆ្លងកាត់ការសិក្សាអស់រយៈពេល ៤ឆ្នាំ នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកបរិញ្ញាបត្រនីតិសាស្ត្រ កន្លងមកនេះ យើងខ្ញុំមានការចាប់អារម្មណ៍ ទៅលើមុខវិជ្ជានីតិអន្តរជាតិសាធារណៈយ៉ាងខ្លាំង និងមានគោលបំណងចង់ទទួលបាននៅឱកាសដើម្បីបម្រើការងារក្នុងផ្នែកនីតិអន្តរជាតិសាធារណៈនេះផងដែរ។ យើងសង្ឃឹមថានៅពេលបញ្ចប់ថ្នាក់បរិញ្ញាបត្រគឺ និងរើសយកប្រធានបទមួយ ដែលទាក់ទងនឹងនីតិអន្តរជាតិសាធារណៈ មកសរសេរជាអត្ថបទសារណាដើម្បីបញ្ចប់ការសិក្សាផ្នែកនេះ។ ជាលទ្ធផលពួកយើងក៏បានដូចបំណងពិតមែន គឺនៅក្នុងឆ្នាំសិក្សាទី ៤ នេះសាលាបានតម្រូវឱ្យពួកយើងបានសរសេរសារណា ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។ ហើយខណៈនោះយើងខ្ញុំក៏បានស្នើសុំយោបល់ពីលោកគ្រូដែលមានជំនាញពាក់ព័ន្ធ ឱ្យជួយណែនាំ អំពីប្រធានបទមួយស្ដីអំពី៖ ការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ លោកគ្រូបានទទួលយកនូវការស្នើប្រធានបទរបស់ក្រុមយើងខ្ញុំ។

សារណាមួយនេះបានកើតចេញពី ការខិតខំប្រឹងប្រែងតាំងពីឆ្នាំមូលដ្ឋាន មកដល់ពេលនេះទើបធ្វើឱ្យយើងអាចបកស្រាយ ប្រធានបទអំពី ការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ ប្រធានបទរបស់យើងបានចងក្រងឡើងដោយ យើងខ្ញុំបានរកមើលគ្រប់ឯកសារដែលបានពាក់ព័ន្ធទាំងអស់ ហើយឯកសារទាំងអស់នោះភាគច្រើនគឺជា ឯកសារអន្តរជាតិ ដែលទាមទារឱ្យក្រុមយើងខ្ញុំត្រូវធ្វើការបកប្រែ និងព្រមទាំងពុំសូវមានសវតានៃការស្រាវជ្រាវពីមុនមកនោះទេ។ តែទោះជាយ៉ាងណាបណ្ណាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានផ្ដល់នូវឯកសារមួយចំនួនសម្រាប់ជួយសម្រួលដល់ការស្រាវជ្រាវនេះ ដែលជាការទាក់ទាញមួយឱ្យយើងទាំងពីរលើកយកប្រធានបទមួយនេះមកធ្វើសរសេរ។ យើងខ្ញុំជឿជាក់ថាប្រធានបទនេះ មានលក្ខណៈពិសេសប្លែកពីគេទាំងខ្លឹមសារ និងពាក្យមួយចំនួន ម្យ៉ាងវិញទៀតដោយសារតែ ប្រធានបទមួយនេះវាមានវិសាលភាពធំទូលាយ យើងខ្ញុំសុំលើកយកតែចំណុចសំខាន់ៗប៉ុណ្ណោះមកធ្វើការបកស្រាយ ប៉ុន្តែដោយសារពាក្យបច្ចេកទេសមួយចំនួនពុំមានអត្ថន័យចំជាភាសាខ្មែរនោះឡើយ ដែលមូលហេតុនេះហើយ នាំឱ្យវាមានការលំបាកក្នុងការបកប្រែភាសាបច្ចេកទេស ច្បាប់អន្តរជាតិ មកជាភាសាខ្មែរឱ្យត្រូវទៅតាមអត្ថន័យ។

ដូច្នេះហើយយើងខ្ញុំ សូមធ្វើការអភ័យទោសទុកជាមុន ចំពោះចំណុចខ្វះខាត ឬកំហុសឆ្គងក្នុងអត្ថន័យត្រង់កន្លែងណាមួយធ្វើឱ្យមានលក្ខណៈមិនគ្រប់ជ្រុងជ្រោយដល់មិត្តអ្នកអាន ព្រមទាំងអ្នកស្រាវជ្រាវទាំងអស់។ យើងខ្ញុំក៏សូមទទួលយកនូវមតិរិះគន់ពី សំណាក់ លោកលោកស្រី សាស្ត្រាចារ្យ សិស្សនិស្សិត គ្រប់មជ្ឈដ្ឋានទាំងអស់ដើម្បី កែលម្អអត្ថបទស្រាវជ្រាវមួយនេះ ដោយក្ដីគោរពរាប់អានយ៉ាងជ្រាលជ្រៅជាទីបំផុតដើម្បីធ្វើឱ្យសារណាមួយនេះកាន់តែមានភាពល្អប្រសើរឡើង។

# មាតិកា

**សេចក្ដីផ្ដើម** ..................................................... ១

## ជំពូកទី១

## សញ្ញាណទូទៅនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ

**ផ្នែកទី១៖ ប្រវត្តិតុលាការព្រហ្មទណ្ឌអន្តរជាតិ** ..................................................... ៥

**កថាខណ្ឌទី១៖ ការវិវត្តនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ** ..................................................... ៥

១.សំណើដំបូងនៃការបង្កើត តុលាការព្រហ្មទណ្ឌអន្តរជាតិ ..................................................... ៥

២.សេចក្ដីព្រាងច្បាប់ក្នុងការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ..................................................... ៧

២.១.ការកើតឡើងជាស្ថាពររបស់ តុលាការព្រហ្មទណ្ឌអន្តរជាតិ ..................................................... ៨

**កថាខណ្ឌទី២៖ រចនាសម្ព័ន្ធរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ** ..................................................... ៨

១.អង្គការចាត់តាំងរបស់តុលាការ ..................................................... ៨

១.១.ធិបតីប្រធាន ..................................................... ៨

១.២.អង្គជំនុំជម្រះ ..................................................... ៩

១.២.១.អង្គមុនជំនុំជម្រះ ..................................................... ៩

១.២.២.អង្គជំនុំជម្រះដំបូង ..................................................... ១០

១.២.៣.អង្គជំនុំជម្រះឧទ្ធរណ៍ ..................................................... ១១

១.២.៤.ការជ្រើសរើសចៅក្រម ..................................................... ១១

១.៣.ការិយាល័យរដ្ឋអាជ្ញា ..................................................... ១២

១.៤.ការិយាល័យក្រឡាបញ្ជី ..................................................... ១២

២.អំពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ..................................................... ១៣

២.១.បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់បុគ្គលពាក់ព័ន្ធ ..................................................... ១៤

២.២.ការបដិសេធបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ..................................................... ១៤

**ផ្នែកទី២៖ ចក្ខុវិស័យ និងបេសកកម្មរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ** ..................................................... ១៥

**កថាខណ្ឌទី១៖ ចក្ខុវិស័យ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ**........................................ ១៥
១.ចក្ខុវិស័យ ........................................ ១៥
២.បេសកកម្ម........................................ ១៥
**កថាខណ្ឌទី២៖ គោលបំណង និងសារៈសំខាន់ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ**........ ១៥
១.គោលបំណង ........................................ ១៥
២.សារៈសំខាន់នៃការអនុវត្តច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ........................................ ១៦
**កថាខណ្ឌទី៣៖ ទំនាក់ទំនងអង្គការសហប្រជាជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ** .. ១៦
១.ឯករាជ្យភាពរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ........................................ ១៦
២.ភាពពាក់ព័ន្ធរវាងស្ថាប័នទាំងពីរ ........................................ ១៧

## ជំពូកទី២

## ដំណើរការនៃការអនុវត្តច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

**ផ្នែកទី១៖ គោលការណ៍ទូទៅរបស់តុលាការ**........................................ ១៨
**កថាខណ្ឌទី១៖ គោលការណ៍ទូទៅ ក្នុងការអនុវត្តច្បាប់**........................................ ១៨
១.គោលការណ៍ នីត្យានុកូលភាព ........................................ ១៨
១.១.គ្មានបទល្មើសព្រហ្មទណ្ឌ បើសិនគ្មានច្បាប់ចែង ........................................ ១៨
១.២.គ្មានទោសបើគ្មានច្បាប់កំណត់ ........................................ ១៩
២.គោលការណ៍មិនជំនុំជម្រះពីរដង ........................................ ១៩
**កថាខណ្ឌទី២៖ គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌអន្តរជាតិ**........................ ២០
១.ការទទួលខុសត្រូវព្រហ្មទណ្ឌអន្តរជាតិ........................................ ២០
១.១ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់មេបញ្ជាការ និងថ្នាក់លើផ្សេងៗទៀត ........................ ២១
១.២.អំពីមូលហេតុនៃការរួចផុតពីការទទួលខុសត្រូវរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ........................ ២២
១.២.១.អំពីការច្រឡំលើអង្គហេតុ ឬអង្គច្បាប់........................................ ២៣
២.គ្មានលក្ខណៈប្រតិសកម្ម និងមិនមានការអនុវត្តអាជ្ញាយុកាល ........................................ ២៣

**ផ្នែកទី២៖ ច្បាប់ក្នុងការអនុវត្ត របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ** .............................. ២៤

**កថាខណ្ឌទី១៖ អំពីច្បាប់ដែលត្រូវយកមកអនុវត្តន៍** .............................. ២៤

១.ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម .............................. ២៤

២.វិធាននៃនីតិវិធី និងភស្តុតាង .............................. ២៤

៣.សន្ធិសញ្ញា គោលការណ៍ និងវិធាននៃច្បាប់អន្តរជាតិ .............................. ២៥

៤.យុត្តិសាស្ត្ររបស់តុលាការ .............................. ២៦

**កថាខណ្ឌ២៖ យុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ** .............................. ២៦

១.បទល្មើសស្ថិតក្នុងដែនយុត្តាធិការ .............................. ២៦

១.២.ករណីសិក្សា (ប្រទេស ប៉ាឡេស្ទីនការប្រកាសទទួលយកយុត្តាធិការ) .............................. ២៧

២.ការផ្តួចផ្តើមក្នុងការអនុវត្តយុត្តាធិការ .............................. ២៨

២.១.ការអនុវត្តច្បាប់ .............................. ២៨

២.១.១.ការផ្តួចផ្តើមការអនុវត្តច្បាប់ដោយរដ្ឋភាគី .............................. ២៨

២.១.២.ការផ្តួចផ្តើមដោយក្រុមប្រឹក្សាសន្តិសុខ (UNSC) .............................. ២៩

២.១.៣.ការផ្តួចផ្តើមពីរដ្ឋអាជ្ញា .............................. ៣០

២.១.៣.១.ករណីសិក្សា (ក្រុមភេរវករ អាល់កៃដា) .............................. ៣១

**ផ្នែកទី៣៖ ការពិនិត្យបឋមលើស្ថានការណ៍** .............................. ៣២

**កថាខណ្ឌទី១៖ ធាតុផ្សំនៃការពិនិត្យបឋម** .............................. ៣២

១.ការវាយតម្លៃបឋម .............................. ៣៣

១.១.បទល្មើស និងគោលការណ៍ទូទៅ .............................. ៣៣

២.អំណាចយុត្តាធិការរបស់តុលាការ.............................. ៣៤

២.១.ភាពមិនប្រតិសកម្មនៃច្បាប់ .............................. ៣៤

២.២.ប្រធានបទនៃបទល្មើស .............................. ៣៤

៣.អំពីភាពដែលអាចទទួលយកបាន……………………………………………………………………៣៦

៣.១.ការបំពេញបន្ថែម ..........................................................................................................៣៦

៣.១.១.កត្តាក្នុងការបំពេញបន្ថែម........................................................................................ ៣៧

៣.២.បន្ទុកនៃភស្តុតាង............................................................................................................ ៣៧

៣.២.១.ករណីសិក្សា (ប្រទេសអ៊ីរ៉ាក់) .................................................................................... ៤០

៤.ផលប្រយោជន៍នៃយុត្តិធម៌ .................................................................................................. ៤១

**កថាខណ្ឌទី២៖ ការចាប់ផ្តើមនៃការស៊ើបអង្កេត**..........................................................................៤៣

១.ការស៊ើបអង្កេត.....................................................................................................................៤៣

១.២.ការអភិវឌ្ឍ ក្នុងការស៊ើបអង្កេត ......................................................................................... ៤៤

២.កិច្ចសហប្រតិបត្តិការ រដ្ឋភាគី ............................................................................................. ៤៤

២.១.សំណើសុំកិច្ចសហប្រតិបត្តិការ ........................................................................................ ៤៦

២.២.សារៈសំខាន់របស់រដ្ឋភាគីក្នុងការអនុវត្តច្បាប់.......................................................................... ៤៦

២.២.១.ករណីសិក្សា (ម៉ាឡាវី ឆាដ និងជីប៊ូទី) ..............................................................................៤៧

៣.ការពន្យារពេលនៃការស៊ើបអង្កេត ........................................................................................ ៤៨

៣.១.ក្រុមប្រឹក្សាសន្តិសុខ............................................................................................................ ៤៨

៣.២.រដ្ឋភាគី........................................................................................................................... ៤៩

៤.ការបោះបង់ការស៊ើបអង្កេត ................................................................................................... ៥០

**កថាខណ្ឌទី៣៖ ដំណាក់កាលមុនការជំនុំជម្រះ** ............................................................................... ៥០

១.សមត្ថកិច្ចអង្គមុនជំនុំជម្រះ...................................................................................................... ៥១

១.១.ដីកាចាប់ខ្លួន ឬដីកាកោះហៅ.................................................................................................. ៥១

១.២.កាតព្វកិច្ចរបស់រដ្ឋភាគីដើម្បីសហប្រតិបត្តិការ.............................................................................៥២

១.២.១.នីតិវិធីក្រោមច្បាប់ជាតិ.......................................................................................................៥២

១.២.២.ការចាប់ខ្លួនបណ្តោះអាសន្ន....................................................................................................៥២
១.២.៣.ការប្រគល់ជនត្រូវចោទទៅឱ្យតុលាការ...............................................................................៥៣
១.២.៣.១.លក្ខខណ្ឌក្នុងការស្នើ...................................................................................................៥៣
២.វត្តមានរបស់ជនត្រូវចោទ.................................................................................................................. ៥៤
៣.ការបញ្ជាក់អំពីការចោទប្រកាន់ ......................................................................................................... ៥៥
៣.១.ការជំទាស់ការចោទប្រកាន់ ............................................................................................................ ៥៦
៣.១.១.ករណីសិក្សា (ប្រទេសកូតឌីវ័រ) ...................................................................................................៥៧
**ផ្នែកទី៤៖ ដំណាក់កាលការជំនុំជម្រះ** ...................................................................................................... ៥៨
**កថាខណ្ឌទី១៖ ផ្នែកជំនុំជម្រះដំបូង**........................................................................................................ ៥៨
១.ទីតាំងសម្រាប់ជំនុំជម្រះ ..................................................................................................................... ៥៨
១.១.វត្តមានជនជាប់ចោទ........................................................................................................................ ៥៩
១.២.ឯកសារពាក់ព័ន្ធ និងការជំនុំជម្រះ.................................................................................................... ៥៩
២.សមត្ថកិច្ចរបស់អង្គជំនុំជម្រះ.............................................................................................................. ៦០
**កថាខណ្ឌទី២៖ ការបើកសវនាការ ជំនុំជម្រះ** ........................................................................................... ៦១
១.ការធ្វើសេចក្តីថ្លែងការណ៍................................................................................................................... ៦១
២.ការបង្ហាញភស្តុតាង...........................................................................................................................៦២
២.១.ភស្តុតាង.........................................................................................................................................៦២
២.១.១.ការផ្តល់សក្ខីកម្ម របស់សាក្សី..........................................................................................................៦២
២.១.១.១.លក្ខខណ្ឌក្នុងការផ្តល់សក្ខីកម្ម......................................................................................................៦៣
២.១.១.២.អំពីព័ត៌មាន ឯកសាររបស់តតិយជន................................................................................................ ៦៤
**កថាខណ្ឌទី៣៖ ការសម្រេចសេចក្តី របស់ចៅក្រម** ..................................................................................... ៦៥
១.វត្តមានរបស់ចៅក្រម.......................................................................................................................... ៦៥

២.នីតិវិធីក្នុងការសម្រេច ........ ៦៥

២.១.ដែនកំណត់ក្នុងការសម្រេច ........ ៦៦

៣.ការប្រកាសសាលក្រម........ ៦៦

៣.១.លក្ខខណ្ឌក្នុងការប្រកាស ........ ៦៦

៣.១.១.វិធានអន្តរជាតិ និងការប្រកាសសាលក្រម........៦៧

៣.១.១.១.អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស........៦៧

៣.១.១.២.កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ........៦៧

៣.២.រយៈពេលសម្រាប់ប្រកាស ........ ៦៨

**ផ្នែកទី៥៖ អង្គជំនុំជម្រះជាន់ខ្ពស់** ........ ៦៨

**កថាខណ្ឌទី១៖ បណ្តឹងឧទ្ធរណ៍** ........ ៦៩

១.លក្ខខណ្ឌក្នុងការប្តឹង........ ៦៩

១.២.កំហុសផ្នែកនីតិវិធី........ ៦៩

១.៣.កំហុសនៃអង្គហេតុ........ ៦៩

១.៤.កំហុសនៃអង្គច្បាប់ ........៧០

២.មូលហេតុនៃទោស........៧០

**កថាខណ្ឌទី២៖ អំពីការប្តឹងឧទ្ធរណ៍ប្រឆាំងសេចក្តីសម្រេចផ្សេងៗ** ........៧១

១.នីតិវិធីក្នុងបណ្តឹងឧទ្ធរណ៍ ........៧១

២.បណ្តឹងសើរើលើសេចក្តីសម្រេចថាមាន ឬគ្មានពិរុទ្ធភាព........៧២

២.១.មូលហេតុនៃការប្តឹង........៧២

៣.ការប្រកាសសាលដីកា ........ ៧៣

## ជំពូកទី៣

## ការអនុវត្តសាលក្រម និងសាលដីការបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

**ផ្នែកទី១៖ អំពីតួនាទីរបស់រដ្ឋភាគីក្នុងការអនុវត្តដាក់ទោសពន្ធនាគារ** ........៧៥

**កថាខណ្ឌទី១៖ សិទ្ធិរបស់តុលាការក្នុងការចាត់តាំង រដ្ឋភាគី** ........ ៧៥
១.ការដាក់លក្ខខណ្ឌ ........ ៧៦
១.១.អំពីការដាក់ឱ្យអនុវត្តន៍ទោស ........ ៧៦
១.២.ទណ្ឌកម្ម ........ ៧៧
២.ការត្រួតពិនិត្យ និងលក្ខខណ្ឌដាក់ឱ្យអនុវត្តន៍ទោសពន្ធនាគារ ........ ៧៧
២.១.ការកម្រិតដែនកំណត់នាំយកទៅជំនុំជម្រះ ឬការដាក់ទោសចំពោះបទល្មើសផ្សេង ........ ៧៧
**កថាខណ្ឌទី២៖ អំពីការត្រួតពិនិត្យដោយតុលាការលើការបន្ធូរបន្ថយទោស** ........ ៧៨
១.ការពិចារណាបន្ធូរបន្ថយទោស ........ ៧៨
២.អំពីការផ្ទេរជននោះនៅពេលបញ្ចប់ការដាក់ទោស ........ ៧៨
**ផ្នែកទី២៖ សំណងសម្រាប់ជនរងគ្រោះ** ........ ៧៩
**កថាខណ្ឌទី១៖ គោលការណ៍នៃសំណង** ........ ៧៩
១.ការរួមផ្សំនៃវិធានផ្សេងៗ ........ ៧៩
២.នីតិវិធីក្នុងការធ្វើសំណង ........ ៨០
២.១.លក្ខខណ្ឌនៃការធ្វើសំណង ........ ៨១
២.១.១ការអនុវត្តរបស់តុលាការ ........ ៨១
២.២.អ្នកទទួលផលនៃសំណង ........ ៨២
**កថាខណ្ឌទី២៖ ការសងជំងឺចិត្តលើជនត្រូវបានចាប់ខ្លួន ឬសម្រេចថាមានពិរុទ្ធភាព** ........ ៨៣
១.ការសងជំងឺចិត្តជនរងគ្រោះដោយសារការចាប់ខ្លួន ........ ៨៣
១.១.ការអនុវត្តចំពោះសំណងសម្រាប់ការផ្តន្ទាទោសដោយអយុត្តិធម៌ ........ ៨៣
២.កាលៈទេសៈពិសេសដែលចាត់ទុកជាកំហុសធ្ងន់ ........ ៨៤
**សេចក្តីសន្និដ្ឋាន** ........ ៨៥
**អនុសាសន៍** ........ ៨៧
**ឯកសារយោង**

## ឧបសម្ព័ន្ធ

# អក្សរកាត់

| | |
|---|---|
| ICC | = International Criminal Court<br>(តុលាការព្រហ្មទណ្ឌអន្តរជាតិ) |
| ICJ | = International Court of Justice<br>(តុលាការយុត្តិធម៌អន្តរជាតិ) |
| ICTY | = International Criminal Tribunal for The Formers Yugoslavia<br>(តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី) |
| ICTR | =United Nation International Criminal Tribunal for Rwanda<br>(តុលាការឧក្រិដ្ឋកម្មអន្តរជាតិ របស់អង្គការសហប្រជាជាតិ សម្រាប់ប្រទេសរ៉វាន់ដា) |
| INTERPOL | = The International Criminal Police Organization<br>(អង្គការប៉ូលិសឧក្រិដ្ឋកម្មអន្តរជាតិ) |
| UN | = United Nation<br>(អង្គការសហប្រជាជាតិ) |
| UNSC | = United Nations Security Council<br>(ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ) |
| DOC | = Document<br>(អត្ថបទ ឯកសារ) |
| IGOS | = Intergovernmental Organizations<br>(អង្គការអន្តររដ្ឋាភិបាល) |
| NGOS | = Non-Governmental Organizations<br>(អង្គការក្រៅរដ្ឋាភិបាល) |
| IMT | = International Military Tribunal<br>(តុលាការយោធាអន្តរជាតិ) |

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

បន្ទាប់ពីមនុស្សជាតិបានរស់នៅជាមួយសង្គ្រាម ដែលពោរពេញទៅដោយការកាប់សម្លាប់ និងការរំលោភបំពានដោយសារតែជម្លោះផ្សេងៗ ដែលកើតឡើងដោយប្រទេសមហាអំណាចនានា ក្នុងពិភពលោកក៏ដូចជា នយោបាយ ឬការឈ្លានពានដែលបានបំផ្លាញ សន្តិភាពផ្តល់នូវទុក្ខវេទនាសម្រាប់ជីវិតយ៉ាងច្រើន ដោយមើលឃើញពីការលំបាកនេះហើយទើបបណ្តាលឱ្យប្រទេសមួយចំនួនបានចូលរួមបង្កើត អង្គការអន្តរជាតិជាច្រើនដែលបង្ហាញពីគោលបំណងក្នុងការរក្សាសន្តិភាព ធានាសន្តិសុខអន្តរជាតិ និងរឹតចំណងទំនាក់ទំនងរវាងប្រជាជាតិនីមួយៗ នៅលើពិភពលោកក្នុងសហប្រតិបត្តិការ សេដ្ឋកិច្ច សង្គម និងវប្បធម៌ដែលមានដូចជា អង្គការសហប្រជាជាតិ សហភាពអឺរ៉ុប សមាគមអាស៊ាន និងស្ថាប័នផ្សេងៗ ទៀតជាដើម។ តួយ៉ាងគេយល់ឃើញថា មូលហេតុដែលបណ្តាលឱ្យមានការបាត់បង់ជីវិតភាគច្រើនគឺជា បទល្មើសព្រហ្មទណ្ឌអន្តរជាតិដ៏ធ្ងន់ធ្ងរទាំងឡាយ ហើយករណីនេះបានគំរាមកំហែងដល់សន្តិសុខ ពិភពលោកយ៉ាងខ្លាំងដូច្នេះហើយទើបយើងឃើញមានស្ថាប័នពិសេសមួយដែលបង្កើតសម្រាប់ដាក់ទោសលើបុគ្គលរូបណាដែល បង្កឱ្យមាននូវការកាប់សម្លាប់រង្គាលផ្សេងៗ ទៅលើជីវិតមនុស្សជាតិ ដែលការគាំពារជីវិតមនុស្សទាំងនោះស្ថិតក្រោមដែនសមត្ថកិច្ចរបស់ស្ថាប័នអន្តរជាតិមួយហៅថា តុលាការព្រហ្មទណ្ឌអន្តរជាតិ។ តុលាការនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការលុបបំបាត់នូវអំពើហិង្សាឃោរឃៅជាសកល។ តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺជាតុលាការ បង្កើតឡើងដើម្បីកាត់ទោសបុគ្គលដែលបានប្រព្រឹត្ត ឧក្រិដ្ឋកម្ម និងទទួលខុសត្រូវចំពោះសកម្មភាពទាំងអស់នោះ។ តុលាការនេះក៏ជាតុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ដែលបំពេញបន្ថែមដល់តុលាការជាតិ ក្នុងការដោះស្រាយបទល្មើស ដែលជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរកំពុងកើតមាន។ ការកើតឡើងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺដើម្បីធ្វើការឆ្លើយតបទៅនិងការទទួលស្គាល់ថា មិនអាចមានសន្តិភាពដោយគ្មានយុត្តិធម៌ គ្មានយុត្តិធម៌ដោយច្បាប់ និងគ្មានច្បាប់ដែលមានអត្ថន័យ បើគ្មានតុលាការដែលជាអ្នកសម្រេចថាអ្វីដែលត្រឹមត្រូវ និងស្របច្បាប់នៅក្រោមវិធានអន្តរជាតិ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយគោលបំណងទាំងអស់នេះអាចទទួលបានជោគជ័យវាពាក់ព័ន្ធជាមួយដំណើរការអនុវត្តច្បាប់ និងការសហការពីស្ថាប័នផ្សេងៗ ឬរដ្ឋដែលជាភាគី របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ចំណុចនេះក៏បានបង្ហាញឱ្យឃើញនៅការប្រឈមមុខទៅនឹងបញ្ហាជាច្រើន រួមទាំងការអនុវត្តកិច្ចសហប្រតិបត្តិការជាមួយរដ្ឋភាគី (ភាពស្របច្បាប់ សិទ្ធិអំណាច) និងភាពលំអៀងណាមួយដែលអាចកើតមាន ឬឧបសគ្គនយោបាយដែលអនុវត្តន៍ ដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ចំពោះការអនុវត្តសិទ្ធតុលាការ។ បញ្ហាប្រឈមទាំងនេះបាននាំឱ្យមាននៅចម្ងល់ដែលពាក់ព័ន្ធទៅនឹងប្រធានបទមួយដែលនិយាយពីដំណើរនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីការពារជីវិតមនុស្សជាតិឱ្យជៀសផុតពីការកាប់សម្លាប់រង្គាលទាំងអស់ក្នុងសកលលោក លុះត្រាតែការអនុវត្តច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានប្រព្រឹត្តទៅដោយរលូន និងការមានការចូលរួមពីភាគីផ្សេងៗ ដូច្នេះការស្រាវជ្រាវលើប្រធានបទនេះ បានធ្វើឡើងដោយឆ្លើយតបទៅនឹងសំណួរដូចខាងក្រោមនេះ៖

- តើភាពពាក់ព័ន្ធក្នុងដំណើរការអនុវត្តច្បាប់ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានប្រព្រឹត្តទៅយ៉ាងដូចម្តេចខ្លះ?
- តើរដ្ឋភាគីមានកាតព្វកិច្ចអ្វីខ្លះ ក្នុងការចូលរួមសហការជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

គោលបំណងចំពោះការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំចង់ឱ្យ មិត្តនិស្សិត មិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវ និងសាធារណជនទាំងអស់បានយល់ដឹងអំពី របៀបរបបនៃដំណើរការក្នុងការអនុវត្តនូវច្បាប់ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ជាពិសេសភាពពាក់ព័ន្ធផ្សេងៗ ដែលជាកត្តាចម្បងដែលចូលរួមយ៉ាងសំខាន់ ក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិនេះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះមានទំហំ និងដែនកំណត់ច្បាស់លាស់។ ចំពោះការសិក្សាស្រាវជ្រាវ ប្រធានបទក្រុមយើងខ្ញុំ និងលើកយកមកបង្ហាញអំពី ដំណាក់កាល ឬចំណុចដែលមានក្នុងដំណើរនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់តុលាការព្រហ្មទណ្ឌអន្តជាតិ និងការពាក់ព័ន្ធផ្សេងៗ ដែលមានក្នុងការអនុវត្ត ក៏រំលេចនូវវិធីសាស្ត្រមួយចំនួន អមជាមួយករណីសិក្សាដែលកើតមានឡើងជាក់ស្តែង ក្នុងព្រឹត្តិការណ៍អន្តរជាតិកន្លងមកដើម្បីធ្វើការពន្យល់ឱ្យកាន់តែស៊ីជម្រៅ និងងាយស្រួលសម្រាប់ការស្វែងយល់ក្នុងប្រធានបទនេះ។ ក្នុងដែនកំណត់នៃការស្រាវជ្រាវអំពីប្រធានបទ ការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានធ្វើឡើងចាប់ពីថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០២៤ រហូតដល់ ក្នុងថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានសារប្រយោជន៍ណាស់សម្រាប់ក្រុមនិស្សិតស្រាវជ្រាវ និងសង្គមសម្រាប់ជាឯកសារជំនួយក្នុងការសិក្សារៀនសូត្រ៖

– សារប្រយោជន៍ចំពោះក្រុមនិស្សិត៖ ស្វែងយល់ពីការអនុវត្តច្បាប់លក្ខណៈអន្តរជាតិ យល់អំពីទិដ្ឋភាពចំពោះការដោះស្រាយបញ្ហាដែលកើតក្នុងដែនយុត្តាធិការរបស់អន្តរជាតិ លើសពីនេះក្រុមនិស្សិត និង

ទទួលបានចំណេះដឹងកាន់តែទូលំទូលាយ ក្នុងការអភិវឌ្ឍខ្លួនដើម្បីទទួលយកនៅឱកាសការងារថ្មីៗ នាពេលអនាគត ព្រមទាំងជាស្ពានក្នុងការបន្តការសិក្សាទៅថ្នាក់អនុបណ្ឌិត។

– សារប្រយោជន៍ចំពោះសង្គម៖ ជាទុនសម្រាប់សាធារណជន និងនិស្សិតជំនាន់ក្រោយក្នុងការសិក្សាស្រាវជ្រាវបន្តជួយសម្រួលក្នុងការសិក្សាស្រាវជ្រាវឱ្យកាន់តែរហ័ស យោងតាមរយៈទិន្នន័យនេះ។ ទុកជាបទពិសោធ និងគំនិតមួយចំនួនសម្រាប់ជំនួយស្មារតីដល់និស្សិត ជំនាន់ក្រោយក្នុងការស្រាវជ្រាវ ឬការស្វែងរកប្រធានបទថ្មី សម្រាប់ការស្រាវជ្រាវ។

– ឯកសារជំនួយក្នុងការស្រាវជ្រាវ៖ ឯកសារដែលបានដកស្រង់ ក្នុងការសរសេរសារណានេះភាគច្រើនសុទ្ធតែជាឯកសារផ្លូវការ ដែលបានបោះពុម្ព និងការទទួលស្គាល់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ អត្ថន័យដែលមានក្នុងឯកសារនេះ ក៏អាចរំលេចនូវព័ត៌មានផ្សេងៗ ដែលអ្នកសិក្សាស្រាវជ្រាវ កំពុងតែស្វែងរក ដែលពាក់ព័ន្ធជាមួយនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ។

# ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

## ៦.១.ប្រភេទទិន្នន័យ និងបច្ចេកទេសប្រមូលទិន្នន័យ

### ៦.១.១.ប្រភេទទិន្នន័យ

ទិន្នន័យសម្រាប់ការស្រាវជ្រាវលើប្រធាននេះត្រូវបានបែងចែងចេញជាពីរ ដែលមានដូចជា ទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ។

#### ៦.១.១.១.ទិន្នន័យចម្បង

ទិន្នន័យចម្បងជាទិន្នន័យដែលក្រុមស្រាវជ្រាវ យកពីឯកសារផ្លូវការរបស់គេហទំព័រ តុលាការព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់គ្រឹះដែលជានៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

#### ៦.១.១.២.ទិន្នន័យបន្ទាប់បន្សំ

ចំពោះការប្រមូលទិន្នន័យបន្ទាប់បន្សំវិញគឺជា ទិន្នន័យដែលក្រុមរបស់យើងខ្ញុំធ្វើការស្រាវជ្រាវទៅលើប្រភពឯកសារផ្លូវការ ដែលមានស្រាប់នានាដូចខាងក្រោម៖

- ឯកសារដែលមានស្រាប់នៅក្នុងបណ្ណាល័យនានា
- ឯកសារនានាដែលបោះពុម្ពរួចបានពីការសិក្សាស្រាវជ្រាវ
- ឯកសាររបស់អង្គការអន្តរជាតិឬស្ថាប័ននានាសហប្រតិបត្តិការដែលជាប់ពាក់ព័ន្ធជាមួយនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ។

### ៦.១.២.បច្ចេកទេសប្រមូលទិន្នន័យ

បច្ចេកទេសក្នុងការប្រមូលទិន្នន័យ គឺក្រុមយើងខ្ញុំ បែងចែកចេញពីរដំណាក់កាល ដោយក្នុងដំណាក់កាលដំបូងធ្វើជាការអាន និងសិក្សាស្រាវជ្រាវហើយធ្វើការប្រមូលបង្កើតជាមាតិកា ឬធ្វើជាឯកសារគោលក្នុងការស្រាវជ្រាវដែលឆ្លើយតបទៅ និងប្រធានបទ ហើយដំណាក់កាលបន្ទាប់គឺធ្វើការបញ្ជូនឱ្យលោកគ្រូ ដឹកនាំ ដើម្បីធ្វើការត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងធ្វើការកែលម្អដោយផ្អែកទៅតាមការផ្តល់យោបល់ របស់លោកគ្រូដឹកនាំ។ ជាចុងក្រោយទទួលបាននៅទម្រង់ជាឯកសារដែលមាន លក្ខណៈគ្រប់គ្រាន់ត្រូវតាមស្តង់ដា របស់សាកលវិទ្យាល័យដើម្បីធ្វើការប្រគល់ជូនគណៈកម្មការ។

#### ៦.១.២.១.បច្ចេកទេសវិភាគទិន្នន័យ

លទ្ធផលដែលក្រុមទទួលបានពី ឯកសារនានា ឬដែលបានមកពីការសួរទៅកាន់លោកគ្រូផ្ទាល់ ដែលធ្វើការពណ៌នា ទៅតាមគោលបំណងនៃមាតិកា ក្នុងប្រធានបទនៃការស្រាវជ្រាវនេះ។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណារបស់យើងខ្ញុំនឹងធ្វើការលើកយក ដំណើរនៃការអនុវត្តច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ មកធ្វើការបកស្រាយអំពី សារៈសំខាន់មួយចំនួនក្នុងដំណើរនៃការអនុវត្ត អមជាមួយករណីជាក់ស្តែងដែលធ្លាប់ កើតមានក្នុងព្រឹត្តិការណ៍ អន្តរជាតិមកបង្ហាញ ដោយយើងខ្ញុំបាទបានបន្តចេញជា **៣ ជំពូក** ដែលមាន ៖

**ជំពូកទី១** និយាយអំពី៖ សញ្ញាណទូទៅ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ

**ជំពូកទី២** និយាយអំពី៖ ដំណើរការនៃការអនុវត្តច្បាប់របស់ តុលាការព្រហ្មទណ្ឌអន្តរជាតិ

**ជំពូកទី៣** និយាយអំពី៖ ការអនុវត្តសាលក្រម និងសាលដីការបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

# ជំពូកទី១

# សញ្ញាណទូទៅនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ

# ជំពូកទី១

# សញ្ញាណទូទៅនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ

តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានគេស្គាល់យ៉ាងទូលំទូលាយថាជាស្ថាប័នមួយដែលជាផ្នែកមួយនៃនីតិអន្តរជាតិដែលមានយុត្តាធិការទៅលើរឿងព្រហ្មទណ្ឌដែលកើតឡើងក្រោមរូបភាពជា បទល្មើសដែលកំណត់ថា ជាករណីមានកម្រិតធ្ងន់ធ្ងរជាប់ទាក់ទងទៅ និងកាប់សម្លាប់ ដែលសហគមន៍អន្តរជាតិទាំងមូលមានការព្រួយបារម្ភ។ កន្លងមកយើងបានលើកឡើងរួចមកហើយថា តុលាការព្រហ្មទណ្ឌអន្តរជាតិបង្កើតឡើងដើម្បីបំពេញបន្ថែមទៅលើយុត្តាធិការជាតិរបស់ប្រទេសជារដ្ឋភាគី ដែលបង្កឱ្យកើតមាននូវការកាប់សម្លាប់ជីវិតមនុស្សយ៉ាងធ្ងន់ធ្ងរក្រោមសកម្មភាពផ្សេងៗ ដែលត្រូវបានកំណត់ក្នុងនៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយគេអាចកំណត់បានថាជាសកម្មភាពនៃបទល្មើសព្រហ្មទណ្ឌអន្តរជាតិ។

## ផ្នែកទី១៖ ប្រវត្តិតុលាការព្រហ្មទណ្ឌអន្តរជាតិ

ភាពភ័យរន្ធត់ដោយសារបញ្ហានៃសង្គ្រាមធំៗ ដែលកើតមានឡើងជាច្រើនទស្សវត្សរ៍ ដែលមានការបាត់បង់ជីវិតមនុស្សអស់ជាច្រើនលាននាក់ បាននាំឱ្យសហគមន៍អន្តរជាតិ ងាកមកចាប់អារម្មណ៍ក្នុងការបង្កើតឱ្យមាននូវលិខិតុបករណ៍ជាច្រើនដែលទាក់ទង និងការការពារជីវិតមនុស្សដែលជាជំហាននាំឱ្យមានការវិវត្តជាច្រើននៅក្នុងទំនាក់ទំនងអន្តរជាតិ ហើយមានការកាត់ទោសនូវឧក្រិដ្ឋជនសង្គ្រាមនានា ពីមជ្ឈដ្ឋានអន្តរជាតិបានធ្វើឱ្យមានការអភិវឌ្ឍនៅច្បាប់ព្រហ្មទណ្ឌអន្តរជាតិក្នុងគោលបំណងថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ ព្រមទាំងការពារសន្តិភាពក្នុងតំបន់។

### កថាខណ្ឌទី១៖ ការវិវត្តនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ

ការចាប់ផ្តើមដែលធ្វើឱ្យមានការបង្កើតនូវតុលាការព្រហ្មទណ្ឌអន្តរជាតិគឺដោយសារតែមានការ ស្នើសុំផ្សេងៗ និងបញ្ហាដែលបានកើតដោយគ្មានដំណោះស្រាយដែលមូលដ្ឋានសំខាន់ធ្វើឱ្យ សហគមន៍អន្តរជាតិចូលរួមគ្នាដើម្បី ស្វែងដំណោះស្រាយនោះ។

#### ១.សំណើដំបូងនៃការបង្កើត តុលាការព្រហ្មទណ្ឌអន្តរជាតិ

បន្ទាប់ពីឆ្លងកាត់សង្គ្រាមក្នុងឆ្នាំ ១៨៧២ (សង្គ្រាមបារាំង-ព្រុចស៊ី) ដោយលោក Gustav Moynier ដែលជាសហស្ថាបនិកអង្គការកាកបាទក្រហមអន្តរជាតិបានមើលឃើញពីភាពឃោរឃៅនៅក្នុងអំឡុងពេល នៃសង្គ្រាមកើតឡើង លោកក៏បានស្នើឡើងនូវតុលាការអន្តរជាតិជាអចិន្ត្រៃយ៍ ទៅកាន់សហគមន៍អន្តរជាតិ ប៉ុន្តែយ៉ាងណាសំណើនេះមិនត្រូវបានគេគិតគូរឡើយ។ ដែលនេះបានបង្ហាញពីចំណុចចាប់ផ្តើមនៃការវិវត្តជា លើក

ដំបូងនៃការឈានទៅរកការបង្កើតស្ថាប័នអន្តរជាតិមួយដែលឯករាជ្យសម្រាប់ការដោះស្រាយ បទល្មើសឧក្រិដ្ឋកម្មដែលបាន កើតឡើង។[1] ក្រោយមកទៀតបន្ទាប់ពីសង្គ្រាមលោកលើកទី ១ បានបញ្ចប់សន្ធិសញ្ញាទីក្រុង វ៉ែសៃ ឆ្នាំ ១៩១៩ បានបង្កើតឡើងក្នុងគោលបំណងអំពាវនាវឱ្យតុលាការអន្តរជាតិកាត់ទោសទៅលើមេដឹកនាំដែលបានបង្កើតឱ្យមានសង្គ្រាម និងបណ្តាលឱ្យមនុស្សស្លាប់ជាច្រើនដែលតម្រូវឱ្យមានការទទួលខុសត្រូវលើអំពើនោះសម្រាប់បុគ្គលដែលប្រព្រឹត្តនៅឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ។ ក្នុងសន្ធិសញ្ញានេះបានចែងអំពីការស្នើឱ្យមានការបង្កើតតុលាការអន្តរជាតិសម្រាប់កាត់ទោសមេដឹកនាំ ដែលគេឃើញមានចែងនៅក្នុងមាត្រា ២៧ នៃសន្ធិសញ្ញានេះ។ ដូច្នេះ សន្ធិសញ្ញា វ៉ែសៃ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំគំនិតនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ និងបានរួមចំណែកជាជំហានក្នុងការបង្កើត តុលាការព្រហ្មទណ្ឌអន្តរជាតិ [2]។ បន្ទាប់ពីនោះនៅពេលសង្គ្រាមលោកលើកទី ២ ឆ្នាំ ១៩៤៥ ត្រូវបានបញ្ចប់រដ្ឋាភិបាលសម្ព័ន្ធមិត្តដែលបានទទួលជ័យជម្នះក្នុងសង្គ្រាមនោះបានបង្កើតតុលាការចំពោះកិច្ចមួយដើម្បីកាត់ទោសទៅលើមេដឹកនាំ និងអាជ្ញាធរយោធាចំពោះបទល្មើសឧក្រិដ្ឋកម្មសង្គ្រាម និងអំពើឃោរឃៅក្នុងសម័យសង្គ្រាមលោក។ មហាអំណាចដែលជាសម្ព័ន្ធមិត្តទាំងបួន មាន បារាំង សហភាពសូវៀត ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក បានបង្កើតតុលាការយោធាអន្តរជាតិ (IMT) ដែលមានដូចជា តុលាការ ទីក្រុង នូរើបឺក និងតូក្យូ ដើម្បីធ្វើការផ្តន្ទាទោសទៅលើឧក្រិដ្ឋជនសង្គ្រាមធំៗទាំងនោះ។[3] នៅក្នុងឆ្នាំ ១៩៤៨ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តអនុសញ្ញាស្តីពីការទប់ស្កាត់ និងការដាក់ទណ្ឌកម្មនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលអនុសញ្ញានេះបង្កើតកាតព្វកិច្ចលើភាគីដើម្បីចាត់វិធានការទប់ស្កាត់ និងដាក់ទណ្ឌកម្ម។ អនុសញ្ញានេះត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិដើម្បីឆ្លើយតបទៅនឹងអំពើឃោរឃៅដែលបានប្រព្រឹត្តក្នុងកំឡុងសង្គ្រាមលោកលើកទី ២ និងរួមទាំងការសម្លាប់រង្គាល ហើយវាគឺជាលិខិតុបករណ៍ច្បាប់អន្តរជាតិដំបូងគេដែលទទួលស្គាល់ និងកាត់ទោសទៅលើបទល្មើសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។[4] អនុសញ្ញានេះបាន កំណត់និយមន័យនៃអំពើប្រល័យពូជសាសន៍ថាជា "អំពើដែលបានប្រព្រឹត្តដោយចេតនាដើម្បីបំផ្លាញ ទាំងមូល ឬមួយផ្នែក ក្រុមជាតិ ជាតិសាសន៍ ពូជសាសន៍

---

[1]គេហទំព័រ គណកម្មាធិការអន្តរជាតិនៃកាកបាទក្រហម.ចូលមើលថ្ងៃទីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤
https://www.icrc.org/en/doc/resources/documents/article/other/57jp4m.htm

[2]គេហទំព័រ ការវិវត្តន៍នៃយុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ
https://www.aba-icc.org/about-the-icc/evolution-of-international-criminal-justice/

[3]គេហទំព័រ សារមន្ទីរ រំលឹកការសម្លាប់សម្លាប់រង្គាល នៅសហរដ្ឋអាមេរិក,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤
http://surl.li/mkkqlk

[4]មាត្រា១ នៃ អនុសញ្ញាស្តីពីការទប់ស្កាត់ និងការដាក់ទណ្ឌកម្មនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍,ចូលមើលថ្ងៃទីថ្ងៃទី០៨ ខែមេសា ឆ្នាំ ២០២៤
https://www.measboralaws.com/images/pdf/laws-regulation/f4ced74e4c5467bdf500a0eb5af151c8.pdf

ឬសាសនា” ហើយរាយបញ្ជីអំពើចំនួនប្រាំដែលដែលចាត់ទុកជាអំពើប្រល័យពូជសាសន៍អនុសញ្ញាស្តីពីការទប់ស្កាត់ និងផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នេះ មានសារៈសំខាន់ ព្រោះវាបានត្រួសត្រាយផ្លូវសម្រាប់ការអភិវឌ្ឍនូវច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ។[5]

នៅចុងសម័យសង្គ្រាមត្រជាក់គេឃើញមានការកើតឡើងនៅការប្រយុទ្ធប្រឆាំង និងគ្រឿងញៀនដែលកើតមានក្នុងប្រទេស ទ្រីនីដាដ និងតូបាហ្គោ នៅខែធ្នូ ឆ្នាំ១៩៨៩។ ជាការឆ្លើយតបទៅនឹងករណីទាំងនេះ មហាសន្និបាតបានស្នើឱ្យ គណៈកម្មការច្បាប់អន្តរជាតិបន្តការងារលើតុលាការព្រហ្មទណ្ឌអន្តរជាតិដែលមានយុត្តាធិការដើម្បីរួមបញ្ចូលការជួញដូរគ្រឿងញៀន។ ក្នុងនោះផងដែរគួបផ្សំទៅ និងជម្លោះដែលកើតជាបន្តបន្ទាប់នៅទសវត្សរ៍ឆ្នាំ ១៩៩០ ដូចជា ប្រទេសយូហ្គោស្លាវី (ICTY) ទាក់ទងអំពើឃោរឃៅដែលបានប្រព្រឹត្តក្នុងតំបន់បាល់កាន់ពីការប្រយុទ្ធគ្នារវាងជនជាតិភាគតិច និងអំពើហិង្សាចំពេលមានការបែកបាក់នៃអតីតប្រទេសយូហ្គោស្លាវី លើសពីនេះ ប្រទេស រវ៉ាន់ដា (ICTR) ទាក់ទងអំពើប្រល័យពូជសាសន៍ និងការរំលោភធ្ងន់ធ្ងរដទៃទៀតនៃច្បាប់មនុស្សធម៌អន្តរជាតិ ទាំងអស់នេះបានធ្វើឱ្យគណៈកម្មការច្បាប់អន្តរជាតិ រួមគ្នាជាមួយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបង្កើតតុលាការចំពោះកិច្ចឡើង (អាដហុក) ដើម្បីដោះស្រាយបញ្ហាព្រហ្មទណ្ឌអន្តរជាតិដែលកើតមានក្នុងប្រទេសទាំងនោះ។ បញ្ហាទាំងអស់នេះបានធ្វើឱ្យរស់ឡើងវិញ នូវសំណើដើម្បីសម្រាប់បង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ។[6]

## ២.សេចក្តីព្រាងច្បាប់ក្នុងការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ

បន្ទាប់ពីបញ្ហាទាំងអស់នេះបានកើតមាន ជាបន្តបន្ទាប់មកហើយនៅក្នុងឆ្នាំ ១៩៩៤ គណៈកម្មការច្បាប់អន្តរជាតិ បានបង្ហាញសេចក្តីព្រាងលក្ខន្តិកៈចុងក្រោយរបស់ខ្លួនសម្រាប់ តុលាការព្រហ្មទណ្ឌអន្តរជាតិ ទៅកាន់មហាសន្និបាតអង្គការសហប្រជាជាតិដើម្បីផ្តល់អនុសាសន៍ និងធ្វើការកោះប្រជុំដើម្បីចរចាសន្ធិសញ្ញា ព្រមទាំងអនុម័តលក្ខន្តិកៈនេះ។ ក្នុងការពិចារណាលើបញ្ហាសំខាន់ៗ នៅក្នុងសេចក្តីព្រាងលក្ខន្តិកៈ មហាសន្និបាតបានបង្កើតគណៈកម្មាធិការស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបានប្រជុំពីរដងក្នុងមួយឆ្នាំ (១៩៩៥)។ ពីឆ្នាំ១៩៩៦ ដល់ ១៩៩៨ មហាសន្និបាតនៃអង្គការសហប្រជាជាតិ ក៏បានបង្កើតនូវគណៈកម្មាធិការស្តីពី ការរៀបចំការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិដោយមានសម័យប្រជុំចំនួន៦ដង ហើយក៏ឃើញមានសន្និសីទ

[5] គេហទំព័រផ្លូវការរបស់អង្គការសហប្រជាជាតិ,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤
https://www.un.org/en/genocideprevention/genocide-convention.shtml

[6] គេហទំព័រផ្លូវការរបស់គម្រោងការតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤
https://www.aba-icc.org/about-the-icc/evolution-of-international-criminal-justice/#fn:source1989

អង្គការសហប្រជាជាតិស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលហៅថា "សន្និសីទទីក្រុងរ៉ូម" បានប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១៥ ខែមិថុនា ឈានដល់ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ១៩៩៨ នៅទីក្រុងរ៉ូម ប្រទេសអ៊ីតាលី ព្រមទាំងមានរដ្ឋាភិបាលជាង ១៦០ ប្រទេស បានធ្វើការចូលរួមនៅក្នុងសន្និសីទមួយនេះផងដែរ។[7]

### ២.១.ការកើតឡើងជាស្ថាពររបស់ តុលាការព្រហ្មទណ្ឌអន្តរជាតិ

ជាលទ្ធផលចុងក្រោយ តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានបង្កើតឡើងស្របតាមច្បាប់ស្តីពីលក្ខន្តិកៈទីក្រុងរ៉ូម ឆ្នាំ១៩៩៨ ដោយលក្ខន្តិកៈនេះជាមូលដ្ឋានក្នុងការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបានបង្កើតជាស្ថាពរនៅថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០០២។[8] តុលាការព្រហ្មទណ្ឌអន្តរជាតិមានទីតាំងនៅទីក្រុងឡាអេ ប្រទេសហូឡង់ ដែលមានប្រទេសចំនួន ១២៤ គឺជារដ្ឋភាគីនៃលក្ខន្តិកៈទីក្រុងរ៉ូម ក្នុងចំណោមនោះ ៣៣ ជារដ្ឋតំបន់អាហ្វ្រិក ១៩ ជារដ្ឋអាស៊ីប៉ាស៊ីហ្វិក ១៩ មកពីអឺរ៉ុបខាងកើត ២៨ មកពីអាមេរិកឡាទីន និងរដ្ឋការាបៀន និង២៥ មកពីអឺរ៉ុបខាងលិច និងរដ្ឋផ្សេងទៀត។[9]

## កថាខណ្ឌទី២៖ រចនាសម្ព័ន្ធរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

### ១.អង្គការចាត់តាំងរបស់តុលាការ

តុលាការព្រហ្មទណ្ឌអន្តរជាតិមាន រចនាសម្ព័ន្ធចំនួនបួន៖

- ធិបតីប្រធាន
- អង្គជំនុំជម្រះ (មុនជំនុំជម្រះ,ជំនុំជម្រះដំបូង,ជំនុំជម្រះឧទ្ធរណ៍)
- ការិយាល័យរដ្ឋអាជ្ញា
- ការិយាល័យក្រឡាបញ្ជី។

### ១.១.ធិបតីប្រធាន

ធិបតីប្រធានមានចៅក្រមបីរូប (ប្រធាន និងអនុប្រធានពីររូប) ជ្រើសរើសដោយភាគច្រើនដាច់ខាតនៃចៅក្រមទាំង ១៨ របស់តុលាការសម្រាប់រយៈពេលអតិបរមាពីរ ឬបីឆ្នាំ។ ធិបតីប្រធានទទួលខុសត្រូវចំពោះការ

---

[7] គេហទំព័រផ្លូវការសម្ព័ន្ធសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០២៤ https://www.coalitionfortheicc.org/explore/20-icc-benefits

[8] មាត្រា១ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០២៤ https://legal.un.org/icc/statute/99_corr/cstatute.htm

[9] សភារដ្ឋភាគីនៃលក្ខន្តិកៈទីក្រុងរ៉ូម,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ https://asp.icc-cpi.int/states-parties

គ្រប់គ្រងតុលាការលើកលែងតែការិយាល័យរដ្ឋអាជ្ញាតំណាងឱ្យតុលាការទៅកាន់ពិភពខាងក្រៅ និងជួយជាមួយការរៀបចំការងាររបស់ចៅក្រម ធិបតីប្រធានក៏ទទួលខុសត្រូវក្នុងការអនុវត្ត ឬការងារផ្សេងទៀត ដូចជាការធានាការអនុវត្តទោសដែលដាក់ដោយតុលាការ។[10]

## ១.២.អង្គជំនុំជម្រះ

ចៅក្រមទាំង១៨រូប រួមទាំងចៅក្រមបីរូបនៃធិបតីប្រធាន ត្រូវបានចាត់តាំងឱ្យមាននៅតុលាការ ចំនួនបីផ្នែក៖ ផ្នែកមុនជំនុំជម្រះ (មានចៅក្រមប្រាំពីរ) ផ្នែកអង្គជំនុំជម្រះដំបូង (មានចៅក្រមប្រាំមួយនាក់) និងផ្នែកអង្គជំនុំជម្រះឧទ្ធរណ៍ (មានចៅក្រមប្រាំនាក់)។

### ១.២.១.អង្គមុនជំនុំជម្រះ

អង្គមុនជំនុំជម្រះ ត្រូវបំពេញដោយចៅក្រមបីរូបនៃចៅក្រមផ្នែកមុនការ ជំនុំជម្រះក្តី ឬដោយចៅក្រមតែមួយរូបនៃផ្នែកនោះ ស្របតាមច្បាប់លក្ខន្តិកៈនេះ និងវិធាននៃ នីតិវិធី និងភស្តុតាង។ ក្នុងផ្នែកមុនការជំនុំជម្រះចៅក្រមត្រូវមាន សមាសភាពអាទិភាព ដែលមានបទពិសោធន៍ខាងជំនុំជម្រះបទល្មើសព្រហ្មទណ្ឌ ចៅក្រមត្រូវបម្រើការក្នុងផ្នែកនេះសម្រាប់ រយៈពេលបីឆ្នាំ។[11]

មុខងារមួយរបស់អង្គមុនជំនុំជម្រះ គឺអាចពិនិត្យឡើងវិញនូវសេចក្តីសម្រេចមិនដំណើរការ ជម្រះរឿងក្តីរបស់រដ្ឋអាជ្ញា តាមគំនិតផ្តួចផ្តើមផ្ទាល់របស់អង្គមុនជំនុំជម្រះ សេចក្តីសម្រេចរបស់ រដ្ឋអាជ្ញាមានប្រសិទ្ធភាពបាន កាលណា អង្គមុនជំនុំជម្រះយល់ស្របតាម។[12] គោលការណ៍នេះ ធ្វើឡើងក្នុងការគោរពនូវអំណាចយុត្តាធិការ និងភាពចាំបាច់នៃការជំនុំជម្រះផងដែរ។ ការបញ្ជា ឬសេចក្តីសម្រេចរបស់អង្គមុនជំនុំជម្រះ ត្រូវតែមានការយល់ព្រមដោយមតិភាគច្រើន នៃចៅក្រមរបស់ខ្លួន។ បើគ្មានការចែងផ្ទុយពីនេះ ក្នុងករណីខ្លះមានការយល់ព្រមពីចៅក្រម តែមួយរូបនៃ អង្គមុនជំនុំជម្រះ ដែលចៅក្រមនោះអាចអនុវត្តមុខងារដែលបានចែងនៅក្នុងច្បាប់ នៃលក្ខន្តិកៈនេះគឺគ្រប់គ្រាន់ហើយ។[13] អង្គមុនជំនុំជម្រះក្តីក៏អាចពិនិត្យឡើងវិញនូវសេចក្តីសម្រេចមិនដំណើរការជ

[10] សៀវភៅចំណងជើង“មកដឹងអំពីតុលាការព្រហ្មទណ្ឌអន្តរជាតិ”បោះពុម្ពផ្សាយដោយស្ថាប័នតុលាការព្រហ្មអន្តរជាតិទំព័រទី ១៩,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤
https://www.icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[11] មាត្រា ៣៩ (ក) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤
https://www.icc-cpi.int/about/the-court

[12] មាត្រា ៥៣ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤
https://www.icc-cpi.int/about/the-court

[13] មាត្រា ៥៧ (២) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤

រឿងក្តីរបស់រដ្ឋអាជ្ញា ក្រៅពីគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន ដោយតាមសំណើសុំរបស់ រដ្ឋ ឬរាល់សំណើរបស់ក្រុមប្រឹក្សាសន្តិសុខផងដែរ។ ក្រៅពីនេះ អង្គមុនជំនុំជម្រះក្តីអាចធ្វើការចេញ បញ្ជា និងដីកាដែលមានភាពចាំបាច់សម្រាប់គោលបំណងនៃការស៊ើបអង្កេត តាមសំណើរបស់រដ្ឋអាជ្ញា។ ជាចាំបាច់បន្ទាប់ពីការផ្តួចផ្តើមការស៊ើបអង្កេត តាមរយៈពាក្យសុំរបស់រដ្ឋអាជ្ញា ស្របតាមមាត្រា ៥៨ នៃលក្ខន្តិកៈនៃទីក្រុងរ៉ូម អង្គមុនជំនុំជម្រះត្រូវចេញដីកាចាប់ខ្លួនជន ណាមួយ ឬដីកាកោះហៅឱ្យបង្ហាញខ្លួន។ លើសពីនេះ ក្នុងភាពចាំបាច់អង្គមុនជំនុំជម្រះក្តី ក៏អាចផ្តល់នូវការការពារ និងភាពស្ងៀមស្ងាត់ គ្មានការឆោឆៅខែាន ដល់ជនរងគ្រោះ និងសាក្សី អាចជួយរក្សាភស្តុតាង អាចជួយការពារជនដែលត្រូវបានចាប់ខ្លួន ឬជនដែលបានបង្ហាញខ្លួនតាមដីកាកោះហៅឱ្យបង្ហាញខ្លួន និងអាចជួយការពារព័ត៌មានសន្តិសុខជាតិ។ ក្នុងពេលវេលាសមហេតុផលមួយ បន្ទាប់ពីការប្រគល់ខ្លួន ឬការបង្ហាញខ្លួនរបស់ជននោះ ដោយស្ម័គ្រចិត្តនៅចំពោះមុខតុលាការ អង្គមុនជំនុំជម្រះ ត្រូវបើកសវនការ ដើម្បីបញ្ជាក់ពី បទចោទប្រកាន់ ដែលរដ្ឋអាជ្ញាប៉ុនប៉ងស្វែងរកឱ្យមានការជំនុំជម្រះ។ សវនាការត្រូវបានបើកធ្វើឡើងដោយមានវត្តមាននៃរដ្ឋអាជ្ញា និងជនជាប់ចោទ ព្រមទាំងអ្នកការពារក្តីរបស់ ជនជាប់ចោទផងដែរ។ ប៉ុន្តែការបើកសវនាការដើម្បីបញ្ជាក់អំពីបទចោទប្រកាន់ដែល រដ្ឋអាជ្ញាប៉ងស្វែងរកឱ្យមានការជំនុំជម្រះក៏អាចប្រព្រឹត្តទៅដោយគ្មានវត្តមាននៃជនដែលត្រូវ ចោទប្រកាន់បានផងដែរ។[14]

### ១.២.២.អង្គជំនុំជម្រះដំបូង

អង្គជំនុំជម្រះដំបូង គឺត្រូវប្រាកដថាការកាត់ក្តី មានលក្ខណៈយុត្តិធម៌ និងលឿនរហ័ស ហើយត្រូវបានធ្វើឡើង ដោយមានការគោរពពេញលេញដល់សិទ្ធិរបស់ជនជាប់ចោទ និងគិតគូរ បានសមរម្យដល់ការការពារជនរងគ្រោះ និងសាក្សី។ ប៉ុន្តែ អង្គជំនុំជម្រះដំបូងអាចកំណត់ថាកាលៈទេសៈពិសេសដែលតម្រូវថាដំណើរការរឿងក្តីខ្លះ ត្រូវធ្វើឡើងក្នុងបន្ទប់សម្ងាត់ សម្រាប់គោលបំណងដើម្បីការពារព័ត៌មានអាថ៌កំបាំង ឬព័ត៌មាន ប៉ះពាល់ដល់ស្មារតីដើម្បីផ្តល់ជាភស្តុតាង។[15] ក្នុងករណីមានការថ្កោលទោស អង្គជំនុំជម្រះដំបូងត្រូវ ពិចារណាទោសដែលសមស្រប ទណ្ឌកម្មទៅនឹងបទល្មើស។ លើសពីនេះតុលាការអាចដាក់ទណ្ឌកម្មបន្ថែមលើទោសពន្ធនាគារ នូវការផាកពិន័យជាប្រាក់ ឬការដកហូតផលពីការលក់ទ្រព្យ ការដកហូតទ្រព្យសម្បត្តិ និងទ្រព្យធនដែលបានមក

---

https://www.icc-cpi.int/about/the-court

[14] មាត្រា ៦១ (១) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤

https://www.icc-cpi.int/about/the-court

[15] មាត្រា ៦៤ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤

https://www.icc-cpi.int/about/the-court

ដោយផ្ទាល់មិនផ្ទាល់ ពីបទល្មើសព្រហ្មទណ្ឌនោះ។ ម៉្យាងវិញទៀត តុលាការអាចចេញបញ្ជាផ្ទាល់លើ ពិរុទ្ធជន ដោយបញ្ជាក់នូវការជួសជុលដែលសមស្របដល់ ឬទាក់ទងនឹងជនរងគ្រោះ រួមមាន ការសងវិញ សំណងជម្ងឺចិត្ត និងការស្តារនីតិសម្បទាឡើងវិញ។[16]

### ១.២.៣.អង្គជំនុំជម្រះឧទ្ធរណ៍

អង្គជំនុំជម្រះឧទ្ធរណ៍ (សមាសភាពនៃចៅក្រមទាំងប្រាំ នៃផ្នែកឧទ្ធរណ៍) ដែលទទួលពាក្យបណ្ដឹងប្រឆាំងសេចក្ដីសម្រេចផ្សេងៗ ដោយរដ្ឋដែលពាក់ព័ន្ធ ឬរដ្ឋអាជ្ញាដោយមានការអនុញ្ញាតរបស់អង្គជំនុំជម្រះដំបូង ក៏ដូចជាអ្នកតំណាងផ្នែកច្បាប់នៃជនរងគ្រោះ ពិរុទ្ធជន ឬម្ចាស់សុចរិតនៃទ្រព្យសម្បត្តិដែលរងអានុភាពប្រឆាំងដោយសារការបញ្ជារបស់តុលាការ។[17] អង្គជំនុំជម្រះឧទ្ធរណ៍ អាចបដិសេធ ឬកែប្រែសេចក្តីសម្រេចឬការដាក់ទោសនោះបាន ឬបញ្ជា ឱ្យធ្វើការជំនុំជម្រះសារជាថ្មី ដោយអង្គជំនុំជម្រះមួយផ្សេងទៀត ក្នុងករណីដែលអង្គជំនុំជម្រះឧទ្ធរណ៍ យល់ឃើញថា មានភាពអយុត្តិធម៌ក្នុងសភាពមួយដែលប៉ះពាល់ដល់ភាពដែលអាចទុកចិត្តបាននៃសេចក្តីសម្រេចលើការដាក់ទោស ត្រូវបានគេ ប្ដឹងឧទ្ធរណ៍បានត្រូវប៉ះពាល់ជាធំដុំដោយការភាន់ច្រឡំទៅលើអង្គហេតុ ឬទៅលើអង្គច្បាប់ខាងនីតិវិធី។

### ១.២.៤.ការជ្រើសរើសចៅក្រម

ការជ្រើសរើសចៅក្រម ត្រូវបានជ្រើសរើសដោយសន្និបាត នៃរដ្ឋភាគីដោយផ្អែកលើ មូលដ្ឋានដែលបានបង្កើតឡើងរបស់ពួកគេ សមត្ថភាពផ្នែកច្បាប់ និងនីតិវិធីព្រហ្មទណ្ឌ និងផ្នែកពាក់ព័ន្ធនៃច្បាប់អន្តរជាតិ ដូចជាច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្ស។ ចៅក្រមត្រូវមានចំណេះដឹង ទូលំទូលាយយ៉ាងជំនាញលើបញ្ហាជាក់លាក់ ការបោះឆ្នោតជ្រើសរើសចៅក្រម ត្រូវគិតពីតម្រូវការសម្រាប់ការតំណាងប្រព័ន្ធច្បាប់សំខាន់ ៗ នៃពិភពលោក តំណាងដោយ យុត្តិធម៌នៃការសមភាព និងសមធម៌។ ចៅក្រម គឺជាបុគ្គលដែលមានសីលធម៌ខ្ពស់ មានភាពមិនលំអៀង និងសុចរិតភាព លក្ខណៈសម្បត្តិដែលទាមទារដោយក្នុងរដ្ឋភាគីនីមួយៗ ព្រមទាំងមានបទពិសោធន៍យ៉ាងទូលំទូលាយទាក់ទង នឹងសកម្មភាពរបស់តុលាការ។ អង្គជំនុំជម្រះមានការទទួលខុសត្រូវទៅលើការ ធានានូវភាពត្រឹមត្រូវនៃដំណើរការនីតិវិធី និងការគ្រប់គ្រងត្រឹមត្រូវ និងយុត្តិធម៌។[18]

---

[16] មាត្រា ៧៧ (២) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤

[17]មាត្រា ៨២ (២) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤

[18] សៀវភៅចំណេះដឹង"មកដឹងអំពីតុលាការព្រហ្មទណ្ឌអន្តរជាតិ"បោះពុម្ពផ្សាយដោយស្ថាប័នតុលាការព្រហ្មអន្តរជាតិទំព័រទី ២០,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤
https://www.icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

## ១.៣.ការិយាល័យរដ្ឋអាជ្ញា

ការិយាល័យរដ្ឋអាជ្ញាគឺជាស្ថាប័នឯករាជ្យរបស់តុលាការ ដែលមានភារកិច្ចគឺដើម្បីទទួល និងវិភាគព័ត៌មានអំពីស្ថានភាព ឬឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងដែនសមត្ថកិច្ចរបស់ តុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីវិភាគស្ថានភាពដែលកំណត់ថាមានមូលដ្ឋានសមហេតុផលដើម្បីចាប់បើកផ្ដើមការស៊ើបអង្កេតដែលសំអាងថាជាបទល្មើស ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មនៃការឈ្លានពាន និងនាំខ្លួនជនល្មើសនៃឧក្រិដ្ឋកម្មទាំងនេះទៅកាន់តុលាការ។

ដើម្បីបំពេញភារកិច្ចរបស់ខ្លួន ការិយាល័យរដ្ឋអាជ្ញាបែកចែកជាបីផ្នែក៖

- ផ្នែកស៊ើបអង្កេត៖ ដែលទទួលខុសត្រូវក្នុងការស៊ើបអង្កេត (រួមទាំងការប្រមូល និងពិនិត្យភស្តុតាង ការសាកសួរមនុស្សក្រោមការស៊ើបអង្កេតក៏ដូចជាជនរងគ្រោះ និងសាក្សី)។ ក្នុងន័យនេះសម្រាប់គោលបំណង ការបង្កើតការពិត លក្ខន្តិកៈតម្រូវឱ្យការិយាល័យរដ្ឋអាជ្ញាធ្វើ ការស៊ើបអង្កេតករណីចោទប្រកាន់ និងលើកលែងទោសស្មើគ្នា។
- ផ្នែកជម្រះក្ដី៖ រដ្ឋអាជ្ញាមានតួនាទីក្នុងដំណើរការស៊ើបអង្កេត ប៉ុន្តែក៏ជាប្រធានទំនួលខុសត្រូវគឺការដោះស្រាយសំណុំរឿងនៅចំពោះមុខអង្គជំនុំជម្រះនានានៃតុលាការ។
- ផ្នែកយុត្តាធិការ៖ ការបំពេញបន្ថែម និងកិច្ចសហប្រតិបត្តិការ ដែលជាការគាំទ្រមួយរបស់ផ្នែកស៊ើបអង្កេត ហើយវាយតម្លៃព័ត៌មានដែលទទួលបាន និងស្ថានភាពដែលបញ្ជូនទៅតុលាការ វិភាគស្ថានភាព ករណីដើម្បីកំណត់ភាពអាចទទួលយកបាន និងជួយធានានូវកិច្ចសហប្រតិបត្តិការក្នុងការិយាល័យរដ្ឋអាជ្ញាដើម្បីបំពេញតួនាទី របស់ខ្លួន។[19] ត្រង់ចំណុចទាំងអស់នេះ បានបង្ហាញឱ្យឃើញថា ការស៊ើបអង្គតគឺជាកាតព្វកិច្ចចម្បងរបស់រដ្ឋអាជ្ញា។

## ១.៤.ការិយាល័យក្រឡាបញ្ជី

ការិយាល័យក្រឡាបញ្ជី ត្រូវទទួលខុសត្រូវចំពោះដំណើរការផ្នែកយុត្តិធម៌ និងរដ្ឋបាលដល់គ្រប់ផ្នែកទាំងអស់របស់តុលាការប្រកបដោយប្រសិទ្ធភាព ដែលដំណើរការក្រោមសិទ្ធិអំណាចរបស់ធិបតីប្រធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ផ្ដល់សេវាដល់ផ្នែកផ្សេងៗ ទៀតរបស់តុលាការ ហើយទទួលខុសត្រូវចំពោះ៖

---

[19] សៀវភៅចំណងជើង"មកដឹងអំពីតុលាការព្រហ្មទណ្ឌអន្តរជាតិ"បោះពុម្ពផ្សាយដោយស្ថាប័នតុលាការព្រហ្មអន្តរជាតិទំព័រទី ២១,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤
https://www.icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

- ការគាំទ្រផ្នែកតុលាការ មានដូចជា៖ ការបកប្រែ និងការបកស្រាយ ការគ្រប់គ្រងកំណត់ត្រារបស់តុលាការ ការគាំទ្រដល់ការចូលរួមរបស់ជនរងគ្រោះ និងការបង្ហាញខ្លួនសាក្សីក្នុងដំណើរការនីតិវិធី ការគ្រប់គ្រងជំនួយផ្នែកច្បាប់ ជំនួយការប្រឹក្សាផ្សេងៗទៀត និងការគ្រប់គ្រងមជ្ឈមណ្ឌលឃុំឃាំង។
- កិច្ចការសម្រាប់ផ្នែកខាងក្រៅ មានដូចជា៖ ការផ្តល់ព័ត៌មានសាធារណៈ និងការផ្សព្វផ្សាយ ការគាំទ្រការិយាល័យ និងទំនាក់ទំនងខាងក្រៅ ព្រមទាំងការគ្រប់គ្រង ទៅលើថវិការបស់តុលាការ ធនធានមនុស្ស សន្តិសុខសណ្តាប់ធ្នាប់ និងសេវារដ្ឋបាលផ្សេងៗទៀត។ ការិយាល័យផ្នែកក្រឡាបញ្ជីនីមួយៗ ត្រូវបានជ្រើសរើសដោយចៅក្រមពេញអង្គ របស់តុលាការ សម្រាប់រយៈពេលប្រាំឆ្នាំ។ [20]

## ២.អំពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

តុលាការ ត្រូវមានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ នៅលើដែនដីនៃរដ្ឋភាគីនីមួយៗ ដែលចាំបាច់សម្រាប់ក្នុងការបំពេញការងារ តាមគោលបំណងរបស់តុលាការ។ នៅពេលបំពេញភារកិច្ច ឬដោយគោរពតាមភារកិច្ចរបស់តុលាការ ចៅក្រម រដ្ឋអាជ្ញា រដ្ឋអាជ្ញារង និងក្រឡាបញ្ជី ត្រូវមានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដូចដែលបានផ្តល់ដល់ប្រមុខនៃបេសកកម្មការទូតនានា ហើយបន្ទាប់ពី ការផុតកំណត់នៃអាណត្តិបំពេញការងាររបស់ខ្លួនហើយនោះ ត្រូវបានបន្តផ្តល់អភ័យឯកសិទ្ធិពីដំណើរការផ្នែកច្បាប់រាល់គ្រប់ សកម្មភាព ទាក់ទងលើពាក្យសំដីដែលបាននិយាយដោយផ្ទាល់មាត់ ឬពាក្យសំដីជាលាយលក្ខណ៍អក្សរ ព្រមទាំងសកម្មភាព ទាំងឡាយដែលពួកគេបំពេញក្នុងសម្បទាផ្លូវការរបស់ខ្លួន។ ត្រង់នេះសបញ្ជាក់ឱ្យឃើញថា នៃសមាជិកទាំងអស់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ និងទទួលបានសិទ្ធិការទូតសុទ្ធតែមានអភ័យឯកសិទ្ធិដាច់ខាតចំពោះអំណាចយុត្តាធិការព្រហ្មទណ្ឌ និងរដ្ឋប្បវេណីរបស់រដ្ឋម្ចាស់ផ្ទះដែលជាភាគីរបស់ នៃលក្ខន្តិកៈទីក្រុងរ៉ូម ។[21]

- អភ័យឯកសិទ្ធិ គឺជាសិទ្ធិទាំងឡាយដែលរដ្ឋម្ចាស់ផ្ទះផ្តល់ឲ្យទៅបេសកកម្មការទូត និងបុគ្គលិកទាំងអស់នៃបេសកកម្មការទូត ក្នុងការរួចផុតពីអំណាចយុត្តាធិការរបស់រដ្ឋម្ចាស់ផ្ទះ ព្រមទាំងធានានូវភាពមិនអាចបំពានបាន ក្នុងការការពាររាល់ហេតុការណ៍ណាមួយដែលអាចប៉ះពាល់ ឬរំខានដល់សកម្មភាពបំពេញមុខងាររបស់ពួកគេ មិនតែប៉ុណ្ណោះក៏អាចរួចផុតអំពីការចាប់ខ្លួន ឬការឃុំឃាំង និងការអនុវត្ត

[20]គេហទំព័រផ្លូវការសម្ព័ន្ធសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤
https://www.coalitionfortheicc.org/explore/20-icc-benefits

[21] មាត្រា ៤៨ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤
https://www.icc-cpi.int/about/the-court

សាលក្រមរបស់តុលាការនៃរដ្ឋម្ចាស់ផ្ទះ ទោះបីជាពួកគេប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬឧក្រិដ្ឋកម្មធ្ងន់ធ្ងរក្នុងកាលៈទេសៈណាក៏ដោយ។

- បុព្វសិទ្ធិ សំដៅលើសិទ្ធិទាំងឡាយដែលរដ្ឋម្ចាស់ផ្ទះផ្តល់ឲ្យសម្រាប់សម្រួលដល់សកម្មភាពការងាររបស់បេសកកម្មការទូត ដើម្បីដោះស្រាយ និងបំបាត់ភាពសាំញ៉ាំផ្នែករដ្ឋបាលសាធារណៈនៅក្នុងទឹកដីនៃរដ្ឋម្ចាស់ផ្ទះ។[22] បុគ្គលិកផ្សេងៗទៀតដូចជា ក្រឡាបញ្ជីរង និងបុគ្គលិកនៃការិយាល័យអយ្យការ និងបុគ្គលិកនៃការិយាល័យផ្នែកក្រឡាបញ្ជី ត្រូវមានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ព្រមទាំងមធ្យោបាយសម្រួលការចាំបាច់ទាំងឡាយ ដើម្បីបំពេញមុខងាររបស់ខ្លួន ស្របតាមកិច្ចព្រមព្រៀងស្តីពី បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់តុលាការ។

## ២.១.បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់បុគ្គលពាក់ព័ន្ធ

អ្នកការពារ អ្នកជំនាញ សាក្សី ឬបុគ្គលណាមួយដែលតម្រូវឱ្យមានវត្តមាន នៅឯអាសនៈរបស់តុលាការត្រូវបានផ្តល់ឱ្យនូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនោះ តាមការចាំបាច់ដើម្បីឱ្យការប្រព្រឹត្តទៅរបស់តុលាការ ប្រព្រឹត្តទៅដោយសមរម្យ ស្របតាមកិច្ចព្រមព្រៀងស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់តុលាការ។[23]

## ២.២.ការបដិសេធ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

ជាទូទៅ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាំងនោះអាចត្រូវបានដកហូតវិញដោយ ច្បាប់ដែលបានកំណត់នៅក្នុង នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ព្រមទាំងវិធាននីតិវិធី និងភស្តុតាងដែលបានកំណត់ដោយៈ

- ចៅក្រម ឬរដ្ឋអាជ្ញា អាចត្រូវបានបដិសេធវិញ តាមមតិភាគច្រើនដាច់ខាតរបស់ចៅក្រម
- ក្រឡាបញ្ជី អាចត្រូវបានបដិសេធវិញ ដោយអធិបតីប្រធាន
- រដ្ឋអាជ្ញារង និងបុគ្គលិកនៃការិយាល័យអយ្យការ ត្រូវបានបដិសេធវិញ ដោយរដ្ឋអាជ្ញា
- ក្រឡាបញ្ជីរង និងបុគ្គលិកនៃការិយាល័យផ្នែកសៀវភៅបញ្ជីអាចត្រូវបានបដិសេធវិញដោយក្រឡាបញ្ជី។[24]

[22] អនុសញ្ញាក្រុងវៀនស្តីពី ទំនាក់ទំនងការទូត ឆ្នាំ ១៩៦៥ យោងតាមកថាខ័ណ្ឌទី១ មាត្រា ៣១,ចូលមើលថ្ងៃទី១១ខែមេសា ឆ្នាំ២០២៤ https://www.measboralaws.com/images/pdf/laws-regulation/d63cdc1689a29bada594bc9fe0b1cf0a.pdf

[23] មាត្រា ៤៨(១),(២),(៣) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

[24] មាត្រា ៤៨(៥) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤

# ផ្នែកទី២៖ ចក្ខុវិស័យ និងបេសកកម្មរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

## កថាខណ្ឌទី១៖ ចក្ខុវិស័យ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

### ១.ចក្ខុវិស័យ

បន្ទាប់ពីការបង្កើតឡើងជាស្ថាប័នយ៉ាងរឹងមាំហើយ តុលាការព្រហ្មទណ្ឌអន្តរជាតិនេះបានធ្វើការផ្តោតសំខាន់ទៅលើវិស័យមួយចំនួនដែលជាវិស័យអាទិភាពក្នុងចក្ខុវិស័យ ដើម្បីទប់ស្កាត់ការកើតឡើងនៃការកាប់សម្លាប់ដោយធ្វើឡើងក្នុងសកម្មភាពដែលច្បាប់អន្តជាតិបានកំណត់ថាវាជាបទឧក្រិដ្ឋ កុំឱ្យបន្តកើតមាននាពេលខាងមុខ។

### ២.បេសកកម្ម

ឯបេសកកម្មរបស់ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺផ្តោតលើការលើកកម្ពស់ភាពយុត្តិធម៌អន្តរជាតិ ដែលជាស្ថាប័នឯករាជ្យមានបេសកកម្មដើម្បីកាត់ទោសបុគ្គល ចំពោះការទទួលខុសត្រូវដែលបង្កឱ្យកើតមានឧក្រិដ្ឋកម្មនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[25]

## កថាខណ្ឌទី២៖ គោលបំណង និងសារៈសំខាន់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

### ១.គោលបំណង

តុលាការព្រហ្មទណ្ឌអន្តរជាតិបានបង្កើតឡើងក្នុងគោលបំណងមួយយ៉ាងជាក់លាក់នោះគឺការ ប្រយុទ្ធប្រឆាំងជាមួយ និងការរួចផុតពីការកាត់ទោសដោយច្បាប់ចំពោះឧក្រិដ្ឋជនដែលបានប្រព្រឹត្តបទល្មើសនោះ។ ហើយតុលាការនេះមានគោលបំណងក្នុងការរក្សាការពារ ព្រមទាំងធានាថា បុគ្គលដែលបានប្រព្រឹត្តបទល្មើសដែលត្រូវបានចាត់ទុកថា បទឧក្រិដ្ឋត្រូវតែទទួលទោស។[26]

---

https://www.icc-cpi.int/about/the-court

[25] សៀវភៅចំណងជើង"មកដឹងអំពីតុលាការព្រហ្មទណ្ឌអន្តរជាតិ"បោះពុម្ពផ្សាយដោយស្ថាប័នតុលាការព្រហ្មអន្តរជាតិទំព័រទី១០,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤

https://www.icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[26] គេហទំព័រផ្លូវការ តុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០២៤

https://www.icc-cpi.int/about/the-court

### ២.សារៈសំខាន់នៃការអនុវត្តច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

សារៈសំខាន់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ យើងលើកយកចំណុចសំខាន់ដែលជាហេតុផលមួយចំនួន ក្នុងការអនុវត្តច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មានសារៈសំខាន់សម្រាប់ពិភពលោកដែលមានជាក់ស្តែង និងបានកំណត់យ៉ាងជាក់លាក់ពេលតុលាការត្រូវបានបង្កើត ៖

- ការបញ្ចប់និទ្ទណ្ឌភាពរបស់បុគ្គលដែលបានប្រព្រឹត្ត ឬការបង្កឱ្យមាននូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ព្រមទាំងការបង្កើតនីតិរដ្ឋដោយកាត់ទោសបុគ្គលដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ។[27]
- អនុវត្តច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងធ្វើការលើកកម្ពស់យុត្តិធម៌អន្តរជាតិក្នុងការបំពេញបន្ថែមយុត្តាធិការជាតិ ត្រូវបានរចនាឡើងដើម្បីបំពេញបន្ថែមដល់ប្រព័ន្ធច្បាប់ជាតិឱ្យកាន់តែប្រសើរជាមុន  ហើយវាអាចធ្វើអន្តរាគមន៍បានលុះត្រាតែរដ្ឋមួយនោះជារដ្ឋភាគី។[28]

យ៉ាងណាមិញភាពសំខាន់ចម្បងក្នុងការអនុវត្តច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ យ៉ាងសុក្រឹត្យមិនលម្អៀងបានធ្វើឱ្យបណ្តារមេដឹកនាំ ឬជនមួយចំនួនទៀតលើពិភពលោកមានការខ្លាចរអា និងមិនហ៊ានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌអន្តរជាតិបន្តទៅទៀត។

## កថាខណ្ឌទី៣៖ ទំនាក់ទំនងអង្គការសហប្រជាជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ

### ១.ឯករាជ្យភាពរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ត្រូវបានបង្កើតឡើងដោយសន្ធិសញ្ញាពហុភាគី វាគឺជាស្ថាប័នដាច់ដោយឡែកទាំងស្រុងទល់នឹងអង្គការសហប្រជាជាតិ។ តុលាការ ព្រហ្មទណ្ឌអន្តរជាតិទទួលបានមុខងារ និងសិទ្ធិអំណាចរបស់ខ្លួនពីសន្ធិសញ្ញា មិនមែនមកពីអង្គការសហប្រជាជាតិទេ (UN)។ ដូច្នេះ តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺជាអង្គការអន្តរជាតិដែលឯករាជ្យ។[29] ទោះជាយ៉ាងណាក៏ដោយ តុលាការគឺជាផ្នែកមួយនៃប្រព័ន្ធអន្តរជាតិ ដែលអង្គការសហប្រជាជាតិជាអ្នកគាំពារ មានតម្រូវការក្នុងការសម្របសម្រួលការទទួលខុសត្រូវចំពោះកិច្ច

[27] គេហទំព័រផ្លូវការ របស់អង្គការសហប្រជាជាតិស្តីពីតួនាទី តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ក្នុងការបញ្ចប់និទណ្ឌភាព និងការបង្កើតនីតិរដ្ឋ https://www.un.org/en/chronicle/article/role-international-criminal-court-ending-impunity-and-establishing-rule-law

[28] មាត្រា១៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ៨ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

[29] មាត្រា ១ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

ការរបស់អង្គការសហប្រជាជាតិក្នុងការរក្សាសន្តិភាព និងសន្តិសុខ ជាមួយនឹងតួនាទីតុលាការ លើសពីនេះ ទំនាក់ទំនង ឬកិច្ចសហប្រតិបត្តិការ អន្តរជាតិគឺប្រើប្រាស់គោលនយោបាយទាំងនោះ ស្ថិតក្រោមការធានារបស់អង្គការសហប្រជាជាតិ ព្រមទាំងមានកាតព្វកិច្ចមួយផ្នែកនៃអង្គការសហប្រជាជាតិក្នុងការសហការ និងផ្តល់ការគាំទ្រដល់តុលាការ ព្រហ្មទណ្ឌអន្តរជាតិ។[30] កិច្ចព្រមព្រៀងទំនាក់ទំនងបង្កើតក្របខណ្ឌទូទៅសម្រាប់កិច្ចសហប្រតិបត្តិការរវាងអង្គភាពទាំងអស់របស់អង្គការសហប្រជាជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ នេះត្រូវតម្រូវឱ្យមានការភ្ជាប់រចនាសម្ព័ន្ធរវាងស្ថាប័នទាំងពីរ។ តុលាការក៏មានទំនាក់ទំនងជិតស្និទ្ធជាមួយអង្គការសហប្រជាជាតិ ដែលត្រូវបានគ្រប់គ្រងដោយកិច្ចព្រមព្រៀងទំនាក់ទំនងរវាងស្ថាប័នទាំងពីរដែលបានអនុម័តក្នុងឆ្នាំ ២០០៤។[31]

## ២.ភាពពាក់ព័ន្ធរវាងស្ថាប័នទាំងពីរ

បើក្រឡេកមកមើលនៃលក្ខន្តិកៈទីក្រុងរ៉ូម វិញយើងក៏ឃើញមាននៅអត្ថន័យនៃច្បាប់មួយចំនួនដែលបានបង្ហាញពីការសហការគ្នា រវាងអង្គភាពទាំងពីរនេះមានដូចជា  មាត្រា ២ និយាយអំពីទំនាក់ទំនងរួមរវាងតុលាការ និងអង្គការសហប្រជាជាតិ ព្រមទាំងកំណត់បញ្ហាជាក់លាក់បន្ថែមត្រូវបានដោះស្រាយដែលមាននៅក្នុងបទប្បញ្ញត្តិផ្សេងៗ ទៀត។ ដែលមានដូចជា មាត្រា ១៣(ខ) បង្ហាញអំពី ក្រុមប្រឹក្សាសន្តិសុខអាចធ្វើការផ្តល់យុត្តាធិការដល់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងដំណើរការនីតិវិធីចំពោះបញ្ហាណាមួយដែលបានកើតឡើង ក្នុងនោះមាត្រា ១៦ ចែងថា ក្រុមប្រឹក្សាសន្តិសុខអាចផ្អាក ឬពន្យារពេលដំណើរការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ តុលាការយុត្តិធម៌អន្តរជាតិ ដែលជាស្ថាប័នតុលាការសំខាន់របស់អង្គការសហប្រជាជាតិ អាចមានតួនាទីយោងតាមមាត្រា ១១៩(២) ក្នុងការដោះស្រាយវិវាទរវាងរដ្ឋភាគីនៃនៃលក្ខន្តិកៈទីក្រុងរ៉ូម។ ជាចុងក្រោយនៅក្នុងមាត្រា ១១៥(ខ) បានចែងថា អង្គការសហប្រជាជាតិអាចផ្តល់មូលនិធិដល់តុលាការ ក្រោមការយល់ព្រមពីមហាសន្និបាត ជាពិសេសទាក់ទង និងការចំណាយដែលកើតឡើង ពីការបញ្ជូនស្ថានការណ៍ណាមួយទៅតុលាការ ឬមានការណែនាំដោយក្រុមប្រឹក្សាសន្តិសុខក្នុងការចាប់ផ្តើមយុត្តាធិការ ក្នុងរឿងក្តីនានា ដែលបានកើតឡើង។

---

[30] រដ្ឋធម្មនុញ្ញអង្គការសហប្រជាជាតិ មាត្រា ១,ចូលមើលថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០២៤ https://treaties.un.org/doc/publication/ctc/uncharter.pdf

[31] កិច្ចព្រមព្រៀងទំនាក់ទំនងរវាង តុលាការព្រហ្មទណ្ឌអន្តរជាតិ និងអង្គការសហប្រជាជាតិ,ចូលមើលថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០២៤ https://legal.un.org/ola/media/UN-ICC_Cooperation/UN-ICC%20Relationship%20Agreement.pdf

# ជំពូកទី២

# ដំណើរការនៃការអនុវត្ត
# ច្បាប់របស់តុលាការព្រហ្មទណ្ឌ
# អន្តរជាតិ

# ជំពូកទី២

# ដំណើរការនៃការអនុវត្តច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

ដំណើរការនៃការអនុវត្តច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺជាចំណុចសំខាន់មួយដែលបង្ហាញអំពីលក្ខណៈនៃការប្រព្រឹត្តទៅក្នុងការលុបបំបាត់ ឬដាក់ទោសទៅលើជនណាម្នាក់ ដែលបានបង្កើតឱ្យមានបទល្មើសដែលតុលាការព្រហ្មទណ្ឌអន្តរជាតិបានចាត់ទុកថា នាំឱ្យមាននៅការកាប់សម្លាប់ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន។ ដែលសកម្មភាពនោះបានធ្វើឱ្យស្លាប់ជីវិត ឬបង្កឱ្យមានការ គំរាមកំហែងដល់ជីវិតក្នុងសកលលោក ចំពោះដំណើរការនៃការអនុវត្តច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បើយើងមើលក្នុងច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិវិញ យើងបានឃើញនូវការកំណត់អំពី សញ្ញាណនៃដំណើរការនោះដោយមាន នូវការចាប់ផ្តើមអនុវត្តន៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិនៅក្នុងខ្លឹមសារនៃច្បាប់នេះ បានបង្ហាញអំពីការ ការផ្តួចផ្តើមនៃការអនុវត្តច្បាប់ ការពិនិត្យបឋម ការស៊ើបអង្កេត ការចាប់ខ្លួន ឬកោះហៅឱ្យចូលខ្លួន និងជំនុំជម្រះ ការផ្តន្ទាទោស ព្រមទាំងការទទួលខុសត្រូវទៅលើអំពើដែលជាបទល្មើសរបស់បុគ្គលនោះ។[32]

## ផ្នែកទី១៖ គោលការណ៍ទូទៅរបស់តុលាការ

ការអនុវត្តច្បាប់របស់តុលាការ ព្រហ្មទណ្ឌអន្តរជាតិត្រូវគោរពទៅតាម បទបញ្ញត្តិ ឬគោលការណ៍ទូទៅដែលមានក្នុង លក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ មិនតែប៉ុណ្ណោះតុលាការក៏ត្រូវគោរពទៅតាមវិធានអន្តរជាតិនានាដែលពាក់ព័ន្ធ។

## កថាខណ្ឌទី១៖ គោលការណ៍ទូទៅ ក្នុងការអនុវត្តច្បាប់

### ១.គោលការណ៍ នីត្យានុកូលភាព

តុលាការព្រហ្មទណ្ឌអន្តរជាតិ បានបង្កើតឡើងដោយមាននូវគោលការណ៍សំខាន់ៗ ក្នុងការអនុវត្តដូចដែលមានចែងក្នុង លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលមានអំណាចក្នុងការអនុវត្តយុត្តាធិការខ្លួនលើឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត និងព្រួយបារម្ភមួយសម្រាប់អន្តរជាតិ ជាពិសេសមនុស្សជាតិទាំងមូល។ ជាចាំបាច់ក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិបាន ស្ថាប័ននេះត្រូវតែគោរពទៅលើគោលការណ៍មាននៅក្នុងច្បាប់អន្តរជាតិ ឬច្បាប់ស្តីពីលក្ខន្តិកៈទីក្រុងរ៉ូមជាមុនសិន។ គោលការណ៍នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គឺជាគោលគំនិតជាមូលដ្ឋានមួយ ដែលគាំទ្រដល់ការកាត់ទោសជនណាម្នាក់ដែលបង្កឱ្យមាន ឧក្រិដ្ឋកម្មអន្តរជា

[32]មាត្រា ១២,១៥,៥៣,៥៨,៨២,១០៣នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

តិ។គោលការណ៍នេះជាចម្បងដែលគេឃើញមានសម្រាប់ការអនុវត្តនូវច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់តុលាការដូចជាគោលការណ៍នីត្យានុកូលភាព។

### ១.១.គ្មានបទល្មើសព្រហ្មទណ្ឌ បើសិនគ្មានច្បាប់ចែង

តួយ៉ាងអនុលោមតាមច្បាប់លក្ខន្តិកៈនេះ គ្មានជនណាម្នាក់ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ លើកលែងតែ ការប្រព្រឹត្តនោះបង្កឱ្យកើតឡើងនូវបទល្មើសព្រហ្មទណ្ឌដែលស្ថិតក្នុងច្បាប់របស់តុលាការ។ ក្នុងនិយមន័យនៃបទល្មើសព្រហ្មទណ្ឌ ត្រូវតែបកស្រាយអធិប្បាយឱ្យលម្អិត ហើយមិនត្រូវពង្រីកវិសាលភាព ដោយការពន្យល់ប្រៀបធៀបឡើយ។ នៅក្នុងករណីមានវិមតិសង្ស័យ ការកំណត់និយមន័យនោះ ត្រូវបកស្រាយជាប្រយោជន៍ដល់ជនដែលកំពុងត្រូវរងការធ្វើការស៊ើបអង្កេត ដោយត្រូវនាំយកមកជំនុំជម្រះ ឬត្រូវបានសម្រេចឱ្យមានពិរុទ្ធភាព។ មាត្រានេះ មិនត្រូវប៉ះពាល់ដល់ការស្តែងចេញចរិតលក្ខណៈនៃការប្រព្រឹត្តណាមួយ ដែលមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌក្រោមច្បាប់អន្តរជាតិ ឯករាជ្យពីច្បាប់លក្ខន្តិកៈនេះឡើយ ដោយច្បាប់ទាំងនោះអាចមានគោលការណ៍ ឬចរិតលក្ខណៈផ្សេងៗ ពីគ្នា។

### ១.២.គ្មានទោសបើគ្មានច្បាប់កំណត់

ជនដែលត្រូវតុលាការសម្រេចឱ្យមានពិរុទ្ធភាព អាចត្រូវដាក់ទណ្ឌកម្មស្របតាមច្បាប់លក្ខន្តិកៈនេះតែប៉ុណ្ណោះ ចំណុចនេះបានបញ្ជាក់ថាទោះបីមានបទល្មើសក្តីដូចដែលបានចែងក្នុងច្បាប់ហើយ ក៏ប៉ុន្តែពុំបានចែងពីកម្រិតស្ថានភាពនៃទោសនោះ តុលាការមិនអាចដាក់ទណ្ឌកម្មបានឡើយដោយហេតុថាពុំមានច្បាប់ចែង។ [33]

## ២.គោលការណ៍មិនជំនុំជម្រះពីរដង

គោលការណ៍នេះ បានបង្ហាញពីសកម្មភាពមិនជំនុំជម្រះពីដងទៅលើបុគ្គលដដែល ឬការដែលមិនអាចធ្វើកាត់ទោស និងផ្តន្ទាទោសលើសពីម្តង ព្រមទាំងមានការមិនអនុញ្ញាតឱ្យជនណាម្នាក់ត្រូវជំនុំជម្រះនៅក្នុងតុលាការមួយទៀតផ្សេងទៀតផងដែរ។ បើជនណាត្រូវបានតុលាការព្រហ្មទណ្ឌអន្តជាតិសម្រេចឱ្យមានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពរួចទៅហើយនោះទេ ចំពោះបទល្មើសព្រហ្មទណ្ឌដែលបានប្រព្រឹត្តនោះ។ លើកលែងតែដំណើរការជម្រះនោះ ត្រូវបានធ្វើឡើងសម្រាប់គោលបំណងលាក់កំបាំងជនដែលពាក់ព័ន្ធ ពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ សម្រាប់បទល្មើសដែលស្ថិតនៅក្នុងយុត្តាធិការនៃតុលាការនោះ ឬបើមិនអញ្ចឹងទេ ត្រូវបានធ្វើឡើងដោយគ្មានឯករាជ្យ ឬដោយគ្មានភាពឥតលំអៀង មិនស្របតាមបទដ្ឋាន នៃដំណើរការត្រឹមត្រូវតាមច្បាប់ដែល

[33] មាត្រា ២២,២៣ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ៧ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

ទទួលស្គាល់ដោយច្បាប់អន្តរជាតិ ហើយត្រូវបានធ្វើឡើងតាមរបៀបមួយដែល ក្នុងកាលៈទេសៈនានា មិនស្រប តាមចេតនានាំខ្លួនជនដែលពាក់ព័ន្ធនោះមករកយុត្តិធម៌។[34]

## កថាខណ្ឌទី២៖ គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌអន្តរជាតិ

### ១.ការទទួលខុសត្រូវព្រហ្មទណ្ឌអន្តរជាតិ

ជនដែលបានប្រព្រឹត្តបទល្មើស ឬមានការចូលរួមដោយមិនថា ការចូលរួមជាសកម្មភាព ឬបញ្ញាស្មារតី គឺត្រូវតែទទួលខុសត្រូវចំពោះទង្វើទាំងនោះ ប៉ុន្តែយ៉ាងណាតុលាការ និងមិនមានយុត្តាធិការលើជនណាម្នាក់ ដែលមានអាយុក្រោម ១៨ ឆ្នាំ នៅពេលប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌដែលត្រូវបានចោទប្រកាន់នោះឡើយ។[35] តុលាការត្រូវមានយុត្តាធិការលើរូបវន្តបុគ្គល អនុលោមតាមច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម ជនដែលប្រព្រឹត្តបទល្មើស ព្រហ្មទណ្ឌនៅក្នុងយុត្តាធិការតុលាការ ត្រូវទទួលខុសត្រូវ និងទទួលទណ្ឌកម្មជា លក្ខណៈបុគ្គលស្របតាម ច្បាប់លក្ខន្តិកៈនេះ ប្រសិនបើជននោះ៖

- ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ទោះជាក្នុងរូបភាពជាឯកត្តជន ក្នុងរូបភាពរួមជាមួយអ្នកផ្សេងទៀត ឬក៏តាម រយៈជនដទៃទៀត ដោយមិនគិតថាជនដទៃទៀតនោះទទួលខុសត្រូវខាងព្រហ្មទណ្ឌ ឬអត់នោះទេ។
- ការជំរុញចិត្តឱ្យប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះ ដែលតាមពិត កើតមានឡើងដោយចេតនា ឬត្រូវបាន ប៉ងធ្វើឡើង។
- សម្រាប់គោលបំណងសម្រួលដល់ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះ ទំនុកបម្រុងកំដរ ឬក៏ជួយក្នុងការ ប្រព្រឹត្ត ឬការប៉ងប្រព្រឹត្ត រួមទាំងការផ្តល់មធ្យោបាយសម្រាប់ការប្រព្រឹត្តផងដែរ។ តាមមធ្យោបាយណា មួយផ្សេងទៀត រួមចំណែកនៅក្នុងការប្រព្រឹត្ត ឬប៉ងប្រព្រឹត្តិនូវបទល្មើសព្រហ្មទណ្ឌនោះ ដោយជនមួយ ក្រុមដែលធ្វើអំពើនោះឡើងក្នុងគោលបំណងរួមតែមួយ។ ការរួមចំណែកនេះត្រូវចាត់ទុកលក្ខណៈជា ចេតនា ដែលបង្ហាញ :

បានធ្វើឡើងដោយមានបំណងបន្តសកម្មភាពព្រហ្មទណ្ឌ ឬគោលបំណងព្រហ្មទណ្ឌរបស់ក្រុមដែល សកម្មភាព ឬគោលបំណងទាំងនោះពាក់ព័ន្ធទៅ និងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នៅក្នុងយុត្តាធិការ តុលាការ ឬបានធ្វើឡើងដោយមានការដឹងអំពីចេតនារបស់ក្រុមចង់ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ទាក់ទង និង បទល្មើសព្រហ្មទណ្ឌនៃអំពើប្រល័យពូជសាសន៍ ឬបទល្មើសណាមួយផ្សេងទៀត ក្នុងញុះញង់អ្នកដទៃដោយ

---

[34] មាត្រា ២០ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤

[35] មាត្រា ២៦ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

ផ្ទាល់ និងជាសាធារណៈ ឱ្យប្រព្រឹត្តអំពើដែលជាបទល្មើសទាំងអស់ ក្នុងដែនយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។

ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះ ដោយការធ្វើសកម្មភាពដែលចាប់ផ្តើមការអនុវត្តដោយជំហានហើយក៏បញ្ចប់ ប៉ុន្តែបទល្មើសព្រហ្មទណ្ឌមិនបានកើតឡើងដោយសារតែកាលៈទេសៈឯករាជ្យពីចេតនារបស់ជននោះ។ ទោះបីជាយ៉ាងណាក៏ដោយ ជនដែលបោះបង់ចោលនូវកិច្ចខិតខំប្រឹងប្រែងដើម្បីប្រព្រឹត្តបទល្មើសនោះ ឬក៏ទប់ស្កាត់នូវការសម្រេច ការប្រព្រឹត្តបទល្មើសនោះមិនត្រូវទទួលទណ្ឌកម្មក្រោមច្បាប់លក្ខន្តិកៈនេះចំពោះការប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះទេ បើសិនជាជននោះបានបោះបង់ចោលដោយស្ម័គ្រចិត្ត និងដោយពេញលេញនូវគោលបំណងដែលបានកំណត់ដោយច្បាប់ព្រហ្មទណ្ឌអន្តរជាតិនោះ។

- គ្មានបទបញ្ញត្តិណាមួយ នៃច្បាប់លក្ខន្តិកៈនេះដែលទាក់ទងទៅនឹងការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាលក្ខណៈ បុគ្គលត្រូវប៉ះពាល់ដល់ការទទួលខុសត្រូវរបស់រដ្ឋ ក្រោមច្បាប់អន្តរជាតិឡើយ។[36]

## ១.១.ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់មេបញ្ជាការ និងថ្នាក់លើផ្សេងៗទៀត

មេបញ្ជាការកងទ័ព ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះបទល្មើសដែលប្រព្រឹត្តដោយ កងកម្លាំងដែលស្ថិតនៅក្រោមបញ្ជា និងការត្រួតពិនិត្យរបស់ខ្លួនក្នុងករណីដែលមេបញ្ជាការកងទ័ពបានដឹង ឬគួរតែបានដឹងថាកងកម្លាំងកំពុងប្រព្រឹត្ត ឬប្រុងនឹងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយខកខានមិនបាន ចាត់វិធានការទាន់ពេលវេលាក្នុងក្របខណ្ឌនៃអំណាចរបស់ខ្លួន ដើម្បីទប់ស្កាត់ ឬបង្ក្រាបការប្រព្រឹត្តរបស់កងកម្លាំង និងមិនបានរាយការណ៍ដល់អាជ្ញាធរមានសមត្ថកិច្ចដើម្បីធ្វើការស៊ើបអង្កេត។ ចំពោះទំនាក់ទំនងរវាងថ្នាក់លើ(មេ) និងថ្នាក់ក្រោម(កូនចៅ) ក៏ទទួលខុសត្រូវខាងព្រហ្មទណ្ឌដូចទៅ និងមេបញ្ជាការផងដែរក្នុងករណីដែលថ្នាក់លើបានដឹង ឬគួរតែបានដឹងអំពីការដែលថ្នាក់ក្រោមកំពុងប្រព្រឹត្ត ឬប្រុងនឹងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយខកខានមិនបានចាត់វិធានការដើម្បីទប់ស្កាត់ ឬបង្ក្រាបបទល្មើសនោះ និងមិនបានធ្វើការរាយការណ៍ដល់អាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់វិធានការតាមនីតិវិធី។[37]

[36] មាត្រា ២៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

[37] មាត្រា ២៨ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

## ១.២.អំពីមូលហេតុនៃការរួចផុតពីការទទួលខុសត្រូវរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

មូលហេតុផ្សេងៗ សម្រាប់ការរួចពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលមានចែងក្នុងច្បាប់លក្ខន្តិកៈ នេះជនម្នាក់មិនត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ បើសិនជា នៅពេលដែលជននោះប្រព្រឹត្តៈ

- ជននោះមានជំងឺវិបត្តិស្មារតី ឬអនិបុណភាព ដែលបំផ្លាញសម្បទាក្នុងការយល់ដឹង ពីការខុសច្បាប់ ប្រភេទនៃការប្រព្រឹត្តរបស់ខ្លួន ឬសម្បទាក្នុងការគ្រប់គ្រងការប្រព្រឹត្តរបស់ខ្លួនឱ្យស្របតាមតម្រូវការ នៃច្បាប់ ។
- ជននោះស្ថិតនៅក្នុងសភាពស្រវឹងដែលការស្រវឹងបំផ្លាញសម្បទារបស់ជននោះលើការយល់ដឹងភាពខុសច្បាប់ ឬប្រភេទនៃការប្រព្រឹត្តរបស់ខ្លួន លើកលែងតែជននោះស្រវឹងដោយស្ម័គ្រចិត្តនៅក្នុងកាលៈទេសៈ ដែលជននោះបាន ដឹង ឬបានមិនអើពើចំពោះ ហានិភ័យ ដែលជាលទ្ធផលនៃការស្រវឹងនោះ ទំនងជាភ្ជាប់ការចូលរួមនៅក្នុងការប្រព្រឹត្តដែលបង្កនូវបទល្មើសព្រហ្មទណ្ឌ ក្នុងយុត្តាធិការតុលាការ ។
- ជនធ្វើអំពើសមហេតុផលដើម្បីការពារខ្លួន ឬការពារជនម្នាក់ទៀត ឬនៅក្នុងករណីបទល្មើសសង្គ្រាម ការពារទ្រព្យសម្បត្តិដែលសំខាន់ចាំបាច់សម្រាប់ការចិញ្ចឹមជីវិតរបស់ជននោះ ឬរបស់ជនដទៃទៀត ឬទ្រព្យដែលសំខាន់ ចាំបាច់សម្រាប់បំពេញសកម្មភាពយោធា ទល់នឹងការប្រើប្រាស់ដោយកំលាំងខុសច្បាប់ ដែលប្រុងនឹងកើតមានឡើងតាមរបៀប មួយសមាមាត្រទៅ និងកម្រិត នៃគ្រោះថ្នាក់ចំពោះជននោះ ឬចំពោះជនដទៃទៀត ឬចំពោះទ្រព្យដែលត្រូវបានការពារនោះ។ ហេតុដែលជននោះពាក់ព័ន្ធ និងប្រតិបត្តិការការពារធ្វើឡើងដោយបង្ខំ ក៏ជាមូលហេតុក្នុងការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។ ការប្រព្រឹត្តដែលត្រូវបានចោទថា បង្កបង្កើតនូវបទល្មើសព្រហ្មទណ្ឌស្ថិតនៅក្នុងយុត្តាធិការតុលាការបានត្រូវធ្វើឡើងដោយមានការបង្ខិតបង្ខំដែលជាលទ្ធផលមកពីការគំរាមកំហែងចំពោះក្ខីមរណៈដែលប្រុងនឹងកើតមានឡើង ឬនូវការឈឺចាប់ផ្នែករូបកាយដែលកំពុងមាន ឬដែលប្រុងនឹងកើតមានឡើងចំពោះជននោះ ឬចំពោះជនដទៃទៀត ហើយជននោះ ធ្វើអំពើត្រឹមកម្រិត ចាំបាច់ និងសមហេតុផលដើម្បីបញ្ចៀសការគំរាមកំហែងនេះ ក្នុងលក្ខខណ្ឌថា ជននោះមិនមាន ចេតនាបង្កឱ្យមានការឈឺចាប់ធំជាងទំហំនៃការឈឺចាប់ដែលត្រូវបានពុះពារជៀសវាង។ ការគំរាមកំហែងនោះអាចជាបានធ្វើឡើងដោយជនម្នាក់ផ្សេងទៀត បានបង្កបង្កើតឡើងដោយកាលៈទេសៈ ផ្សេងៗទៀត ដែលហួសពីលទ្ធភាពគ្រប់គ្រងរបស់ជននោះ។[38]

---

[38]មាត្រា ៣១ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

### ១.២.១.អំពីការច្រឡំលើអង្គហេតុ ឬអង្គច្បាប់

ការច្រឡំអំពីអង្គហេតុអាចជាមូលហេតុមួយសម្រាប់ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ក្នុងករណី ធ្វើអវិជ្ជមានកម្ម (ប្រឆាំង) ទៅនឹងធាតុបញ្ញាស្មារតី ដែលត្រូវតម្រូវដោយ បទល្មើសព្រហ្មទណ្ឌទាំងអស់នោះ។ ការច្រឡំអំពីអង្គច្បាប់ ថាតើការប្រព្រឹត្តណាមួយជាក់លាក់ គឺជាបទល្មើសព្រហ្មទណ្ឌស្ថិតនៅក្នុងយុត្តាធិការ តុលាការ ឬអត់មិនត្រូវជាមូលហេតុសម្រាប់ការរួចពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ។ ប៉ុន្តែបើការច្រឡំអំពីអង្គច្បាប់ជា មូលហេតុសម្រាប់ការរួចពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ បើសិនជាប្រឆាំង និងធាតុបញ្ញាស្មារតីដែលតម្រូវដោយបទល្មើសនោះ ដោយសេចក្តីបង្គាប់នៃច្បាប់ ដោយបទល្មើសព្រហ្មទណ្ឌ ត្រូវបានប្រព្រឹត្តធ្វើឡើងដោយជនម្នាក់ តាមបញ្ជា របស់រដ្ឋាភិបាល ឬរបស់ថ្នាក់លើ ទោះជាស៊ីវិលក្តី ឬយោធាក្តី មិនត្រូវឱ្យជននោះរួចពីបន្ទុកនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ លើកលែងតែ :

- ជននោះមានកាតព្វកិច្ចផ្លូវច្បាប់ត្រូវគោរពបញ្ជារបស់រដ្ឋាភិបាល ឬរបស់ថ្នាក់លើនោះ
- ជននោះមិនបានដឹងថា ការបញ្ជានោះខុសច្បាប់
- ការបញ្ជានោះមិនបានបង្ហាញជាក់ស្តែងថា ខុសច្បាប់ ។[39]

តុលាការត្រូវកំណត់ពីភាពដែលអាចក្នុងការអនុវត្តបាន មូលហេតុសម្រាប់ការរួចផុតពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចែងនៅក្នុងច្បាប់លក្ខន្តិកៈនេះ ចំពោះករណីដែលដាក់ឱ្យតុលាការសម្រេច។ នៅក្នុងពេលជំនុំជម្រះ តុលាការអាចពិចារណាមូលហេតុសម្រាប់ការឱ្យរួចពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ពីមូលហេតុទាំងឡាយដែលបានលើកឡើងខាងលើ ដែលមូលហេតុនោះត្រូវបានទាញយកចេញមកពីច្បាប់ដែលអាចយកមកអនុវត្តន៍បាន ដូចដែលមានចែងនៅក្នុងមាត្រា ២១ ព្រមទាំងនីតិវិធីទាក់ទងទៅនឹងការពិចារណាលើមូលហេតុនោះ ដែលមានចែងនៅក្នុងវិធាននៃនីតិវិធី និងភស្តុតាងផងដែរ។

## ២.គ្មានលក្ខណៈប្រតិសកម្ម និងមិនមានការអនុវត្តអាជ្ញាយុកាល

គ្មានជនណាម្នាក់ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌ ក្រោមច្បាប់លក្ខន្តិកៈនេះ ចំពោះការប្រព្រឹត្តធ្វើឡើងមុនពេលដែលច្បាប់លក្ខន្តិកៈនេះចូលជាធរមានឡើយ។ ក្នុងករណីមានការកែប្រែផ្លាស់ប្តូរនៅក្នុងច្បាប់ដែលអាចយកមកអនុវត្តបាន ចំពោះករណីមួយមុនមានសាលក្រមស្ថាពរ ត្រូវអនុវត្តច្បាប់ដែលមានលក្ខណៈជាប្រយោជន៍ដល់ជនដែលកំពុងត្រូវបានស៊ើបអង្កេត ត្រូវបាននាំយកមកជំនុំជម្រះ ឬត្រូវសម្រេចឱ្យមានពិរុទ្ធភាព

[39] មាត្រា ៣២,៣៣ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

ត្រង់នេះគេចង់និយាយថា ត្រូវសម្រេចតាមច្បាប់ចាស់តែត្រូវបានកែប្រែ ព្រោះមិនទាន់ចូលជាធរមានទេ។ [40] ចំពោះបទល្មើសទាំងអស់ ដែលកើតមានហើយស្ថិតក្រោមដែនយុត្តាធិការរបស់តុលាការ ព្រហ្មទណ្ឌអន្តរជាតិ គឺមិនមែនជាកម្មវត្ថុនៃអាជ្ញាយុកាលឡើយ។[41]

## ផ្នែកទី២៖ ច្បាប់ក្នុងការអនុវត្ត របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

### កថាខណ្ឌទី១៖ អំពីច្បាប់ដែលត្រូវយកមកអនុវត្តន៍

តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវអនុវត្តន៍លក្ខន្តិកៈទីក្រុងរ៉ូមស្ដីពី តុលាការព្រហ្មទណ្ឌអន្តរជាតិ វិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការ សន្ធិសញ្ញា និងគោលការណ៍ វិធាននៃច្បាប់អន្តរជាតិ ព្រមទាំងយុទ្ធសាស្ត្ររបស់តុលាការកន្លងមក។

#### ១.ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម

ដូចដែលយើងបានដឹងមកហើយថាច្បាប់ស្ដីពីលក្ខន្តិកៈទីក្រុងរ៉ូម គឺជាមូលដ្ឋានគ្រឹះមួយសំខាន់ក្នុងការបង្កើតតុលាការ ហើយចំពោះច្បាប់ស្ថាប័ននេះត្រូវបានយកមកអនុវត្តក្នុងរឿងក្ដីដែលជាបទល្មើសនោះត្រូវតែគោរពតាមលក្ខន្តិកៈនេះជាចម្បង ជាពិសេសនោះក៏បានផ្ដល់ឱ្យនូវអំណាចផ្សេងទៀត សម្រាប់តុលាការ ក្នុងការបំពេញមុខងាររបស់ខ្លួន យោងតាមការកំណត់នេះយើងអាចដឹងថាលក្ខន្តិកៈទីក្រុងរ៉ូម គឺជាច្បាប់កំពូលរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។[42]

#### ២.វិធាននៃនីតិវិធី និងភស្តុតាង

វិធាននៃនីតិវិធី និងភស្តុតាង គឺជាឧបករណ៍សម្រាប់អនុវត្តលក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលជាវិធានដ៏សំខាន់បន្ទាប់លក្ខន្តិកៈទីក្រុងរ៉ូម ក្នុងដំណើរការនៃការអនុវត្តច្បាប់។ ក្នុងការបញ្ជាក់អំពីវិធាននៃនីតិវិធី និងភស្តុតាង ត្រូវបានយកចិត្តទុកដាក់តាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីជៀសវាងការធ្វើឡើងវិញ នៅបទប្បញ្ញត្តិនៃលក្ខន្តិកៈនេះ។ សេចក្ដីយោងផ្ទាល់ចំពោះលក្ខន្តិកៈត្រូវបានបញ្ចូលក្នុងវិធាន ដែលសមស្រប ដើម្បីបញ្ជាក់ពីទំនាក់ទំនងរវាងវិធាន និងលក្ខន្តិកៈទីក្រុងរ៉ូម ដូចមានចែងក្នុងមាត្រា ៥១ ជាពិសេស

---

[40] មាត្រា ២៤ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

[41] មាត្រា ២៩ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

[42] មាត្រា ២១ (១) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

កថាខណ្ឌទី ៤ និងទី ៥។ ក្នុងគ្រប់ករណីទាំងអស់ វិធាននៃនីតិវិធី និងភស្តុតាងគួរតែត្រូវបានអនុវត្តរួមជាមួយ និងជាកម្មវត្ថុនៃលក្ខន្តិកៈ វិធាននៃនីតិវិធី និងភស្តុតាងរបស់ តុលាការមិនប៉ះពាល់ដល់វិធាននីតិវិធីសម្រាប់តុលាការជាតិណាមួយឡើយ ឬប្រព័ន្ធច្បាប់ក្នុងគោលបំណងជាតិដំណើរការ។[43]

## ៣.សន្ធិសញ្ញា គោលការណ៍ និងវិធាននៃច្បាប់អន្តរជាតិ

ប៉ុន្តែក្រៅពីលក្ខន្តិកៈទីក្រុងរ៉ូម និងវិធាននៃនីតិវិធី និងភស្តុតាងនេះ គេក៏អាចប្រើប្រាស់នូវសន្ធិសញ្ញាដែលកិច្ចព្រមព្រៀងផងដែរ ហើយកិច្ចព្រមព្រៀងនោះត្រូវតែអនុលោម ទៅតាមអនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់នៃសន្ធិសញ្ញា មានចែងក្នុងមាត្រា ៣១ និង៣២។ សន្ធិសញ្ញា និងគោលការណ៍ វិធាននៃច្បាប់អន្តរជាតិ ដែលអាចយកមកអនុវត្តបាន រួមបញ្ចូលទាំងគោលការណ៍នៃច្បាប់អន្តរជាតិពីជម្លោះប្រដាប់អាវុធ តុលាការអាចប្រើក្នុងអនុវត្តបានលុះត្រាតែមានលក្ខខណ្ឌពីរ ដែលមានដូចជា៖

- បទល្មើសដែលកំណត់ថាជាឧក្រិដ្ឋកម្ម ក្នុងច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម ប៉ុន្តែសកម្មភាពនោះបានរំលេចនូវធាតុផ្សំផ្សេងៗ ដែលច្បាប់ពុំអាចកំណត់នូវសញ្ញាណបានច្បាស់ត្រង់ចំណុចនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិក៏អាចប្រើប្រាស់នូវសន្ធិសញ្ញា និងគោលការណ៍ វិធាននៃច្បាប់អន្តរជាតិ បន្ថែមសម្រាប់ចំណុចខ្វះខាតទាំងនេះ។
- ភាពខ្វះចន្លោះនៃច្បាប់ដែលមិនអាច ធ្វើការបកស្រាយ ឬអនុវត្តបាននៅស្ថានភាពមួយសម្រាប់បទល្មើសដែលកើតមាននោះ ត្រង់ចំណុចទី ២ ក៏គេអាចប្រើនូវសន្ធិសញ្ញាបានផងដែរ។

ត្រង់នេះបានបង្ហាញថាបើកាលណា ដំណើរនៃការជម្រះក្ដីមួយ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មិនអាចស្វែងរកដំណោះស្រាយចំពោះសំណួរផ្លូវច្បាប់ ឬបញ្ហាដែលបានកើតឡើងទាំងនោះ នៅក្នុងប្រភពផ្ទៃក្នុងនៃច្បាប់របស់ខ្លួន ឬនៅក្នុងសន្ធិសញ្ញា គោលការណ៍ និងវិធាននៃច្បាប់អន្តរជាតិទេ តុលាការអាចស្វែងរកដំណោះស្រាយនៅក្នុងគោលការណ៍ទូទៅនៃច្បាប់ដែលបានមកពី ច្បាប់ជាតិរដ្ឋភាគី ក្នុងលក្ខខណ្ឌថាមិនផ្ទុយទៅនឹងច្បាប់អន្តរជាតិ ព្រមទាំងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ពិសេស បទដ្ឋានអន្តរជាតិផ្សេងៗ ដែលមានជាស្តង់ដាស្របតាមការទទួលស្គាល់ជាអន្តរជាតិ។[44]

---

[43] សៀវភៅ វិធាននៃនីតិវិធី និងភស្តុតាង បោះពុម្ពដោយមន្ត្រីកំណត់ត្រានៃសភារដ្ឋភាគីចំពោះលក្ខន្តិកៈទីក្រុងរ៉ូមរបស់អន្តរជាតិ ក្នុងចំណុចកំណត់ចំណាំ,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤

https://www.icc-cpi.int/sites/default/files/Publications/Rules-of-Procedure-and-Evidence.pdf

[44] មាត្រា ២១ (គ) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤

តែទោះជាយ៉ាងណាការអនុវត្តយុត្តាធិការជាតិនេះ បានបង្ហាញឱ្យឃើញនូវ លក្ខខណ្ឌដែលមិនស្រប អំពីលក្ខន្តិកៈទីក្រុងរ៉ូម និងជាមួយច្បាប់អន្តរជាតិ បទដ្ឋាន និងស្តង់ដាទទួលស្គាល់ជាអន្តរជាតិដោយពេលខ្លះរដ្ឋជាភាគីអាចជាអ្នកដាក់ពាក្យសុំមិនស្របតាម។[45]

### ៤.យុត្តិសាស្ត្ររបស់តុលាការ

ក្រៅពីចំណុចដែលបានលើកបង្ហាញខាងលើនេះ តុលាការក៏អាចធ្វើការដោះស្រាយរឿងក្តី ដែលកើតមានដោយយោងទៅតាមសេចក្តីសម្រេចពីមុនរបស់ខ្លួន និងភាពដែលស្រដៀងគ្នានៃរឿងក្តីនោះ។ តួយ៉ាងការអនុវត្ត និងការបកស្រាយច្បាប់ អនុលោមតាមមាត្រា ២១ នេះ ត្រូវតែស្របគ្នាជាមួយ និងសិទ្ធិមនុស្ស ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ហើយមិនត្រូវមានភាពខុសប្លែកដែលប្រឆាំងគ្នា ផ្អែកលើមូលដ្ឋានដូចជា យែនឌ័រ ដែលបានកំណត់ពន្យល់នៅក្នុងកថាខណ្ឌទី៣ នៃមាត្រា ៧ អាយុ ពូជសាសន៍ ពណ៌សម្បុរ ភាសា សាសនា ឬជំនឿ ទស្សនៈនយោបាយ ឬទស្សនៈផ្សេងៗទៀត ដែលជាភាពពាក់ព័ន្ធដូចជា ដើមកំណើតជាតិ ជាតិពន្ធ ឬ ដើមកំណើតសង្គម ទ្រព្យសម្បត្តិ កំណើត ឬឋានៈសង្គមឡើយ។[46] ចុងក្រោយគួរកត់សំគាល់ថា មាត្រា ២១ (៣) សំដៅលើការអនុវត្តច្បាប់ដែលបានបង្ហាញអំពី ការបកស្រាយដែលជាប់ពាក់ព័ន្ធជាមួយសិទ្ធិមនុស្សនេះ ដើម្បីធ្វើធានាថាសិទ្ធិមនុស្សត្រូវបានតុលាការយកមកអនុវត្តន៍ផងដែរ ការអនុវត្តសិទ្ធិមនុស្សអាចគាំទ្រដល់ការកំណត់អត្តសញ្ញាណ នៃភាពចន្លោះ ឬខ្វះខាតដែលកើតមាននៅក្នុងប្រព័ន្ធច្បាប់ផ្ទៃក្នុង របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបំពេញតម្រូវការប្រើប្រាស់ពីប្រភពច្បាប់ខាងក្រៅរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។[47]

## កថាខណ្ឌ២៖ យុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

### ១.បទល្មើសស្ថិតក្នុងដែនយុត្តាធិការ

តុលាការព្រហ្មទណ្ឌអន្តរជាតិជាស្ថាប័នអចិន្ត្រៃយ៍ ហើយត្រូវមានអំណាចអនុវត្តយុត្តាធិការរបស់ខ្លួនលើជនទាំងឡាយ ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរបំផុតដែលជាការព្រួយបារម្ភរបស់អន្តរជាតិ ដូចមាន

---

https://www.icc-cpi.int/about/the-court

[45] រដ្ឋអាជ្ញា v. Katanga និងNgudjolo, ICC PT ។ ឆ. I, ការសម្រេចចិត្តលុបចោលការហាមឃាត់ទំនាក់ទំនង និងការទំនាក់ទំនងរវាង Germain Katanga និងMathieu Ngudjolo Chui ថ្ងៃទី 13 ខែ មិនា ឆ្នាំ 2008 ទំព័រ១២, ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤

https://www.icc-cpi.int/sites/default/files/CourtRecords/CR2008_05172.PDF

[46]មាត្រា ២១ (៣) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤

https://www.icc-cpi.int/about/the-court

[47]រដ្ឋអាជ្ញា v. Lubanga, ICC សាលក្រមរបស់អង្គជំនុំជម្រះឧទ្ធរណ៍របស់ Thomas Lubanga Dyilo ICC ស្តីពីផ្លូវច្បាប់ ទំព័រទី ០២, ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤

https://haguejusticeportal.net/Docs/Commentaries%20PDF/Senier_Lubanga_EN.pdf

ចែងក្នុងច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម និងត្រូវជាការបន្ថែមលើយុត្តាធិការព្រហ្មទណ្ឌជាតិ ដែលមានសមត្ថកិច្ចទៅលើបទល្មើសដែលមានដូចជា ៖

- ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍
- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ
- ឧក្រិដ្ឋកម្មសង្គ្រាម
- ឧក្រិដ្ឋកម្មឈ្លានពាន។[48]

តុលាការមានសមត្ថកិច្ចចំពោះរដ្ឋដែលជាភាគី របស់លក្ខន្តិកៈទីក្រុងរ៉ូម សម្រាប់បញ្ហាដែលទាក់ទងជាមួយ និងបទល្មើសទាំងអស់ដែលមានចែងក្នុងមាត្រា ៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម។ ហើយតុលាការក៏អាចធ្វើការអនុវត្តយុត្តាធិការរបស់ខ្លួននេះបានក្នុងស្ថានភាពដែលជនល្មើសទាំងនោះ ត្រូវបានចោទប្រកាន់ដោយជនជាតិនៃរដ្ឋភាគី ឬកន្លែងដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តនៅលើទឹកដីនៃរដ្ឋភាគី។ ម្យ៉ាងវិញទៀតនោះ រដ្ឋដែលមិនមែនជាភាគីនៃលក្ខន្តិកៈក៏អាចអនុវត្តយុត្តាធិការរបស់តុលាការអាចសម្រេចចិត្តទទួលយកយុត្តាធិការរបស់តុលាការនេះ ដោយការប្រកាសទទួលយក ដោយជូនដំណឹងទៅតុលាការ។

**១.២.ករណីសិក្សា** (ប្រទេស ប៉ាឡេស្ទីនការប្រកាសទទួលយកយុត្តាធិការ)

ជាក់ស្តែងដូចជា ករណីប្រទេស ប៉ាឡេស្ទីនការទទួលយកយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តជាតិនេះ ដែលបានអនុញ្ញាតឱ្យតុលាការធ្វើការស៊ើបអង្កេត និងកាត់ទោសបុគ្គលដែលប្រព្រឹត្ត ឬធ្វើឱ្យកើតមានឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតដែលជាស្ថានភាពមួយនៃការព្រួយបារម្ភជាអន្តរជាតិ ដូចជាអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តនៅក្នុងទឹកដីប៉ាឡេស្ទីន។ ឆ្នាំ ២០០៩ អាជ្ញាធរជាតិប៉ាឡេស្ទីនបានដាក់ពាក្យទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ នូវសេចក្តីប្រកាសដើម្បីទទួលយកយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់ទឹកដីប៉ាឡេស្ទីន។ សេចក្តីប្រកាសដែលជាលិខិតរបស់អាជ្ញាធរជាតិ ប៉ាឡេស្ទីន ចេញពីការិយាល័យរដ្ឋមន្ត្រី នៃក្រសួងយុត្តិធម៌ ដោយបង្ហាញពីខ្លឹមសារក្នុងការទទួលស្គាល់យុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលធ្វើឱ្យតុលាការមានយុត្តាធិការលើទឹកដីនោះ ដោយអនុលោមតាមមាត្រា ១២ កថាខណ្ឌ ៣ នៃលក្ខន្តិកៈទីក្រុងរ៉ូមហើយសេចក្តីប្រកាសនេះធ្វើឡើងគឺជាការឆ្លើយតបទៅ និងជម្លោះដែលកើតមានរវាងប្រទេសអ៊ីស្រាអែល-ប៉ាឡេស្ទីនដែលកំពុងបន្ត និងបណ្តាលឱ្យកើតមានការបាត់បង់នូវប្រជាជន

[48]មាត្រា ៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

របស់ប៉ាឡេស្ទីន ហើយត្រូវបានគេមើលឃើញថាជាមធ្យោបាយមួយក្នុងការធ្វើឱ្យបុគ្គលមានការ ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលត្រូវបានកើតឡើងនេះ។ [49]

## ២.ការផ្តួចផ្តើមក្នុងការអនុវត្តយុត្តាធិការ

### ២.១.ការអនុវត្តច្បាប់

ការអនុវត្តយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តជាតិនេះធ្វើឡើងបាន ដោយចាប់ផ្តើមពីចំណុចដំបូងគឺជាយន្តការនៃការផ្តួចផ្តើម (TRIGGER MECHANISM) ដែលធ្វើឱ្យមានការអនុវត្តយុត្តាធិការ បានបង្ហាញនៅពេលណាដែលរដ្ឋមួយចូលរួមជារដ្ឋភាគីតុលាការ និងផ្តល់សច្ចាប័នលើឯកសារធាតុផ្សំរបស់ខ្លួន ក្នុងការទទួលយកយុត្តាធិការរបស់តុលាការដោយស្វ័យប្រវត្តិ។ ហើយការអនុវត្តនេះទៀតសោតបានធ្វើឡើងតាមរយៈ ការស្នើក្នុងទិដ្ឋភាពផ្តួចផ្តើមដោយ រដ្ឋភាគីជាអ្នកដាក់សំណើ ឬការស្នើពីស្ថានភាពពីបទល្មើសនោះ តាមរយៈក្រុមប្រឹក្សាសន្តិសុខ និងការផ្តួចផ្តើមពីរដ្ឋអាជ្ញាដោយមើលឃើញនូវស្ថានភាពចាត់ទុកជាបទល្មើស ដូចដែលបានកំណត់ក្នុងច្បាប់នៃលក្ខន្តិកៈទីក្រុងរ៉ូម តាមរយៈសិទ្ធិក្នុងការអនុវត្តអំណាចរបស់រដ្ឋអាជ្ញា។[50] រដ្ឋភាគី និងរដ្ឋអាជ្ញាអាចចាប់ផ្តើមដំណើរការនីតិវិធីទាក់ទង និងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅលើទឹកដីរបស់រដ្ឋភាគី ឬដោយគិតពីសញ្ជាតិជនជាប់ចោទ របស់រដ្ឋភាគី។[51]

#### ២.១.១.ការផ្តួចផ្តើមការអនុវត្តច្បាប់ដោយរដ្ឋភាគី

រដ្ឋដែលជាភាគី របស់តុលាការព្រហ្មទណ្ឌអន្តរជាតិអាចបញ្ជូនស្ថានភាពមួយទៅកាន់តុលាការ ដែលមើលឃើញថាស្ថានភាពនោះវាជាឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មទាំងបួន ដែលមាននៅក្នុងដែនយុត្តាធិការរបស់តុលាការ។[52] ត្រង់ចំណុចនេះយើងក៏ឃើញមានប្រទេសមួយ បានធ្វើការបញ្ជូនលទ្ធផល ឬស្ថានភាពផ្ទាល់ខ្លួនទៅកាន់តុលាការដោយខ្លួនឯង ជាក់ស្តែងដូចជា សាធារណរដ្ឋអាហ្វ្រិកកណ្តាលបានបញ្ជូនស្ថានភាពរដ្ឋ ខ្លួនឯងផ្ទាល់ បានធ្វើឡើងនៅក្នុងខែធ្នូ ឆ្នាំ២០០៤ ហើយការស៊ើបអង្កេតរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានបើកនៅក្នុងខែឧសភា ឆ្នាំ២០០៧ ដោយផ្តោតលើឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែល

---

[49] សេចក្តីប្រកាសរបស់ប៉ាឡេស្ទីនទៅកាន់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ៖ ស្តីពីបញ្ហារដ្ឋ,ចូលមើលថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០២៤
https://iccforum.com/media/background/gaza/2009-05-19_Quigley_Memo_on_Palestine_Declaration.pdf

[50]មាត្រា ១៤ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០២៤
https://www.icc-cpi.int/about/the-court

[51]មាត្រា ១២(២) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០២៤
https://www.icc-cpi.int/about/the-court

[52]មាត្រា ១៤ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០២៤
https://www.icc-cpi.int/about/the-court

បានប្រព្រឹត្តនៅក្នុងបរិបទនៃជម្លោះ រវាងប្រធានាធិបតី Ange-Félix Patassé បានទទួលការគាំទ្រពីកងកម្លាំងនៃចលនារំដោះកុងហ្គោរបស់ Jean-Pierre Bemba បានប្រព្រឹត្តអំពើឃោរឃៅយ៉ាងធ្ងន់ធ្ងរ រួមទាំងការសម្លាប់រង្គាល និងការរំលោភកំឡុងពេលដែលតតាំង ជាមួយពួកក្រុមឧទ្ទាមដែលដឹកនាំដោយ François Bozizé នៅក្នុងប្រទេស។[53] ដោយមើលឃើញពីស្ថានភាពដែលកំពុងតែកើតមានឡើងទាំងនេះហើយ ទើបរដ្ឋាភិបាលអន្តរកាលរបស់សាធារណរដ្ឋអាហ្វ្រិកកណ្តាល បានធ្វើការបញ្ជូនទៅកាន់ តុលាការព្រហ្មទណ្ឌអន្តរជាតិ លើកទីពីរក្នុងខែឧសភា ឆ្នាំ២០១៤។

### ២.១.២.ការផ្តួចផ្តើមដោយក្រុមប្រឹក្សាសន្តិសុខ (UNSC)

ការបញ្ជូនស្ថានភាព ឬទិដ្ឋភាពទូទៅដែលបង្ហាញអំពីសញ្ញាណនៃបទល្មើស ដើម្បីធ្វើការផ្តួចផ្តើមឱ្យមានការអនុវត្តច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តជាតិ ត្រង់នេះបានចង្អុលបង្ហាញពីស្ថានភាព នៃអន្តកម្មរវាងក្រុមប្រឹក្សាសន្តិសុខ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ការធ្វើសកម្មភាពបែបនេះដោយយោងទៅលើអំណាចរបស់ខ្លួនក្រោមជំពូកទី ៧ នៃធម្មនុញ្ញអង្គការសហប្រជាជាតិស្តីអំពី អំពើនាំធ្វើឱ្យប៉ះពាល់សន្តិភាពដែលកម្រិតក្នុងមាត្រា ៤០ អបជាមួយការទទួលស្គាល់ច្បាប់នៃលក្ខន្តិកៈទីក្រុងរ៉ូម អំពីសកម្មភាពក្រុមប្រឹក្សាសន្តិសុខ។[54] ក្នុងការបញ្ជូនបញ្ហាទៅរដ្ឋអាជ្ញាដើម្បីផ្តួចផ្តើមការស៊ើបអង្កេតដោយអនុលោមតាមជំពូកទី ៧ នៃធម្មនុញ្ញអង្គការសហប្រជាជាតិកំណត់អំណាចរបស់ក្រុមប្រឹក្សាសន្តិសុខ ដើម្បីដោះស្រាយការគំរាមកំហែងដល់សន្តិភាព ការរំលោភលើសន្តិភាព ឬអំពើឈ្លានពានដោយសកម្មភាពនេះទទួលស្គាល់ដោយ នៃលក្ខន្តិកៈទីក្រុងរ៉ូម មិនតែប៉ុណ្ណោះការផ្តួចផ្តើម ឬការបញ្ជូនស្ថានភាពនេះអាចបង្កើតយុត្តាធិការទៅលើរដ្ឋដែលមិនមែនជាភាគីច្បាប់នៃលក្ខន្តិកៈទីក្រុងរ៉ូមបានផងដែរ។[55] ជាក់ស្តែងករណីប្រទេស ដាហ្វួរ និងលីប៊ី ក្រុមប្រឹក្សាសន្តិសុខបានបញ្ជូនស្ថានភាពរបស់ប្រទេសពីរនេះទៅតុលាការដោយមើលឃើញអំពីការគំរាមកំហែងដល់សុខសន្តិភាព ដែលទោះបីជារដ្ឋទាំងពីនេះមិនមែនជាភាគីនៃ តុលាការព្រហ្មទណ្ឌអន្តរជាតិក៏ដោយ។ ទោះជាយ៉ាងណាការសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិ ក្នុងការបញ្ជូនស្ថានភាពណាមួយទៅកាន់តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវធ្វើឡើងជាឯកច្ឆ័ន្ទ ហើយប្រទេសមួយចំនួនអាចប្រឆាំង ឬបដិសេធមិនបោះឆ្នោតលើដំណោះស្រាយបែបនេះត្រង់ចំណុច

---

[53] ប្រវត្តិនយោបាយហិង្សារបស់សាធារណរដ្ឋអាហ្វ្រិកកណ្តាលចូលមើលថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០២៤
https://www.hrw.org/reports/2007/car0907/4.htm

[54] ធម្មនុញ្ញអង្គការសហប្រជាជាតិ,ចូលមើលថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០២៤
https://treaties.un.org/doc/publication/ctc/uncharter.pdf

[55]មាត្រា១៣ (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០២៤
https://www.icc-cpi.int/about/the-court

នេះបានរំលេច នូវផលវិបាករបស់ក្រុមប្រឹក្សាដែលបានស្ថិតនៅក្រោមសម្ពាធពីការមិនយល់ព្រម ដែលសំដៅលើការបដិសេធពីសមាជិករបស់ខ្លួន ដើម្បីធ្វើការសម្រេចដាក់ស្ថានភាពរបស់ប្រទេសមួយទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីបញ្ជូនស្ថានភាពទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ។

ត្រង់ចំណុចនេះផងដែរវាធ្វើឲ្យមានផលវិបាកមួយចំនួនដែលទាក់ទិនទៅ និងការកំណត់នូវសកម្មភាពត្រឹមត្រូវរបស់ក្រុមប្រឹក្សាសន្តិសុខនៅក្រោមជំពូក ៧ នៃរដ្ឋធម្មនុញ្ញអង្គការសហប្រជាជាតិថាតើសកម្មភាពរបស់ក្រុមប្រឹក្សាសន្តិសុខនោះត្រឹមត្រូវ ដែលឆ្លុះបញ្ចាំងពីសកម្មភាពរបស់ខ្លួនក្នុងការធ្វើការបញ្ជូនស្ថានការណ៍របស់ប្រទេសណាមួយ។[56] មកទល់នឹងពេលនេះ ទាំងរដ្ឋអាជ្ញា និងភាគីណាមួយនៃស្ថានការណ៍នៅចំពោះមុខតុលាការមិនបានជំទាស់ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាសន្តិសុខក្នុងការបញ្ជូនស្ថានភាពជាក់លាក់មួយទៅកាន់តុលាការ ទោះយ៉ាងណាក៏ដោយ ក្នុងគ្រប់ស្ថានភាពផ្តួចផ្តើមទាំងអស់ រួមទាំងការបញ្ជូនដោយក្រុមប្រឹក្សាសន្តិសុខ ឬដោយរដ្ឋភាគីក្តីមិនមែនក្តី រដ្ឋអាជ្ញាត្រូវតែបំពេញ ការចាប់ផ្តើមដោយខ្លួនឯងផ្ទាល់ដោយផ្អែកលើមូលដ្ឋានសមហេតុផលសម្រាប់ការស៊ើបអង្កេត និងអនុវត្តតាមលក្ខខណ្ឌផ្សេងទៀតនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមសម្រាប់ការផ្តួចផ្តើមការស៊ើបអង្កេត រួមទាំងតម្រូវការនៃមាត្រា ៥៣។[57]

### ២.១.៣.ការផ្តួចផ្តើមពីរដ្ឋអាជ្ញា

រដ្ឋអាជ្ញាអាចផ្តួចផ្តើមក្នុងការទាមទារឱ្យបើកស៊ើបអង្កេត ដោយផ្អែកលើអំណាចរបស់ខ្លួនផ្ទាល់ (PROPIO MOTU) ដែលជាឆន្ទានុសិទ្ធិរបស់ រដ្ឋអាជ្ញា យោងលើមូលដ្ឋាន ឬព័ត៌មានអំពីបទល្មើសព្រហ្មទណ្ឌដែលស្ថិតក្នុងដែនយុត្តាធិការរបស់តុលាការ។ រដ្ឋអាជ្ញាអាចអនុវត្តអំណាចតាមសិទ្ធិរបស់ខ្លួនដោយផ្អែកលើព័ត៌មានដែលបានមកពីប្រភពណាមួយចំនួន រួមទាំងបុគ្គលក្រុម រដ្ឋ អង្គការអន្តររដ្ឋាភិបាល (IGOs) និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) ឬប្រភពដែលគួរឱ្យជឿបានដទៃទៀតដែលខ្លួនយល់ថា សមស្របហើយអាចទទួលសក្ខីកម្មជា លាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់នៅក្នុងអាសនៈតុលាការ។[58] រដ្ឋអាជ្ញាត្រូវវិភាគលម្អិត និងហ្មត់ចត់នៃព័ត៌មានដែលទទួលបាន បន្ទាប់បើរដ្ឋអាជ្ញាសន្និដ្ឋានថា មានមូលដ្ឋានសមហេតុផលដើម្បីបន្តបើកការស៊ើបអង្កេតខ្លួនត្រូវដាក់ជូនទៅ អង្គមុនជំនុំជម្រះ នៅសំណើសុំធ្វើការស៊ើបអង្កេតដោយភ្ជាប់ជាមួយ និងឯក

[56]ក្រុមប្រឹក្សាសន្តិសុខ និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤ http://surl.li/qnlxt

[57]មាត្រា១៣ (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

[58] មាត្រា ១៥ (២) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

សារសំអាងគាំទ្រទាំងឡាយដែលប្រមូលបាន ពីជនរងគ្រោះ អាចដាក់ជាសេចក្តីថ្លែងការណ៍ជូន អង្គមុនជំនុំជម្រះដោយអនុលោមតាមវិធាននៃនីតិវិធី និងភស្តុតាង បើអង្គមុនជំនុំជម្រះយល់ស្របថា មានមូលដ្ឋានសមហេតុផលដែលជឿថាវាជាបទល្មើសព្រហ្មទណ្ឌ រដ្ឋអាជ្ញាបន្តចាប់ផ្តើមនៅដំណាក់កាលនៃស៊ើបអង្កេតបាន។[59] តែប្រសិនបើរដ្ឋអាជ្ញាកំណត់ថាមិនមានមូលដ្ឋានណាមួយសមហេតុផលដើម្បីបើកការស៊ើបអង្កេតនោះទេ ត្រូវជូនដំណឹងជាសម្ងាត់ទៅភាគីដែលបានផ្ញើនៃឯកសារនេះ ឬព័ត៌មាននោះវិញ។[60]

**២.១.៣.១.ករណីសិក្សា** (ក្រុមភេរវករ អាល់កៃដា)

បន្ទាប់ពីពួកភេរវករ អាល់កៃដាបានវាយប្រហារមជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោកនៅ ទីក្រុងញូវយ៉ក និងមន្ទីរបញ្ចកោណក្នុងទីក្រុងវ៉ាស៊ីនតោនឌីស៊ីនៅថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០០១ សហរដ្ឋអាមេរិកបានចាប់ផ្តើមយកខ្លួនចូលក្នុង សង្គ្រាមលើភេរវកម្ម។ សហរដ្ឋអាមេរិកបានទាមទារឱ្យរដ្ឋាភិបាលរបស់តាលីបង់នៃប្រទេស អាហ្វហ្កានីស្ថាន ប្រគល់មេដឹកនាំអាល់កៃដា Osama bin Laden និងបញ្ឈប់ប្រតិបត្តិការភេរវករអាល់កៃដានៅក្នុងប្រទេសអាហ្វហ្កានីស្ថាន  ប៉ុន្តែរដ្ឋាភិបាលតាលីបង់បានបដិសេធ។ នៅក្នុងខែតុលា ឆ្នាំ២០០១ កងកម្លាំងចម្រុះដែលដឹកនាំដោយសហរដ្ឋអាមេរិក បានលុកលុយលើប្រទេសអាហ្វហ្កានីស្ថាន ព្រមទាំងធ្វើការវាយប្រហារទៅលើរដ្ឋាភិបាលតាលីបង់ និងភេរវករអាល់កៃដា នៅក្នុងដំណើរនៃសង្គ្រាម ជនស៊ីវិលត្រូវបានសម្លាប់ដោយកងកម្លាំងចម្រុះដឹកនាំដោយសហរដ្ឋអាមេរិក កងកម្លាំងរដ្ឋាភិបាលអាហ្វហ្កានីស្ថាន  ក្រុមបះបោរតាលីបង់ និងក្រុមបះបោរប្រដាប់អាវុធផ្សេងទៀត។[61] បន្ទាប់ពីទទួលបានការទំនាក់ទំនងតាំងពីខែមិថុនា ឆ្នាំ២០០៦ រដ្ឋអាជ្ញា Fatou Bensouda ក្នុងឆ្នាំ២០០៧ បានប្រើប្រាស់សិទ្ធរបស់ខ្លួន ក្នុងការផ្តួចផ្តើមការអនុវត្តច្បាប់ ហើយបានស្នើសុំការអនុញ្ញាតពីអង្គមុនជំនុំជម្រះ ដើម្បីចាប់ផ្តើមបើកការស៊ើបអង្កេតលើបទល្មើស ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានចោទប្រកាន់ ដែលបានប្រព្រឹត្តនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធដែលកំពុងបន្តនៅសាធារណរដ្ឋអ៊ីស្លាមអាហ្វហ្កានីស្ថាន។ ការិយាល័យរដ្ឋអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានធ្វើការពិនិត្យបឋមរបស់ខ្លួនជាសាធារណៈដោយផ្អែកលើមូលដ្ឋានថា មានឧក្រិដ្ឋកម្មឃោរឃៅបានប្រព្រឹត្តនៅលើទឹកដីរបស់រដ្ឋភាគី។

---

[59] មាត្រា ១២ (១),(២) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

[60] មាត្រា ១៦ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

[61] របាយការណ៍ការពិនិត្យបឋម លើស្ថានភាពប្រទេសអាហ្វហ្កានីស្ថានទំព័រទី១៨,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/sites/default/files/iccdocs/otp/OTP-Pre-Exam-2014.pdf

## ផ្នែកទី៣៖ ការពិនិត្យបឋមលើស្ថានការណ៍

មុននឹងចាប់ផ្តើមការស៊ើបអង្កេតលើករណីជាក់លាក់ណាមួយដែលពាក់ព័ន្ធ និងឧក្រិដ្ឋកម្ម រដ្ឋអាជ្ញាត្រូវតែបើកការពិនិត្យបឋមទៅលើករណីនោះមុនសិន។ ការពិនិត្យបឋមលើស្ថានការណ៍ដែលត្រូវអនុវត្តច្បាប់ នៃបទល្មើសដែលត្រូវបានចោទប្រកាន់នឹងត្រូវបានបញ្ជូនទៅរដ្ឋអាជ្ញា នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ មិនថាដោយការផ្តួចផ្តើមពីរដ្ឋភាគី ក្រុមប្រឹក្សាសន្តិសុខភាគី ឬការប្រើប្រាស់អំណាច របស់រដ្ឋអាជ្ញាក៏ដោយ សំណុំរឿងនោះតែងតែចាប់ផ្តើមជាមួយនឹងជំហានដំបូងដែលហៅថា "ការពិនិត្យបឋម"។ ខណៈពេលដែលពាក្យ "ការពិនិត្យបឋម" ត្រូវបានប្រើនៅក្នុងមាត្រា ១៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ។[62]

### កថាខណ្ឌទី១៖ ធាតុផ្សំនៃការពិនិត្យបឋម

រដ្ឋអាជ្ញា នៃតុលាការព្រហ្មទណ្ឌអន្តរជាតិអាចចាប់ផ្តើមបើកការស៊ើបអង្កេតជាផ្លូវការ បើសកម្មភាពនោះបង្ហាញនូវការបំពេញ ធាតុផ្សំបួនចំណុច ក្នុងការពិនិត្យបឋមដែលមានដូចជា ៖

- ការវាយតម្លៃបឋមលើស្ថានភាពដែលទទួលបាន ឬបញ្ជូនមក
- អំណាចយុត្តាធិការរបស់តុលាការ
- ភាពអាចទទួលយកបាន
- ផលប្រយោជន៍យុត្តិធម៌ ( នេះសំដៅទៅលើការវាយតម្លៃនៃកត្តាផ្សេងៗ ដោយចៅក្រមក្នុងការចេញនៅការសម្រេចក្នុងការបើកការស៊ើបអង្កេត លើករណីណាមួយដែលផ្អែកលើផលប្រយោជន៍នៃយុត្តិធម៌ និងផលប្រយោជន៍ជនរងគ្រោះ )។[63]

នៅក្នុងដំណាក់កាលពិនិត្យបឋម ធាតុផ្សំដែលបានលើកមកទាំងបួននៅខាងលើនេះពិតជាមានសារៈសំខាន់ណាស់នៅក្នុងការចង្អុលបង្ហាញ និងនាំផ្លូវរដ្ឋអាជ្ញាឈានទៅរកការបើកស៊ើបអង្កេតទៅលើទឹកដីនៃរដ្ឋភាគីណាមួយដែលខ្លួនបានសង្ស័យ ថាបានប្រព្រឹត្តនូវបទឧក្រិដ្ឋដែលស្ថិតនៅក្នុងដែនយុត្តាធិការរបស់ខ្លួន។

[62] មាត្រា ១៥ (៦) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

[63] របាយការណ៍ស្តីពីការពិនិត្យបឋមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិឆ្នាំ ២០២០ ទំព័រទី ៤,ចូលមើលថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/sites/default/files/itemsDocuments/2020-PE/2020-pe-report-eng.pdf

### ១.ការវាយតម្លៃបឋម

ក្នុងការវាយតម្លៃបឋមនេះគឺ តុលាការនឹងធ្វើការយកករណីដែលបានកើតឡើង ផ្ទៀបនឹងគោលការណ៍ទូទៅដែលមានចែងនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ព្រមទាំងលក្ខខណ្ឌផ្សេងៗទៀត ដែលអាចចាត់ទុក ឬកំណត់ថាករណីដែលបានកើតឡើងនោះជាបទល្មើសបានដែលអាចមានសិទ្ធក្នុងការដោះស្រាយ។

#### ១.១.បទល្មើស និងគោលការណ៍ទូទៅ

នៅក្នុងការចាប់ផ្តើមសម្រាប់ការវាយតម្លៃនៅក្នុងការពិនិត្យបឋមនេះគេនឹងមើលទៅលើបទល្មើសដែលបានបញ្ជូនមកពីរដ្ឋភាគីក្តី ពីអង្គការក្រៅរដ្ឋាភិបាលក្តី ពីក្រុមប្រឹក្សាសន្តិសុខក្តី ថាតើបទល្មើសទាំងអស់នេះបានស្របទៅក្នុងគោលការណ៍ទូទៅរបស់ច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិដែរ ឬទេ ដែលគេនិងធ្វើការវាយតម្លៃលើបទល្មើសដែលបានកំណត់ដោយច្បាប់ ព្រមទាំងស្ថិតក្រោមដែនសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ភាពមិនប្រតិសកម្ម យុត្តាធិការដែនដី នីតិភាពរបស់បុគ្គលដែលត្រូវកាត់ទោស លើសពីនេះតុលាការ និងធ្វើការពិនិត្យលើការបំពេញបន្ថែម និងបន្ទុកនៃភស្តុតាងផងដែរ។[64] ការវាយតម្លៃដំបូងនៃព័ត៌មានដែលទទួលបានដោយការិយាល័យរដ្ឋអាជ្ញាតុលាការព្រហ្មទណ្ឌអន្តរជាតិ មិនថាពីរដ្ឋ បុគ្គល ឬអង្គកាផ្សេងៗ ព័ត៌មាននេះត្រូវបានវិភាគ និងដាក់ចូលទៅក្នុងប្រភេទមួយក្នុងចំណោមបួនប្រភេទ៖

- បញ្ហាដែលបង្ហាញឱ្យឃើញនៅខាងក្រៅយុត្តាធិការរបស់តុលាការ
- បញ្ហាដែលត្រូវពិនិត្យបឋមរួចហើយ
- បញ្ហាដែលស្ថិតក្រោមការស៊ើបអង្កេតផ្លូវការ ឬកាត់ទោសរួចហើយ
- យ៉ាងណាក៏ដោយបើសិនជាមានបញ្ហាដែលមិនមានលក្ខណៈដូចទៅនឹងប្រភេទណាមួយក្នុងចំណោមបីប្រភេទខាងលើនេះទេ ទាមទារឱ្យមានការវិភាគបន្ថែម។ ប្រភេទព័ត៌មានចុងក្រោយនេះអាចនាំឱ្យមានការចាប់ផ្តើមនៃការពិនិត្យបឋមថ្មី ហើយដូច្នេះក៏លេចនៅករណីថ្មីដែលត្រូវនាំមកតុលាការ។ ដំណាក់កាល ការវាយតម្លៃបឋម គឺជាទម្រង់ដ៏សំខាន់មួយដើម្បីលុបបំបាត់ករណីដែលមានសក្តានុពលដែលបង្ហាញឱ្យឃើញថាវាស្ថិត នៅខាងក្រៅដែនសមត្ថកិច្ចរបស់តុលាការ។[65]

---

[64] មាត្រា ១៥ (១) (២) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០២៤

https://www.icc-cpi.int/about/the-cour

[65] សៀវភៅ ការអនុវត្តច្បាប់របស់តុលាការអន្តរជាតិ បោះពុម្ពផ្សាយដោយ មេធាវី Beth Van Schaack និងសាស្ត្រាចារ្យ Ronald Slye ទំព័រទី ១៤៤ ជំពូកទី ៤,ចូលមើលថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០២៤
https://archive.org/details/internationalcri0000vans/page/144/mode/1up?view=theater

## ២.អំណាចយុត្តាធិការរបស់តុលាការ

តុលាការព្រហ្មទណ្ឌអន្តជាតិ ក្នុងដំណាក់កាលអំពីអំណាចយុត្តាធិការនេះ រដ្ឋអាជ្ញាត្រូវមើលទៅលើ បទល្មើសដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួនដើម្បីធ្វើការវាយតម្លៃដោយរដ្ឋអាជ្ញាក្នុងអំឡុងពេលពិនិត្យបឋមដែលមានដូចជា ៖

### ២.១.ភាពមិនប្រតិសកម្មនៃច្បាប់

តុលាការព្រហ្មទណ្ឌអន្តជាតិ មានយុត្តាធិការសម្រាប់តែអំពើ ឬករណីណាដែលត្រូវបានប្រព្រឹត្តបន្ទាប់ពីសន្ធិសញ្ញាទីក្រុងរ៉ូមចូលជាធរមាននៅថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០០២ ប្រសិនបើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់បានកើតឡើងមុនកាលបរិច្ឆេទនេះ តុលាការមិនអាចមានយុត្តាធិការលើសំណុំរឿងនោះ បានឡើយ។ [66] ទោះយ៉ាងណាក៏ដោយ មានករណីលើកលែងមួយនៅពេល ដែលក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិដែលធ្វើសកម្មភាពក្រោមជំពូកទី ៧ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ដែលបានសំដៅលើ ការបញ្ជូនស្ថានភាពទៅកាន់ការិយាល័យរដ្ឋអាជ្ញា របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ ក្នុងករណីបែបនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិអាចធ្វើការស៊ើបអង្កេត ហើយប្រសិនបើមានការធានា និងកាត់ទោសបុគ្គលចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តមុនពេលលក្ខន្តិកៈចូលជាធរមាន។[67]

### ២.២.ប្រធានបទនៃបទល្មើស

បទល្មើសដែលត្រូវបានចោទប្រកាន់ត្រូវតែជាឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬអំពើប្រល័យពូជសាសន៍ ដូចដែលបានកំណត់នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម។ ប្រសិនបើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ណាមួយ មិនស្ថិតនៅក្នុងនិយមន័យមួយក្នុងចំណោមនិយមន័យទាំងនេះទេ ករណីនេះតុលាការព្រហ្មទណ្ឌអន្តជាតិនិងមិនអាចបើកការស៊ើបអង្កេត ឬអនុវត្តអំណាចយុត្តាធិការរបស់ខ្លួនបានទេដូចដែលមានចែងក្នុងមាត្រា ៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម។ រដ្ឋអាជ្ញាត្រូវតែបង្កើតមូលដ្ឋានត្រឹមត្រូវ សមហេតុផលសម្រាប់ការជឿថាឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មទាំងបួននៅក្នុងយុត្តាធិការរបស់តុលាការត្រូវបានប្រព្រឹត្ត ហើយដើម្បីកំណត់បទល្មើសបាន រដ្ឋអាជ្ញាត្រូវតែពិចារណាជាបឋម លើអត្ថិភាពនៃធាតុផ្សំដែលបានកំណត់ក្នុង ច្បាប់នៃលក្ខន្តិកៈទីក្រុងរ៉ូម ដែលបានចង្អុល បង្ហាញយ៉ាងច្បាស់ពីបទល្មើសទាំងនោះក្នុង មាត្រា ៦, ៧, ៨ ដែលរំលេច

---

[66]មាត្រា ១១ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០២៤
https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[67] សៀវភៅចំណងជើង"មកដឹងអំពីតុលាការព្រហ្មទណ្ឌអន្តរជាតិ"បោះពុម្ពផ្សាយដោយស្ថាប័នតុលាការព្រហ្មអន្តរជាតិទំព័រទី២៦,ចូលមើលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤
https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

ចេញ អំពីជម្លោះប្រដាប់អាវុធ ថាតើមានការវាយប្រហារលើប្រជាជនស៊ីវិល ហើយសកម្មភាពនោះមានការរីករាលដាល ឬលក្ខណៈជាប្រព័ន្ធ ទំនាក់ទំនងរវាងអំពើឧក្រិដ្ឋកម្មជាក់លាក់ដែលបានចោទប្រកាន់ តួនាទីជាក់ស្តែង ឬដោយច្បាប់នៃជនល្មើសដែលត្រូវបានចោទប្រកាន់ និងធាតុចិត្តសាស្ត្រដែលបង្ហាញឱ្យឃើញនៅគោលបំណងរបស់ជនល្មើស ដូចជា៖ ចេតនាជាក់លាក់ ឬទូទៅ របស់ជនសង្ស័យក្នុងការបង្កើតឱ្យមានការបំផ្លាញទាំងស្រុង ឬដោយផ្នែក អំពីការវាយប្រហាររីករាលដាល ឬជាប្រព័ន្ធប្រឆាំងនិងប្រជាជនស៊ីវិល។ ទាំងអស់នេះជាកិច្ចការសម្រាប់រដ្ឋអាជ្ញាមុន សម្រេចបើកការស៊ើបអង្កេត ហើយការស៊ើបអង្កេត និងមិនអាចទៅរួចទេបើគ្មានការពិចារណាលើលក្ខខណ្ឌទាំងអស់នេះ។[68] ឧទាហរណ៍៖ តុលាការព្រហ្មទណ្ឌអន្តរជាតិ បានធ្វើការពិនិត្យបឋមលើស្ថានភាពមួយនៅក្នុង ប្រទេស វេណេហ្ស៊ុយអេឡាក្នុងឆ្នាំ ២០០៦ ដើម្បីវិភាគឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលកើតមាននៅក្នុងប្រទេសនោះ។ ទោះជាយ៉ាងណា ការពិនិត្យបឋមនេះត្រូវបានបិទនៅក្រោយឆ្នាំនោះ ព្រោះវាត្រូវបានគេសន្និដ្ឋានធាតុផ្សំនៃករណីនោះពុំទាន់មានលក្ខណៈគ្រប់គ្រាន់ដែលអាចកំណត់ថាវាជាបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ ដូចនេះហើយ តម្រូវការដើម្បីចាប់ផ្តើមបើក ការស៊ើបអង្កេតពេញលេញ មិនត្រូវបានបំពេញនៅពេលនោះ ហើយអំពើដែលបានចោទប្រកាន់មិនបានឈានដល់កម្រិត ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលស្ថិតក្រោមយុត្តាធិការរបស់តុលាការនោះទេ។[69]

### ២.៣.ការវាយតម្លៃលើសញ្ជាតិ និងទឹកដី

តុលាការព្រហ្មទណ្ឌអន្តរជាតិ អាចបើកស៊ើបអង្កេត និងកាត់ទោសបានតែ "រូបវន្តបុគ្គល" ដែលមានអាយុចាប់ពី ១៨ ឆ្នាំ។[70] តុលាការព្រហ្មទណ្ឌអន្តរជាតិ មិនអាចស៊ើបអង្កេត ឬកាត់ទោសទៅលើរដ្ឋាភិបាល សាជីវកម្ម គណបក្សនយោបាយ ឬចលនាឧទ្ទាមបានទេ ប៉ុន្តែអាចស៊ើបអង្កេតបុគ្គលដែលជាសមាជិកនៃក្រុម។ តុលាការព្រហ្មទណ្ឌអន្តរជាតិអាចអនុវត្តយុត្តាធិការលើជនជាតិពីរ រដ្ឋនៅក្នុងយុត្តាធិការរបស់តុលាការតែប៉ុណ្ណោះ ឧទាហរណ៍៖ រដ្ឋភាគី ភាគីមិនមែនរដ្ឋដែលយល់ព្រមលើយុត្តាធិការ ឬត្រូវបានបញ្ជូនដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិក្រោយជំពូកទី ៧ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។[71]ដូចដែលបានបញ្ជាក់

---

[68] សៀវភៅ ការអនុវត្តច្បាប់របស់តុលាការអន្តរជាតិ បោះពុម្ពផ្សាយដោយ មេធាវី Beth Van Schaack និងសាស្ត្រាចារ្យ Ronald Slye ទំព័រទី ១៤៤ ជំពូកទី ៤,ចូលមើលថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០២៤
https://archive.org/details/internationalcri0000vans/page/144/mode/1up?view=theater

[69] របាយការណ៍ពាក់ព័ន្ធ និងស្ថានភាពប្រទេសវេណេហ្ស៊ុយអេឡា ២០០៦ ,ចូលមើលថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០២៤
https://t.ly/u8pZn

[70] មាត្រា ២៥ (១) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០២៤
https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[71] មាត្រា១២ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០២៤

ខាងលើ រដ្ឋដែលមិនមែនជាភាគីក៏អាចដាក់សេចក្តីប្រកាស ចំពោះកិច្ច ( Ad Hoc )ជាមួយតុលាការដែលបង្ហាញថាខ្លួន និងទទួលយកយុត្តាធិការរបស់តុលាការ។ ឧទាហរណ៍៖ នៅក្នុងខែមេសា ឆ្នាំ ២០១៤ រដ្ឋាភិបាលអ៊ុយក្រែនបានប្តឹងទៅតុលាការនូវសេចក្តីប្រកាសមួយក្រោមមាត្រា ១២ កថាខណ្ឌ ៣ ដោយទទួលយកយុត្តាធិការលើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបាន ប្រព្រឹត្តនៅលើទឹកដីរបស់ខ្លួនចាប់ពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០១៣ ដល់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២០១៤ (រយៈពេលនេះមិនរាប់បញ្ចូលព្រឹត្តិការណ៍ទាក់ទង និងការកាន់កាប់របស់រុស្ស៊ីនៅគ្រីមៀ)។[72]រដ្ឋអាជ្ញាត្រូវតែអះអាងថាមាន មូលដ្ឋានសមហេតុផលដើម្បីជឿថាលក្ខខណ្ឌទាំងបីខាងលើនេះត្រូវបានបំពេញ និងអាចបន្តទៅដំណាក់កាលស៊ើបអង្កេតនៃបទល្មើសណាមួយដែលបានកើតឡើង។

### ៣.អំពីភាពដែលអាចទទួលយកបាន

រដ្ឋអាជ្ញា នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវតែមើលថាតើមានតុលាការណាមួយផ្សេងទៀត (ក្នុងស្រុក ឬអន្តរជាតិ) កំពុងស៊ើបអង្កេត និងកាត់ទោសឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នោះបានយ៉ាងត្រឹមត្រូវដែរឬទេ ករណីនេះត្រូវបានគេហៅថា "ការបំពេញបន្ថែម" និងថាតើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នោះគឺជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលស្ថិតក្នុងកម្រិតដែលបាន កំណត់ដោយតុលាការយោងទៅតាមច្បាប់ គំនិតនេះត្រូវបានគេចាត់ទុកថាជា "បន្ទុកនៃភស្តុតាង"។

#### ៣.១.ការបំពេញបន្ថែម

ដើម្បីបំពេញបន្ថែម រដ្ឋអាជ្ញាត្រូវតែវាយតម្លៃថាតើការស៊ើបអង្កេតពិតប្រាកដ ឬការកាត់ទោសត្រូវបានធ្វើឡើងដោយរដ្ឋដែលមានយុត្តាធិការលើបញ្ហានេះ។ ក្នុងដំណាក់កាលបំពេញបន្ថែម រដ្ឋអាជ្ញា និងធ្វើពិចារណាថាតើមានដំណើរការនីតិវិធីក្នុងស្រុកគ្រប់គ្រាន់ដែលពាក់ព័ន្ធ និងជនសង្ស័យដែលមានសក្តានុពលដែរឬទេ ហើយបើមានមែននោះ រដ្ឋអាជ្ញានឹងមិនបន្តការស៊ើបអង្កេតទេ ប៉ុន្តែបន្តតាមដានស្ថានការណ៍។[73] ឧទាហរណ៍៖ ទាក់ទង និងស្ថានភាពនៅក្នុងប្រទេសកូឡុំប៊ី ដែលជាកម្មវត្ថុនៃការពិនិត្យបឋមចាប់ផ្តើមតាំងពីឆ្នាំ ២០០៤ រដ្ឋអាជ្ញាបានកំណត់ថាមានមូលដ្ឋានសមហេតុផលក្នុងការជឿថាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានប្រព្រឹត្តដោយក្រុមប៉ារ៉ាយោធា និងកងកម្លាំងរដ្ឋ។ ទោះបីជាយ៉ាងណា រហូតមកដល់ពេលនេះការិយាល័យរដ្ឋអាជ្ញា បានបដិសេធមិនបន្តការស៊ើបអង្កេតទេ ដោយសារតែខ្លួនបានកំណត់ថាមានដំណើរការ

---

https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[72] សេចក្តីប្រកាសរដ្ឋាភិបាលអ៊ុយក្រែនស្តីពីការទទួលយកយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ,ចូលមើលថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០២៤
https://www.icc-cpi.int/sites/default/files/itemsDocuments/997/declarationRecognitionJuristiction09-04-2014.pdf

[73]មាត្រា ៥៣ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០២៤

ថ្នាក់ជាតិពិតប្រាកដមួយចំនួនពាក់ព័ន្ធ និងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ទាំងអស់នោះ ដែលធ្វើចលនាប្រឆាំង និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយអះអាងពីភាពត្រឹមត្រូវនៃយុត្តាធិការថ្នាក់ជាតិរបស់ខ្លួន។[74]

### ៣.១.១.កត្តាក្នុងការបំពេញបន្ថែម

នៅក្នុងឯកសារគោលនយោបាយស្តីពី ការពិនិត្យបឋម រដ្ឋអាជ្ញាបានកំណត់កត្តាជាច្រើនសម្រាប់ការវាយតម្លៃទាក់ទង និងការបំពេញបន្ថែម។ ដោយកំណត់ថាតើដំណើរការថ្នាក់ជាតិត្រូវបានធ្វើឡើងដោយមានចេតនាការពារបុគ្គលនោះ និងពិចារណាថាតើអាជ្ញាធរក្នុងស្រុកមាន៖

- អនុវត្តជំហានមិនគ្រប់គ្រាន់ក្នុងការស៊ើបអង្កេត ឬការកាត់ទោស
- ខុសពីការអនុវត្តស្តង់ដា ឬនីតិវិធី
- មិនអើពើ និងភស្តុតាង ឬផ្តល់ឱ្យនូវបន្ទុកនៃស្ថានទម្ងន់ទោសមិនគ្រប់គ្រាន់
- ការបំភិតបំភ័យជនរងគ្រោះ សាក្សី ឬបុគ្គលិកតុលាការ
- បង្កើតការរកឃើញដែលមិនអាចកំណត់សម្គាល់បានជាមួយ និងជាមួយភស្តុតាងបានដែលបានផ្តល់ជូនតុលាការ
- បានបង្ហាញឱ្យឃើញពីភាពមិនគ្រប់គ្រាន់ក្នុងការដាក់ទោស និងរបៀបនៃការទទួលខុសត្រូវទាក់ទង ពីស្ថានភាពនៃការប្រព្រឹត្តដែលបានចោទប្រកាន់ និងអះអាងរបស់ជនជាប់ចោទ
- ការបង្កើតការរកឃើញរបស់តុលាការដែលមានកំហុសក្នុងការកំណត់អត្តសញ្ញាណខុស ឬការដែលពិនិត្យកោសល្យវិច្ច័យដែលមានបញ្ហា បរាជ័យនៃការបញ្ចេញភស្តុតាង ប្រឌិតភស្តុតាង សេចក្តីថ្លែងការណ៍ដែលបានរៀបចំ ការបង្ខិតបង្ខំ ការទទួលយកមិនត្រឹមត្រូវ ឬការមិនទទួលយកភស្តុតាង
- ធនធានមិនគ្រប់គ្រាន់សម្រាប់ដំណើរការនៅក្នុងដៃបើធៀប និងសមត្ថភាពរួម ឬបដិសេធមិនផ្តល់ព័ត៌មានក្នុងសហការជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

មានការពន្យារពេលមិនសមហេតុផលពាក់ព័ន្ធ និងការពិចារណាអំពី៖

- ល្បឿននៃជំហានស៊ើបអង្កេត និងដំណើរការនីតិវិធីថាតើការយឺតយ៉ាវក្នុងដំណើរការនីតិវិធីអាចត្រូវបានរាប់ជាសុចរិតក្នុងកាលៈទេសៈដែរឬទេ។ និងថាតើមានភស្តុតាងផ្សេងទៀតដែលបង្ហាញពីការខ្វះចេតនាក្នុងការនាំបុគ្គលដែលពាក់ព័ន្ធមកកាត់ទោសដែរឬទេ។

[74]សហព័ន្ធអន្តរជាតិសម្រាប់សិទ្ធិមនុស្ស,ចូលមើលថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០២៤ https://t.ly/s00El

ឯករាជ្យភាពនៃដំណើរការជាតិត្រូវបានវាយតម្លៃតាម៖

- ការជាប់ពាក់ព័ន្ធនៃបរិបទរដ្ឋ រួមទាំងនាយកដ្ឋានដែលទទួលខុសត្រូវចំពោះច្បាប់ និងសណ្តាប់ធ្នាប់ ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់។
- តួនាទី និងអំណាចដែលរដ្ឋធម្មនុញ្ញបានប្រគល់ឱ្យនៅក្នុងស្ថាប័នផ្សេងៗនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។
- វិសាលភាពដែលការតែងតាំង និងការបណ្តេញចេញអ្នកស៊ើបអង្កេត រដ្ឋអាជ្ញា ឬចៅក្រមដែលប៉ះពាល់ដល់ដំណើរការត្រឹមត្រូវក្នុងសំណុំរឿង។
- ការអនុវត្តរបបនៃអភ័យឯកសិទ្ធិ និងសិទ្ធិយុត្តាធិការសម្រាប់ជនល្មើសដែលត្រូវបានចោទប្រកាន់ជាកម្មសិទ្ធិរបស់រដ្ឋាភិបាល។
- ការជ្រៀតជ្រែកពីផ្នែកនយោបាយក្នុងការស៊ើបអង្កេតកាត់ទោស ឬដំណើរនៃការកាត់ក្តីទាមទាររបស់ភាគីចំពោះស្ថាប័នក្រៅប្រព័ន្ធតុលាការ និងអំពើពុករលួយរបស់រដ្ឋអាជ្ញា ឬចៅក្រម។

ដំណើរការថ្នាក់ជាតិ និងត្រូវបានពិចារណាដោយផ្អែក ឬមិនលម្អៀងដោយផ្អែកលើ៖

- ទំនាក់ទំនងរវាងជនល្មើសដែលសង្ស័យ និងអាជ្ញាធរមានសមត្ថកិច្ចដែលទទួលខុសត្រូវក្នុងការស៊ើបអង្កេតការកាត់ទោស ឬការវិនិច្ឆ័យនៃឧក្រិដ្ឋកម្ម
- សេចក្តីថ្លែងការណ៍ជាសាធារណៈ រង្វាន់ ការដាក់ទណ្ឌកម្ម ការផ្សព្វផ្សាយ ការដកចយ ឬដាក់ពង្រាយ បណ្តេញចេញ ឬការសងសឹកនៅក្នុងទំនាក់ទំនងដល់បុគ្គលិកស៊ើបអង្កេត រដ្ឋអាជ្ញា ឬតុលាការដែលពាក់ព័ន្ធ។ វិសាលភាពនៃសិទ្ធិរបស់ជនជាប់ចោទគឺស្របជាមួយនឹងអ្វីដែលមានចែងក្នុងមាត្រា ៦៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម និងគោលការណ៍នៃដំណើរការត្រឹមត្រូវដែលត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិថាមានចែងនៅក្នុងលិខិតបទដ្ឋាន អន្តរជាតិពាក់ព័ន្ធ ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

អសមត្ថភាពរបស់រដ្ឋក្នុងការធ្វើការស៊ើបអង្កេតពិតប្រាកដ ឬការកាត់ទោសអាស្រ័យទៅលើ៖

- មិនថាដោយសារតែការដួលរលំទាំងស្រុង ឬច្រើនឬមិនមានប្រព័ន្ធតុលាការជាតិរបស់ខ្លួន រដ្ឋគឺមិនអាចធ្វើការប្រមូលភស្តុតាង និងសក្ខីកម្មចាំបាច់មិនអាចទទួលបានជនជាប់ចោទ ឬមិនអាចអនុវត្តនីតិវិធីរបស់ខ្លួន។

ជាចុងក្រោយ រដ្ឋអាជ្ញាក៏អាចពិនិត្យមើលកត្តាខាងក្រោមក្នុងការវាយតម្លៃផងដែរក្នុងការបំពេញបន្ថែម៖

- សមត្ថភាពរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងការអនុវត្តអំណាចតុលាការរបស់ខ្លួននៅក្នុងដែនដីពាក់ព័ន្ធ

- អវត្តមាននៃលក្ខខណ្ឌសុវត្ថិភាពសម្រាប់សាក្សីអ្នកស៊ើបអង្កេត រដ្ឋអាជ្ញា និងចៅក្រម ឬកង្វះប្រព័ន្ធការពារគ្រប់គ្រាន់
- អវត្តមាននៃក្របខណ្ឌនីតិប្បញ្ញត្តិដែលត្រូវការដើម្បីកាត់ទោសការប្រព្រឹត្តដូចគ្នា ឬទម្រង់នៃការទទួលខុសត្រូវ កង្វះធនធានគ្រប់គ្រាន់សម្រាប់ការស៊ើបអង្កេត និងការកាត់ទោសប្រកបដោយប្រសិទ្ធភាព និងការរំលោភលើសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ។

ការស៊ើបអង្កេតក្នុងស្រុក ឬការកាត់ទោសតាមធម្មតានឹងធ្វើឡើងដោយរដ្ឋនៅលើទឹកដីដែលឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ឬដោយរដ្ឋនៃសញ្ជាតិរបស់ជនជាប់ចោទ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើរដ្ឋណាមួយដែលមានយុត្តាធិការលើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់កំពុងស៊ើបអង្កេត ឬកាត់ទោសយ៉ាងពិតប្រាកដនោះ តម្រូវការនៃការបំពេញបន្ថែមមិនត្រូវបានបំពេញ។[75]

## ៣.២.បន្ទុកនៃភស្តុតាង

សមាសធាតុទីពីរនៃភាពដែលអាចទទួលយកបានគឺ បន្ទុកនៃភស្តុតាង បន្ទុកស្ថានភាព រួមទាំងបន្ទុកដែលសក្តានុពលនៃបទល្មើស គឺជាករណីមួយដែលរដ្ឋអាជ្ញា កំណត់ថាសំណុំរឿងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ត្រូវតែជាឧក្រិដ្ឋកម្មដ៏ឃោរឃៅ ដែលរដ្ឋអាជ្ញា របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ កំណត់លើការខូតខាតដែលបានកើតឡើងក្នុងករណីនោះ ដោយមើលលើមាត្រដ្ឋាន លក្ខណៈ និងផលប៉ះពាល់នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់។[76] ដើម្បីនាំខ្លួនជនសង្ស័យទៅតុលាការ គោលគំនិតបន្ទុកនៃភស្តុតាងដែលរដ្ឋអាជ្ញាត្រូវពិនិត្យមើលនោះរួមមាន៖ បរិមាណ និងគុណភាព រួមទាំងមាត្រដ្ឋាន ឥរិយាបទ របៀបនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម និងផលប៉ះពាល់ដែលកើតឡើងដោយសកម្មភាពនោះ ហើយដើម្បីវាយតម្លៃទំហំនៃឧក្រិដ្ឋកម្មណាមួយ រដ្ឋអាជ្ញានិងពិនិត្យមើលលើ៖ ចំនួនជនរងគ្រោះដោយផ្ទាល់ និងដោយប្រយោល ទំហំនៃការខូចខាតដែលបណ្ដាលមកពីឧក្រិដ្ឋកម្ម ជាពិសេសការខូចខាតរាងកាយ ឬផ្លូវចិត្តដែលបង្កឡើងចំពោះជនរងគ្រោះ ក្រុមគ្រួសាររបស់ពួកគេ ឬការរីករាលដាលក្នុងភូមិសាស្ត្រ។ លក្ខណៈនៃឧក្រិដ្ឋកម្មសំដៅទៅលើធាតុជាក់លាក់នៃបទល្មើសនីមួយៗ (ឧទាហរណ៍៖ ការសម្លាប់ ការធ្វើទារុណកម្ម ការរំលោភ) ទាក់ទងនឹងរបៀបប្រព្រឹត្តបទឧក្រិដ្ឋរដ្ឋអាជ្ញាពិនិត្យមានន័យថា ប្រើដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្ម កម្រិតនៃការចូលរួម និងចេតនារបស់ជនល្មើស (ប្រសិនបើអាចយល់បាននៅ

---

[75]សៀវភៅ ការអនុវត្តច្បាប់របស់តុលាការអន្តរជាតិ បោះពុម្ពផ្សាយដោយ មេធាវី Beth Van Schaack និងសាស្ត្រាចារ្យ Ronald Slye ទំព័រទី ១៤៦,១៤៧ ជំពូកទី ៤,ចូលមើលថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២៤ https://archive.org/details/internationalcri0000vans/page/144/mode/1up?view=theater

[76] ឯកសារគោលនយោបាយស្តីពីការពិនិត្យបឋម របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ជំពូកទី ៤ ទំព័រទី ១៥,ចូលមើលថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២៤ OTP - Policy Paper Preliminary Examinations 2013.pdf (icc-cpi.int)

ដំណាក់កាលនេះ) វិសាលភាពដែលឧក្រិដ្ឋកម្មមានលក្ខណៈជាប្រព័ន្ធ ឬជាលទ្ធផលពីផែនការ ឬគោលនយោបាយរៀបចំ ឬបើមិនដូច្នេះទេ បណ្ដាលមកពីការរំលោភបំពានអំណាច ឬមន្ត្រី។ សមត្ថភាព និងធាតុផ្សំនៃអំពើឃោរឃៅ រួមទាំងភាពងាយរងគ្រោះរបស់ជនរងគ្រោះ ហេតុផលណាមួយដែលពាក់ព័ន្ធ និងការរើសអើង ការប្រើប្រាស់ការរំលោភ និងអំពើហិង្សាផ្លូវភេទជាមធ្យោបាយបំផ្លាញជាក្រុម។[77]

ជាចុងក្រោយ ដើម្បីវាយតម្លៃពីផលប៉ះពាល់នៃឧក្រិដ្ឋកម្ម រដ្ឋអាជ្ញានឹងត្រូវពិនិត្យមើលការរងទុក្ខលំបាករបស់ជនរងគ្រោះ និងភាពងាយរងគ្រោះកើនឡើងរបស់ពួកគេ ពីអំពើឧក្រិដ្ឋដែលបានបង្កឡើងជាបន្តបន្ទាប់ និងការខូចខាតសង្គមសេដ្ឋកិច្ច និងបរិស្ថានបានធ្វើឱ្យប៉ះពាល់ដល់សហគមន៍ផងដែរ។

### ៣.២.១.**ករណីសិក្សា** (ប្រទេសអ៊ីរ៉ាក់)

គោលគំនិតក្នុងការស៊ើបអង្កេត ទៅលើស្ថានភាពនៅក្នុងប្រទេសអ៊ីរ៉ាក់ត្រូវបានបិទដោយផ្អែកលើមូលដ្ឋាននៃការពិនិត្យបឋមដែលរកឃើញថា ខណៈពេលដែលឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់តុលាការអាចត្រូវបានប្រព្រឹត្តដោយបុគ្គលនៃរដ្ឋភាគី ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់មិនបានបំពេញនូវ ឬបង្ហាញឱ្យឃើញនូវបន្ទុកនៃភស្តុតាងនោះទេ។ អ៊ីរ៉ាក់មិនមែនជារដ្ឋភាគីចំពោះនៃលក្ខន្តិកៈទីក្រុងរ៉ូម ស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិទេ ហើយមិនបានដាក់សេចក្ដីប្រកាសអាជហុកមាត្រា ១២ (៣) ដែលទទួលយកយុត្តាធិការរបស់តុលាការនោះទេ។ [78] ទោះបែបនេះក្ដី ចក្រភពអង់គ្លេស ដែលជារដ្ឋភាគី មានកងទ័ពឈរជើងនៅអ៊ីរ៉ាក់ ដែលជាផ្នែកនៃប្រតិបត្តិការសេរីភាពអ៊ីរ៉ាក់។ រដ្ឋអាជ្ញា បានបើកការផ្ដួចផ្ដើមការស៊ើបអង្កេតតាមសិទ្ធអំណាចរបស់ខ្លួនតាមមាត្រា ១៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបានចោទប្រកាន់ទៅលើកងទ័ពអង់គ្លេសបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលអង់គ្លេសបានស្ថិតនៅក្រោមក្នុងយុត្តាធិការរបស់តុលាការ ជាគ្រឿងបន្ថែមសម្រាប់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តលើទឹកដីរបស់ជនជាតិនៃរដ្ឋមិនមែនភាគី។ អតីតរដ្ឋអាជ្ញា Moreno Ocampo បានកំណត់ក្នុងខែកុម្ភៈ ឆ្នាំ ២០០៦ ថាព័ត៌មានដែលមានមិនបានបង្ហាញពីការវាយប្រហារដោយចេតនាលើជនស៊ីវិល ឬថាកម្លាំងលើសលប់ទាក់ទង និងផលប្រយោជន៍យោធាដែលបានត្រូវបានប្រើប្រាស់នោះទេ។ ទាក់ទងនឹងការរំលោភបំពានលើការឃុំខ្លួន ផ្ទុយទៅវិញរដ្ឋអាជ្ញាបានសន្និដ្ឋានថា មានមូលដ្ឋានសមហេតុផលដែលជឿថាឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់តុលាការត្រូវបានប្រព្រឹត្ត ពោលគឺការសម្លាប់ដោយចេតនា និងអំពើអមនុស្សធម៌លើបុគ្គល ៤ ទៅ ១២ នាក់ប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ លោកបានកំណត់ថា កម្រិតបន្ទុកភស្តុតាងមិនត្រូវ

[77] ឯកសារគោលនយោបាយស្ដីពីការពិនិត្យបឋម របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ជំពូកទី ៤ ទំព័រទី ១៥,ចូលមើលថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២៤ OTP - Policy Paper Preliminary Examinations 2013.pdf (icc-cpi.int)

[78] មាត្រា ៥៣ (១) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

បានបំពេញនោះទេ ជាពិសេសបើប្រៀបធៀបទៅ និងស្ថានភាពផ្សេងទៀត ដែលកើតមានក្នុងយុត្តាធិការរបស់តុលាការ។[79]

## ៤.ផលប្រយោជន៍នៃយុត្តិធម៌

គោលគំនិតនៃ "ផលប្រយោជន៍នៃយុត្តិធម៌" គឺជាធាតុផ្សំដ៏សំខាន់នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ជាពិសេសក្នុងដំណាក់កាលពិនិត្យបឋមដើម្បីចាប់ផ្តើមបន្តក្នុងបើកការស៊ើបអង្កេតដែលជាដំណាក់កាលបន្ទាប់។ [80]សូម្បីតែនៅពេលដែលលក្ខខណ្ឌយុត្តាធិការ និងសិទ្ធិអនុញ្ញាតត្រូវបានបំពេញក៏ដោយ រដ្ឋអាជ្ញាតុលាការព្រហ្មទណ្ឌអន្តរជាតិ មានឆន្ទានុសិទ្ធិក្នុងការកំណត់ថាតើការបញ្ជូន ឬមិនបញ្ជូនសំណុំរឿងនោះដោយពិចារណាលើថាវាមានបម្រើ "ផលប្រយោជន៍នៃយុត្តិធម៌" ដែរឬទេ។ រដ្ឋអាជ្ញាអាចសម្រេចមិនបន្តការស៊ើបអង្កេត ឬការកាត់ទោស ប្រសិនបើសម្រេចថាមានហេតុផលសំខាន់ៗ ក្នុងការជឿថានេះមិនមែនជាផលប្រយោជន៍នៃយុត្តិធម៌។[81]ខណៈពេលដែលរដ្ឋអាជ្ញាត្រូវតែបង្ហាញថាមានហេតុផលសមហេតុផលសម្រាប់ការជឿថាតម្រូវការនៃការបំពេញបន្ថែម និងបន្ទុកនៃភស្តុតាងត្រូវបានបំពេញ ក៏មានចំណុចមួយទៀតដែលរដ្ឋអាជ្ញាត្រូវពិចារណានោះគឺ "ផលប្រយោជន៍នៃយុត្តិធម៌"។ រហូតមកដល់ពេលនេះ នៅមិនទាន់មានស្ថានភាពណាមួយដែលត្រូវ ពិនិត្យបឋម ដែលត្រូវបានវិភាគយ៉ាងពេញលេញទាក់ទង និងធាតុនោះទេ។ រដ្ឋអាជ្ញា និងមិនបន្តទៅមុខជាមួយនឹងការស៊ើបអង្កេតទេប្រសិនបើមានការសន្និដ្ឋានថាគ្មានមានហេតុផលសំខាន់ៗ សម្រាប់ការជឿថាបម្រើឱ្យ ផលប្រយោជន៍នៃយុត្តិធម៌ ហើយក្នុងការធ្វើការវាយតម្លៃនេះ រដ្ឋអាជ្ញាបានគិតគូរពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ក៏ដូចជាទស្សនៈរបស់ជនរងគ្រោះ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដូចជា មេដឹកនាំនយោបាយសាសនា និងសហគមន៍ រដ្ឋ និងអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។[82]

ផលប្រយោជន៍នៃយុត្តិធម៌ នេះសង្កត់ធ្ងន់លើចំណុចបីមានដូចខាងក្រោម៖

---

[79] របាយការណ៍ស្តីពីស្ថានភាពប្រទេសអ៊ីរ៉ាក់ ២០២០ ជំពូកទី ៧ ទំព័រទី ៤៦, ,ចូលមើលថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០២៤ https://www.icc-cpi.int/sites/default/files/itemsDocuments/201209-otp-final-report-iraq-uk-eng.pdf

[80] ឯកសារគោលនយោបាយស្តីពីការពិនិត្យបឋម របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ជំពូកទី ៤ ទំព័រទី ១៦,ចូលមើលថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២៤ https://www.icccpi.int/sites/default/files/itemsDocuments/OTP%20Preliminary%20Examinations/OTP%20-%20Policy%20Paper%20Preliminary%20Examinations%20%202013.pdf

[81] មាត្រា ៥៣ (១) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[82] សៀវភៅ ការអនុវត្តច្បាប់របស់តុលាការអន្តរជាតិ បោះពុម្ពផ្សាយដោយ មេធាវី Beth Van Schaack និងសាស្ត្រាចារ្យ Ronald Slye ទំព័រទី ១៥៥ ជំពូកទី ៤,ចូលមើលថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២៤ https://archive.org/details/internationalcri0000vans/page/156/mode/1up?view=theater

- ចំណុចទីមួយៈ គឺឆន្ទានុសិទ្ធិរបស់រដ្ឋអាជ្ញា គួរស៊ើបអង្កេត ឬអត់ ក្រោមមាត្រា ៥៣ (១)(គ) ដោយពិចារណាចំពោះភាពធ្ងន់ធ្ងរនៃបទល្មើស និងផលប្រយោជន៍របស់ជនរងគ្រោះ តើមានហេតុផលមួយសមរម្យ ដែលទោះជាយ៉ាងណា ធ្វើឱ្យជឿថាការស៊ើបអង្កេត និងមិនបម្រើប្រយោជន៍យុត្តិធម៌ទេ និងមិនបើកការស៊ើបអង្កេតក្រោមមាត្រា ៥៣(២)(គ) ការនាំយកមកជំនុំជម្រះមិនបម្រើផលប្រយោជន៍យុត្តិធម៌ ដោយបានពិចារណាលើគ្រប់កាលៈទេសៈទាំងអស់ រួមទាំងភាពធ្ងន់ធ្ងរនៃបទល្មើស ព្រហ្មទណ្ឌ ប្រយោជន៍របស់ជនរងគ្រោះ ព្រមទាំងអាយុ ឬពិការភាពរបស់ជនជាប់ចោទ និងតួនាទីរបស់គេ ក្នុងអំពើល្មើសព្រហ្មទណ្ឌដែលត្រូវបានចោទប្រកាន់ឡើង។ លក្ខណៈពិសេសនៅក្នុងមាត្រាខាងលើនេះ អាច ជួយចង្អុលផ្លូវឈានដល់ការស៊ើបអង្កេត ឬអត់ ក្នុងឆន្ទានុសិទ្ធិរបស់ រដ្ឋអាជ្ញា បើសិនលក្ខណៈវិនិច្ឆ័យដែលបានបង្កើតឡើងក្នុងមាត្រា ៥៣(១) (ក) និង(ខ) ឬមាត្រា ៥៣(២)(ក) និង(ខ) ត្រូវបានបំពេញ។
- ចំណុចទីពីរ ៖ លក្ខណៈវិនិច្ឆ័យសម្រាប់ការអនុវត្តច្បាប់របស់ខ្លួន និងត្រូវបានដឹកនាំដោយគោលបំណងនៃលក្ខន្តិកៈនេះ ពោលគឺការទប់ស្កាត់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលទាក់ទងនឹងសហគមន៍អន្តរជាតិតាមរយៈការបញ្ចប់និទណ្ឌភាព។
- ចំណុចទី៣៖ ការកំណត់ពីភាពខុសប្លែកគ្នារវាងគោលគំនិត ឬទស្សនៈនៃផលប្រយោជន៍យុត្តិធម៌ និងផលប្រយោជន៍សន្តិភាព ដែលមានការវាយតម្លៃផ្សេងៗពីស្ថាប័នក្រៅពីតុលាការព្រហ្មទណ្ឌអន្តជាតិ។[83]

ជាចុងក្រោយគួរកត់សំគាល់ថា រដ្ឋអាជ្ញាត្រូវមានកាតព្វកិច្ចជូនដំណឹងទៅដល់អង្គមុនជំនុំជម្រះ ដើម្បីធ្វើការពិនិត្យសំណើ និងឯកសារសំអាងគាំទ្រទាំងឡាយ ហើយបើពិចារណាឃើញថា មានមូលដ្ឋានសមហេតុផលដើម្បីបន្តធ្វើការស៊ើបអង្កេត ដែលករណីនោះស្ថិតក្នុងយុត្តាធិការតុលាការនោះ ខ្លួនត្រូវអនុញ្ញាត ឱ្យចាប់ផ្តើមធ្វើការស៊ើបអង្កេត ដោយគ្មានអគតិធម៌ ចំពោះការកំណត់ជាបន្ទាប់ទៀតដោយតុលាការអំពី យុត្តាធិការ ព្រមទាំងភាពអាចទទួលយកបាន។ ការសម្រេចចិត្តណាមួយមិនស៊ើបអង្កេត ឬមិនកាត់ទោសដោយផ្អែកលើមាត្រា ៥៣(១) (ក) និង(ខ) ឬមាត្រា ៥៣(២)(ក) និង(ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ អង្គមុនជំនុំជម្រះអាចជ្រើសរើសពិនិត្យសេចក្តីសម្រេចបែបនេះ ដែលបន្ទាប់មក ការសម្រេចមិនបើកការស៊ើបអង្កេតរបស់រដ្ឋអាជ្ញា និងមានប្រសិទ្ធភាព លុះត្រាតែមានការអនុម័តដោយអង្គមុនជំនុំជម្រះ។[84] ការបដិសេធរបស់អង្គ

---

[83]ឯកសារគោលនយោបាយស្តីពីផលប្រយោជន៍យុត្តិធម៌ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ទំព័រទី ១,ចូលមើលថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២៤ ICCOTPInterestsOfJustice.pdf (icc-cpi.int)

[84] មាត្រា ១៨ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ៣ ខែឧសភា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

មុនជំនុំជម្រះមិនអនុញ្ញាតឱ្យធ្វើការស៊ើបអង្កេត មិនត្រូវច្រានចោលជាមុននូវការ ដាក់បង្ហាញសំណើបន្តបន្ទាប់ទៀតរបស់រដ្ឋអាជ្ញា ដោយយោងលើអង្គហេតុ ឬភស្តុតាងថ្មីលើស្ថានភាពដដែលនោះឡើយ។ រដ្ឋអាជ្ញាក៏អាចស្វែងរកព័ត៌មានបន្ថែមពីប្រភពដែលអាចទុកចិត្តបាន និងធ្វើការពិនិត្យបឋមលើបញ្ហាណាមួយដែលនៅក្នុងដៃរបស់រដ្ឋអាជ្ញា មិនបង្ហាញឱ្យឃើញថានៅខាងក្រៅយុត្តាធិការរបស់តុលាការ"។

## កថាខណ្ឌទី២៖ ការចាប់ផ្តើមនៃការស៊ើបអង្កេត

### ១.ការស៊ើបអង្កេត

បន្ទាប់ពីលក្ខខណ្ឌការពិនិត្យបឋម ត្រូវបានបំពេញហើយរដ្ឋអាជ្ញា និងធ្វើការបើកស៊ើបអង្កេតលើស្ថានភាពមួយដោយផ្អែកលើព័ត៌មានដែលបានផ្តល់ឱ្យ តាមរយៈពី រដ្ឋ បុគ្គល ក្រុម ឬអង្គការផ្សេងៗ ហើយលុះត្រាតែរដ្ឋអាជ្ញា មានមូលហេតុ សមហេតុផលដើម្បីជឿថាតុលាការ និងមានយុត្តាធិការលើបទល្មើសដែលបានកើតឡើងនោះ។[85] ចំពោះការបំពេញបន្ថែមនោះតម្រូវឱ្យតុលាការពន្យារពេលដំណើរការនីតិវិធីជាតិ ឬប្រសិនបើភាពធ្ងន់ធ្ងរ នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់មិនធានាដល់ការអះអាងនៃយុត្តាធិការ។ នៅក្នុងការស៊ើបអង្កេត ការិយាល័យរដ្ឋអាជ្ញា ធ្វើការប្រមូលព័ត៌មានឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីបង្ហាញការពិតអំពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ក៏ដូចជាដើម្បីកំណត់ថាអ្នកណាជាអ្នកទទួលខុសត្រូវសម្រាប់ការកើតឡើងនៃបទឧក្រិដ្ឋនេះដោយ ការស៊ើបអង្កេតត្រូវមើលទៅលើចំណុចដូចជា ៖

- ការត្រួតពិនិត្យកន្លែងដែលឧក្រិដ្ឋកម្មដែលបានចោទប្រកាន់
- ការប្រមូលភស្តុតាងដូចជា ទិន្នន័យទូរស័ព្ទដៃ អ៊ីមែល វិទ្យុ វីដេអូ រូបថត នាទីប្រជុំ ទំនាក់ទំនងយោធា និងប៉ូលិស សុន្ទរកថា និងសម្ភារៈធ្វើកោសល្យវិច្ឆ័យដូចជា របាយការណ៍
- សម្ភាសសាក្សី និងជនរងគ្រោះ
- ការពិគ្រោះយោបល់ជាមួយអ្នកជំនាញពាក់ព័ន្ធ និងអ្នកឯកទេស
- ការវិភាគប្រតិបត្តិការហិរញ្ញវត្ថុ
- ការិយាល័យរដ្ឋអាជ្ញា តម្រូវឱ្យធ្វើស្របច្បាប់ក្នុងការចាត់វិធានការណ៍ណាក៏ដោយដែលចាំបាច់ដើម្បីប្រមូលភស្តុតាងទាំងអស់ដែលពាក់ព័ន្ធ និងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ រួមទាំងភស្តុតាងនៃការចោទប្រកាន់ និងការលើកលែងទោស។ មុនពេលសវនាការចាប់ផ្តើម រដ្ឋអាជ្ញាត្រូវតែបង្ហាញភស្តុតាងជាច្រើនដល់មេធាវីការពារក្តី។ នេះរាប់បញ្ចូលទាំងភស្តុតាងទាំងអស់

[85] មាត្រា ៥៣ (១) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

ដែលរដ្ឋអាជ្ញាមានបំណងពឹងផ្អែកលើការកាត់ក្តី និងភស្តុតាងណាមួយដែលមាននិន្នាការបង្ហាញពីភាពគ្មានទោសកំហុសរបស់ជនជាប់ចោទ ឬដែលប៉ះពាល់ដល់ភាពជឿជាក់នៃភស្តុតាងរបស់រដ្ឋអាជ្ញា។[86]

## ១.២.ការអនុវត្ត ក្នុងការស៊ើបអង្កេត

ករណីនៅពេលដែលរដ្ឋអាជ្ញាបានបញ្ចប់ការពិនិត្យបឋមដែលជាដំណាក់កាលមុន ហើយសម្រេចចិត្តបន្តបើកការស៊ើបអង្កេតនោះ ការិយាល័យរដ្ឋអាជ្ញារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបង្កើតក្រុមរួមគ្នាមួយដែលត្រូវបានបង្កើតឡើងដើម្បីសម្រាប់បម្រើដល់គោលបំណង នៃការស៊ើបអង្កេត ក្នុងស្ថានភាពណាមួយ។ [87] ក្រុមស៊ើបអង្កេតដែលមាន ៣ ផ្នែកតំណាងឱ្យ យុត្តាធិការ ការបំពេញបន្ថែម និងកិច្ចសហប្រតិបត្តិការ សម្រាប់ការស៊ើបអង្កេត និងការកាត់ទោស បន្ទាប់មកការិយាល័យរដ្ឋអាជ្ញា រួមគ្នាវិភាគព័ត៌មាន និងភស្តុតាងដែលប្រមូលបានក្នុងដំណាក់កាលពិនិត្យបឋម និងស្វែងរកបង្កើតភស្តុតាងបន្ថែម ចាប់ផ្តើមបង្កើតសម្មតិកម្មករណី។ ក្រុមដែលបង្កើតរួមគ្នានោះត្រូវពិនិត្យមើលព័ត៌មាន និងភស្តុតាងដែលប្រមូលបាន ហើយត្រូវកំណត់លទ្ធផលដែលបានមកពីបទឧក្រិដ្ឋនោះជាបណ្តោះអាសន្ន (សម្មតិកម្ម) ដែលកំណត់អត្តសញ្ញាណឧប្បត្តិហេតុដែលត្រូវស៊ើបអង្កេត និងបុគ្គលដែលបានប្រព្រឹត្ត ឬបុគ្គលដែលទំនងជាទទួលខុសត្រូវលើករណីបទល្មើសធ្ងន់ជាងគេ។ លទ្ធផលបណ្តោះអាសន្ន ឬសម្មតិកម្ម និងរួមបញ្ចូលការចង្អុលបង្ហាញជាបណ្តោះអាសន្ននៃការចោទប្រកាន់ទៅលើបុគ្គល ក្នុងការទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌ និងបានបង្ហាញពីកាលៈទេសៈដែលអាចលើកលែងទោសបាន។ នៅក្នុងសម្មតិកម្មករណីបណ្តោះអាសន្ននីមួយៗ ក្រុមរួមគ្នាត្រូវមានគោលបំណងកំណត់យកបទល្មើសដែលឆ្លុះបញ្ចាំងពី ឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតដែលបង្ហាញឱ្យឃើញនៅ ប្រភេទជាចម្បងនៃជនរងគ្រោះ ដែលរួមមាន៖ ផ្លូវភេទ និងយេនឌ័រ អំពើហិង្សាទូទៅ និងអំពើហិង្សាលើកុមារ ហើយដែលកើតឡើងច្រើនបំផុតនៃមាត្រដ្ឋានដែលបានកម្រិត និងផលប៉ះពាល់នៃឧក្រិដ្ឋកម្មដោយយោងតាមមាត្រា ៥៤ (១)(ខ) និងបទប្បញ្ញត្តិ ៣៤ នៃច្បាប់ស្តីពីការិយាល័យរដ្ឋអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិ បន្ទាប់មកក្រុមរដ្ឋអាជ្ញាដែលបានបង្កើតរួមគ្នាត្រូវបញ្ជូនសម្មតិកម្ម នៃករណីបណ្តោះអាសន្ន ទៅអង្គមុនជំនុំជម្រះសម្រាប់ធ្វើការអនុម័ត។[88]

---

[86] គេហទំព័រផ្លូវការនៃគម្រោងការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ៣ ខែឧសភា ឆ្នាំ២០២៤ https://how-the-icc-works.aba-icc.org/

[87] ច្បាប់ស្តីការិយាល័យរដ្ឋអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ផ្នែកទី៤ ច្បាប់ ៣២ ទំព័រទី១៨,ចូលមើលថ្ងៃទី ៣ ខែឧសភា ឆ្នាំ២០២៤ https://www.icc-cpi.int/sites/default/files/NR/rdonlyres/FFF97111-ECD6-40B5-9CDA-792BCBE1E695/280253/ICCBD050109ENG.pdf

[88] ច្បាប់ស្តីការិយាល័យរដ្ឋអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ផ្នែកទី៤ ច្បាប់ ៣៣,៣៤ ទំព័រទី១៨,ចូលមើលថ្ងៃទី ៣ ខែឧសភា ឆ្នាំ២០២៤ https://t.ly/EpdC6

បន្ទាប់ពីអង្គជំនុំជម្រះធ្វើការអនុម័ត ហើយក្រុមរដ្ឋអាជ្ញាត្រូវបង្កើតផែនការបន្ថែម ដើម្បីគាំទ្រដល់ការស៊ើបអង្កេត ដែលរួមមានការប្រមូលភស្តុតាងថ្មី ធានាកិច្ចសហប្រតិបត្តិការរបស់រដ្ឋពាក់ព័ន្ធ ឬអង្គការអន្តររដ្ឋាភិបាល និងសាកសួរជនសង្ស័យ ជនរងគ្រោះ និងសាក្សី។[89] ក្នុងការជ្រើសរើសបុគ្គលដែលត្រូវចោទសួរពាក់ព័ន្ធ និងការស៊ើបអង្កេត រដ្ឋអាជ្ញាត្រូវវាយតម្លៃចំពោះ កម្រិតនៃភាពជឿជាក់របស់បុគ្គលនោះ និងត្រូវគិតគូរដល់សុវត្ថិភាព សុខុមាលភាពរបស់គាត់ រួមទាំងគ្រប់ទិដ្ឋភាពទាំងអស់ដែលទាក់ទង និងហានិភ័យនៃការប៉ះទង្គិចឡើងវិញ។ មុននឹងទាក់ទងបុគ្គលដែលត្រូវសាកសួរពាក់ព័ន្ធ និងការស៊ើបអង្កេត ការិយាល័យរដ្ឋអាជាត្រូវប្រមូលព័ត៌មានឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន អំពីកម្រិតនៃហានិភ័យដែលពាក់ព័ន្ធចំពោះបុគ្គលនោះ ក៏ដូចជាសម្រាប់អ្នកដទៃដែលអាចប្រឈមមុខ និងហានិភ័យដោយសារការសាកសួរបែបនេះ រួមទាំង អ្នកដែលសម្របសម្រួលទំនាក់ទំនងរវាងការិយាល័យ និងបុគ្គលដែលត្រូវសាកសួ។[90] ដោយផ្អែកលើការកំណត់នៃកម្រិតហានិភ័យ ការិយាល័យអាចពិចារណាជម្រើសផ្សេងៗចំពោះការសាកសួរផងដែរ។ សុខុមាលភាពផ្លូវកាយ និងផ្លូវចិត្តរបស់បុគ្គលដែលត្រូវបានសាកសួរដោយការិយាល័យ និងត្រូវបានចាត់ទុកថាងាយរងគ្រោះ (ជាពិសេសកុមារ ជនពិការ និងជនរងគ្រោះយេនឌ័រ និងឧក្រិដ្ឋកម្មផ្លូវភេទ) និងត្រូវវាយតម្លៃដោយតក្កវិជ្ជា ចិត្តសាស្រ្ត-សង្គមឬអ្នកជំនាញផ្សេងទៀត។ អំឡុងពេលសម្ភាសទល់មុខគ្នា មុនពេលសួរសំណួរ ការវាយតម្លៃនេះ និងកំណត់ថាតើស្ថានភាពរបស់បុគ្គលនោះនៅពេលជាក់លាក់ អនុញ្ញាតឱ្យគាត់ត្រូវបានសាកសួរដោយគ្មានហានិភ័យនៃការរងរបួសឡើងវិញ។ ទោះជាយ៉ាងណានៅពេលដែលបុគ្គលម្នាក់មានអាយុក្រោមដប់ប្រាំបីឆ្នាំ រដ្ឋអាជ្ញាត្រូវទទួលបានការយល់ព្រមពីឪពុកម្តាយ អាណាព្យាបាល ឬមនុស្សពេញវ័យដែលពាក់ព័ន្ធផ្សេងទៀត មុនពេលសាកសួរចំពោះបុគ្គលដែលត្រូវបានចោទសួរដោយរដ្ឋអាជ្ញា នៅអំឡុងពេលស៊ើបអង្កេតនោះត្រូវបានធានាសិទ្ធិ ឬសកម្មភាពពួកគេ ដែលបានកំណត់ក្នុងច្បាប់នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ។[91]

## ២.កិច្ចសហប្រតិបត្តិការរដ្ឋភាគី

ក្រឡេកមកមើល រដ្ឋភាគីវិញក៏ជាផ្នែកមួយដែលបានគាំទ្រដល់ការស៊ើបអង្កេតផងដែរ ដោយសារតែតុលាការ និងមិនអាចអនុវត្តច្បាប់ដោយរលូនបានទេ បើគ្មានការសហការពីរដ្ឋភាគី ហើយសកម្មភាពដែលពិបាកជាក់ស្តែងទាំងអស់នោះមានដូចជា  តុលាការមិនមានកម្លាំងប៉ូលិសផ្ទាល់សម្រាប់ប្រតិបត្តិការណាមួយ

[89] វិធាននៃនីតិវិធី និងភស្តុតាង ជំពូកទី ៥ ផ្នែកទី ១ ច្បាប់ ១០៤ ការវាយតម្លៃព័ត៌មានដោយរដ្ឋអាជ្ញា,ចូលមើលថ្ងៃទី ៣ ខែឧសភា ឆ្នាំ២០២៤ https://www.icc-cpi.int/sites/default/files/RulesProcedureEvidenceEng.pdf

[90] ច្បាប់ស្តីការិយាល័យរដ្ឋអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ផ្នែកទី៤ ច្បាប់  ៣៦,៣៧ ទំព័រទី១៨,ចូលមើលថ្ងៃទី ៣ ខែឧសភា ឆ្នាំ២០២៤ https://t.ly/EpdC6

[91] ច្បាប់ស្តីការិយាល័យរដ្ឋអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ផ្នែកទី៤ ច្បាប់  ៣៨ ទំព័រទី២០,ចូលមើលថ្ងៃទី ៣ ខែឧសភា ឆ្នាំ២០២៤ https://t.ly/EpdC6

ឬអំណាចអនុវត្តឯករាជ្យទេ ហើយតុលាការក៏មិនអាចចូល ឬទទួលបានភស្តុតាងនៅក្នុងប្រទេសណាមួយ ដោយអនាធិបតេយ្យដែលគ្មានការអនុញ្ញាតពីប្រទេសទាំងនោះទេ។

### ២.១.សំណើសុំកិច្ចសហប្រតិបត្តិការ

តុលាការមានអំណាច ស្នើសុំរដ្ឋភាគីទាំងឡាយឲ្យធ្វើកិច្ចសហប្រតិបត្តិការ ទៅតាមសំណើណាមួយ ដែលខ្លួនបានស្នើ ហើយត្រូវតែបញ្ជូនតាមរយៈបណ្តាញការទូត ឬតាមបណ្តាញដែលសមស្របដទៃទៀត ដែលកំណត់ទុកជាមុន ដោយរដ្ឋភាគីនីមួយៗ នៅពេលដែលខ្លួនផ្តល់សច្ចាប័ន អនុម័តយល់ព្រមចូលជាសមាជិក នៃលក្ខន្តិកៈទីក្រុងរ៉ូមនេះ។ ម្យ៉ាងវិញសំណើកិច្ចសហប្រតិបត្តិការ ក៏អាចបញ្ជូនតាមរយៈអង្គការប៉ូលិសឧក្រិដ្ឋកម្មអន្តរជាតិ ឬតាមរយៈអង្គការក្នុងតំបន់ណាមួយដែលសមស្រប។ ទាំងនេះធ្វើឡើង ដោយសារ មានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការ តុលាការ និងប៉ូលិសឧក្រិដ្ឋកម្មអន្តរជាតិ (INTERPOL)។[92] សំណើស្នើ និងឯកសារណាមួយសម្រាប់គាំទ្រសំណើ ត្រូវធ្វើឡើង ឬអមជាមួយច្បាប់បកប្រែជាភាសាផ្លូវការរបស់រដ្ឋហត្ថលេខីនោះ ឬជាភាសាការងាររបស់តុលាការនេះស្របតាមការជ្រើសរើសឡើងនៅពេលផ្តល់សច្ចាប័ន។ ពេលដែលរដ្ឋភាគីខកខានមិនបានអនុវត្តតាមសំណើ ដោយរារាំងតុលាការមិនឲ្យអនុវត្តមុខងារ និងអំណាចរបស់ខ្លួន នោះតុលាការអាចធ្វើការសន្និដ្ឋានហើយបញ្ជូន ទៅសន្និបាតនៃរដ្ឋភាគី ឬទៅក្រុមប្រឹក្សាសន្តិសុខ យោងតាមមាត្រា៨៦ (៧)។

### ២.២.សារៈសំខាន់របស់រដ្ឋភាគីក្នុងការអនុវត្តច្បាប់

តុលាការព្រហ្មទណ្ឌអន្តរជាតិ និងការិយាល័យរដ្ឋអាជ្ញាពឹងផ្អែកលើ "កិច្ចសហប្រតិបត្តិការ និងជំនួយ" នៃរដ្ឋភាគីទាំងនោះ ដើម្បីសម្រួលដល់ការស៊ើបអង្កេត និងការកាត់ទោស។ កិច្ចសហប្រតិបត្តិការ និងជំនួយអាចរួមមាន៖

- អនុញ្ញាតឱ្យចូលប្រើឯកសារ និងភស្តុតាងផ្សេងទៀត
- ចាត់តាំងបុគ្គលិកក្នុងស្រុកដើម្បីជួយដល់ដំណើរការស៊ើបអង្កេត
- ជួយស្វែងរកសាក្សី និងជនរងគ្រោះ ឬជួយក្នុងការកំណត់អត្តសញ្ញាណទីតាំងឧក្រិដ្ឋកម្ម។ [93]

[92]កិច្ចព្រមព្រៀងរវាងការិយាល័យរដ្ឋអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិ និងប៉ូលីសឧក្រិដ្ឋកម្មអន្តរជាតិចូលមើលថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០២៤
https://www.icc-cpi.int/news/icc-cooperation-agreement-between-office-prosecutor-and-interpol

[93]មាត្រា ៨៦ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ,ចូលមើលថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០២៤
https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

ប្រសិនបើរដ្ឋភាគីណាមួយមិនសហការជាមួយនឹងសំណើរបស់រដ្ឋអាជ្ញាដើម្បីធ្វើសកម្មភាព ស៊ើបអង្កេតក្នុងទឹកដីរបស់ខ្លួន អង្គមុនជំនុំជម្រះអាចអនុញ្ញាតការស៊ើបអង្កេតនៅនឹងកន្លែងបាន ប៉ុន្តែប្រសិនបើរដ្ឋមិនសហការគឺដោយសារតែមិនមានអាជ្ញាធរណាមួយ ឬមិនមានសមាសធាតុណាមួយនៃប្រព័ន្ធតុលាការរបស់ខ្លួនមានសមត្ថកិច្ចដើម្បីអនុវត្តសំណើសុំកិច្ចសហប្រតិបត្តិការនោះ អង្គមុនជំនុំជម្រះមិនអាចអនុញ្ញាតបើកការស៊ើបអង្កេតនៅនឹងកន្លែងបានទេ។ ប្រសិនបើរដ្ឋភាគីណាមួយមិនគោរពតាមសំណើសុំសហការជាមួយតុលាការ តុលាការអាចធ្វើការរកឃើញលទ្ធផលនោះ ហើយបញ្ជូនរឿងនេះទៅសន្និបាតនៃរដ្ឋភាគី។ មានតែរដ្ឋភាគីប៉ុណ្ណោះដែលស្ថិតនៅក្រោមកាតព្វកិច្ចផ្អែកលើសន្ធិសញ្ញាដើម្បីអនុវត្តន៍តាមច្បាប់តុលាការ។ រដ្ឋដែលមិនមែនជាភាគីអាចស្ថិតនៅក្រោមកាតព្វកិច្ចស្រដៀងគ្នានេះ ដែលត្រូវបានបញ្ជូនមកដោយក្រុមប្រឹក្សាសន្តិសុខ ឧទាហរណ៍ដូចជា៖ នៅក្នុងដំណោះស្រាយការ បញ្ជូនស្ថានភាពដែលគេបានសង្ស័យមានបទល្មើសកើតឡើង ពាក់ព័ន្ធនឹងប្រទេសស៊ូដង់ និងលីប៊ី ដែលមិនមែនជារដ្ឋភាគីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។[94]

**២.២.១.ករណីសិក្សា** ( ម៉ាឡាវី ឆាដ និងជីប៊ូទី )

ទោះជាយ៉ាងណាមកទល់នឹងពេលនេះ តុលាការបានធ្វើការរកឃើញជាច្រើននៃការមិនសហការក្នុងការចាប់ខ្លួន ដូចជាករណីទាក់ទង និងការធ្វើដំណើររបស់ប្រធានាធិបតី Omar Al Bashir ទៅកាន់រដ្ឋភាគីមួយចំនួន រួមមាន ម៉ាឡាវី ឆាដ និងជីប៊ូទី ដោយពួកគេស្នើថា មានផលវិបាកពីក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងអភ័យឯកសិទ្ធិដែលលោក al-Bashir ទទួលបានក្នុងនាមជាប្រមុខរដ្ឋ ដែលនេះអាចជាកត្តាក្នុងការសម្រេចចិត្តមិនចាប់ខ្លួនគាត់ពីសំណាក់រដ្ឋភាគីទាំងនោះ។ យ៉ាងណាក៏ដោយរហូតមកដល់ពេលនេះ ក្រុមប្រឹក្សាសន្តិសុខមិនទាន់បានឆ្លើយតបតាមផ្លូវជាក់លាក់ណាមួយឡើយការខ្វះការឆ្លើយតបពីក្រុមប្រឹក្សាសន្តិសុខអាចនិងជំរុញឱ្យរដ្ឋដទៃទៀត បដិសេធមិនចាប់ខ្លួនលោក al-Bashir ផងដែរ។[95]

ក្នុងការលើកឡើងនេះយើងបានមើលឃើញថា បើគ្មានកិច្ចសហប្រតិបត្តិការ ឬការចូលរួមពីរដ្ឋភាគីទេ តុលាការព្រហ្មទណ្ឌអន្តរជាតិ  មិនអាចដំណើរការបានទេ ព្រោះតុលាការត្រូវពឹងផ្អែកលើ រដ្ឋភាគីជាសសរស្តម្ភនៃការអនុវត្តរបស់ខ្លួន នៅពេលដែលរដ្ឋបានអនុម័ត សន្ធិសញ្ញាបង្កើតលក្ខន្តិកៈទីក្រុងរ៉ូម ពួកគេបានសម្រេចចិត្តថាតុលាការ និងមិនមានអំណាចអនុវត្តដោយផ្ទាល់ខ្លួននោះទេ ផ្ទុយទៅវិញរដ្ឋភាគីដែលបានដើរតួនាទី ក្នុង

[94] បេសកកម្មអចិន្ត្រៃយ៍របស់ប្រទេសបារាំងទៅអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក,ចូលមើលថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០២៤ https://onu.delegfrance.org/we-encourage-the-icc-to-continue-its-efforts-to-enhance-its-engagement-in-libya

[95]របាយការណ៍របស់អង្គមុនជំនុំជម្រះ ស្តីពីការជូនដំណឹងដល់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងសភានៃរដ្ឋភាគីអំពីការមិនសហការរបស់ប្រទេសម៉ាឡាវី ក្នុងការចាប់ខ្លួន Omar Al Bashir ,ទំព័រទី ៦,ចូលមើលថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០២៤ https://www.icc-cpi.int/sites/default/files/CourtRecords/CR2011_21722.PDF

ទំនួលខុសត្រូវក្នុងការគាំទ្រ ដល់មុខងារតុលាការ និងការិយាល័យរដ្ឋអាជ្ញា ដោយផ្តល់កិច្ចសហប្រតិបត្តិការជាក់ស្តែងដំណាក់កាលនៃសកម្មភាពរបស់តុលាការ រួមទាំងការស៊ើបអង្កេត ការចាប់ខ្លួន និងការផ្ទេររបស់ជនសង្ស័យលទ្ធភាពទទួលបានភស្តុតាង និងសាក្សី, ការការពារបុគ្គល និងការអនុវត្តសាលក្រម ឬសាលដីកា និងការកាត់ទោសរបស់តុលាការ។ ភាគីទី ៩ នៃលក្ខន្តិកៈទីក្រុងរ៉ូមបានបង្ហាញ អំពីការកំណត់កាតព្វកិច្ចផ្លូវច្បាប់នៃរដ្ឋភាគី ដើម្បីគាំទ្រ និងសម្រួលការងារ របស់តុលាការពេញមួយដំណើរការ។ [96]

ជាចុងក្រោយក្នុងចំណុចនេះ នៅពេលដែល ការិយាល័យរដ្ឋអាជ្ញាបានធ្វើការស៊ើបអង្កេតគ្រប់គ្រាន់ និងបានរកឃើញហេតុផលសមស្របដើម្បីជឿ ឬកំណត់ថាបុគ្គលណាម្នាក់បានប្រព្រឹត្តបទឧក្រិដ្ឋ នៅក្នុងយុត្តាធិការរបស់តុលាការ រដ្ឋអាជ្ញាអាចស្នើសុំឱ្យអង្គមុនជំនុំជម្រះដើម្បី ចេញដីកាចាប់ខ្លួន ឬការកោះហៅជននោះ មកបង្ហាញខ្លួន ដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវនៃការចោទប្រកាន់នោះ ទោះយ៉ាងណាក៏ដោយការស៊ើបអង្កេតនេះក៏អាចនឹងត្រូវបានពន្យាពេលដោយសារ កត្តាផ្សេងៗ ដែលបានលើកមកបង្ហាញ ដោយក្រុមប្រឹក្សាសន្តិសុខ ឬក៏ជាសំណើសុំពន្យារពេលរបស់រដ្ឋភាគី ក្រោមរូបភាព និងហេតុផលដែលអាចទទួលយកបានណាមួយហើយត្រូវបានទទួលស្គាល់ ឬមានកំណត់នៅក្នុងច្បាប់ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិនេះ។[97]

## ៣.ការពន្យារពេលនៃការស៊ើបអង្កេត

### ៣.១.ក្រុមប្រឹក្សាសន្តិសុខ

ទោះបីជាដំណើរការត្រូវបានផ្តួចផ្តើមនៅចំពោះមុខតុលាការយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិនៅតែមានសិទ្ធ ឬសមត្ថភាពក្នុងការពន្យារពេលសកម្មភាពនៅចំពោះមុខតុលាការសម្រាប់រយៈពេលមួយឆ្នាំ ដោយផ្អែកលើមូលដ្ឋានដែលអាចកើតឡើងវិញ។[98] បើយើងក្រឡេកមើលក្នុងការកំណត់នៃមាត្រា ១៦ នៃលក្ខន្តិកៈទីក្រុងរ៉ូមបានចែងថា៖ គ្មានការស៊ើបអង្កេត ឬការកាត់ទោសអាចត្រូវបានចាប់ផ្តើម ឬដំណើរការក្រោមលក្ខន្តិកៈនេះក្នុងរយៈពេល ១២ ខែបន្ទាប់ពីក្រុមប្រឹក្សាសន្តិសុខ បានស្ថិតក្នុងដំណោះស្រាយ ដែលបានអនុម័តក្រោមជំពូកទី ៧ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ដែលមាត្រានេះបានធ្វើឱ្យមានប្រសិទ្ធភាពក្នុងការពន្យារពេល ហើយសំណើនោះអាចត្រូវបានបន្តដោយក្រុមប្រឹក្សាសន្តិសុខក្រោម

[96]ឯកសារស្តីពីការណែនាំនូវលើកិច្ចសហប្រតិបត្តិការរបស់រដ្ឋជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិ៖បទពិសោធន៍ និងអាទិភាព,ចូលមើលថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០២៤
https://www.icc-cpi.int/sites/default/files/2022-04/66-Recommendations-Flyer-ENG.pdf

[97]មាត្រា ៥៨ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ,ចូលមើលថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០២៤
https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[98]មាត្រា ១៦ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤
https://www.icc-cpi.int/about/the-court

លក្ខខណ្ឌដូចគ្នា។ តែទោះបីជាយ៉ាងនេះក្តី រហូតមកដល់ពេលនេះ ការពន្យារពេលស្ថិតក្រោមលក្ខខណ្ឌនេះ នៅតែមិនទាន់ឃើញមានការប្រើប្រាស់បាននៅពេលគេនិយាយអំពីស្ថានភាពផ្ទាល់នៅចំពោះមុខតុលាការ ដូចជាករណីការស្នើសូមរបស់ប្រទេសកេនយ៉ា ក្នុងឆ្នាំ២០១១ និង២០១៣ ដែលបានស្នើសុំទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិឱ្យពន្យារពេលសំណុំរឿង ការស៊ើបអង្កេតរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ប្រឆាំងនឹងប្រធានាធិបតី Uhuru Kenyatta អនុប្រធានាធិបតី William Ruto ចំពោះអំពើហិង្សាដែលកើតមានក្រោយការបោះឆ្នោតឆ្នាំ២០០៧-២០០៨ ក្រោមហេតុផលថា អាចគំរាមកំហែងដល់សន្តិភាព និងសន្តិសុខអន្តរជាតិ។[99]

ក្នុងការពន្យារពេលគេឃើញមានលក្ខខណ្ឌមាត្រា ១៦ នៃលក្ខន្តិកៈទីក្រុងរ៉ូមត្រូវបានចាក់ឫសជាប់គ្នានៅក្នុងមាត្រា ២៣ នៃសេចក្តីព្រាងលក្ខន្តិកៈគណៈកម្មការច្បាប់អន្តរជាតិ។ (សេចក្តីព្រាងលក្ខន្តិកៈសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលមានការអត្ថាធិប្បាយ របាយការណ៍គណៈកម្មការច្បាប់អន្តរជាតិក្នុងឆ្នាំ ១៩៩៤( UN Doc A/49/10; របាយការណ៍របស់ គណៈកម្មការច្បាប់អន្តរជាតិ ស្តីពីការងារនៃសម័យប្រជុំលើកទី ៤៦ ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ១៩៩៤ អង្គការសហប្រជាជាតិ Doc A/49/ 355 ថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ១៩៩៩) សេចក្តីព្រាងរបស់គណៈកម្មការច្បាប់អន្តរជាតិបានស្នើថា ដំណើរការតុលាការណាមួយ និងមិនអាចដំណើរការដោយគ្មានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាសន្តិសុខ ប្រសិនបើស្ថានការណ៍ធ្លាក់ក្រោមឧត្តមានុភាពនៃជំពូកទី ៧ ធម្មនុញ្ញអង្គការសហប្រជាជាតិ។ ក្នុងសន្និសីទទីក្រុងរ៉ូម រដ្ឋបានសម្តែងការព្រួយបារម្ភជាច្រើន ដូចជាហានិភ័យការជ្រៀតជ្រែកជាមួយឯករាជ្យភាពរបស់តុលាការ ពិសេសខ្លាចមានឥទ្ធិពលនយោបាយមិនសមរម្យណាមួយដោយក្រុមប្រឹក្សាសន្តិសុខដែលធ្វើឱ្យមានផលវិបាកដល់តុលាការនេះ។[100]

### ៣.២.រដ្ឋភាគី

បើសិនមានការអនុវត្តសំណើបន្ទាន់មួយ រដ្ឋភាគីអាចបង្អាក់ដល់ដំណើរការស៊ើបអង្កេត ឬការនាំយកមកជំនុំជម្រះដែលកំពុងតែប្រព្រឹត្តទៅលើរឿងក្តីមួយផ្សេង អំពីរឿងក្តីនៅក្នុងសំណើបន្ទាន់នោះរដ្ឋទទួលសំណើអាចពន្យារពេលអនុវត្តសំណើបន្ទាន់នោះ មួយរយៈតាមការយល់ព្រមពីតុលាការ។ ទោះបីជាយ៉ាងណាក្តី រយៈពេលពន្យារមិនត្រូវលើសរយៈពេលដែល ចាំបាច់ដើម្បីបំពេញនូវការស៊ើបអង្កេត ឬការនាំយកមកជំនុំជម្រះ ដែលពាក់ព័ន្ធនៅក្នុងរដ្ឋទទួលសំណើឡើយ។ មុនពេលធ្វើ ការសម្រេចពន្យារពេលរដ្ឋទទួលសំណើគួរតែពិចារណាថា

[99]ដំណោះស្រាយរបស់ក្រុមប្រឹក្សាសន្តិសុខក្នុងការស្វែងរកការពន្យារពេលការកាត់ក្តីរបស់មេដឹកនាំកេនយ៉ាចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤ https://shorturl.at/ikDZ8

[100] របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិស្តីពីការងារនៃសម័យប្រជុំលើកទីសែសិបប្រាំមួយរបស់ខ្លួន ថ្ងៃទី ០២ ខែឧសភា -២២ ខែកក្កដា ឆ្នាំ ១៩៩៤ កំណត់ត្រាផ្លូវការនៃមហាសន្និបាត សម័យប្រជុំលើកទី ៤៩ ទំព័រទី៤៤,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤ https://legal.un.org/ilc/documentation/english/reports/a_49_10.pdf

ការជួយជ្រោមជ្រែង អាចត្រូវផ្តល់ជូនភ្លាមៗ ក្រោមលក្ខខណ្ឌមួយចំនួន ឬអត់។ ប្រសិនបើការសម្រេចពន្យារពេលត្រូវបានធ្វើឡើងស្របតាមកថាខណ្ឌខាងលើនេះ រដ្ឋអាជ្ញានៅតែអាចស្វែងរកវិធានការដើម្បីរក្សាភស្តុតាងស្របតាមច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមបាន។[101]

### ៤.ការបោះបង់ការស៊ើបអង្កេត

ទោះជាយ៉ាងណារដ្ឋអាជ្ញាក៏អាចបោះបង់ការស៊ើបអង្កេតរបស់ខ្លួនបានលុះត្រាតែជឿថាមិនមានមូលដ្ឋានសមហេតុផល ដើម្បីដំណើរការដោយផ្អែកលើកត្តាខាងដូចខាងក្រោម៖

- តើព័ត៌មានដែលរដ្ឋអាជ្ញាទទួលបាននោះ មានមូលដ្ឋានសមហេតុផលឱ្យជឿទុកចិត្តបានថាបទល្មើសដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ ត្រូវបានជនល្មើសប្រព្រឹត្ត ឬកំពុងត្រូវបានជនល្មើសនោះប្រព្រឹត្ត  ថាតើរឿងក្តីនេះអាច ឬនិងអាចទទួលយកបានក្រោមមាត្រា ១៧។
- ពិចារណាចំពោះភាពធ្ងន់ធ្ងរនៃបទល្មើស និងផលប្រយោជន៍របស់ជនរងគ្រោះ តើមានហេតុផលដែលសមរម្យ ដែលទោះជាយ៉ាងណា ធ្វើឱ្យជឿថាការស៊ើបអង្កេត និងមិនបានបម្រើប្រយោជន៍យុត្តិធម៌ទេ។
- ប្រសិនបើរដ្ឋអាជ្ញាសម្រេចថា មិនមានមូលដ្ឋានសមហេតុផលក្នុងការដំណើរការជម្រះរឿងក្តី ហើយការសម្រេចរបស់ខ្លួនត្រូវផ្អែកថា វាមិនបានបម្រើផលប្រយោជន៍យុត្តិធម៌ សម្រាប់ជនរងគ្រោះហើយរដ្ឋអាជ្ញាត្រូវតែជូនដំណឹងទៅអង្គមុនជំនុំជម្រះ។[102]

## កថាខណ្ឌទី៣៖ ដំណាក់កាលមុនការជំនុំជម្រះ

បន្ទាប់ពីការស៊ើបអង្កេត បានកំណត់ថាត្រឹមត្រូវហើយគ្មានការជំទាស់នោះ តុលាការ និងចាប់ផ្តើមបើកការជំនុំជម្រះ ដែលក្នុងដំណាក់កាលនេះយើងឃើញមាន នូវនីតិវិធីមុនជំនុំជម្រះដោយតុលាការ និងសម្រេចចេញនូវដីកាកោះហៅឱ្យបង្ហាញខ្លួនជនត្រូវចោទ ដោយស្របទៅតាម នីតិវិធីនៃដំណើរការនេះអនុលោមតាមមាត្រា ៥៨  នៃច្បាប់នៃលក្ខន្តិកៈទីក្រុងរ៉ូម ហើយព្រមទាំងបញ្ជាក់អំពីការចោទប្រកាន់ទៅជនល្មើសនោះ។

[101]មាត្រា ១៦ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤
https://www.icc-cpi.int/about/the-court

[102] មាត្រា៥៣(១)  នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០២៤
https://www.icc-cpi.int/about/the-court

## ១.សមត្ថកិច្ចអង្គមុនជំនុំជម្រះ

អង្គមុនជំនុំជម្រះ ត្រូវធ្វើការអនុវត្តមុខងាររបស់ខ្លួនស្រប តាមបទបញ្ញត្តិនៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម។ សេចក្តីសម្រេចរបស់អង្គមុនជំនុំជម្រះដែលចេញក្រោមមាត្រា បដិសេធការស៊ើបអង្កេត ,ការព្យួរសេចក្តីសម្រេច, ពីការតវ៉ាលើយុត្តាធិការ ការអនុញ្ញាតសិទ្ធក្នុងការធ្វើសកម្មភាពនៃរដ្ឋភាគី។ [103] លើសពីនេះការកំណត់ចំពោះភស្តុតាង បញ្ជាក់ ឬបដិសេធបទចោទ កថាខណ្ឌទី ៧ មាត្រា ៦១ ត្រូវតែមានការយល់ព្រមដោយមតិភាគច្រើននៃចៅក្រមរបស់ខ្លួនផងដែរ។ តាមសំណើសុំរបស់រដ្ឋអាជ្ញា អង្គមុនជំនុំជម្រះអាចចេញដីកា ដែលមានការចាំបាច់ក្នុងគោលបំណងនៃការស៊ើបអង្កេត តាមសំណើសុំរបស់ជនដែលត្រូវបានចាប់ខ្លួន ឬជនដែលបានបង្ហាញខ្លួនតាមដីកាកោះហៅឱ្យបង្ហាញខ្លួន តាមមាត្រា ៥៨ អង្គមុនជំនុំជម្រះអាចចេញ វិធានការផ្សេងៗ តួយ៉ាងវិធានការទាំងឡាយដែលបានចែង ក្នុងមាត្រា ៥៦ ឬអាចស្វែងរកកិច្ចសហប្រតិបត្តិការ អនុលោមតាមភាគីទី ៩ ដែលអាចជាការចាំបាច់សម្រាប់ជួយជននោះក្នុងការរៀបចំកិច្ចការពារខ្លួន។ កាលណាមានការចាំបាច់ អង្គមុនជំនុំជម្រះ អាចផ្តល់នូវការការពារ និងភាពស្ងៀមស្ងាត់គ្មានការឆោឆៅរំខាន ដល់ជនរងគ្រោះ និងសាក្សី ក្នុងការជួយរក្សាភស្តុតាង អាចជួយការពារជនដែលត្រូវបានចាប់ខ្លួន ឬជនដែលបានបង្ហាញខ្លួនតាមដីកាកោះហៅឱ្យបង្ហាញខ្លួន និងអាចជួយការពារព័ត៌មានសន្តិសុខជាតិ។ អង្គមុនជំនុំជម្រះ អាចអនុញ្ញាឱ្យរដ្ឋអាជ្ញាធ្វើការបើកស៊ើបអង្កេតពិសេសណាមួយ ក្នុងទឹកដីនៃរដ្ឋភាគី ដោយគ្មានការធានានៃកិច្ចសហប្រតិបត្តិការពីខាងរដ្ឋភាគីក្រោមភាគទី ៩ នៃច្បាប់នៃលក្ខន្តិកៈទីក្រុងរ៉ូម ដែលអាចធ្វើទៅបានចំពោះទស្សនៈយល់ឃើញរបស់រដ្ឋដែលមានការពាក់ព័ន្ធ នោះមិនមានលទ្ធភាពយ៉ាងជាក់ច្បាស់ក្នុងការប្រតិបត្តិនូវសំណើសុំកិច្ចសហប្រតិបត្តិការដោយសារមិនមានអាជ្ញាធរណាមួយ ឬអង្គភាពណាមួយនៃប្រព័ន្ធយុត្តាធិការនៃរដ្ឋរបស់ខ្លួន ដែលមានសមត្ថកិច្ចដើម្បីប្រតិបត្តិនូវសំណើ សុំកិច្ចសហប្រតិបត្តិការនោះ។[104]

### ១.១.ដីកាចាប់ខ្លួន ឬកោះហៅ

ក្រោយបញ្ចប់ការស៊ើបអង្កេតហើយ ភស្តុតាងដែលប្រមូលបានដោយរដ្ឋអាជ្ញា ត្រូវបានអង្គមុនជំនុំជម្រះជឿថាមានហេតុផលសមស្របដើម្បីប្រាកដថា បុគ្គលម្នាក់ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដ៏ឃោរឃៅ រដ្ឋអាជ្ញារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ អាចស្នើឱ្យអង្គមុនជំនុំជម្រះចេញដីកាកោះហៅ ឬដីកាចាប់ខ្លួនជននោះ។[105]

---

[103] មាត្រា១៥,១៨,១៩,៥៤(២) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០២៤ https://www.icc-cpi.int/about/the-court

[104] មាត្រា ៥៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ,ចូលមើលថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[105] មាត្រា ៥៨ (១),(ក) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ,ចូលមើលថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២៤

ការកោះហៅអាចត្រូវបានធ្វើឡើងប្រសិនបើអង្គមុនជំនុំជម្រះយល់ស្របថាវាជា គឺជាភាពចាំបាច់ក្នុងការចាប់ខ្លួនជននោះ ដើម្បីធានាថាបុគ្គលនោះបង្ហាញខ្លួននៅក្នុងសវនាការ។ វាក៏អាចត្រូវបានចេញផងដែរប្រសិនបើចៅក្រមគិតថាវាចាំបាច់ដើម្បីធានាថា បុគ្គលនោះមិនរារាំងការស៊ើបអង្កេត ឬរារាំងបុគ្គលនោះពីការបន្តប្រព្រឹត្តឧក្រិដ្ឋកម្មស្រដៀង និងអ្នកដែលត្រូវបានគេសង្ស័យថាបានប្រព្រឹត្ត។[106] កាលណាដីកាចាប់ខ្លួន ឬដីកាកោះហៅឱ្យបង្ហាញខ្លួនត្រូវបានចេញក្រោមមាត្រា ៥៨ និងតុលាការត្រូវបានពិចារណាលើអនុភាពនៃភស្តុតាង និងសិទ្ធិនៃបណ្តារដ្ឋភាគីដែលមានការពាក់ព័ន្ធ ដូចមានចែងនៅក្នុងច្បាប់លក្ខន្តិកៈនេះ និងវិធាននៃនីតិវិធី និងភស្តុតាង អង្គមុនជំនុំជម្រះ អាចស្វែងរកកិច្ចសហប្រតិបត្តិការពីបណ្តារដ្ឋនានា ស្របតាមកថាខណ្ឌទី ១ នៃមាត្រា ៩៣ ដើម្បីចាត់វិធានការការពារសម្រាប់គោលបំណងផ្សេងៗ ជាពិសេសសម្រាប់ជាប្រយោជន៍របស់ជនរងគ្រោះ ក្នុងការចាប់ខ្លួន ឬកោះហៅនេះក៏បានរំលេចចេញនូវ ភាពសំខាន់នៃការសហការរបស់រដ្ឋភាគីសម្រាប់គាំទ្រដល់ដំណើរការ។

## ១.២.កាតព្វកិច្ចរបស់រដ្ឋភាគីដើម្បីសហប្រតិបត្តិការ

រដ្ឋភាគីមានកាតព្វកិច្ចធ្វើកិច្ចសហប្រតិបត្តិការយ៉ាងពេញលេញជាមួយ តុលាការក្នុងការស៊ើបអង្កេត និងនាំយកជនត្រូវចោទទៅជំនុំជម្រះ ទៅតាមបទល្មើសព្រហ្មទណ្ឌដែលស្ថិតនៅក្នុងយុត្តាធិការនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។

### ១.២.១.នីតិវិធីក្រោមច្បាប់ជាតិ

ក្នុងការសហការរដ្ឋភាគីទាំងឡាយត្រូវធានាឱ្យបានថា ខ្លួនមាននីតិវិធីក្រោមច្បាប់ជាតិរបស់ខ្លួនដែលអាចជាច្បាប់ ឬវិធានការណ៍ណាមួយ សម្រាប់ការអនុវត្តកិច្ចសហប្រតិបត្តិការគ្រប់ទ្រង់ទ្រាយ ជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិ។

### ១.២.២.ការចាប់ខ្លួនបណ្តោះអាសន្ន

ក្នុងករណីបន្ទាន់ តុលាការអាចធ្វើការស្នើសុំឲ្យមានការចាប់ខ្លួនជាបណ្តោះអាសន្ននៃជនដែលគេ កំពុងធ្វើការស្វែងរកនោះក្នុងរយៈពេលមួយ ដើម្បីរង់ចាំការបង្ហើយសំណើសុំប្រគល់ខ្លួន និងឯកសារដែលពាក់ព័ន្ធ។ ការចាប់ខ្លួនបណ្តោះអាសន្ន អាចធ្វើឡើងតាមមធ្យោបាយណាមួយដែលអាចបញ្ជូន ឯកសារជា លាយលក្ខណ៍អក្សរបាន ហើយត្រូវមាន៖

---

https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[106]មាត្រា ៥៨ (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ,ចូលមើលថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

- ព័ត៌មានដែលពណ៌នាអំពីជនដែលត្រូវស្វែងរកនោះ និងដែលមានលក្ខណៈគ្រប់គ្រាន់ដើម្បីធ្វើការកំណត់អត្តសញ្ញាណជននោះ និងព័ត៌មានស្តីអំពីទីកន្លែងដែលជននោះស្នាក់នៅ។
- សេចក្តីថ្លែងការណ៍សង្ខេបអំពីបទល្មើសព្រហ្មទណ្ឌសម្រាប់ស្វែងរកចាប់ខ្លួនជននោះ និងសេចក្តី ថ្លែងការណ៍អំពីអង្គហេតុដែលចោទឡើងដើម្បីបង្កើតជាបទល្មើសព្រហ្មទណ្ឌនោះ ប្រសិនជាអាច ត្រូវមានទាំងកាលបរិច្ឆេទ និងទីកន្លែងនៃបទល្មើសព្រហ្មទណ្ឌកើតឡើងនោះផងដែរ។
- សេចក្តីថ្លែងការណ៍អំពីដីកាសុំការចាប់ខ្លួន ឬមានសាលក្រមសម្រេចថាមានពិរុទ្ធភាពប្រឆាំងនិងជនដែលត្រូវស្វែងរក សេចក្តីថ្លែងការណ៍អំពីសំណើសុំប្រគល់ខ្លួនជនដែលត្រូវស្វែងរក។[107]

ទោះយ៉ាងណា ការចាប់ខ្លួននេះត្រូវធ្វើឡើងដោយគោរពទៅលើសិទ្ធិរបស់ ជនត្រូវចោទ ហើយសិទ្ធិនោះដែលត្រូវបានធានាពេញមួយដំណើរការ។

### ១.២.៣.ការប្រគល់ខ្លួនជនត្រូវចោទទៅឱ្យតុលាការ

តុលាការអាចបញ្ជូនសំណើដើម្បីសុំការចាប់ខ្លួន ឬសុំការប្រគល់ខ្លួនជនណាមួយដោយអមជាមួយនូវឯកសារគាំទ្រសំណើដែលបានបញ្ជាក់ ទៅរដ្ឋណាមួយដែលជននោះត្រូវបានគេរកឃើញលើទឹកដី នៃរដ្ឋនោះ សំណើសុំការចាប់ និងប្រគល់ខ្លួន ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ។

#### ១.២.៣.១.លក្ខខណ្ឌក្នុងការស្នើ

នៅក្នុងករណីសំណើសុំការចាប់ខ្លួន ឬប្រគល់ខ្លួនជនណាម្នាក់ដែលត្រូវបាន អង្គមុនជំនុំជម្រះ ចេញដីកា ចាប់ខ្លួនត្រូវធ្វើឡើងដោយ ៖

- ព័ត៌មានដែលពណ៌នាអំពីជនដែលត្រូវស្វែងរកនោះ ដែលមានលក្ខណៈគ្រប់គ្រាន់ដើម្បីកំណត់អត្តសញ្ញាណជននោះ និងព័ត៌មានស្តីអំពីទីកន្លែងដែលជននោះអាចស្នាក់នៅ
- ដីកាចាប់ខ្លួនមួយច្បាប់
- ឯកសារសេចក្តីថ្លែងការណ៍ ឬព័ត៌មានទាំងឡាយ ដែលអាចមានសារៈសំខាន់ចាំបាច់ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវផ្សេងៗសម្រាប់ដំណើរការប្រគល់ខ្លួននៅក្នុងរដ្ឋទទួលសំណើ លើកលែងតែលក្ខខណ្ឌតម្រូវទាំងអស់នោះមិន ដាក់បន្ទុកកាន់តែធ្ងន់លើសពីលក្ខខណ្ឌតម្រូវទាំងឡាយ ដែលត្រូវអនុវត្តលើសំណើសុំការធ្វើបត្យាប័ន ដោយស្របតាមសន្ធិសញ្ញា ឬការចាត់ចែងរវាងរដ្ឋទទួលសំណើ និងរដ្ឋដទៃ

[107] មាត្រា ៩១ (១),(២) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ,ចូលមើលថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

ផ្សេងទៀត និងបើសិនអាចធ្វើទៅបានលក្ខខណ្ឌតម្រូវគួរតែមានបន្ទុកស្រាលជាង ដោយពិចារណាលើប្រភេទដោយឡែកនៃតុលាការ។

ហើយសំណើដែលតុលាការស្នើបញ្ជូននោះត្រូវមាន សេចក្តីថ្លែងការណ៍ជាសង្ខេបអំពីអង្គហេតុនៃរឿងក្តី និងអំពីចរិតលក្ខណៈនីត្យានុកូលនៃអង្គហេតុដីកាសុំការចាប់ខ្លួន និងដីកាប្រគល់ខ្លួនដែលអាចមានសារៈសំខាន់ចាំបាច់ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវផ្សេងៗ សម្រាប់ដំណើរការប្រគល់ខ្លួន។[108]

នៅក្នុងករណី សំណើសុំការចាប់ និងប្រគល់ខ្លួនជនណាមួយដែលត្រូវបានតុលាការសម្រេចថាមានពិរុទ្ធភាពរួចទៅហើយ សំណើនោះត្រូវតែមានការគាំទ្រដោយ ៖

- ដីកាដែលសុំការចាប់ខ្លួនជននោះ
- សាលក្រមសម្រេចថាមានពិរុទ្ធភាព
- ព័ត៌មានដែលបញ្ជាក់ថា ជនដែលត្រូវស្វែងរកនោះ គឺជាជនដែលសាលក្រមសម្រេច មានពិរុទ្ធភាព នោះសំដៅលើ និងសាលក្រមប្រកាសទោស ចំនួនមួយច្បាប់ តែបើសិនជនដែលត្រូវស្វែងរកនោះ បាននិងកំពុងជាប់ទោស ហើយក្នុងករណីជាប់ទោសពន្ធនាគារ លិខិតបញ្ជាក់អំពីរយៈពេលបានជាប់ឃុំរួចហើយ និងរយៈពេលជាប់ឃុំដែលនៅសល់។

ក្រោយពីមានការស្នើសុំដោយរដ្ឋភាគីត្រូវតែពិគ្រោះយោបល់ជាមួយតុលាការ អំពីបញ្ហាទូទៅ ឬបញ្ហាពិសេស ដែលទាក់ទងនឹងលក្ខខណ្ឌតម្រូវណាមួយក្រោមបទប្បញ្ញត្តិនៃច្បាប់ជាតិនៃប្រទេសរបស់ខ្លួន។ ក្នុងកំឡុងពេលពិគ្រោះយោបល់ រដ្ឋភាគីត្រូវតែផ្តល់យោបល់ដល់តុលាការ អំពីលក្ខខណ្ឌ តម្រូវណាមួយដោយច្បាប់ប្រទេសខ្លួន។[109]

## ២.វត្តមានរបស់ជនត្រូវចោទ

បន្ទាប់ពីការបង្ហាញខ្លួនរបស់ជនត្រូវចោទតុលាការនឹងធ្វើការកំណត់នូវពេលវេលា ភាសាដែលត្រូវប្រើប្រាស់ និងការពិចារណាលើសិទ្ធស្នើរបស់ជនសង្ស័យ  និងកាលបរិច្ឆេទនៃសវនាការបញ្ជាក់ពីការចោទប្រកាន់។ ការកំណត់កាលបរិច្ឆេទក្នុងការចោទប្រកាន់ ហើយតុលាការ និងសម្រេចបើកដំណើរការនៃការបញ្ជាក់ពីការចោទដោយចាប់ផ្តើមការពិនិត្យឡើងវិញនៃកំណត់ត្រា ឬពិនិត្យភស្តុតាង លើករណីនោះ ព្រមទាំងបានកំណត់ពេល

[108] មាត្រា ៩១ (១),(២) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ,ចូលមើលថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[109] មាត្រា ៩១ (៣) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ,ចូលមើលថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

វេលាសម្រាប់ការឆ្លើយតប មកវិញក្រោមបទប្បញ្ញត្តិ ២៤ នៃវិធាននៃនីតិវិធី និងភស្តុតាង ត្រង់ចំណុចនេះ តុលាការ និងធ្វើទំនាក់ទំនងក្រៅផ្លូវការជាមួយភាគី និងក្រឡាបញ្ជីដើម្បីសម្រួលដល់នីតិវិធី និងធ្វើការរៀបចំ ឬការបញ្ជូនបញ្ហាជាក់លាក់ណាមួយ មិនតែប៉ុណ្ណោះ ចៅក្រមបានយល់ព្រមបង្កើតក្រុមការងារមួយដើម្បីសម្រួលដល់ការអនុវត្តដំណើរការនីតិវិធីទាក់ទង និងទម្រង់បែបបទនៃការស្នើសុំរបស់ជនរងគ្រោះសម្រាប់ការចូលរួមក្នុងដំណើរការនីតិវិធីតុលាការ និងបើកសន្និសីទស្តីពីស្ថានភាពដោយផ្ទាល់មាត់ និងធ្វើការបំភ្លឺអំពីការប្រព្រឹត្តនៃដំណើរការនីតិវិធីហើយអាច និងត្រូវបានផ្តល់ជូនភាគីក្នុងអំឡុងពេលសន្និសីទ។ ពេលការបំភ្លឺបានបញ្ចប់ហើយ តុលាការនិងចាប់ផ្តើម ដំណើរនៃការ បង្ហាញភស្តុតាង និងការជជែកទៅកាន់អង្គមុនជំនុំជម្រះ។[110] ការបង្ហាញភស្តុតាងរវាងភាគីនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺជាទិដ្ឋភាពសំខាន់នៃដំណើរការច្បាប់ ដោយធានានូវតម្លាភាព និងយុត្តិធម៌ក្នុងដំណើរការនីតិវិធី ដែលការលាតត្រដាងអំពីភាពពាក់ព័ន្ធ និងការចែករំលែកភស្តុតាងរវាងរដ្ឋអាជ្ញានិងមេធាវីការពារក្តី ដែលអនុញ្ញាតឱ្យភាគីទាំងពីរអាចចូលមើល និងពិនិត្យព័ត៌មានដែលពាក់ព័ន្ធ ឬកែសម្រួល ពីឯកសារដែលបានបង្ហាញ ដើម្បីការពារព័ត៌មានដែលបានស៊ើប ឬបុគ្គលដែលពាក់ព័ន្ធក្នុងដំណើរការផ្លូវច្បាប់។[111] ការលើកលែងទាំងនេះអនុញ្ញាតឱ្យមានការផ្លាស់ប្តូរឡើងវិញនូវព័ត៌មានកំណត់អត្តសញ្ញាណ ព័ត៌មានលម្អិតទំនាក់ទំនង និងទិន្នន័យរសើបផ្សេងទៀត ប្រសិនបើត្រូវបានបង្ហាញវាប៉ះពាល់ដល់សុវត្ថិភាព ឯកជនភាព ឬសុខុមាលភាពរបស់សាក្សី ជនរងគ្រោះ ឬបុគ្គលផ្សេងទៀតដែលពាក់ព័ន្ធ និងករណីនេះ។

## ៣.ការបញ្ជាក់អំពីការចោទប្រកាន់

ក្នុងដំណើរការនៃដំណាក់កាលនេះ អង្គមុនជំនុំជម្រះធ្វើការកំណត់នៅវិសាលភាព នៃការជជែកវែកញែក ទាក់ទងនឹងភស្តុតាងដែលបានបង្ហាញទៅកាន់អង្គមុនជំនុំជម្រះក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលមានសារៈសំខាន់សម្រាប់បញ្ជាក់ការចោទប្រកាន់។ នៅពេលសវនាការ រដ្ឋអាជ្ញាត្រូវគាំទ្របទចោទប្រកាន់នីមួយៗ ដោយមានការបង្ហាញភស្តុតាងយ៉ាងគ្រប់គ្រាន់ ដើម្បីបង្កើតជាមូលហេតុសំខាន់ៗ ដើម្បីឱ្យជឿថា ជននោះបានប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់នោះពិតមែន។ ចំពោះជនត្រូវចោទ អាចជំទាស់ទៅនឹងបទចោទប្រកាន់ប្រជែងតវ៉ាអំពីភស្តុតាងដែលបានបង្ហាញដោយរដ្ឋអាជ្ញា និងបង្ហាញភស្តុតាងរបស់ខ្លួន។ បន្ទាប់មក ប្រសិនបើអង្គមុនជំនុំជម្រះសន្និដ្ឋានថា មានភស្តុតាងដែលបានបង្ហាញនោះមិនគ្រប់គ្រាន់ ក្នុងការជឿថាជននោះបានប្រព្រឹត្តបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នោះ ការចោទប្រកាន់ត្រូវច្រានចោល និងដោះលែងបុគ្គលម្នាក់

[110] សៀវភៅណែនាំអំពីការអនុវត្តមុនជំនុំជម្រះ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ចូលមើលថ្ងៃ ២៧ ខែ៥ ឆ្នាំ២០២៤ https://www.icc-cpi.int/sites/default/files/iccdocs/other/Pre-Trial_practice_manual_(September_2015).pdf

[111] វិធាននៃនីតិវិធី និងភស្តុតាង ជំពូកទី ៤ ផ្នែកទី ២ ច្បាប់ ៧៧ ការត្រួតពិនិត្យធាតុផ្សំរបស់ រដ្ឋអាជ្ញា,ចូលមើលថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២៤ https://www.icc-cpi.int/sites/default/files/Publications/Rules-of-Procedure-and-Evidence.pdf

នោះ ឬផ្អាកសវនាការ ដើម្បីស្នើសុំឱ្យរដ្ឋអាជ្ញាប្រមូលភស្តុតាងបន្ថែមថ្មី ឬផ្លាស់ប្តូរចំពោះការចោទប្រកាន់ជាមួយ និងភស្តុតាងដែលបានបង្ហាញ។ ក្នុងករណីដែលភស្តុតាងនោះមិនត្រូវបានបំពេញតាមបទល្មើសដែលត្រូវបានចោទប្រកាន់ទេ អង្គមុនជំនុំជម្រះអាចនឹងបដិសេធមិនបញ្ជាក់ពីការចោទប្រកាន់នោះ ឬពន្យារពេលសវនាការ ហើយស្នើឱ្យរដ្ឋអាជ្ញាផ្តល់ភស្តុតាងបន្ថែមថ្មី ឬកែប្រែការចោទប្រកាន់ប្រសិនបើភស្តុតាងបង្ហាញពីការខុសគ្នា ឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់តុលាការត្រូវបានប្រព្រឹត្ត។[112]

## ៣.១.ការជំទាស់ការចោទប្រកាន់

ការជំទាស់ទៅនឹងការចោទប្រកាន់នៅពេលដែលរដ្ឋអាជ្ញាបានកំណត់អត្តសញ្ញាណរបស់ ជនត្រូវចោទ ដែលនិងត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងស្ថានភាពដែលបានបញ្ជូននោះ រដ្ឋ ឬជនត្រូវចោទអាចចាប់ផ្តើមការតតាំង និងការចោទប្រកាន់ទាក់ទងនឹងបុគ្គលនោះ  ដោយតុលាការក៏អាចធ្វើការវិភាគលទ្ធភាពទទួលយកបានលើអ្វីដែលបានចោទប្រកាន់ដែលផ្អែកលើមូលដ្ឋាន នៃសវនាការ អង្គមុនជំនុំជម្រះបដិសេធមិនបញ្ជាក់អំពីបទចោទប្រកាន់ទាំងឡាយនោះ ដែលទាក់ទងនឹងអ្វីដែលខ្លួនបានកំណត់ថា គ្មានភស្តុតាងគ្រប់គ្រាន់ទេ ឬផ្អាកការធ្វើសវនាការ និងស្នើសុំរដ្ឋអាជ្ញាឱ្យពិចារណាក្នុងការផ្តល់ភស្តុតាងបន្ថែម ឬធ្វើការស៊ើបអង្កេតបន្ថែមទៀត លើបទចោទប្រកាន់ជាក់លាក់មួយ អាចកែប្រែបទចោទប្រកាន់ណាមួយ ដោយហេតុថាភស្តុតាងដែលបានដាក់ជូន បង្ហាញថាមានលេចឡើង នូវបទល្មើសព្រហ្មទណ្ឌផ្សេងមួយទៀត ដែលស្ថិតក្នុងវង្វង់យុត្តាធិការរបស់តុលាការ។[113] ជាទូទៅភាពដែលអាចទទួលយកបាន អាចធ្វើការជំទាស់បានតែម្តងគត់ លុះត្រាតែមាន "កាលៈទេសៈពិសេស"។ [114] កាលៈទេសៈពិសេស ដែលបង្ហាញថាមានតុលាការ ផ្សេងដែលកំពុងអនុវត្តលើករណីនេះ បើមិនមានការស៊ើបអង្កេតក្នុងស្រុក ឬការកាត់ទោសលើបញ្ហាដែលកំពុងស្ថិតក្រោមការពិចារណាទេនោះ សំណុំរឿងត្រូវបានចាត់ទុកថាអាចទទួលយកបាន និងអាចដំណើរការនីតិវិធីបន្តទៀត។ ប៉ុន្តែជាក់ស្តែង បើផ្អែកលើភាពអសកម្មនៅកម្រិតក្នុងស្រុក នៅពេលតុលាការពិចារណាអំពីលទ្ធភាពទទួលយកបាននៃការកាត់ទោសនោះ  ប្រសិនបើមានការស៊ើបអង្កេតក្នុងស្រុក ឬការកាត់ទោសនោះរដ្ឋត្រូវតែបង្ហាញថាតើដំណើរការក្នុងស្រុកទាំងនោះ រួមបញ្ចូលបុគ្គលដូចគ្នា និងការប្រព្រឹត្តដូចគ្នាដែលជាកម្មវត្ថុនៃសំណុំរឿងរបស់រដ្ឋអាជ្ញាដែរឬទេ។ ប្រសិនបើដំណើរការក្នុងប្រទេសបំពេញតាមស្តង់ដានៃការប្រព្រឹត្តដូចគ្នា និងសកម្មភាពបុគ្គល

---

[112] មាត្រា ៦១ (៥),(៧) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ,ចូលមើលថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[113] មាត្រា ៦១ (៦)  នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ,ចូលមើលថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[114] មាត្រា ៥៨  នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ,ចូលមើលថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០២៤

ដូចគ្នា នោះតុលាការនិងវាយតម្លៃពីភាពពិតប្រាកដនៃការស៊ើបអង្កេត ឬការកាត់ទោសដោយ រដ្ឋអាជ្ញាត្រូវពិចារណាលើលទ្ធភាពបីក្នុងការវាយតម្លៃពីភាពពិតប្រាកដនៃការស៊ើបអង្កេត ឬការកាត់ទោស៖

- ដំណើរការថ្នាក់ជាតិត្រូវបានអនុវត្តន៍ដោយមានចេតនាការពារបុគ្គលពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើង។
- ដំណើរការថ្នាក់ជាតិត្រូវបានពន្យារពេលក្នុងលក្ខណៈដែលមិនស៊ីសង្វាក់គ្នាជាមួយនិងចេតនានាំបុគ្គលដែលពាក់ព័ន្ធមករកយុត្តិធម៌។
- ដំណើរការនីតិវិធីមិនត្រូវបានធ្វើឡើងដោយឯករាជ្យ ឬមិនលំអៀង បើមិនដូច្នេះទេក្នុងលក្ខណៈដែលស្របជាមួយ និងចេតនានាំបុគ្គលនោះមកកាត់ទោស។ កត្តាទាំងនេះត្រូវបានពិភាក្សានៅក្នុងព័ត៌មានលម្អិតខាងលើទាក់ទង និងការវិភាគលទ្ធភាពក្នុងដំណាក់កាលពិនិត្យបឋម។[115]

### ៣.១.១.ករណីសិក្សា (ប្រទេសកូតឌីវ័រ)

ករណីក្នុងការបញ្ជាក់អំពីការចោទប្រកាន់លើលោក LaurentGbagbo ជាអតីតប្រធានាធិបតីនៃប្រទេសកូតឌីវ័រ ដែលបម្រើការពីឆ្នាំ ២០០០ ដល់២០១១ បន្ទាប់ពីចាញ់ការបោះឆ្នោតប្រធានាធិបតីឆ្នាំ ២០១០ ជាមួយលោក Alassane Ouattara លោកGbagbo បានបដិសេធមិនចុះចេញពីតំណែង ដែលនាំឱ្យមានវិបត្តិនយោបាយ និងសង្គ្រាមស៊ីវិលជាថ្មីនៅប្រទេសកូតឌីវ័រ។ តុលាការព្រហ្មទណ្ឌអន្តរជាតិ បានចោទប្រកាន់លោក Gbagbo ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពាក់ព័ន្ធ និងអំពើហិង្សាក្រោយការបោះឆ្នោតក្នុងឆ្នាំ ២០១០ និង ២០១១ ដែលបានសម្លាប់មនុស្សជាង ៣០០០នាក់។ ក្នុងឆ្នាំ២០១១ លោក Gbagbo ត្រូវបានចាប់ខ្លួនដោយកងកម្លាំងស្មោះត្រង់និងOuattara ដែលគាំទ្រដោយទាហានបារាំង និងអង្គការសហប្រជាជាតិ ហើយត្រូវបានផ្ទេរទៅ តុលាការព្រហ្មទណ្ឌអន្តរជាតិ នៅទីក្រុងឡាអេដើម្បីធ្វើការកាត់ក្តី។ ប៉ុន្តែករណីនេះត្រូវបានពន្យារពេលក្នុងការបញ្ជាក់បទចោទប្រកាន់កាលពីខែកុម្ភៈ ឆ្នាំ២០១៣ បន្ទាប់ពីបញ្ជាក់ពីសវនាការលើការចោទប្រកាន់នេះត្រូវបានជំទាស់ ថាលោកមិនទទួលស្គាល់អ្វីដែលបានចោទប្រកាន់ទេ។[116]អង្គមុនជំនុំជម្រះបានសម្រេចក្នុងខែមិថុនា ឆ្នាំ២០១៣ ថាមានភស្តុតាងមិនគ្រប់គ្រាន់ដើម្បី បញ្ជាក់ការចោទប្រកាន់លើលោក Gbagbo។ អាស្រ័យ

[115] មាត្រា ១៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ,ចូលមើលថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[116] គេហទំព័រព័ត៌មានបារាំង ២៤ អំពីការជំទាស់ការចោទប្រកាន់ LaurentGbagbo ,ចូលមើលថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០២៤ https://www.france24.com/en/

ហេតុនេះ អង្គមុនជំនុំជម្រះបានប្រាប់ឱ្យរដ្ឋអាជ្ញាត្រូវបន្តការស៊ើបអង្កេត ដើម្បីធ្វើការផ្តល់ភស្តុតាងថ្មីបន្ថែមទាក់ទងទៅនឹងងការចោទប្រកាន់ទាំងអស់ដែលផ្តល់ពីភាពសមហេតុផលចំពោះការចោទប្រកាន់ទាំងនោះ។[117]

ទោះជាយ៉ាងណា ប្រសិនបើអង្គមុនជំនុំជម្រះសម្រេចថាភស្តុតាងទាំងនោះត្រូវបានបំពេញយ៉ាងត្រឹមត្រូវតាមអ្វីដែលបានកំណត់ក្នុងច្បាប់ហើយនោះ អង្គមុនជំនុំជម្រះអាចសម្រេចចិត្តក្នុងការផ្ទេរសំណុំរឿងទាំងនោះពីដំណាក់កាលអង្គមុនជំនុំជម្រះនេះទៅកាន់ សវនាការជំនុំជម្រះដំបូងដើម្បីធ្វើការកាត់ក្តីលើករណីនោះ។

## ផ្នែកទី៤៖ ដំណាក់កាលការជំនុំជម្រះ

ក្នុងដំណាក់កាលជំនុំជម្រះតុលាការព្រហ្មទណ្ឌអន្តរជាតិបានធ្វើការបន្តចេញទៅជា ពីរផ្នែកដែលគេឃើញមានដូចជា ផ្នែកជំនុំជម្រះដំបូង និងផ្នែកជំនុំជម្រះឧទ្ធរណ៍ ដែលបានកំណត់យ៉ាងច្បាស់លាស់នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ។

## កថាខណ្ឌទី១៖ ផ្នែកជំនុំជម្រះដំបូង

ក្រោយពីការបញ្ជាក់អំពីបទចោទលើបុគ្គលដែលប្រព្រឹត្តនោះហើយ ធិបតីប្រធាន នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ និងបង្កើតអង្គជំនុំជម្រះដំបូងសម្រាប់ ដំណើរការក្នុងសំណុំរឿងនោះ ព្រមទាំងលើកនូវវិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការ មកពិគ្រោះយោបល់សម្រាប់ការយល់ដឹងលម្អិតបន្ថែមទៀតអំពីរបៀបដែលដំណើរការសវនាការត្រូវបានធ្វើឡើង។[118]

### ១.ទីតាំងសម្រាប់ជំនុំជម្រះ

ការកាត់ក្តីជាធម្មតា និងប្រព្រឹត្តទៅនៅទីក្រុងឡាអេ ប្រទេសហូឡង់ ទោះបីជាតុលាការបាន ពិចារណាលើករណីសវនាការនៅកន្លែងផ្សេងទៀត ដើម្បីនៅជិតកន្លែងរបស់ជនរងគ្រោះ សាក្សី និងភស្តុតាងក៏ដោយ។[119] យ៉ាងណាមិញរដ្ឋអាជ្ញា ឬមេធាវីការពារក្តី ព្រមទាំងចៅក្រមភាគច្រើននៃតុលាការអាចដាក់ពាក្យស្នើសុំ ឬផ្តល់អនុសាសន៍ផ្លាស់ប្តូរទីកន្លែងដែលតុលាការកាត់ក្តីបាន ដូចគ្នានេះធិបតីប្រធាន នៃតុលាការត្រូវពិគ្រោះជាមួយរដ្ឋដែលតុលាការមានបំណងសម្រាប់បើកការជំនុំជម្រះ ប្រសិនបើរដ្ឋនោះយល់ព្រមថាតុលាការអាចបើកការកាត់ក្តី

[117] របាយការណ៍ទាក់ទងនឹងស្ថានភាពប្រទេសកូតឌីវ័រ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ https://www.icc-cpi.int/sites/default/files/CaseInformationSheets/gbagbo-goudeEng.pdf

[118] មាត្រា ៦១ (១១) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[119] មាត្រា ៦២ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ៨ ខែឧសភា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

នៅក្នុងរដ្ឋនោះ ការសម្រេចចិត្តកាត់ក្តី នៅក្នុងរដ្ឋមួយក្រៅពីរដ្ឋម្ចាស់ផ្ទះ ចៅក្រមត្រូវយកមកប្រជុំពេញអង្គ ដោយសំឡេងភាគច្រើនពីរភាគបី តែមកទល់ពេលនេះ ការកាត់ក្តី ទាំងអស់របស់តុលាការបានកើតឡើង ស្ថិតនៅក្នុងឯទីក្រុងឡាអេតែប៉ុណ្ណោះ។ លើសពីនេះរដ្ឋអាជ្ញា និងមេធាវីការពារក្តី ក៏អាចស្នើសុំសម្រេចលើបញ្ហាណាមួយដែលទាក់ទងនឹងការប្រព្រឹត្តទៅនៃដំណើរការនីតិវិធី សំណើណាមួយពីរដ្ឋអាជ្ញា ឬមេធាវីការពារក្តី ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។

### ១.១.វត្តមានជនជាប់ចោទ

ដំណើរការនៃការជម្រះក្តី របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ តម្រូវឱ្យមានវត្តមានរបស់ជនជាប់ចោទក្នុងអំឡុងពេលដំណើរការនៃសវនាការនោះ។ ក៏ប៉ុន្តែទោះជាយ៉ាងណា ដំណើរការកាត់ក្តីមួយអាចប្រព្រឹត្តិទៅដោយអវត្តមាននៃជនជាប់ចោទបាន ប្រសិនបើវត្តមានរបស់ជាប់ចោទ នៅចំពោះមុខតុលាការបានរំខានដល់ប្រព្រឹត្តទៅនៃសវនាការនោះ អង្គជំនុំជម្រះអាចដកជនជាប់ចោទចេញដើម្បីសម្រួលដល់ការកាត់ក្តី យ៉ាងណាក៏ដោយ អង្គជំនុំជម្រះត្រូវបានអនុញ្ញាតឱ្យមានវត្តមានតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាវីដេអូក្នុងអំឡុងពេលផ្នែកណាមួយ នៃការសាកល្បងរបស់ជនជាប់ចោទ។[120]

យ៉ាងណាមិញ ការកាត់ក្តីជាធម្មតាធ្វើឡើងនៅទីសាធារណៈ ប៉ុន្តែផ្នែកខ្លះនៃដំណើរការនីតិវិធីអាចត្រូវបានរក្សាទុកនៅក្នុងកំណត់ត្រាដើម្បីការពារជនរងគ្រោះឬសាក្សី ឬដើម្បីការពារព័ត៌មានសម្ងាត់ ឬព័ត៌មានស៊ើបដែលនឹងត្រូវបានបង្ហាញជាភស្តុតាង។[121]

### ១.២.ឯកសារពាក់ព័ន្ធ និងការជំនុំជម្រះ

ក្នុងការរក្សាឯកសារ ការិយាល័យក្រឡាបញ្ជី ត្រូវចាត់វិធានការដើម្បីធ្វើឱ្យការរក្សាកំណត់ត្រានោះបានពេញលេញ និងត្រឹមត្រូវនៃដំណើរការទាំងអស់ រួមទាំងប្រតិចារឹក (ឯកសារពាក់ព័ន្ធរឿងក្តី ឬដំណើរការកាត់ក្តី) ការថតសំឡេង និងវីដេអូ និងមធ្យោបាយផ្សេងទៀតនៃការចាប់យកសំឡេង ឬរូបភាព។ អង្គជំនុំជម្រះអាចបញ្ជាឱ្យលាតត្រដាងនូវរាល់ ឬផ្នែកនៃកំណត់ត្រានៃកិច្ចដំណើរការនីតិវិធីជាសម្ងាត់ នៅពេលដែលមានហេតុផលសម្រាប់ការមិនបង្ហាញព័ត៌មាន។[122] លើសពីនេះ អង្គជំនុំជម្រះអាចអនុញ្ញាតឱ្យបុគ្គលក្រៅពីក្រឡាបញ្ជី ថតរូប

[120] វិធាននៃនីតិវិធី និងភស្តុតាង ជំពូកទី ៦ ផ្នែកទី ៦ ច្បាប់ ១៣៤ ,ចូលមើលថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២៤ https://www.icc-cpi.int/sites/default/files/Publications/Rules-of-Procedure-and-Evidence.pdf

[121] មាត្រា ៦៧,៦៨ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[122] មាត្រា ៦២ (១០) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

សំឡេង ឬវីដេអូព្រមទាំងមធ្យោបាយផ្សេងទៀតក្នុងការចាប់យកសំឡេង រូបភាពនៃដំណើរការ ពិសេសបញ្ហាទាំងឡាយណាដែលសំខាន់ នៅចំពោះមុខអង្គជំនុំជម្រះអាច និងត្រូវបានស្តាប់នៅដោយមុខអង្គជំនុំជម្រះ។ [123]

## ២.សមត្ថកិច្ចរបស់អង្គជំនុំជម្រះ

មុខងារ និងអំណាចរបស់អង្គជំនុំជម្រះដំបូងនេះ ត្រូវតែអនុវត្តស្របទៅតាមលក្ខន្តិកៈដែលជាច្បាប់គោលរបស់តុលាការ ព្រមទាំងវិធាននៃនីតិវិធី និងភស្តុតាង អង្គជំនុំជម្រះត្រូវធានាថាការកាត់ក្តីមានភាពយុត្តិធម៌ និងឆាប់រហ័ស ហើយត្រូវបានធ្វើឡើងដោយការគោរពពេញលេញចំពោះសិទ្ធិរបស់ជនជាប់ចោទ និងដោយយកចិត្តទុកដាក់ចំពោះការការពារជនរងគ្រោះ និងសាក្សី។ ត្រង់ចំណុចនេះបានផ្តល់ឱ្យអង្គជំនុំជម្រះនូវកាតព្វកិច្ចធានាដល់គុណភាពនៃការជំនុំជម្រះ និងណែនាំអង្គជំនុំជម្រះសាលាដំបូងនេះឱ្យធានានូវការគោរពពេញលេញចំពោះសិទ្ធិរបស់ជនជាប់ចោទ និងការគោរពយ៉ាងត្រឹមត្រូវលើការការពារជនរងគ្រោះ និងសាក្សី។[124] ការពិភាក្សាជាមួយភាគី និងអនុម័តនីតិវិធីដែលចាំបាច់ ដើម្បីជួយសម្រួលដល់ដំណើរការនីតិវិធីដោយយុត្តិធម៌ និងឆាប់រហ័ស ការកំណត់នៅភាសាដែលប្រើប្រាស់មួយ ឬច្រើនដែលត្រូវប្រើក្នុងពេលជំនុំជម្រះ និងការបង្ហាញនូវឯកសារ ឬព័ត៌មាន ដែលមិនត្រូវបានបង្ហាញពីមុនមក ឱ្យបានគ្រប់គ្រាន់មុនការចាប់ផ្តើមការជំនុំជម្រះដើម្បីជួយឱ្យការរៀបចំនេះ បានគ្រប់គ្រាន់សម្រាប់ជំនុំជម្រះ ដូច្នេះវាជាកាតព្វកិច្ចរបស់អង្គជំនុំជម្រះដំបូង តែបើសិនមិនពិនិត្យទេ តុលាការត្រូវមើលថាមានអ្វីមួយពិតប្រាកដ ដែលបានបង្ហាញក្នុងដំណាក់កាលមុនជំនុំជម្រះ និងអាចទទួលយកបាន ដើម្បីអនុម័ត។ លើសពីនេះប្រសិនបើចាំបាច់ ដើម្បីឱ្យដំណើរការរបស់ខ្លួនមានប្រសិទ្ធភាព និងមានយុត្តិធម៌ ក្នុងដំណើរជំនុំជម្រះ អង្គជំនុំជម្រះដំបូងអាចបញ្ជូនបញ្ហាពិនិត្យបឋមត្រឡប់ទៅអង្គមុនជំនុំជម្រះវិញ ឬទៅចៅក្រមផ្សេងទៀតនៅក្នុងផ្នែកមុនជំនុំជម្រះ។[125] ការសម្រេចចិត្តរបស់អង្គជំនុំជម្រះដំបូង ក្នុងការបញ្ជូនបញ្ហាបឋមទៅអង្គមុនជំនុំជម្រះ គឺស្ថិតក្រោមលក្ខខណ្ឌថា "ចាំបាច់សម្រាប់ដំណើរការប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌" នៃអង្គជំនុំជម្រះ។[126] ចំពោះអង្គជំនុំជម្រះដំបូងអាចសម្រេច លើការកាត់ក្តីណាមួយដោយស្របក្នុងកាត់ក្តីរួមគ្នា ឬដាច់ដោយឡែកពីគ្នាទាក់ទងទៅនឹងសំណុំរឿងមានជនជាប់ចោទលើសពីម្នាក់។

---

[123] មាត្រា ៦១ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[124] មាត្រា ៦៣ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[125] មាត្រា ៦៤ (៤) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[126] សន្និសីទការទូតរបស់អង្គការសហប្រជាជាតិ នៃអ្នកតំណាងពេញសមត្ថភាពលើការបង្កើតរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ចំណុចទី ៤,ចូលមើលថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២៤ https://www.legal-tools.org/doc/2c77c2/pdf/

ហេតុផលនៅពីក្រោយច្បាប់នេះគឺជាផលប្រយោជន៍នៃយុត្តិធម៌អាចតម្រូវឱ្យអ្នកពាក់ព័ន្ធក្នុងអំពើឧក្រិដ្ឋកម្មតែមួយ និងដូចគ្នាគួរតែត្រូវបានកាត់ទោសក្នុងពេលតែមួយ ដើម្បីជៀសវាងភាពមិនស៊ីសង្វាក់គ្នា និងភាពផ្ទុយគ្នា។ ពាក់ព័ន្ធជនជាប់ចោទរួមនឹងត្រូវកាត់ទោសរួមគ្នា លុះត្រាតែអង្គជំនុំជម្រះដំបូង ចេញនូវសេចក្តីសម្រេចដោយខ្លួនផ្ទាល់ ឬតាមសំណើរបស់រដ្ឋអាជ្ញា ឬមេធាវីការពារក្តី។ ការកាត់ក្តីរួមនេះធ្វើឡើងអាចត្រូវបានធានាក្នុងគោលបំណងបីដូចខាងក្រោមៈ

- ដើម្បីជៀសវាងការរើសអើងធ្ងន់ធ្ងរដល់ជនជាប់ចោទ
- ដើម្បីការពារផលប្រយោជន៍នៃយុត្តិធម៌
- ដោយជនជាប់ចោទរួមបានសារភាពកំហុស ហើយអាចបន្តចាត់ការតាមមាត្រា ៦៥ កថាខណ្ឌ ២។[127]

ក្នុងការបំពេញមុខងាររបស់ខ្លួនមុនការកាត់ក្តី ឬអំឡុងពេលសវនាការ អង្គជំនុំជម្រះអាចតាមការចាំបាច់ អនុវត្តអំណាចរបស់អង្គជំនុំជម្រះដែលមានចែងក្នុងមាត្រា ៦៤(៦) អាចអនុវត្តមុខងារណាមួយរបស់អង្គមុនជំនុំជម្រះ ដូចជាចេញ ដីកាចាប់ខ្លួនជាដើម តម្រូវឱ្យមានអ្នកចូលរួម និងសក្ខីកម្មរបស់សាក្សី និងការទទួលយកឯកសារ ភស្តុតាងដទៃទៀត ដោយការទទួលជំនួយពីរដ្ឋ ប៉ុន្តែព័ត៌មានមួយចំនួន និងត្រូវបានរក្សាជាអាថ៌កំបាំង ដូចមានចែងក្នុងច្បាប់លក្ខន្តិកៈនេះ បើសិនជាមានការចាំបាច់។ លើសពីនេះក៏មានការស្វែងរកនៅភស្តុតាងបន្ថែមពីលើភស្តុតាងដែលបានប្រមូលរួចហើយកាលមុនពេលជំនុំជម្រះ ឬដែលបានបង្ហាញដោយភាគីទាំងឡាយនៅក្នុងអំឡុងពេលជំនុំជម្រះព្រមទាំងធ្វើការវិនិច្ឆ័យបញ្ហាដែលទាក់ទងផ្សេងៗ ដែលមានដូចជា ការការពារជនជាប់ចោទ សាក្សី និងជនរងគ្រោះ។

## កថាខណ្ឌទី២៖ ការបើកសវនាការជំនុំជម្រះ

### ១.ការធ្វើសេចក្តីថ្លែងការណ៍

ជំហានដំបូងនៃការកាត់ក្តីគឺអង្គជំនុំជម្រះដំបូង ត្រូវអានឱ្យឱ្យជនជាប់ចោទស្តាប់ នូវបទចោទប្រកាន់ដែល បានបញ្ជាក់ពីមុនមក ដោយអង្គមុនជំនុំជម្រះការធ្វើបែបនេះក៏ដើម្បីធានាឱ្យមានការបញ្ជាញព័ត៌មានត្រឹមត្រូវវាងភាគី ពិសេសជាងនេះទៀត គឺធានាដល់ដំណើរការនៃជំនុំជម្រះ។[128] សម្រាប់ការធ្វើសេចក្តីថ្លែងការណ៍នេះតុលាការត្រូវធ្វើឡើងដោយ បង្ហាញអំពីការគិតគូពីសិទ្ធរបស់ជនជាប់ចោទ ដែលពួកគេត្រូវបានទទួល

---

[127] វិធាននៃនីតិវិធី និងភស្តុតាង ជំពូកទី ៥ ផ្នែកទី ៦ ច្បាប់ ១៣៦ ការកាត់ក្តីរួម និងដោយឡែក,ចូលមើលថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០២៤https://www.icc-cpi.int/sites/default/files/Publications/Rules-of-Procedure-and-Evidence.pdf

[128] វិធាននៃនីតិវិធី និងភស្តុតាង ជំពូកទី ៥ ផ្នែកទី ៦ ច្បាប់ ១៣២ ,ចូលមើលថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤ https://www.icc-cpi.int/sites/default/files/Publications/Rules-of-Procedure-and-Evidence.pdf

ព័ត៌មានរហ័សទាន់ពេល និងព័ត៌មានពិស្តារអំពីប្រភេទមូលហេតុ និងខ្លឹមសារនៃការ ចោទប្រកាន់នៅក្នុងភាសាមួយដែលជនជាប់ចោទយល់ និងនិយាយបានយ៉ាងពេញលេញ។[129]

## ២.ការបង្ហាញភស្តុតាង

បន្ទាប់ពីធ្វើសេចក្តីថ្លែងការណ៍ហើយ រដ្ឋអាជ្ញា និងមេធាវី ឬអ្នកតំណាងជនជាប់ចោទ ក្នុងដំណាក់កាលនេះអាចដាក់ជូនភស្តុតាងដែលទាក់ទង និងករណីដែលបានកើតឡើង ស្របតាមមាត្រា ៦៤។ តុលាការត្រូវមាន អំណាចស្នើសុំឱ្យដាក់ជូននូវភស្តុតាងទាំងអស់ ដែលខ្លួនពិចារណាយល់ឃើញថាបើចាំបាច់ ដើម្បីធ្វើការកំណត់ព្រមទាំងស្វែងរកការពិត ឬភាពត្រឹមត្រូវ។ បន្ទាប់មកអង្គជំនុំជម្រះអាចចាប់ផ្តើមអនុញ្ញាតឱ្យរដ្ឋអាជ្ញាបង្ហាញភស្តុតាងរបស់ខ្លួន ដែលប្រមូលបានដើម្បីបញ្ជាក់អំពីកំហុសរបស់ជនជាប់ចោទលើសពីការសង្ស័យ និងហេតុផលផ្សេងៗ ក្នុងការគាំទ្រការចោទប្រកាន់របស់ខ្លួនក្នុងនាមរដ្ឋអាជ្ញា ក្រោយមកមេធាវីការពារក្តីត្រូវបានអនុញ្ញាតឱ្យធ្វើការបញ្ជាក់ពីភាពត្រឹមត្រូវ នូវអ្វីដែលបានលើកឡើងរបស់រដ្ឋអាជ្ញា ឬធ្វើការបដិសេធចំពោះការចោទប្រកាន់ពីរដ្ឋអាជ្ញា ព្រមទាំងភាពត្រឹមត្រូវនៃភស្តុតាង របស់រដ្ឋអាជ្ញាដែលបានលើកយកមកបង្ហាញ។[130] ស្របពេលជាមួយគ្នានោះដែរ បន្ទាប់ពីករណីរបស់រដ្ឋអាជ្ញាត្រូវបានបញ្ចប់ មេធាវីការពារក្តីអាចធ្វើការលើកឡើង ឬបង្ហាញភស្តុតាងផ្ទាល់ខ្លួនរបស់ពួកគេវិញម្តង ហើយបន្ទាប់មក រដ្ឋអាជ្ញា ត្រូវបានអនុញ្ញាតឱ្យធ្វើការសំអាងនូវភាពត្រឹមត្រូវ ចំពោះភស្តុតាងដែលមេធាវីបានលើកឡើងទាំងអស់នោះ។ យ៉ាងណាមិញ ភស្តុតាងដែលបានលើកឡើង រវាង រដ្ឋអាជ្ញា និងមេធាវីនឹងត្រូវបានតុលាការពិចារណា ព្រមទាំងពិនិត្យពីភាពត្រឹមត្រូវដែលអាចទទួលយកបាន។

### ២.១.ភស្តុតាង

ភាពត្រឹមត្រូវនៃភស្តុតាង ត្រូវបានកំណត់ តាមមធ្យោបាយដោយមិនអាចបំពានលើច្បាប់លក្ខន្តិកៈនេះ ភស្តុតាងដែលមាន ឬទទួលបានមកពីការបំពានលើសិទ្ធិមនុស្សទាំងឡាយ ដែលត្រូវបានទទួលស្គាល់ដោយច្បាប់ អន្តរជាតិមិនត្រូវអាចទទួលយកបានឡើយដូចជា៖

- ការបំពាននាំឱ្យមានវិមតិសង្ស័យជាដុំកំភួន លើភាពអាចយកជាការបានភស្តុតាង
- ការទទួលយកភស្តុតាង ទំនងជាប្រឆាំងដល់ និងទំនងជាបង្កព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់សុច្ចរិតភាព ព្រមទាំងដំណើរការជម្រះរឿងក្តី។

[129] មាត្រា ៦៧(១),(ក) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០២៤

[130] មាត្រា ៦១(៥),៦៧(១)(ង) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០២៤

តុលាការ អាចវិនិច្ឆ័យពីភាពមានទំនាក់ទំនង ឬភាពអាចទទួលយកបាននៃភស្តុតាងណាមួយ ដោយយកមកពិចារណា ក្នុងចំណោមតម្លៃផ្សេងៗទៀត នូវតម្លៃមានលក្ខខណ្ឌនៃភស្តុតាង និងអគតិធម៌ណាដែលបានបណ្តាលមកពីភស្តុតាង នោះ ចំពោះការជំនុំជម្រះប្រកបដោយយុត្តិធម៌ ឬដល់ការវាយតម្លៃដោយយុត្តិធម៌នៃសក្ខីកម្មរបស់សាក្សី ស្របតាមវិធាននៃនីតិវិធី និងភស្តុតាង។ នៅពេលធ្វើសេចក្តីសម្រេច អំពីភាពត្រឹមត្រូវដែលមានទំនាក់ទំនង ឬភាពដែលអាចទទួលយកបានភស្តុតាងដែលប្រមូលបាន ដោយរដ្ឋណាមួយ តុលាការមិនត្រូវវិនិច្ឆ័យផ្អែកលើការអនុវត្តនៃច្បាប់ជាតិរបស់រដ្ឋនោះទេ លើសពីនេះតុលាការត្រូវគោរព និងធ្វើការកត់សំគាល់ពីបុព្វសិទ្ធិនៃភាពអាថ៌កំបាំង ដូចមានចែងក្នុងវិធាននៃនីតិវិធី និងភស្តុតាង។[131] អង្គជំនុំជម្រះដំបូង ត្រូវធ្វើឱ្យប្រាកដថា កំណត់ហេតុពេញលេញមួយនៃការជំនុំជម្រះដែលឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ អំពីដំណើរការជម្រះរឿងក្តី ហើយកំណត់ហេតុនោះត្រូវបានរក្សាទុក និងអភិរក្សការពារទុកដោយក្រឡាបញ្ជី ជនរងគ្រោះត្រូវបានអនុញ្ញាតឱ្យផ្តល់សក្ខីកម្មនៅពេលជំនុំជម្រះ។

### ២.១.១.ការផ្តល់សក្ខីកម្មរបស់សាក្សី

ស្របតាមវិធាននៃនីតិវិធី និងភស្តុតាង មុនពេលផ្តល់សក្ខីកម្ម សាក្សីម្នាក់ៗត្រូវផ្តល់ការសន្យាចំពោះភាពពិតប្រាកដនៃភស្តុតាង ដែលត្រូវផ្តល់ឱ្យដោយសាក្សីនោះ។ សក្ខីកម្មរបស់សាក្សីក្នុងពេលជំនុំជម្រះ ត្រូវផ្តល់ដោយបុគ្គលផ្ទាល់ខ្លួន លើកលែងតែស្ថិតក្នុងកម្រិត វិសាលភាព ដែលមានចែងក្នុងវិធានការដែលបានកំណត់ក្នុង នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ។[132]

#### ២.១.១.១.លក្ខខណ្ឌក្នុងការផ្តល់សក្ខីកម្ម

តុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏អាចអនុញ្ញាតផងដែរ ឱ្យផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ ឬសក្ខីកម្មដែលបានថតទុករបស់សាក្សីណាម្នាក់ តាមមធ្យោបាយបច្ចេកវិទ្យា វិដេអូ ឬខ្សែអាត់ ព្រមទាំងការណែនាំបង្ហាញអំពីឯកសារផ្សេងៗ ឬលិខិតបញ្ជាក់ដោយជាលាយលក្ខណ៍អក្សរ ដែលជាកម្មវត្ថុនៃច្បាប់លក្ខន្តិកៈនេះ និងស្របទៅតាមវិធាននៃនីតិវិធី និងភស្តុតាង។ វិធានការទាំងនេះមិនត្រូវមានលក្ខណៈ អគតិធម៌ចំពោះ ឬមិនត្រូវមានលក្ខណៈមិនស្របជាមួយសិទ្ធិរបស់ជនជាប់ចោទឡើយ។

---

[131] មាត្រា ៦៩(៤),(៥),(៧) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[132]មាត្រា ៦៨ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

ភាគីទាំងឡាយ អាចដាក់ជូនភស្តុតាងដែលទាក់ទងនឹងករណីនេះ ស្របតាមមាត្រា ៦៤។ តុលាការត្រូវមានអំណាចស្នើសុំឱ្យដាក់ជូននូវភស្តុតាងទាំងអស់ ដែលខ្លួនពិចារណាយល់ឃើញថាចាំបាច់ដើម្បីធ្វើការកំណត់រកការពិត។ ការផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីដែលត្រូវបានហៅដោយ ការិយាល័យរដ្ឋអាជ្ញា ហើយក៏អាចផ្តល់សក្ខីកម្មដោយឯករាជ្យពី រដ្ឋអាជ្ញាផងដែរ។ តំណាងជនរងគ្រោះត្រូវបានអនុញ្ញាតឱ្យដាក់ភស្តុតាងដើម្បីធ្វើគាំទ្រ ឬដើម្បីបង្ហាញពីភាពមិនគួរឱ្យទុកចិត្ត នៃភស្តុតាងដែលបង្ហាញដោយ រដ្ឋអាជ្ញា និងមេធាវីការពារក្តី។ អ្នកតំណាងរបស់ជនរងគ្រោះក៏ត្រូវបានអនុញ្ញាតឱ្យធ្វើការអង្កេតជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ផងដែរ នៅពេលដែលអង្គជំនុំជម្រះដំបូងអនុញ្ញាត។[133]

### ២.១.១.២.អំពីព័ត៌មាន ឯកសាររបស់តតិយជន

បើសិនជា រដ្ឋភាគីត្រូវបានស្នើសុំ ដោយតុលាការឱ្យផ្តល់ឯកសារ ឬព័ត៌មានដែលខ្លួនមាននៅក្នុងដៃ ដែលស្ថិត ក្រោមការកាន់កាប់ ឬការត្រួតត្រារបស់ខ្លួន ដែលត្រូវបានបង្ហាញដល់ខ្លួនជាការសម្ងាត់ដោយរដ្ឋមួយ ដោយអង្គការអន្តររដ្ឋាភិបាលមួយ ឬដោយអង្គការអន្តរជាតិមួយ តុលាការត្រូវស្វែងរកការយល់ព្រមពីអ្នកប្រភពដើម ដើម្បីបង្ហាញឯកសារ ឬព័ត៌មាននោះ។ បើអ្នកប្រភពដើម ជារដ្ឋភាគីមួយ រដ្ឋនោះត្រូវមានការយល់ព្រមឱ្យបង្ហាញនូវព័ត៌មាន ឬឯកសារ និងទទួលខុសត្រូវលើការដោះស្រាយបញ្ហានៃការបង្ហាញព័ត៌មានដល់តុលាការ ដោយអនុលោមតាមបទប្បញ្ញត្តិ។[134] បើអ្នកប្រភពដើម មិនមែនជារដ្ឋភាគីទេ ហើយបដិសេធមិនយល់ព្រមឱ្យបង្ហាញទេនោះរដ្ឋដែលត្រូវបានស្នើសុំត្រូវផ្តល់ ដំណឹងដល់តុលាការថាខ្លួនមិនអាចផ្តល់នូវឯកសារដោយសារខ្លួនមានកាតព្វកិច្ចរក្សាអាថ៌កំបាំងឱ្យអ្នកប្រភពដើមជាមុនទៅហើយ។ ចំពោះអ្នកដែលបានផ្តល់នៅសក្ខីកម្ម មិនពិតទៅតុលាការដោយចេតនានោះនឹងត្រូវចាត់ទុកជាបទល្មើសដែលប្រឆាំងនឹងរដ្ឋបាលយុត្តិធម៌សម្រាប់សកម្មភាពបែបនេះ។[135]

នៅពេលដែលការកាត់ក្តីត្រូវបានបញ្ចប់អង្គជំនុំជម្រះ និងចាប់ផ្តើមចេតនាជាលក្ខណៈឯកជន ពោលគឺជា ឆន្ទានុសិទ្ធិ ហើយឈានដល់សាលក្រមមានទោស ឬមិនមានទោស។ ចេញសាលក្រមរបស់ខ្លួនជាមួយនឹងហេតុផលជាលាយលក្ខណ៍អក្សរ។

---

[133] មាត្រា ៦៩ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[134] មាត្រា ៧២ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ៣ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[135] មាត្រា ៧២ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ៣ ខែមិថុនា ឆ្នាំ២០២៤ https://www.measboralaws.com/free_document/222

## កថាខណ្ឌទី៣៖ ការសម្រេចសេចក្ដី របស់ចៅក្រម

### ១.វត្តមានរបស់ចៅក្រម

ជាទូទៅ សមាសភាពចៅក្រមទាំងអស់នៃអង្គជំនុំជម្រះត្រូវតែមានវត្តមាននៅដំណើរការលម្អិត នីមួយៗ នៃការជំនុំជម្រះ និងមានវត្តមានតាំងពីដើមដល់ចប់នៅក្នុងការពិភាក្សាដើម្បីធ្វើការសម្រេចរបស់ខ្លួនចំពោះជនជាប់ចោទ។ ដោយឈរលើគោលការណ៍ ទាំងនេះ ធិបតីប្រធាននៃតុលាការព្រហ្មទណ្ឌអន្តរជាតិ អាចចាត់ឱ្យចៅក្រម បំរុងម្នាក់ ឬច្រើននាក់តាមដែលមាន ឱ្យមានវត្តមាននៅក្នុងដំណាក់កាលនីមួយៗ នៃការជំនុំជម្រះ និងដើម្បីជំនួសសមាជិកម្នាក់ នៃអង្គជំនុំជម្រះប្រសិនបើសមាជិករូបណា មិនមានវត្តមាន ឬអាចបន្តការចូលរួមក្នុងការកាត់ក្តីបាន។ ទាំងអស់នេះដើម្បីឱ្យអង្គជំនុំជម្រះត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវនៅ ដំណាក់កាលនីមួយៗ នៃសវនាការ ហើយមានសមត្ថកិច្ចក្នុងការចេញសាលក្រមត្រឹមត្រូវ។[136]

### ២.នីតិវិធីក្នុងការសម្រេច

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះត្រូវផ្អែកលើការវាយតម្លៃរបស់ខ្លួន លើភស្តុតាង និងដំណើរការជម្រះរឿងក្តីទាំងមូល។ បែបនេះក៏បង្ហាញឱ្យឃើញនៅអន្តរកម្មគ្នា ក្នុងដំណាក់កាលមុនជំនុំជម្រះ ដំណាក់កាលជំនុំជម្រះដំបូង និងការជំនុំជម្រះជាន់ខ្ពស់ ដែលមានភាពពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធ ហើយដាក់កម្រិតលើវិសាលភាពអង្គហេតុដែលអាចទទួលយកបាន និងមូលដ្ឋានភស្តុតាងក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើការទទួលខុសត្រូវព្រហ្មទណ្ឌ ស្របពេលជាមួយគ្នាការពារស្វ័យភាពនៃសាលក្រមរបស់អង្គជំនុំជម្រះ។ ការការពារស្វ័យភាពនៃសេចក្តីសម្រេចអង្គជំនុំជម្រះ គឺចាំបាច់សម្រាប់ការធានាឯករាជ្យភាព យុត្តិធម៌ និងតម្លាភាពនៃដំណើរការធ្វើសេចក្តីសម្រេចរបស់ តុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏ដូចជាសម្រាប់ការលើកកម្ពស់សិទ្ធិមនុស្ស ការរក្សាកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការការពារជនរងគ្រោះនៃឧក្រិដ្ឋកម្មធ្ងន់ធ្ងរ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះត្រូវផ្អែកលើដំណើរការជម្រះរឿងក្តី ទាំងមូលបែបនេះក៏ដើម្បីកំណត់នូវទំនាក់ទំនងអ្វីដែលមានរវាងអង្គមុន ជំនុំជម្រះ និងអង្គជំនុំជម្រះដំបូង ដែលផ្តល់ភាពត្រួតស៊ីគ្នា និងត្រឹមត្រូវរវាងការសម្រេចចិត្តដើម្បីបញ្ជាក់ការចោទប្រកាន់ និងសម្រេចចិត្តចេញសាលក្រម។ ការត្រួតស៊ីគ្នាអាចកើតឡើងជាពិសេសក្នុងផ្នែកនៃការរកឃើញនៅលើ និងការវាយតម្លៃលើភស្តុតាងដែលពឹងផ្អែកលើសម្រាប់គោលបំណងបញ្ជាក់ការចោទប្រកាន់របស់អង្គមុនជំនុំជម្រះ និងជាផ្នែកនៃកំណត់ត្រាដែលបានបញ្ជូនទៅអង្គជំនុំជម្រះដំបូង។[137]

---

[136] មាត្រា ៧៤(១) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ៣ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[137] វិធាននៃនីតិវិធី និងភស្តុតាង ជំពូកទី ៥ ផ្នែកទី ៦ ច្បាប់ ១៣០ ការកាត់ក្តីរួម និងដោយឡែក,ចូលមើលថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០២៤https://www.icc-cpi.int/sites/default/files/Publications/Rules-of-Procedure-and-Evidence.pdf

### ២.១.ដែនកំណត់ក្នុងការសម្រេច

សេចក្ដីសម្រេច មិនត្រូវធ្វើឱ្យហួសពីអង្គហេតុ និងកាលៈទេសៈដែលបានពណ៌នានៅក្នុងបទចោទប្រកាន់ និងក្នុងការកែប្រែបទចោទប្រកាន់ណាមួយ។ តុលាការ អាចផ្អែកលើសេចក្ដីសម្រេចរបស់ខ្លួនតែទៅលើភស្តុតាងដែលដាក់ជូន និងបានពិភាក្សានៅចំពោះមុខតុលាការក្នុងពេលជំនុំជម្រះប៉ុណ្ណោះ។ ចៅក្រមត្រូវមានបំណងឱ្យទទួលបានសំឡេងជាឯកច្ឆន្ទនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន ការខកខានមិនបាន នូវសេចក្ដីសម្រេចជាឯកច្ឆន្ទ សេចក្ដីសម្រេចត្រូវធ្វើឡើងតាមមតិភាគច្រើនរបស់ចៅក្រមទាំងឡាយ ហើយការពិភាក្សាសម្រេចរបស់អង្គជំនុំជម្រះត្រូវរក្សាជាការសម្ងាត់។ សេចក្ដីសម្រេចរបស់តុលាការ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវមាននូវសេចក្ដីថ្លែង អំពីការរកឃើញលើភស្តុតាង និងសេចក្ដីសន្និដ្ឋានពេញលេញ ព្រមទាំងមានហេតុផល។ អង្គជំនុំជម្រះ ត្រូវចេញនូវសេចក្ដីសម្រេចតែមួយគត់។ នៅពេលគ្មានភាព ឯកច្ឆន្ទ សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ត្រូវមានទាំងទស្សនៈរបស់មតិភាគច្រើន និងទស្សនៈរបស់មតិភាគតិច។

## ៣.ការប្រកាសសាលក្រម

សាលក្រមអាចត្រូវបានប្រកាសដោយស្របតាមលក្ខខណ្ឌដែលមាន កំណត់នៅក្នុងច្បាប់នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ព្រមទាំងការណែនាំខ្លះៗ ពីគោលការណ៍អន្តរជាតិ ឬក៏សន្ធិសញ្ញាអន្តរជាតិនានា ស្របតាមបទដ្ឋានដែលតុលាការគិតថា ត្រឹមត្រូវ និងអាចទទួលយកបាន។

### ៣.១.លក្ខខណ្ឌក្នុងការប្រកាស

សេចក្ដីសម្រេច ឬសេចក្ដីសង្ខេបនោះ ត្រូវតែប្រកាសនៅក្នុងតុលាការជាចំហបែបនេះក៏ដើម្បី ជាការបម្រើមុខងារក្នុងការបញ្ចេញមតិរបស់សន្ធិសញ្ញាការប្រកាសសាលក្រមជាសាធារណៈនៅចំពោះមុខភាគី និងអ្នកចូលរួម ក៏ជាទិដ្ឋភាពសំខាន់នៃគោលការណ៍នៃសវនាការសាធារណៈផងដែរ។[138] ម្យ៉ាងទៀតដូចដែលយើងបានដឹង តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវធ្វើការដោយគោរពទៅលើសិទ្ធិមនុស្ស ហើយការធ្វើការប្រកាសសាលក្រមជាសាធារណៈគឺ បានចង្អុលបង្ហាញនៅការគោរពទៅតាមវិធានអន្តរជាតិដូចដែលបានចែងនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ព្រមទាំង វិធាននៃនីតិវិធី និងភស្តុតាងផងដែរ។[139]

---

[138]មាត្រា ៧៤ (១) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ៣ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[139]មាត្រា ២១ (៣) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ៣ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

### ៣.១.១.វិធានអន្តរជាតិ និងការប្រកាសសាលក្រម

តួយ៉ាងដំណើរការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវគោរពយ៉ាងចាំបាច់នៅច្បាប់សិទ្ធិមនុស្សអន្តរជាតិដូចដែលបានកំណត់ ហើយយើងក៏ឃើញមានច្បាប់ដែលពាក់ព័ន្ធទាំងនោះដែលមានដូចជា៖ អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។

#### ៣.១.១.១.អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស

ដែលកំណត់អំពីសិទ្ធិស៊ីវិល និងកាតព្វកិច្ចរបស់ជនណាម្នាក់ ឬនៃការចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងនិងជននោះ មនុស្សគ្រប់គ្នាមានសិទ្ធិទទួលបានយុត្តិធម៌ និងសវនាការសាធារណៈក្នុងពេលវេលាសមស្របដោយឯករាជ្យ និងមិនលម្អៀងដែលបង្កើតឡើងដោយច្បាប់។ ការវិនិច្ឆ័យនិងត្រូវប្រកាសជាសាធារណៈ ប៉ុន្តែសារព័ត៌មាននិងសាធារណជនអាចត្រូវបានដកចេញពីផ្នែកទាំងអស់ឬផ្នែកនៃការកាត់ក្តីដើម្បីផលប្រយោជន៍សីលធម៌ សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិក្នុងសង្គមប្រជាធិបតេយ្យ ដែលផលប្រយោជន៍អនីតិជន ឬការការពារជីវិតឯកជនរបស់ភាគីទាមទារ ឬក្នុងកម្រិតចាំបាច់យ៉ាងតឹងរ៉ឹង តាមគំនិតតុលាការក្នុងកាលៈទេសៈពិសេសដែលការផ្សព្វផ្សាយជាសាធារណៈ និងមានការរើសអើងផលប្រយោជន៍នៃយុត្តិធម៌។[140]

#### ៣.១.១.២.កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ស្របពេលគ្នានេះដែលយើងក៏មាននៅភាពពាក់ព័ន្ធ នៃការប្រកាសជាសាធារណៈជាមួយ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក្នុងការកំណត់អំពីសិទ្ធមួយចំនួន អំពីព័ត៌មាន និងសាធារណជន អាចមិនឱ្យចូលរួមទាំងស្រុង ឬផ្នែកមួយនៃសវនាការ សម្រាប់ផលប្រយោជន៍នៃទំនៀមទម្លាប់ល្អ សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិក្នុងសង្គមប្រជាធិបតេយ្យ ឬនៅពេល ផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគី តម្រូវឱ្យធ្វើដូច្នេះ ឬក្នុងកម្រិតដែលចាំបាច់ បំផុត តាមការយល់ឃើញរបស់តុលាការ ក្នុងស្ថានភាពពិសេស ដែលថាការធ្វើជា សាធារណៈ និងនាំឱ្យខូចដល់ផលប្រយោជន៍យុត្តិធម៌។ ប៉ុន្តែ ការចេញសាលក្រម ទាំងអស់ អំពីរឿងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ។ [141]ដូច្នេះ អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស បានកំណត់ថាការប្រកាសសាលក្រមជាសាធារណៈ អាចផ្តល់នៅ ព័ត៌មានសម្រាប់អ្នកដែលមានចំណាប់អារម្មណ៍លើ (អាស្រ័យលើលក្ខណៈពិសេសនៃដំណើរការនីតិវិធី) ការធ្វើបែបនេះក៏ដើម្បីធានានូវ 'ការ

[140] អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស មាត្រា ៦ (១),ចូលមើលថ្ងៃទី ៤ ខែ មិនា ឆ្នាំ២០២៤
https://www.echr.coe.int/documents/d/echr/convention_ENG

[141] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយមាត្រា ១៤ (១),ចូលមើលថ្ងៃទី ៤ ខែ មិនា ឆ្នាំ២០២៤
https://cambodia.ohchr.org/sites/default/files/Treaty/ICCPR_2009K.pdf

ពិនិត្យលើប្រព័ន្ធតុលាការដោយសាធារណៈ ក្នុងគោលបំណងការពារសិទ្ធិក្នុងការកាត់ក្តីដោយយុត្តិធម៌តម្លាភាព ការចូលប្រើជាសាធារណៈ គណនេយ្យភាព ស្តង់ដាច្បាប់។

ទោះជាយ៉ាងណាការសម្រេចក៏អាចធ្វើឡើងជាសម្ងាត់បាន ដោយផ្អែកលើវិធាននៃសិទ្ធិមនុស្សដូចគ្នា បើសិនកាលណាការប្រកាសនោះបានធ្វើឡើងដោយប៉ះពាល់ដល់ប្រយោជន៍អនីតិជន តម្រូវផ្សេងពីនេះ ឬរឿងក្តីអំពីទំនាស់គ្រួសារ ឬអាណាព្យាបាលរបស់កុមារ។[142] ប៉ុន្តែប្រសិនបើគ្មានហេតុផលសមរម្យមួយណាដែលច្បាប់អាចទទួលនូវការប្រកាសជាសាធារណៈទេនោះ អង្គជំនុំជម្រះត្រូវធ្វើការប្រកាសជាសាធារណៈ។

### ៣.២.រយៈពេលសម្រាប់ប្រកាស

តុលាការព្រហ្មទណ្ឌអន្តរជាតិ  អាចធ្វើការប្រកាសសាលក្រមក្នុងពេលវេលាសមរម្យមួយ ប៉ុន្តែយ៉ាងណារយៈពេល នៃការប្រកាសអាចប្រែប្រួលអាស្រ័យលើភាពស្មុគស្មាញនៃសំណុំរឿងនីមួយៗតែការពន្យារពេលច្រើន តុលាការព្រហ្មទណ្ឌអន្តរជាតិ  បានប្រឈមមុខនិងការរិះគន់ចំពោះការកាត់ក្តីក៏ ដោយជនជាប់ចោទអាចប្រឈមមុខ និងពេលវេលាច្រើនក្នុងការឃុំឃាំងមុនពេលកាត់ទោស ឬការដោះលែង។ [143] ទោះជាយ៉ាងណាក៏ដោយ ក្រោយពីការប្រកាសរាល់សេចក្តីសម្រេច ទាំងអស់របស់អង្គចៅក្រម ព្រមទាំងការិយាល័យរដ្ឋអាជ្ញា ឬជនជាប់ចោទអាចធ្វើការប្តឹងជំទាស់សាលក្រមរបស់អង្គជំនុំជម្រះដំបូងនេះទៅកាន់អង្គជំនុំជម្រះជាន់ខ្ពស់។

## ផ្នែកទី៤៖ អង្គជំនុំជម្រះជាន់ខ្ពស់

បន្ទាប់ពីការប្រកាសសាលក្រមហើយ នោះការិយាល័យរដ្ឋអាជ្ញា ឬជនជាប់ចោទអាចធ្វើការប្តឹងជំទាស់សាលក្រមរបស់អង្គជំនុំជម្រះដំបូង ដោយដាក់ការស្នើការជំទាស់នោះទៅតុលាការជាន់ខ្ពស់ ដែលជាទូទៅវាជាបណ្តឹងឧទ្ធរណ៍ ដូចជាការប្តឹងប្រឆាំង និងសេចក្តីសម្រេចផ្សេងៗ និងសើរើ។ ទោះជាយ៉ាងណាការធ្វើបែបនេះទៅបានត្រូវគោរពតាមលក្ខខណ្ឌដែលច្បាប់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានកំណត់ ការធ្វើបែបនេះក៏ធ្វើឱ្យប្រាកដថា ដំណើរការនៃការជំនុំជម្រះបានប្រព្រឹត្តទៅប្រកបដោយ យុត្តិធម៌ និងគ្មានភាពលំអៀងណាមួយបានកើតឡើង។[144]

[142]មាត្រា ៦៤ (៧)(ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ៣ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[143]វិធាននៃនីតិវិធី និងភស្តុតាង ជំពូកទី ៥ ផ្នែកទី ៦ វិធាន ១៤១ ការប្រកាសសាលាលក្រម,ចូលមើលថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤ https://www.icc-cpi.int/sites/default/files/Publications/Rules-of-Procedure-and-Evidence.pdf

[144] មាត្រា ៦៧ (១)នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ៣ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

## កថាខណ្ឌទី១៖ បណ្ដឹងឧទ្ធរណ៍

បណ្ដឹងឧទ្ធរណ៍ ត្រូវបើកសវនាការ ផ្អែកលើមូលដ្ឋានលឿនរហ័ស។ ការប្ដឹងឧទ្ធរណ៍នេះ មិនត្រូវមានអានុភាពព្យួរទុកដោយឯកឯងឡើយ លុះត្រាតែអង្គជំនុំជម្រះឧទ្ធរណ៍ មានការបញ្ជាណាមួយ នៅពេលមានសំណើណាមួយ ដែលស្របតាមវិធាននៃនីតិវិធី និងភស្តុតាង។ អ្នកតំណាងផ្នែកច្បាប់ នៃជនរងគ្រោះ ពិរុទ្ធជន ឬម្ចាស់សុច្ចរិតនៃទ្រព្យសម្បត្តិ ដែលរងអានុភាពប្រឆាំងដោយសារការបញ្ជារបស់តុលាការដោយយោងតាមមូលហេតុផ្សេងៗ ក្រោមមាត្រា ៧៣ អាចប្ដឹងឧទ្ធរណ៍ប្រឆាំង និងបញ្ជានេះដើម្បីការជួសជុលឡើងវិញ ដូចមានចែងក្នុងវិធាននៃនីតិវិធី និងភស្តុតាង។[145]

### ១.លក្ខខណ្ឌក្នុងការប្ដឹង

លក្ខខណ្ឌក្នុងបណ្ដឹងឧទ្ធរណ៍ប្រឆាំង និងសេចក្ដីសម្រេចឱ្យរួចខ្លួន ឬឱ្យមានពិរុទ្ធ ឬប្រឆាំង និងការកាត់ទោស អាចធ្វើទៅបានដោយ ស្របតាមវិធាននៃនីតិវិធី និងភស្តុតាង សេចក្ដីសម្រេចក្រោមមាត្រា ៧៤ រដ្ឋអាជ្ញា ឬពិរុទ្ធជនអាចប្ដឹងឧទ្ធរណ៍ ផ្អែកលើមូលហេតុដូចខាងក្រោមនេះ ៖

- កំហុសផ្នែកនីតិវិធី
- កំហុសនៃអង្គហេតុ
- កំហុសនៃអង្គច្បាប់
- មូលហេតុនៃទោស

### ១.២.កំហុសផ្នែកនីតិវិធី

កំហុសនៃនីតិវិធីរួមមានការមិនអនុលោមតាមតម្រូវការនីតិវិធីជាកាតព្វកិច្ចនៃលក្ខន្តិកៈទីក្រុងរ៉ូម ស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ និងវិធាននៃនីតិវិធី និងភស្តុតាង ក៏ដូចជាកំហុសទាក់ទងនឹងការអនុវត្តការសម្រេចចិត្តដោយអង្គជំនុំជម្រះ។ ឧទាហរណ៍ដូចជា ការទទួលយកភស្តុតាងជាដើម។

### ១.៣.កំហុសនៃអង្គហេតុ

កំហុសនេះការពិតនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ សំដៅទៅលើកំហុស ឬភាពមិនត្រឹមត្រូវនៅក្នុងអង្គហេតុដែលបានបង្ហាញក្នុងអំឡុងពេលសវនាការ ឬការស៊ើបអង្កេត។ កំហុសទាំងនេះអាចមានសារៈសំខាន់

---

[145] មាត្រា ៨២ (២),(៣),(៤) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

និងប៉ះពាល់ដល់លទ្ធផលនៃករណីមួយ។ អង្គជំនុំជម្រះឧទ្ធរណ៍បានថ្លែងថាខ្លួននឹងមិនជ្រៀតជ្រែកដល់ការរកឃើញអង្គហេតុនៃអង្គជំនុំជម្រះដំបូងទេ លុះត្រាតែបង្ហាញថាអង្គជំនុំជម្រះ "បានប្រព្រឹត្តកំហុសច្បាស់លាស់ដែលមានដូចជា៖ យល់ខុសចំពោះអង្គហេតុ គិតដល់អង្គហេតុមិនពាក់ព័ន្ធ ឬខកខានក្នុងការពិចារណាចំពោះភាពពាក់ព័ន្ធក្នុងករណីណាមួយ"។[146]

កំហុសនៃអង្គហេតុ មានកំហុសពីរប្រភេទ៖

- ប្រភេទទីមួយគឺនៅពេលដែលវាត្រូវបានចោទប្រកាន់ថាអង្គជំនុំជម្រះបានប្រព្រឹត្តកំហុសក្នុងការឈានដល់ការសន្និដ្ឋាននៃការពិតដែលខ្លួនបានធ្វើដោយផ្អែកលើភស្តុតាងដែលមានពីមុនមក។
- ប្រភេទទីពីរទាក់ទងនឹងប្រភេទនៅពេលដែលអង្គជំនុំជម្រះដំបូងមានភាពយុត្តិធម៌ក្នុងការឈានដល់ការសន្និដ្ឋានចុងក្រោយដោយផ្អែកលើភស្តុតាងដែលបានបង្ហាញនៅក្នុងសវនាការ ប៉ុន្តែនៅពេលដែលភស្តុតាងត្រូវបានបន្ថែមមានវត្តមានលើបណ្តឹងឧទ្ធរណ៍ធ្វើឱ្យមានការសង្ស័យលើការរកឃើញទាំងនោះ។[147]

### ១.៣.កំហុសនៃអង្គច្បាប់

កំហុសនេះអាចទាក់ទងទៅនឹងការសម្រេចចិត្តដែលធ្វើឡើងដោយអង្គជំនុំជម្រះ ឬការប្រើប្រាស់លើសំណួរនៃច្បាប់សំខាន់ៗ ឬនីតិវិធីរបស់តុលាការ។ ករណីមួយទៀត ចំពោះពិរុទ្ធជន ក៏អាចពឹងផ្អែកលើមូលហេតុផ្សេងៗ ទៀតដែលប៉ះពាល់ដល់ភាពយុត្តិធម៌ ឬដល់ភាពដែលអាចយកជាការបានក្នុងដំណើរការជម្រះក្តី ឬនៃសេចក្តីសម្រេច ដែលអាចបន្ថែមតិចតួចដល់ហេតុផលដែលបានបញ្ជាក់ផ្សេងទៀតនៃបណ្តឹងឧទ្ធរណ៍។

## ២.មូលហេតុនៃទោស

ស្របតាមវិធាននៃនីតិវិធី និងភស្តុតាង ទោសក៏ជាមូលហេតុមួយដែល អាចត្រូវបានប្រើក្នុងការប្តឹងឧទ្ធរណ៍ ដោយរដ្ឋអាជ្ញា ឬពិរុទ្ធជន ផ្អែកលើមូលហេតុនៃភាពមិនសមាមាត្រគ្នា រវាងបទល្មើសដែលបានកើតឡើង និងទោសដែលបានដាក់ឱ្យអនុវត្តន៍នោះ។ ប្រសិនបើនៅក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំង និងទោសតុលាការពិចារណាថា មានមូលហេតុនានាដែលបណ្តាលឱ្យការកាត់ទោសឱ្យមានពិរុទ្ធភាពអាចត្រូវចាត់ទុកជាឥតបានការទាំងស្រុង ឬមួយផ្អែកតុលាការអាចអញ្ជើញឱ្យ រដ្ឋអាជ្ញា ឬពិរុទ្ធជន ដាក់ជូននូវមូលហេតុនានាដើម្បីធ្វើការគាំ

[146]ស្ថានភាពនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល ២ ជំពូកទី ៤ ចំណុច ៩ នៅក្នុងករណីរបស់រដ្ឋអាជ្ញាv. ALFRED YEKATOM និង PATRICE-EDOUARD NGAÏSSONAចូលមើលថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/CourtRecords/0902ebd1807def34.pdf

[147]អង្គជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ទាក់ទងនឹងស្ថានភាពនៅក្នុងសាធារណរដ្ឋហ្វីលីពីនចំណុចទី ១៩,ចូលមើលថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២៤ https://www.icc-cpi.int/sites/default/files/CourtRecords/0902ebd18043e50f.pdf

ទ្រចំពោះការតវ៉ានោះបន្ទាប់មក តុលាការអាចចេញនូវសេចក្តីសម្រេចមួយ អំពីពិរុទ្ធភាពស្របទៅតាមអ្វីដែលបានចែងក្នុងនីតិវិធីនៃដំណើរការជំនុំជម្រះ។[148]

## កថាខណ្ឌទី២៖ អំពីការប្តឹងឧទ្ធរណ៍ប្រឆាំងសេចក្តីសម្រេចផ្សេងៗ

ស្របតាមវិធាននៃនីតិវិធី និងភស្តុតាង ភាគីមួយណា ក៏អាចប្តឹងឧទ្ធរណ៍ប្រឆាំង និងសេចក្តីសម្រេចដូចខាងក្រោម សេចក្តីសម្រេចទាក់ទងនឹងយុត្តាធិការ ឬភាពអាចទទួលយកយកមកជំនុំជម្រះសេចក្តីសម្រេចផ្តល់ ឬបដិសេធចំពោះការដោះលែងជន ដែលកំពុងត្រូវរងការស៊ើបអង្កេត ឬកំពុងត្រូវនាំមកជម្រះ សេចក្តីសម្រេចរបស់អង្គមុនជំនុំជម្រះដែលធ្វើតាមការផ្តួចផ្តើមរបស់សិទ្ធិរដ្ឋអាជ្ញាខ្លួនផ្ទាល់ ក្រោមកថាខណ្ឌទី៣ នៃ មាត្រា៥៦ នេះ សេចក្តីសម្រេចដែលទាក់ទង និងបញ្ហាណាមួយ ដែលទំនងជាប៉ះពាល់យ៉ាងសំខាន់ ដល់ការប្រព្រឹត្តទៅដោយយុត្តិធម៌ និងដោយលឿនរហ័សនៃដំណើរការជម្រះរឿងក្តី ឬប៉ះពាល់យ៉ាងសំខាន់ដល់លទ្ធផលនៃការជំនុំជម្រះ ហើយជាទស្សនៈរបស់អង្គមុនជំនុំជម្រះ ឬអង្គជំនុំជម្រះដំណោះស្រាយជាបន្ទាន់មួយ ដោយអង្គជំនុំជម្រះឧទ្ធរណ៍ អាចជំរុញយ៉ាងសំខាន់ដល់ដំណើរការជម្រះរឿងក្តីនោះ។

### ១.នីតិវិធីក្នុងបណ្តឹងឧទ្ធរណ៍

សម្រាប់គោលបំណងនៃដំណើរការដែលមានចែងនៅក្នុងមាត្រា ៨១ និងក្នុងមាត្រានេះ ចែងថា អង្គជំនុំជម្រះឧទ្ធរណ៍ត្រូវមាន អំណាចទាំងអស់ដែលអង្គជំនុំជម្រះដំបូងមាន។ បើសិនជាអង្គជំនុំជម្រះឧទ្ធរណ៍ យល់ឃើញថា ដំណើរការដែលត្រូវគេប្តឹងឧទ្ធរណ៍ មានភាពអយុត្តិធម៌ក្នុងសភាពមួយ ដែលប៉ះពាល់ដល់ភាពអាចទុកចិត្តបាននៃសេចក្តីសម្រេច ឬលើការដាក់ទោស ឬបើសិនជាអង្គជំនុំជម្រះឧទ្ធរណ៍ យល់ឃើញថា សេចក្តីសម្រេច ឬការដាក់ទោសដែលត្រូវបានគេប្តឹងឧទ្ធរណ៍បានត្រូវប៉ះពាល់ជាធំដុំដោយការភាន់ច្រឡំលើអង្គហេតុ ឬលើអង្គ ច្បាប់ ឬការភាន់ច្រឡំខាងនីតិវិធី អង្គជំនុំជម្រះឧទ្ធរណ៍អាច៖

- បដិសេធ ឬកែប្រែ សេចក្តីសម្រេច ឬការដាក់ទោស នោះបាន
- បញ្ជាឱ្យធ្វើការជំនុំជម្រះសារជាថ្មី ដោយអង្គជំនុំជម្រះមួយផ្សេងទៀត
- សម្រាប់គោលបំណងទាំងនេះ៖ អង្គជំនុំជម្រះឧទ្ធរណ៍ អាចបញ្ជូនបញ្ហាអង្គហេតុត្រឡប់ទៅអង្គជំនុំជម្រះដើមវិញដើម្បី អង្គជំនុំជម្រះនោះ កំណត់អង្គហេតុសារជាថ្មី និងរាយការណ៍ជូនអង្គជំនុំជម្រះឧទ្ធរណ៍វិញ ឬអង្គជំនុំជម្រះឧទ្ធរណ៍ អាចរកភស្តុតាងដោយខ្លួនឯង ដើម្បីកំណត់អង្គហេតុ។ នៅពេលដែលសេចក្តី

[148]មាត្រា ៨១ (២), នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

សម្រេចក្នុងការដាក់ទោសត្រូវបានប្ដឹងឧទ្ធរណ៍ដោយពិរុទ្ធជនតែឯង ឬដោយរដ្ឋអាជ្ញាក្នុងនាមពិរុទ្ធជន នោះសេចក្ដីសម្រេច ឬការដាក់ទោសមិនអាចត្រូវកែប្រែដើម្បីធ្វើឱ្យខូចប្រយោជន៍ពិរុទ្ធជនឡើយ។[149]

ប្រសិនបើនៅក្នុងបណ្ដឹងឧទ្ធរណ៍មួយជំទាស់ និងការដាក់ទោស អង្គជំនុំជម្រះឧទ្ធរណ៍យល់ឃើញថា ការដាក់ទោសពុំ មានសមាមាត្រ និងបទល្មើសព្រហ្មទណ្ឌនោះទេ អង្គជំនុំជម្រះឧទ្ធរណ៍អាចកែប្រែការដាក់ទោស ស្របតាមភាគទី ៧។ ដូចដែលបានបញ្ជាក់រួចមកហើយនៅក្នុងសេចក្ដីអធិប្បាយលើមាត្រា ៨១(២) អង្គជំនុំជម្រះឧទ្ធរណ៍អាចផ្លាស់ប្ដូរទោស ប្រសិនបើមានភាពមិនស្មើគ្នារវាង បទឧក្រិដ្ឋ និងទោស។[150]

## ២.បណ្ដឹងសើរើលើសេចក្ដីសម្រេចថាមាន ឬគ្មានពិរុទ្ធភាព

យោងតាមមាត្រា ៨៤ នៃច្បាប់លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ អ្នកដែលអាចធ្វើ បណ្ដឹងសើរើដើម្បីតទល់នឹងសេចក្ដីសម្រេចស្ថាពរ ដែលសម្រេចលើពិរុទ្ធភាព ឬលើការដាក់ទោសនេះបានរួមមាន ៖

១.ពិរុទ្ធជន ឬទណ្ឌិតខ្លួនឯង

២.បើជននេះស្លាប់ទៅ មានសហព័ទ្ធរបស់គាត់ កូនរបស់គាត់ ឪពុក ឬម្ដាយរបស់គាត់ ឬជនដែលទទួលបានបណ្ដាំជាលាយលក្ខណ៍អក្សរពីពិរុទ្ធជន ឬទណ្ឌិតរូបនេះនៅរស់ថាឱ្យជួយប្ដឹង

៣.រដ្ឋអាជ្ញាក្នុងនាមឱ្យពិរុទ្ធជន ឬទណ្ឌិត។[151]

### ២.១.មូលហេតុនៃការប្ដឹង

មូលហេតុដែលអាចប្ដឹងបានមាន ការរកឃើញនូវភស្ដុតាងថ្មី ដែលកាលនៅពេលជំនុំជម្រះពុំទាន់រកឃើញនៅឡើយ ហើយការរកមិនទាន់ឃើញនេះមិនមែន បណ្ដាលមកពីចេតនាទាំងស្រុង ឬមួយចំណែកណាមួយរបស់ភាគីដាក់ពាក្យសុំនោះឡើយ ម្យ៉ាងទៀតការរកឃើញភស្ដុតាងថ្មីនេះ មានសារៈសំខាន់យ៉ាងខ្លាំង ប្រសិនបើគេរកឃើញវានៅពេលកំពុងជំនុំជម្រះវិញនោះ ការវិនិច្ឆ័យអាចមានលទ្ធផលផ្សេង។ មូលហេតុផ្សេងទៀតគឺថាគេអាចរកឃើញថ្មីៗ ថាភស្ដុតាងដែលមានឥទ្ធិពលលើសេចក្ដី សម្រេចដែលត្រូវបានពិចារណានៅពេលជំនុំជម្រះ និងដែលការសម្រេចថាឱ្យមានពិរុទ្ធភាពដែលសំអាងលើភស្ដុតាងមិនពិតក្លែងក្លាយ ឬត្រូវបានគេ

---

[149] មាត្រា ៨៣ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[150] មាត្រា ៨១ (២) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[151] មាត្រា ៨៤ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

កេងបន្លំ។ មូលហេតុដែល នាំឱ្យមានការប្ដឹងសើរើបានអាចជាកំហុសខុសឆ្គងរបស់ចៅក្រមមួយរូប ឬច្រើនរូប ដែលបានចូលរួមក្នុងការសម្រេចពិរុទ្ធភាព ឬដែលបានចូលរួមក្នុងការបញ្ជាក់អំពីការចោទប្រកាន់ដែលបានធ្វើឡើង។ ហើយកំហុសនេះជាកំហុសដែលមានលក្ខណៈធ្ងន់ធ្ងរ ឬមានការខ្វះខាតយ៉ាងខ្លាំងក្នុងការបំពេញកាតព្វកិច្ចក្នុងនាមជាចៅក្រម ដែលអាចបណ្ដាលឱ្យមានការដកហូតតំណែងគាត់ជាចៅក្រមនាពេលជំនុំជម្រះស្របតាមមាត្រា ៤៦ នៃច្បាប់លក្ខន្តិកៈ តុលាការព្រហ្មទណ្ឌអន្តរជាតិ។ នៅពេលទទួលបានបណ្ដឹងសើរើហើយ អង្គជំនុំជម្រះឧទ្ធរណ៍មានជម្រើសពីរយ៉ាង គឺបើខ្លួនមានមូលដ្ឋានច្បាស់លាស់នោះ អាចបដិសេធបណ្ដឹងដែលប្ដឹងនោះភ្លាមបាន តែបើមិនទាន់ច្បាស់លាស់វិញទេនោះ ហើយពាក្យបណ្ដឹងមានមូលដ្ឋានគ្រប់គ្រាន់ អង្គជំនុំជម្រះឧទ្ធរណ៍ត្រូវតែធ្វើការសម្រេចឱ្យអង្គជំនុំជម្រះដើមឱ្យធ្វើការជំនុំជម្រះក្ដីសារជាថ្មី ឬក៏បង្កើតអង្គជំនុំជម្រះថ្មីមួយទៀតឱ្យធ្វើការជំនុំជម្រះ ឬក៏ធ្វើការជំនុំជម្រះរឿងក្ដី នេះដោយខ្លួនឯងតែម្ដង។ ក្នុងចំណោមអ្នកទាំងបី អ្នកណាមួយដែលត្រូវចូលកាន់ការ ត្រូវធ្វើការស្ដាប់ភាគីពាក់ព័ន្ធឱ្យបានគ្រប់ជ្រុងជ្រោយ ស្របតាមវិធាននីតិវិធី និងភស្ដុតាងមុននឹងអារកាត់សម្រេចកែប្រែសាលក្រមដែលជាកម្មវត្ថុនៃបណ្ដឹងសើរើនេះ ឬអត់។

## ៣.ការប្រកាសសាលដីកា

សាលដីការបស់អង្គជំនុំជម្រះឧទ្ធរណ៍ ត្រូវសម្រេចដោយសំឡេងភាគច្រើននៃអង្គចៅក្រម ហើយត្រូវប្រកាសជាចំហ នៅក្នុងតុលាការ។ សាលដីកាត្រូវបញ្ជាក់អំពីហេតុផលទាំងឡាយដែលបានសំអាង នៅពេលគ្មានការយល់ព្រមជាឯកច្ឆន្ទទេ សាលដីការបស់អង្គជំនុំជម្រះឧទ្ធរណ៍ត្រូវមានទាំងទស្សនៈរបស់មតិភាគច្រើន និងទស្សនៈ មតិភាគតិច ប៉ុន្តែចៅក្រមមួយរូបៗ អាចបញ្ចេញមតិដាច់ដោយឡែក ឬមតិជំទាស់ ដែលទាក់ទងនិងបញ្ហាអង្គច្បាប់ ទោះជាយ៉ាងណា សេចក្ដីសម្រេចនេះ គឺជាលទ្ធផលនៃការពិភាក្សា ដែលនិងផ្អែកលើទិដ្ឋភាពនៃមតិភាគច្រើន យោងតាមមាត្រា ៧៤ (៤ ) នៃលក្ខន្តិកៈទីក្រុងរ៉ូម។ការប្រកាសសាលដីកា វាមិនមានលក្ខណៈខុសគ្នាប៉ុន្មានទេជាមួយការប្រកាសសាលក្រម ខុសត្រង់ថាសាលដីកានេះគឺជាសេចក្ដីសម្រេចចុងក្រោយដែលជាលទ្ធផលសម្រាប់កំណត់ថាមានពិរុទ្ធ ឬគ្មានហើយត្រូវជាប់កាតព្វកិច្ច និងក្លាយជាការបិទបញ្ចប់ចុងក្រោយរបស់អង្គជំនុំជម្រះឧទ្ធរណ៍ លើសពីនេះអង្គជំនុំជម្រះឧទ្ធរណ៍ អាចចេញសាលដីការបស់ខ្លួនដោយគ្មានវត្តមានជនដែលត្រូវសម្រេចថាមានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាព។[152]

[152]ស្ថានភាពនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោក្នុងករណីរដ្ឋអាជ្ញាv. GERMAIN KATANGA អង្គជំនុំជម្រះឧទ្ធរណ៍ ជំពូកទី ៦ ទំព័រទី ៦៥៦, ចូលមើលថ្ងៃទី ៣ ខែមិថុនា ឆ្នាំ២០២៤, ចូលមើលថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៤ https://www.icc-cpi.int/sites/default/files/CourtRecords/CR2015_04025.PDF

# ជំពូកទី៣

# ការអនុវត្តសាលក្រម និងសាលដីការបស់តុលាការ ព្រហ្មទណ្ឌអន្តរជាតិ

# ជំពូកទី៣
# ការអនុវត្តសាលក្រម និងសាលដីការបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

រដ្ឋភាគី គឺជាផ្នែកមួយដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្ត សាលក្រម និងសាលដីកា របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងដាក់ទោសទៅលើជនល្មើសទាំងនោះដែលបានកំណត់ក្នុងសាលក្រមដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ។

## ផ្នែកទី១៖ អំពីតួនាទីរបស់រដ្ឋភាគីក្នុងការអនុវត្តដាក់ទោសពន្ធនាគារ

ការដាក់ទោសពន្ធនាគារនឹងត្រូវធ្វើឡើងនៅក្នុងរដ្ឋមួយដែលចាត់តាំងដោយតុលាការចេញពីបញ្ជីនៃរដ្ឋទាំងឡាយដែលបានបង្ហាញប្រាប់ដល់តុលាការអំពីឆន្ទៈរបស់ខ្លួន ក្នុងការទទួលពិរុទ្ធជន ឬទណ្ឌិត។ នៅពេលប្រកាសអំពីឆន្ទៈរបស់ខ្លួនក្នុងការទទួលពិរុទ្ធជន រដ្ឋមួយអាចដាក់លក្ខខណ្ឌលើការទទួលយករបស់ខ្លួន ដែលបានយល់ព្រមដោយតុលាការ។[153]

## កថាខណ្ឌទី១៖ សិទ្ធិរបស់តុលាការក្នុងការចាត់តាំង រដ្ឋភាគី

ក្នុងពេលអនុវត្តន៍តាមឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីចាត់តាំងរដ្ឋណាមួយ តុលាការត្រូវតែធ្វើ ការពិចារណាលើកត្តាមួយចំនួនដូចជា៖

- គោលការណ៍ដែលថារដ្ឋភាគីទាំងអស់ គួរតែត្រូវរួមចំណែកទទួលខុសត្រូវលើការអនុវត្តក្នុងដាក់ ទោសពន្ធនាគារ ដោយអនុលោមទៅតាមគោលការណ៍នៃការបន្តសមភាព ដូចដែលមានចែងក្នុងវិធាននៃនីតិវិធី និងភស្តុតាង
- ការអនុវត្តតាមស្តង់ដាសន្ធិសញ្ញាអន្តរជាតិដែលត្រូវបានទទួលយកជាទូទៅ ស្តីពីការប្រព្រឹត្តលើពិរុទ្ធជន
- ទស្សនៈរបស់ពិរុទ្ធជន និងសញ្ជាតិរបស់ពិរុទ្ធជន
- កត្តាផ្សេងៗ ទៀតដែលទាក់ទង និងកាលៈទេសៈនៃអំពើល្មើសព្រហ្មទណ្ឌ នៃពិរុទ្ធជន ឬដែលទាក់ទងនឹងការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃការដាក់ទោស ដែលអាចសមស្របក្នុងការចាត់តាំងរដ្ឋភាគីដាក់ឱ្យអនុវត្តន៍នោះ។[154]

[153]មាត្រា ១០៣ (១) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ៣ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[154] មាត្រា ១០៣ (៣) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

បើសិនជាមិនទាន់មានរដ្ឋភាគីណាមួយត្រូវបានចាត់តាំងឡើងក្រោមកថាខណ្ឌទី ១ ការដាក់ទោសពន្ធនាគារ និងត្រូវធ្វើឡើងនៅក្នុងពន្ធនាគារដែលបានផ្តល់ឱ្យដោយរដ្ឋម្ចាស់ផ្ទះ(ប្រទេស ហូឡង់) ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចព្រមព្រៀង។[155] ម៉្យាងវិញទៀតតុលាការអាចសម្រេចឱ្យមានការផ្ទេរទណ្ឌិតទៅពន្ធនាគារនៃរដ្ឋមួយផ្សេងទៀតនៅពេលណាក៏បាន ឬទណ្ឌិតអាចស្នើសុំទៅតុលាការឱ្យផ្ទេរខ្លួនចេញពីរដ្ឋដែលដាក់ឱ្យអនុវត្តន៍សាលក្រមនោះនៅពេលណាក៏បាន។[156]

## ១.ការដាក់លក្ខខណ្ឌ

រដ្ឋភាគីដែលត្រូវបានចាត់តាំង ត្រូវតែជូនដំណឹងមកតុលាការជាបន្ទាន់ ថាតើខ្លួនទទួលយល់ព្រមតាមការចាត់តាំងរបស់តុលាការ ឬអត់។ រដ្ឋដែលដាក់ឱ្យអនុវត្តន៍ ត្រូវតែជូនដំណឹងមកតុលាការចំពោះកាលៈទេសៈពិសេសណាមួយ រួមទាំងការអនុវត្តនូវលក្ខខណ្ឌណាមួយ ដែលបានយល់ព្រម ឬដែលអាចប៉ះពាល់យ៉ាងជាក់ស្តែងលើលក្ខខណ្ឌ និងកម្រិតនៃការដាក់ទោស។ តុលាការ ត្រូវមានរយៈពេលយ៉ាងហោចណាស់ ៤៥ ថ្ងៃដើម្បីទទួលការជូនដំណឹងអំពីកាលៈទេសៈ បែបនេះដែលបានដឹងរួចមកហើយ ឬដែលបានគ្រោងទុកមុន។ ក្នុងរយៈពេលនេះ រដ្ឋដែលដាក់ឱ្យអនុវត្តន៍ មិនត្រូវធ្វើសកម្ម ភាពទាំងឡាយណាដែលអាចមានអគតិធម៌ដល់កាតព្វកិច្ចរបស់ខ្លួនក្រោមមាត្រា ១១០ ឡើយ។ នៅពេលដែលតុលាការមិនអាចឯកភាពលើកាលៈទេសៈដែលបានលើកឡើងក្នុងការដាក់លក្ខខណ្ឌណាមួយ តុលាការអាចអនុវត្តន៍ក្នុងការចាត់តាំងរដ្ឋភាគីផ្សេងទៀត។[157]

### ១.១.អំពីការដាក់ឱ្យអនុវត្តន៍ទោស

តាមលក្ខខណ្ឌដែលរដ្ឋមួយអាចបានកំណត់ ដោយអនុលោមតាមកថាខណ្ឌទី ១ (២) នៃមាត្រា ១០៣ ទោសពន្ធនាគារ និងដាក់កាតព្វកិច្ចលើរដ្ឋភាគីទាំងអស់ ដោយគ្មានការកែប្រែ។ មានតែតុលាការមួយគត់ដែលមានសិទ្ធិសម្រេចលើពាក្យបណ្តឹងឧទ្ធរណ៍។ រដ្ឋដែលដាក់ឱ្យអនុវត្តន៍សាលក្រមមិនអាចជំទាស់រារាំងបណ្តឹងប្រឆាំងនឹងសេចក្តីសម្រេច ឬបណ្តឹងសើរើដែលធ្វើឡើងដោយទណ្ឌិតនោះបានទេ។[158]

---

[155] មាត្រា ៣ (២) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[156] មាត្រា ១០៤ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[157] មាត្រា ១០៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[158] មាត្រា ១០៣ (១) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

### ១.២.ទណ្ឌកម្ម

ទណ្ឌកម្មដែល តុលាការអាចដាក់លើជនដែលមានពិរុទ្ធ មានដូចជាទោសពន្ធនាគារតាមចំនួនដែលបានកំណត់ ដែលមិនលើសពីចំនួនទោសអតិបរិមា៣០ឆ្នាំ ឬអស់មួយជីវិតបើត្រូវបានធ្វើយុត្តិកម្មដោយស្ថានទម្ងន់ដ៏ធ្ងន់នៃបទល្មើសព្រហ្មទណ្ឌ ព្រមទាំងកាលៈទេសៈឯកត្តបុគ្គលរបស់ពិរុទ្ធជន។

## ២.ការត្រួតពិនិត្យ និងលក្ខខណ្ឌដាក់ឱ្យអនុវត្តន៍ទោសពន្ធនាគារ

ការអនុវត្តទោសពន្ធនាគារត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ និងស្របតាមបទដ្ឋានគំរូនៃសន្ធិសញ្ញាអន្តរជាតិ ដែលត្រូវបានគេទទួលយកយ៉ាងទូលំទូលាយក្នុងការគ្រប់គ្រងថែទាំអ្នកទោស។ លក្ខខណ្ឌនៃការដាក់ពន្ធនាគារត្រូវគ្រប់គ្រងដោយច្បាប់របស់រដ្ឋ ដែលដាក់ឱ្យអនុវត្តន៍សាលក្រមនោះ តាមបទដ្ឋានគំរូនៃសន្ធិសញ្ញាអន្តរជាតិនានា ពិសេសគឺមិនផ្ទុយជាមួយអ្វីដែលតុលាកាបានកំណត់ ក្នុងការគ្រប់គ្រងថែទាំអ្នកទោស និងស្របហើយគ្មានករណីណាដែលលក្ខខណ្ឌទាំងនោះមានកម្រិត ធ្ងន់ជាង ឬស្រាលជាងកម្រិត ដែលកំណត់ចំពោះជនដែលត្រូវសម្រេចថា មានពិរុទ្ធភាពលើបទល្មើសស្រដៀងគ្នានៅក្នុង រដ្ឋដែលដាក់ឱ្យអនុវត្តន៍សាលក្រមនោះទេ រាល់ការប្រាស្រ័យទាក់ទងរវាងទណ្ឌិត និងតុលាការមិនត្រូវបានរារាំង និងត្រូវបានទុកជាការសម្ងាត់។[159]

### ២.១.ការកម្រិតដែនកំណត់នាំយកទៅជំនុំជម្រះ ឬដាក់ទោសចំពោះបទល្មើសផ្សេង

ទណ្ឌិតដែលស្ថិតក្រោមការគ្រប់គ្រងថែទាំរបស់រដ្ឋដែលដាក់ឱ្យអនុវត្តន៍សាលក្រមមិនត្រូវរងនូវការនាំខ្លួនយកទៅជំនុំជម្រះក្នុងការដាក់ទោស ឬការធ្វើបត្យាប័នឱ្យទៅរដ្ឋទីបីសម្រាប់ការប្រព្រឹត្ត ដែលពាក់ព័ន្ធមុនពេលបញ្ជូនជននេះទៅកាន់រដ្ឋដែលត្រូវដាក់ឱ្យអនុវត្តន៍សាលក្រមនោះទេ លើកលែងតែការនាំខ្លួនយកមកជំនុំជម្រះការដាក់ទោស ឬការធ្វើបត្យាប័ននេះ ត្រូវបានយល់ព្រមដោយតុលាការតាមការស្នើសុំរបស់រដ្ឋដែលដាក់ឱ្យអនុវត្តន៍សាលក្រមនោះ តុលាការត្រូវសម្រេចរឿងនេះ បន្ទាប់ពីបានស្ដាប់ទស្សនៈរបស់ទណ្ឌិតនោះ។ ការលើកឡើងខាងលើនេះនឹងលែងយកមកអនុវត្ត ប្រសិនបើទណ្ឌិតនោះស្ថិតនៅដោយស្ម័គ្រចិត្តលើសពី ៣០ ថ្ងៃលើទឹកដីរបស់រដ្ឋដែលដាក់ឱ្យអនុវត្តន៍សាលក្រម បន្ទាប់ពីបានទទួលទោសទាំងស្រុងដែលបានចាប់បង្ខំដោយតុលាការ ឬជននោះត្រឡប់ទៅដែនដីនៃរដ្ឋនោះវិញបន្ទាប់ពីខ្លួនបានចាកចេញ។[160]

---

[159] មាត្រា ១០៦ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[160] មាត្រា ១០៨ (១) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

## កថាខណ្ឌទី២៖ អំពីការត្រួតពិនិត្យដោយតុលាការលើការបន្ធូរបន្ថយទោស

រដ្ឋដែលដាក់ឱ្យអនុវត្តន៍សាលក្រម មិនត្រូវដោះលែងទណ្ឌិតមុនកាលផុតកំណត់នៃទោសដែលបានប្រកាសដោយតុលាការឡើយ។ មានតែតុលាការព្រហ្មទណ្ឌអន្តរជាតិមួយគត់ដែលមានសិទ្ធិសម្រេចក្នុងការបន្ធូរបន្ថយទោស និងត្រូវសម្រេចរឿង បន្ទាប់ពីបានស្តាប់ជននោះ។ នៅពេលដែលទណ្ឌិតទទួលទោសបានក្នុងកម្រិត ២/៣ នៃទោសទាំងមូល ឬបាន ២៥ ឆ្នាំករណីទោសពន្ធនាគារមួយជីវិត តុលាការនឹងពិនិត្យឡើងវិញនូវទោស ដើម្បីកំណត់ថា តើវាគួរត្រូវបន្ធូរបន្ថយ ឬអត់ ការត្រួតពិនិត្យនេះមិនត្រូវធ្វើឡើង មុនពេលនោះទេ។[161]

### ១.ការពិចារណាបន្ធូរបន្ថយទោស

ក្នុងករណីពិនិត្យឡើងវិញតាម តុលាការអាចបន្ធូរបន្ថយទោស កាលណាបើតុលាការឃើញថា មានកត្តាមួយ ឬច្រើនក្នុងចំណោមកត្តាទាំងឡាយ ដូចមានរាយខាងក្រោមនេះ៖

- ការស្ម័គ្រចិត្តតាំងពីដើម និងបន្តជាប់ជានិច្ចរបស់ជននោះ ដើម្បីរួមសហការជាមួយតុលាការ ក្នុងការស៊ើបអង្កេត និងការនាំខ្លួនយកទៅការជំនុំជម្រះរបស់តុលាការ។
- ជំនួយដោយស្ម័គ្រចិត្តរបស់ជននោះក្នុងការផ្តល់លទ្ធភាពដល់ការដាក់ឱ្យអនុវត្តន៍សាលក្រម និងដីការបស់តុលាការក្នុងករណីផ្សេងៗទៀត ជាពិសេសផ្តល់ជំនួយក្នុងការស្វែងរកទ្រព្យធនទាំងឡាយតាមដីកាផាកពិន័យ រឹបអូស ឬដីកាឱ្យជួសជុលការខូចខាតដែលអាចប្រើជាប្រយោជន៍សម្រាប់ជនរងគ្រោះ។
- កត្តាផ្សេងៗ ទៀតដែលបង្កើតឱ្យមានការផ្លាស់ប្តូរដ៏សំខាន់ និងច្បាស់លាស់នូវកាលៈទេសៈដែលសមល្មមដើម្បីធ្វើយុត្តិកម្មក្នុងការ បន្ថយទោស ដូចមានចែងក្នុងវិធាននីតិវិធី និងភស្តុតាង។[162]

ប្រសិនបើតុលាការកំណត់ក្នុងការពិនិត្យឡើងជាដំបូងរបស់ខ្លួន ថាវាមិនសមស្របនឹងបន្ធូរបន្ថយទោសទេនោះ ក្រោយមកតុលាការត្រូវពិនិត្យឡើងវិញលើចំណោទបញ្ហានៃការបន្ធូរបន្ថយទោស នៅចន្លោះពេលនោះដែលត្រូវអនុវត្តន៍លក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងវិធាននៃនីតិវិធី និងភស្តុតាង។

[161]មាត្រា ១១០ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[162]មាត្រា ១១០ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

### ២ .អំពីការផ្ទេរជននោះនៅពេលបញ្ចប់ការដាក់ទោស

នៅពេលបញ្ចប់ការដាក់ទោស ហើយជនដែលមិនមែនជាពលរដ្ឋរបស់រដ្ឋដែលដាក់ឱ្យអនុវត្តន៍សាលក្រម ឬសាលដីកា ដោយយោងតាមច្បាប់របស់រដ្ឋដែលដាក់ឱ្យអនុវត្តន៍ ជននោះអាចត្រូវបញ្ជូនទៅកាន់រដ្ឋដែលមានកាតព្វកិច្ចត្រូវទទួលខ្លួន ឬក៏រដ្ឋដទៃទៀតដែលយល់ព្រមទទួលខ្លួន ដោយពិចារណាលើការប្រាថ្នារបស់ជនដែលត្រូវផ្ទេរទៅកាន់រដ្ឋនោះ លើកលែងតែ រដ្ឋដែលដាក់ឱ្យអនុវត្តន៍សាលក្រម ឬសាលដីកានោះ អនុញ្ញាតឱ្យជននោះស្ថិតនៅលើទឹកដីរបស់ខ្លួនបន្តទៀត។ ហើយប្រសិនបើ គ្មានរដ្ឋណាមួយទទួលបន្ទុកសោហ៊ុយចំណាយសម្រាប់ការផ្ទេរជននោះទៅរដ្ឋផ្សេងទៀតទេដោយ អនុលោមទៅតាមច្បាប់ ដោយសោហ៊ុយចំណាយនោះជាបន្ទុករបស់តុលាការ។[163]

តាមបទប្បញ្ញត្តិនៃមាត្រា ១០៨ នៃលក្ខន្តិកៈទីក្រុងរ៉ូម រដ្ឋដែលដាក់ឱ្យអនុវត្តន៍សាលក្រម ឬសាលដីកាដោយយោងតាមច្បាប់របស់ជាតិខ្លួន អាចធ្វើបត្យាប័ន ឬអាចប្រគល់ជននោះទៅឱ្យរដ្ឋដែលស្នើសុំធ្វើបត្យាប័ន ឬសុំឱ្យមានការប្រគល់ខ្លួនជននោះ ដើម្បីវិនិច្ឆ័យទោស ឬដាក់ឱ្យអនុវត្តន៍ទោស។

## ផ្នែកទី២៖ សំណងសម្រាប់ជនរងគ្រោះ

សំណងជាទូទៅត្រូវបានធ្វើឡើងដោយ គោរពទៅតាមគោលការណ៍នៃសណង ឬវិធានរួមផ្សេងៗនៃលិខិតុបករណ៍អន្តរជាតិ ហើយត្រូវស្ថិតក្រោមនីតិវិធី នៃច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

## កថាខណ្ឌទី១៖ គោលការណ៍នៃសំណង

តុលាការ ត្រូវបង្កើតជាគោលការណ៍ដែលទាក់ទងដល់ការជួសជុល សម្រាប់ជនរងគ្រោះរួមមាន ការសង សំណងជំងឺចិត្ត និងការស្តារនីតិសម្បទាឡើងវិញ។ ដោយឈរលើមូលដ្ឋាននេះ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តុលាការអាចកំណត់តាមសំណើ ឬតាមការស្នើរបស់ខ្លួននៅក្នុងកាលៈទេសៈពិសេសៗ នៅកម្រិតវិសាលភាព និងទំហំនៃព្យសនកម្ម ការបាត់បង់ និងគ្រោះថ្នាក់ដល់ ឬទាក់ទង និងជនរងគ្រោះ ហើយថ្លែងពីគោលការណ៍ទាំងឡាយដែលខ្លួនកំពុងសំអាងលើ។

### ១.ការរួមផ្សំនៃវិធានផ្សេងៗ

អង្គជំនុំជម្រះមិនត្រឹមតែអនុវត្តន៍លក្ខន្តិកៈ វិធាន និងបទប្បញ្ញត្តិរបស់តុលាការប៉ុណ្ណោះទេ ថែមទាំងបានរំលឹកឡើងវិញនូវលក្ខណៈសកល និងសន្ធិសញ្ញាសិទ្ធិមនុស្សដែលចែងថា "សិទ្ធិទទួលបានសំណងគឺជា សិទ្ធិ

[163]មាត្រា ១០៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២៤
https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

មនុស្សដែលត្រូវបានបង្កើតឡើងយ៉ាងល្អ និងជាមូលដ្ឋាន៉។ លើសពីនេះ អង្គជំនុំជម្រះបានស្វែងរកការណែនាំពីអ្នកផ្សេងទៀតនៃលិខិតុបករណ៍អន្តរជាតិដែលតម្រូវតាមសំណួរនៃសំណងជនរងគ្រោះរួមមាន៖

- សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការរំលោភបំពានអំណាច
- គោលការណ៍ណែនាំស្តីពីយុត្តិធម៌ក្នុងបញ្ហាពាក់ព័ន្ធ និងជនរងគ្រោះកុមារ ឬសាក្សីនៃឧក្រិដ្ឋកម្ម
- សេចក្តីប្រកាសណៃរ៉ូប៊ី
- គោលការណ៍ និងការអនុវត្តល្អបំផុតស្តីពីការជ្រើសរើសកុមារចូលទៅក្នុងកងកម្លាំងប្រដាប់អាវុធ និងស្តីពីការបំផ្លិចបំផ្លាញ និងសមាហរណកម្មសង្គមនៃទាហានកុមារនៅក្នុងទ្វីបអាហ្វ្រិក
- គោលការណ៍ប៉ារីស។[164]

## ២.នីតិវិធីក្នុងការធ្វើសំណង

តុលាការ អាចចេញបញ្ជាដោយផ្ទាល់លើពិរុទ្ធជន ដោយបញ្ជាក់នៅការជួសជុលអ្វីដែលកើតឡើងពីការប្រព្រឹត្តរបស់ខ្លួន ដែលសមស្របទាក់ទងនឹងជនរងគ្រោះរួមមាន ការសងវិញនូវសំណងជំងឺចិត្ត និងការស្តារនីតិសម្បទាឡើងវិញ។ បើសមស្របតុលាការអាចបញ្ជា ការផ្តល់ឱ្យសម្រាប់ការជួសជុល ត្រូវធ្វើឡើងតាមរយៈមូលនិធិក្នុងភារៈគ្រប់គ្រងដូចមានចែងក្នុងមាត្រា ៧៩ ៖

- មូលនិធិក្នុងភារៈគ្រប់គ្រង ត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់សន្និបាតនៃរដ្ឋភាគីទាំងឡាយសម្រាប់ជាប្រយោជន៍នៃជនរងគ្រោះ និងក្រុមគ្រួសាររបស់ជនរងគ្រោះនោះ ដោយសារតែបទល្មើសព្រហ្មទណ្ឌ ដែលស្ថិតក្នុងវង្វង់យុត្តាធិការរបស់តុលាការ។
- តុលាការ អាចបញ្ជាឱ្យផ្ទេរប្រាក់ និងទ្រព្យសម្បត្តិផ្សេងៗ ដែលប្រមូលបាន ពីការផាកពិន័យ ឬពីការដកហូត ចូលទៅក្នុងមូលនិធិក្នុងភារៈគ្រប់គ្រងតាមដីការបស់តុលាការ។
- មូលនិធិក្នុងភារៈគ្រប់គ្រង ត្រូវចាត់ចែងស្របតាមលក្ខណៈវិនិច្ឆ័យដែលនឹងត្រូវកំណត់ដោយសន្និបាតនៃរដ្ឋភាគីទាំងឡាយ។[165]

---

[164] របាយការណ៍របស់តុលាការស្តីពីគោលការណ៍ពាក់ព័ន្ធ សំណងជនរងគ្រោះ ជំពូកទី ៣ ចំណុចទី១០ បោះពុម្ពឆ្នាំ២០១៣,ចូលមើលថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០២៤
https://asp.icc-cpi.int/sites/asp/files/asp_docs/ASP12/ICC-ASP-12-39-ENG.pdf

[165] មាត្រា ៧៩ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០២៤
https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

មុនពេលចេញបញ្ជាណាមួយតាមមាត្រានេះ តុលាការត្រូវមានការគិតគូរចំពោះការតំណាងក្នុងនាម ពិរុទ្ធជន ជនរងគ្រោះ ជនដែលមានផលប្រយោជន៍ ឬរដ្ឋដែលមានផលប្រយោជន៍ផ្សេងៗទៀត។ ជាទូទៅ សំណងដែលសំខាន់សម្រាប់ជនរងគ្រោះនោះ គឺទទួលភាពយុត្តិធម៌ក្នុងការដំណើរនៃការជំនុំជម្រះ។

## ២.១.លក្ខខណ្ឌនៃការធ្វើសំណង

ផ្អែកលើមូលដ្ឋានខាងលើ អង្គជំនុំជម្រះបានគូសបញ្ជាក់ពីគោលការណ៍ដូចជាសេចក្តីថ្លៃថ្នូរ ការដែល មិនរើសអើង និងការមិនមាក់ងាយ ជនរងគ្រោះទាំងអស់ត្រូវទទួលការព្យាបាលដោយស្មើភាព និងដោយមិនគិត ពីថាតើពួកគេបានចូលរួមក្នុងដំណើរការកាត់ក្តីនោះទេ។ ការយកចិត្តទុកដាក់ជាពិសេស និងអាទិភាពត្រូវតែ បានបង់ទៅតាមតម្រូវការរបស់ជនរងគ្រោះក្នុងស្ថានភាពជាក់លាក់ដូចជាកុមារ ឬជនរងគ្រោះនៃអំពើហិង្សាផ្លូវ ភេទ ឬក៏យេនឌ័រ (រូបរាងកាយ)។ ជនរងគ្រោះត្រូវបានចាត់ទុកដោយការគោរពសេចក្តីថ្លៃថ្នូរ និងសិទ្ធិមនុស្ស រួម ទាំងសិទ្ធិទទួលបានសុវត្ថិភាព និងឯកជនភាព។ សំណងគួរតែត្រូវបានផ្តល់ ជៀសវាងការមាក់ងាយបន្ថែមទៀត ដល់ជនរងគ្រោះ និងការរើសអើងពីគ្រួសារ និងសហគមន៍របស់ពួកគេ។ ហើយសំណងនឹងមិនត្រូវបានប៉ះពាល់ ដល់រង្វាន់ ឬអត្ថប្រយោជន៍ដែលទទួលបានដោយជនរងគ្រោះពីស្ថាប័នផ្សេងទៀត។

## ២.២.ការអនុវត្តរបស់តុលាការ

បន្ទាប់ពីជនណាម្នាក់ត្រូវថ្កោលទោសចំពោះបទល្មើសព្រហ្មទណ្ឌ ក្នុងយុត្តាធិការរបស់ខ្លួន តុលាការអាច កំណត់ថាតើចាំបាច់ត្រូវរកវិធានការ តាមកថាខណ្ឌទី១ នៃមាត្រា៩៣ ដើម្បីដាក់ឱ្យមានប្រសិទ្ធភាពនូវបញ្ជាដែល ខ្លួនអាចធ្វើឡើងតាមមាត្រានេះ។ នៅក្នុងមាត្រា៩១ ក៏បានបង្ហាញពី សិទ្ធរបស់តុលាការក្នុងប្រតិបត្តិការនៃការ ផែកឆេរ ឬការធ្វើអត្តសញ្ញាណកម្ម តាមដាន បញ្ឈប់ ឬរឹបអូសផលដែលបានមកពីការលក់ទ្រព្យ ទ្រព្យសម្បត្តិ ទ្រព្យធន និងឧបករណ៍ប្រើសំរាប់ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ក្នុងគោលបំណងនៃការរឹបអូសជាយថាហេតុ ដោយមិនមានយុត្តិធម៌ ចំពោះសិទ្ធិនៃតតីយជនផ្សេង។[166] រដ្ឋភាគី ត្រូវដាក់ឱ្យមានប្រសិទ្ធភាពនូវសេចក្តីសម្រេច តាមមាត្រានេះ ហាក់ដូចជាបទបញ្ញត្តិនៃមាត្រា១០៩ អាចអនុវត្តន៍បានចំពោះការផាកពិន័យ និងការរឹបអូស។ គ្មានអ្វីមួយក្នុងច្បាប់នេះ ត្រូវបានយកទៅបកស្រាយឱ្យមានលក្ខណៈអគតិធម៌ចំពោះសិទ្ធិជនរងគ្រោះតាមច្បាប់ ជាតិ ឬអន្តរជាតិឡើយ។ ទ្រព្យដែលទទួលបានពីការរឹបអូសផលដែលបានមកពីការលក់ ទ្រព្យផ្សេងៗ ទៀត ឬ ឧបករណ៍ប្រើសម្រាប់ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌអាចនឹងត្រូវទូរទាត់ទៅជាសំណងសម្រាប់ជនរងគ្រោះ។[167]

---

[166] មាត្រា ៩៣ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[167] មាត្រា ៧៩ (១) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

### ២.៣.អ្នកទទួលផលនៃសំណង

សំណងអាចត្រូវបានផ្តល់ឱ្យដោយផ្ទាល់ និងដោយប្រយោល ដល់ជនរងគ្រោះ សមាជិកគ្រួសារនៃជនរងគ្រោះផ្ទាល់ រួមទាំងអ្នកណាដែលព្យាយាមរារាំងការប្រព្រឹត្តិនៃឧក្រិដ្ឋកម្មមួយ ឬច្រើន និងអ្នកដែលរងទុក្ខការខូចខាតផ្ទាល់ខ្លួនជាលទ្ធផលនៃបទល្មើស ដោយមិនគិតថាតើពួកគេបានចូលរួមក្នុងដំណើរការកាត់ក្តីនោះទេ។ ការផ្តល់សំណង និងត្រូវធ្វើឡើងដោយការពិគ្រោះយោបល់ជាមួយជនរងគ្រោះអំពីបញ្ហាសំណង ដូចជាអត្តសញ្ញាណអ្នកទទួលផល អាទិភាព និងឧបសគ្គក្នុងការធានាសំណង។

- ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ៖ សំណងសមរម្យគួរតែត្រូវបានផ្តល់ជូនដល់ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងផ្អែកលើយេនឌ័ ឬវិធានចាំបាច់ដែលត្រូវអនុវត្តដើម្បីធានាថាស្ត្រី និងកុមារីត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងវិធីដ៏សំខាន់ និងស្មើភាពគ្នាក្នុងការកែប្រែ និងការអនុវត្តដីកាសំណង។
- ជនរងគ្រោះជាកុមារ៖ គ្រោះថ្នាក់ដែលទាក់ទងនឹងអាយុរបស់ជនរងគ្រោះ ក៏ដូចជាផលប៉ះពាល់ផ្សេងៗនៃឧក្រិដ្ឋកម្មលើកុមារា និងកុមារីត្រូវយកមកពិចារណា។ រាល់ការសម្រេចចិត្តលើសំណងទាក់ទងនឹងកុមារគួរតែត្រូវបានអនុលោមតាម អនុសញ្ញាស្តីពីសិទ្ធិកុមារ។ ព័ត៌មានដែលអាចយល់បានអំពីដំណើរការសំណងត្រូវផ្តល់ដល់កុមារជនរងគ្រោះ និងអ្នកដែលធ្វើសកម្មភាពជំនួសពួកគេ ហើយជនរងគ្រោះជាកុមារ និងត្រូវពិគ្រោះការសម្រេចចិត្តលើសំណង។

វិសាលភាពនៃសំណង អាចត្រូវបានប្រគល់ជូនបុគ្គល ឬក្រុម យ៉ាងណាវិធីសាស្ត្ររួមគួរតែត្រូវបានប្រើប្រាស់ដើម្បីធានាថា សំណងទៅដល់ជនរងគ្រោះដែលមិនស្គាល់អត្តសញ្ញាណ។ ចំពោះសំណងបុគ្គល និងសមូហភាពអាចត្រូវបានផ្តល់ជូនក្នុងពេលដំណាលគ្នា សំណងបុគ្គលគួរតែជៀសវាងការបង្កើតភាពតានតឹងនៅក្នុងសហគមន៍។ សំណងសមូហភាពគួរដោះស្រាយជនរងគ្រោះដោយជនរងគ្រោះជាបុគ្គល និងសមូហភាព។ ហើយតុលាការគួរតែពិចារណាលើការផ្តល់សេវាវេជ្ជសាស្ត្រ ការស្តារនីតិសម្បទាទូទៅ លំនៅដ្ឋាន ការអប់រំ និងការបណ្តុះបណ្តាល។[168] លើសពីនេះទៅទៀត គេឃើញថា បើជនណាម្នាក់ដែលត្រូវ តុលាការចាប់ខ្លួន ឬសម្រេចឱ្យមានពិរុទ្ធភាព ហើយបន្ទាប់តុលាការបានរកឃើញថា ការសម្រេចនោះ ធ្វើឡើងដោយសារតែកំហុសរបស់តុលាការ បែបនេះតុលាការមានកាតព្វកិច្ច ត្រូវសងជំងឺចិត្តលើជនត្រូវបានចាប់ខ្លួន ឬសម្រេចថាមានពិរុទ្ធភាពនោះ។

---

[168] របាយការណ៍របស់តុលាការស្តីពីគោលការណ៍ពាក់ព័ន្ធ សំណងជនរងគ្រោះ ជំពូកទី៣ ចំណុចទី១២ បោះពុម្ពឆ្នាំ២០១៣,ចូលមើលថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤
https://asp.icc-cpi.int/sites/asp/files/asp_docs/ASP12/ICC-ASP-12-39-ENG.pdf

# កថាខណ្ឌទី២៖ ការសងជំងឺចិត្តលើជនត្រូវបានចាប់ខ្លួន ឬសម្រេចថាមានពិរុទ្ធភាព

## ១.ការសងជំងឺចិត្តជនរងគ្រោះដោយសារការចាប់ខ្លួន

ការសងជំងឺចិត្តចំពោះជនដែលត្រូវបានចាប់ខ្លួន ឬសម្រេចថាមានពិរុទ្ធភាព ជនទាំងឡាយណាដែលជាជនរងគ្រោះពីការចាប់ខ្លួន ឬឃុំខ្លួនដោយខុសច្បាប់ មានសិទ្ធិបង្ខំឱ្យតុលាការសងជំងឺចិត្តមកខ្លួនវិញ។ ដូចដែលយើងបានដឹងហើយថា ការអនុវត្តច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តជាតិត្រូវគោរពទៅតាមវិធានអន្តរជាតិ ពិសេសនោះគឺគោលការណ៍សិទ្ធិមនុស្ស ដូចនេះការចាប់ ឬឃុំខ្លួនជនណាម្នាក់ត្រូវស្របតាម វិធានអន្តរជាតិ ដូចជា៖ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (មាត្រា ៩ កថាខណ្ឌ ៥) ដែលបានលើកឡើងថាជនដែលរងគ្រោះដោយសារតែការចាប់ខ្លួន ឬឃុំខ្លួនដោយមានសិទ្ធិទាមទារសំណងវិញ។[169]

### ១.១.ការអនុវត្តចំពោះសំណងសម្រាប់ការផ្តន្ទាទោសដោយអយុត្តិធម៌

ជនណាម្នាក់ ត្រូវបានតុលាការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌដោយសាលក្រមស្ថាពរហើយ បន្ទាប់មកពិរុទ្ធភាពរបស់ជននោះត្រូវបានតុលាការសើរើឡើងវិញ ដោយសារអង្គហេតុថ្មី ឬដែលទើបរកឃើញថ្មី ដែលបានបង្ហាញយ៉ាងពិតប្រាកដថាមានកំហុសឆ្គងខាងតុលាការ ដូច្នេះជនដែលទទួលរងទណ្ឌកម្មដែលជាលទ្ធផលនៃការសម្រេចថា មានពិរុទ្ធភាពត្រូវបានទទួលសំណងជំងឺចិត្តតាមច្បាប់បាន។[170] ត្រង់ចំណុចនេះយើងក៏បានឃើញយ៉ាងច្បាស់នៅក្នុង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤ កថាខណ្ឌ ៦ បានចែងថា នៅពេលជនណាម្នាក់ ត្រូវបានប្រកាសឱ្យមានពិរុទ្ធពីបទព្រហ្មទណ្ឌជាស្ថាពរ ហើយក្រោយមក ការប្រកាសនេះ ត្រូវបានបដិសេធ ឬត្រូវបាន លើកលែងទោស ដោយហេតុថាអង្គហេតុថ្មី ឬដែលបានរកឃើញថ្មីបញ្ជាក់យ៉ាងច្បាស់ថាមានការខុសឆ្គងពីសំណាក់តុលាការ ជនដែលទទួលរងគ្រោះ ដោយសារ ការដាក់ទោសនេះ ត្រូវទទួលសំណងស្របតាមច្បាប់ លើកលែងតែមានការកំណត់ បង្ហាញថា ការមិនលាតត្រដាងអាថ៌កំបាំងនៃការពិតទាន់ពេល បណ្តាលមកពីជននោះទាំងស្រុង ឬមួយផ្នែក។[171] តែយ៉ាងណាសំណងនឹងមិនត្រូវបានអនុវត្តទេប្រសិនបើភស្តុតាងនោះ មិនបានបង្ហាញអំពី អង្គហេតុ ដែលគ្មាននរណាដឹងនៅពេលជំនុំជម្រះនោះ។

---

[169] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៩ កថាខណ្ឌ ៥,ចូលមើលថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០២៤ https://cambodia.ohchr.org/sites/default/files/Treaty/ICCPR_2009K.pdf

[170] មាត្រា ៨៥ (២) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០២៤ https://icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

[171] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤ កថាខណ្ឌ ៦ចូលមើលថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០២៤ https://cambodia.ohchr.org/sites/default/files/Treaty/ICCPR_2009K.pdf

## ២.កាលៈទេសៈពិសេសដែលចាត់ទុកជាកំហុសធ្ងន់

នៅក្នុងកាលៈទេសៈពិសេស នៅពេលដែលតុលាការរកឃើញនូវ ភស្តុតាងដែលពិតប្រាកដដែលបង្ហាញថា មានកំហុសឆ្គងខាងតុលាការធ្ងន់ធ្ងរ និងជាក់ស្តែង តុលាការអាច ដោយអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន និងយោងទៅតាមលក្ខណៈ វិនិច្ឆ័យនៅក្នុងវិធាននៃនីតិវិធី និងភស្តុតាង ផ្តល់សំណងជំងឺចិត្តចំពោះជនដែលត្រូវបានដោះលែងពីការឃុំខ្លួន បន្ទាប់ពីចេញសាលក្រមស្ថាពរឱ្យរួចខ្លួន ឬបន្ទាប់ពីបន្ទាប់ដំណើរការជម្រះក្តី ដោយសារមូលហេតុខាងលើ។[172] ក្នុងការបង្កើតចំនួននៃសំណងណាមួយស្របតាមមាត្រា ៨៥ កថាខណ្ឌ ៣ អង្គជំនុំជម្រះដែលត្រូវបានចាត់តាំងនៅក្រោមវិធាន ១៧៣ កថាខណ្ឌ១ ត្រូវពិចារណាលើ ផលវិបាកនៃកំហុស និងបង្ហាញការបំពាន់ធ្ងន់ធ្ងរដល់ដំណើរនៃការជម្រះក្តី ព្រមទាំងភាពយុត្តិធម៌លើបុគ្គល គ្រួសារ ស្ថានភាពសង្គម និងវិជ្ជាជីវៈរបស់អ្នកដាក់ពាក្យស្នើសុំ។

ឧទាហរណ៍៖ បន្ទាប់ពីចាប់ខ្លួន និងការអនុវត្តទោសរបស់លោក Jean-Pierre Bemba ត្រូវបានលុបចោលក្នុងឆ្នាំ ២០១៨ គាត់បានស្វែងរកសំណងពីតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ចំនួនប្រហែល ៦៩លានអឺរ៉ូ (ប្រហែល ៧៧ លានដុល្លារ) នេះបើយោងតាមអត្ថបទកាសែត កិច្ចសន្ទនា។ ការទាមទារទាំងនេះគឺផ្អែកលើសមាសភាគពីរ៖ សំណើសុំសំណងដោយសារតែ " កាលៈទេសៈពិសេសដែលចាត់ទុកជាកំហុស ដោយយុត្តិធម៌ និងធ្ងន់ធ្ងរ" តាមមាត្រា ៨៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម និងសំណើសំណងដែលទាក់ទងនឹងការគ្រប់គ្រងមិនត្រឹមត្រូវនៃទ្រព្យសម្បត្តិរបស់គាត់ ខណៈដែលទ្រព្យនោះត្រូវបានបង្កកដោយតុលាការ។ ទោះជាយ៉ាងណាក៏ដោយ នៅថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០២០ អង្គមុនជំនុំជម្រះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានច្រានចោលការទាមទារសំណងរបស់លោក។ ដោយតុលាការបានរកឃើញថាគាត់បានខកខានក្នុងការបង្ហាញថាគាត់បានទទួលរងនូវភាពធ្ងន់ធ្ងរ និងបង្ហាញភាពខុសឆ្គងនៃយុត្តិធម៌ដូចដែលបានកំណត់ដោយមាត្រា ៨៥។ លើសពីនេះ អង្គជំនុំជម្រះបានសម្រេចថាវាមិនមានយុត្តាធិការលើបណ្តឹងទាមទារសំណងទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់គាត់ដែលស្ថិតក្រៅ វិសាលភាពនៃមាត្រា ៨៥ ដូច្នេះ Jean-Pierre Bemba មិនបានទទួលសំណងណាមួយពីតុលាការទេ។ [173] ទោះជាយ៉ាងណាក្តី ក្នុងករណីនេះបានធ្វើឱ្យយើងមើលឃើញអំពីសកម្មភាព ក្នុងការទាមទារសំណង ជំងឺចិត្តលើជនត្រូវបានចាប់ខ្លួន ឬសម្រេចថាមានពិរុទ្ធភាពដោយសារកំហុសរបស់តុលាការក្រោមមាត្រា ៨៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ។

---

[172] មាត្រា ៨៥ (៣) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ,ចូលមើលថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០២៤

[173] ការច្រានចោលការទាមទារសំណង និងការខូចខាតរបស់លោក Bemba,ចូលមើលថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០២៤ https://www.icc-cpi.int/news/icc-pre-trial-chamber-ii-rejects-mr-bembas-claim-compensation-and-damages

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីពួកយើងបានសិក្សា និងស្រាវជ្រាវដោយយកចិត្តទុកដាក់កន្លងមកដើម្បីបញ្ចប់សារណាមួយនេះ ក្រោមប្រធានបទ៖ ការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ពួកយើងបានខិតខំស្វះស្វែង ប្រមូលទិន្នន័យ ដើម្បីទទួលបានព័ត៌មានដ៏ត្រឹមត្រូវ និងក្បោះក្បាយ ទើបនាំឱ្យក្រុមយើងអាចដកស្រង់នូវសេចក្តីសន្និដ្ឋាន ស្របតាមបទដ្ឋាននៃការស្រាវជ្រាវដូចខាងក្រោម៖

បើយោងតាមការសង្កេតចំពោះលទ្ធផលនៃការស្រាវជ្រាវ ពួកយើងយល់ថាតុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ចក្នុងការបង្ក្រាប ក៏ដូចជារារាំងអំពើទាំងឡាយដែលចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌអន្តរជាតិ ដូចជាបទល្មើស( បទល្មើសប្រល័យពូជសាសន៍ បទល្មើសឧក្រិដ្ឋកម្មសង្គ្រាម បទល្មើសប្រឆាំងមនុស្សជាតិ និងបទល្មើសឈ្លានពាន)។ ក្នុងនោះផងដែរដំណើរការនៃការអនុវត្តច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិជាកត្តាស្នូលមួយបានជួយជំរុញឱ្យតុលាការសម្រេចនូវគោលបំណងរបស់ខ្លួនដែលមានដូចជា ការផ្តួចផ្តើម ពិនិត្យបឋម ស៊ើបអង្កេត ការចាប់ខ្លួន ឬកោះហៅឱ្យចូលខ្លួន ការជំនុំជម្រះ ការផ្តន្ទាទោសព្រមទាំងការទទួលខុសត្រូវលើបទល្មើសព្រហ្មទណ្ឌអន្តរជាតិ យ៉ាងណាក៏ដោយការចាប់ខ្លួន ឬនាំយកមកជំនុំជម្រះ គឺជាភារកិច្ចរបស់ រដ្ឋភាគី ដោយសារតែ តុលាការមានត្រឹមតែ ដែនសមត្ថកិច្ចលើបទល្មើសព្រហ្មទណ្ឌអន្តរជាតិដូចដែលបានលើកឡើងខាងលើ ប៉ុន្តែគ្មានដែនដីទេ ដូចនេះហើយរដ្ឋនីមួយៗ មានតួនាទី ធានាក្នុងកិច្ចសហប្រតិបត្តការ និងជ្រោមជ្រែងដល់នីតិវិធីណាមួយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដូចដែលមានចែងក្នុង ភាគទី ៩ នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលនាំឱ្យបេសកកម្ម ឬគោលបំណងរបស់តុលាការណាមួយទទួលបានជោគជ័យ។ យើងបានដឹងមកហើយថាកន្លងមកជាច្រើនឆ្នាំនៃការរស់នៅ ដោយអវត្តមានតុលាការអន្តរជាតិដែលមានយុត្តាធិការ លើបទល្មើសព្រហ្មទណ្ឌអន្តរជាតិ ធ្វើឱ្យពិភពលោកធ្លាក់ចូលក្នុងរូបភាពនៃការកាប់សម្លាប់ យ៉ាងឃោរឃៅ ទោះជាយ៉ាងណាក៏ដោយរូបភាពទាំងនេះត្រូវបានបាត់បង់ទៅវិញបន្តិចម្តងៗ បន្ទាប់ពីការលេចឡើងនូវស្ថាប័នអចិន្ត្រៃយ៍ ដែលមានយុត្តាធិការលើបទល្មើសព្រហ្មទណ្ឌអន្តរជាតិហៅថាតុលាការព្រហ្មទណ្ឌអន្តរជាតិ។ តុលាការនេះបានធ្វើឱ្យបុគ្គលមួយចំនួន ខ្លាចរអា និងមិនហ៊ានប្រព្រឹត្តនូវអំពើណាមួយដែលត្រូវបានចាត់ទុកជា បទឧក្រិដ្ឋ។ មូលហេតុទាំងអស់នេះហើយបានផ្តល់នូវសារៈប្រយោជន៍សម្រាប់ជីវិតមនុស្សជាតិ ដែលចៀសផុតពីទុក្ខវេទនា ឬការកាប់សម្លាប់ផ្សេងៗ ដែលជាលទ្ធផលនៃបទល្មើសណាមួយ។

សរុបជារួមមកតុលាការព្រហ្មទណ្ឌអន្តរជាតិពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ប្រជាជាតិក្នុងសកលលោកទាំងមូល។ តុលាការនេះបានបង្កើតនូវយុត្តាធិការសម្រាប់កាត់ទោសលើបុគ្គលទាំងឡាយណា ឬក៏មេដឹកនាំ ដែលបានប្រព្រឹត្តបទល្មើស យ៉ាងឃោរឃៅ នាំឱ្យមានព្យសនកម្មដល់មនុស្សជាតិ។ តុលាការនេះបាន

បង្កើតឡើងក្នុងគោលបំណងទប់ស្កាត់ការរីករាលដាលនៃបទល្មើសព្រហ្មទណ្ឌអន្តរជាតិតាមរយៈការចាប់ខ្លួន និងនាំយកបណ្តាជនដែលបានប្រព្រឹត្តទាំងនោះមកធ្វើការកាត់ទោសតាមផ្លូវច្បាប់។ សកម្មភាពទាំងអស់នេះ ហើយបានធ្វើឱ្យ ពិភពលោកទាំងមូលទទួលបាននូវសុខសន្តិភាព និងការរស់នៅដោយគ្មានការកាប់សម្លាប់ធ្ងន់ធ្ងរបន្តទៅទៀត ដែលឈានដល់ការលុបបំបាត់អំពើឃោរឃៅក្នុងពិភពលោក មិនតែប៉ុណ្ណោះតុលាការនេះ ក៏បានចូលរួមចំណែកក្នុងការគាំពារ ឬលើកកម្ពស់យុត្តិធម៌អន្តរជាតិ និងធានាក្នុងការទប់ស្កាត់ ការកើតឡើងនៃបទល្មើសព្រហ្មទណ្ឌអន្តរជាតិព្រមទាំងផ្តល់នូវកាតព្វកិច្ចចំពោះរដ្ឋដែលជាភាគីនៃតុលាការនោះតាមរយៈកិច្ចសហប្រតិបត្តិការនានាដែលជាប់ពាក់ព័ន្ធជាមួយបទល្មើស។

# អនុសាសន៍

# អនុសាសន៍

យោងតាមការសិក្សាស្រាវជ្រាវខាងលើដែលប្រមូលបានពីឯកសារនានា ក្រោមប្រធានបទ៖ ការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ រួចមកយើងឃើញថា តុលាការនេះជាតុលាការមួយដែលបង្កើតឡើងសម្រាប់បង្ក្រាប រាល់បទល្មើសព្រហ្មទណ្ឌ ដែលកើតមានក្នុងសមាគមន៍អន្តរជាតិ តែយ៉ាងណាមិញគោលគំនិតរបស់តុលាការនេះ វាអាចធ្វើទៅបានលុះត្រាតែដំណើរនៃការអនុវត្តនូវច្បាប់របស់តុលាការអាចប្រព្រឹត្តដោយមានគាំទ្រ និងចូលរួមពីស្ថាប័នពាក់ព័ន្ធផ្សេងៗ ជាពិសេសនោះទៀតគឺរដ្ឋភាគី ដែលជាកត្តាជំរុញមួយក្នុងការ ឱ្យធ្វើការអនុវត្តរបស់តុលាការទទួលបានជោគជ័យ។ ត្រង់ការលើកឡើងនេះដែរក្នុងស្រាវជ្រាវនេះ យើងបានឃើញមាននូវ ផលវិបាក និងឧបសគ្គមួយចំនួនសម្រាប់ការអនុវត្តច្បាប់របស់តុលាការ ដែលជាមូលដ្ឋានមួយសម្រាប់ក្រុមពួកយើង ធ្វើការសិក្សាស្វែងយល់អំពីគំនិតក្នុងការចៀសវាង និងសម្រួលដល់ឧបសគ្គដែលកើតមានទាំងនោះ ដូច្នេះយើងក៏សូម អនុញ្ញាតបង្ហាញនូវទស្សនៈក្នុងការយល់ឃើញ ដើម្បីឱ្យការអនុវត្តរបស់តុលាការ ឱ្យកាន់តែប្រសើរឡើង តុលាការព្រហ្មទណ្ឌអន្តរជាតិគួរតែពិចារណាលើ៖

- ដោយសារតែដំណើរចូលរួមសហប្រតិបត្តការរបស់រដ្ឋភាគីពិតជាសំខាន់ក្នុងការអនុវត្តច្បាប់ ហើយពេលខ្លះរដ្ឋដែលជាភាគីបានបដិសេធមិនយល់ព្រមតាមការស្នើសុំរបស់តុលាការ ដូចដែលយើងបានលើកជា ករណីសិក្សា ក្នុងអត្ថបទស្រាវជ្រាវ ហេតុនេះតុលាការគួរតែស្វែងរកនូវយុទ្ធសាស្ត្រណាមួយដើម្បីបញ្ចៀសបញ្ហាទាំងនេះ ឧទាហរណ៍៖ ការបង្កើតនូវ វិធានទណ្ឌកម្មលើរដ្ឋភាគីដែលមិនអនុវត្តន៍តាមការស្នើសុំ ឬដីកាណាមួយ
- គួរតែកំណត់នូវមូលហេតុ ឬធាតុផ្សំ ចំពោះលក្ខខណ្ឌរបស់ក្រុមប្រឹក្សាសន្តិសុខក្នុងការអនុវត្តសិទ្ធរបស់ខ្លួនចូលក្នុងសកម្មភាពតុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីចៀសវាងការជ្រៀតជ្រែក ពីឧបសគ្គនយោបាយ របស់ក្រុមប្រឹក្សាសន្តិសុខ
- គួរតែបង្កើតនូវឥទ្ធិពលបន្ថែមចំពោះយុត្តាធិការ ឬសិទ្ធផ្សេងៗ ណាមួយក្នុងការសម្រួលដល់ការអនុវត្តច្បាប់របស់តុលាការ
- គួរតែបង្កើតស្ថាប័ន ដែលមានសមត្ថកិច្ច ផ្ទាល់ខ្លួនក្នុងដែនដីនៃរដ្ឋភាគី ដើម្បីផ្តល់ភាពងាយស្រួលក្នុងការស៊ើបអង្កេតបទល្មើស។

យើងជឿជាក់ថា ទស្សនៈ ឬគំនិតដ៏ស្តួចស្តើងទាំងនេះ ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវអាចជួយជំរុញឱ្យតុលាការទទួលបាន មតិចូលរួមក្នុងការកែលម្អ ចំពោះចំណុចណាដែលអាចនឹងសម្រួលដល់ដំណើរការ ហើយធ្វើឱ្យការអនុវត្តច្បាប់របស់តុលាការកាន់តែប្រសើរជាងមុន ក្នុងកាត់បន្ថយនូវអំពើដែលជា ឧក្រិដ្ឋកម្មអន្តរជាតិ។

# ឯកសារយោង

# ឯកសារយោង

## ១.ច្បាប់

- រដ្ឋធម្មនុញ្ញអង្គការសហប្រជាជាតិ ១៩៤៥

  https://treaties.un.org/doc/publication/ctc/uncharter.pdf
- អនុសញ្ញាស្តីពីការទប់ស្កាត់ និងការដាក់ទណ្ឌកម្មនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ១៩៥១

  https://shorturl.at/Qala2
- អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ១៩៥៣

  https://www.echr.coe.int/documents/d/echr/convention_ENG
- អនុសញ្ញាក្រុងវៀនស្តីពី ទំនាក់ទំនងការទូត ឆ្នាំ ១៩៦៥

  https://rb.gy/6ltwlp
- របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិស្តីពីការងារនៃសម័យប្រជុំលើកទីសែសិបប្រាំមួយរបស់ខ្លួន ថ្ងៃទី ០២ ខែឧសភា -២២ ខែកក្កដា ឆ្នាំ ១៩៩៤ កំណត់ត្រាផ្លូវការនៃមហាសន្និបាត សម័យប្រជុំលើកទី ៤៩ ទំព័រទី៤៤

  https://legal.un.org/ilc/documentation/english/reports/a_49_10.pdf
- ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ២០០២

  https://www.icc-cpi.int/about/the-court
- ឯកសារស្តីពីការណែនាំនៅលើកិច្ចសហប្រតិបត្តិការរបស់រដ្ឋជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិះបទពិសោធន៍ និងអាទិភាព ២០០២

  https://www.icc-cpi.int/sites/default/files/2022-04/66-Recommendations-Flyer-ENG.pdf
- រដ្ឋអាជ្ញា v. Lubanga, ICC សាលក្រមរបស់អង្គជំនុំជម្រះឧទ្ធរណ៍របស់ Thomas Lubanga Dyilo ICC ស្តីពីផ្លូវច្បាប់ ២០០៦

  https://haguejusticeportal.net/Docs/Commentaries%20PDF/Senier_Lubanga_EN.pdf
- ឯកសារគោលនយោបាយស្តីពីផលប្រយោជន៍យុត្តិធម៌ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ២០០៧

  ICCOTPInterestsOfJustice.pdf (icc-cpi.int)
- រដ្ឋអាជ្ញា v. Katanga និងNgudjolo, ICC PT១ ឆ. I, ការសម្រេចចិត្តលុបចោលការហាមឃាត់ទំនាក់ទំនង និងការទំនាក់ទំនងរវាង Germain Katanga និងMathieu Ngudjolo Chui ឆ្នាំ ២០០៨

  https://www.icc-cpi.int/sites/default/files/CourtRecords/CR2008_05172.PDF
- ច្បាប់ស្តីពីការិយាល័យរដ្ឋអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ២០០៩

https://shorturl.at/PjNpo

- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ ២០០៩

  https://cambodia.ohchr.org/sites/default/files/Treaty/ICCPR_2009K.pdf
- វិធាននៃនីតិវិធី និងភស្តុតាង ២០១៣

  https://www.icc-cpi.int/sites/default/files/Publications/Rules-of-Procedure-and-Evidence.pdf
- ឯកសារគោលនយោបាយស្តីពីការពិនិត្យបឋម របស់តុលាការព្រហ្មទណ្ឌអន្តរជាតិឆ្នាំ ២០១៣

  OTP - Policy Paper Preliminary Examinations 2013.pdf (icc-cpi.int)
- របាយការណ៍ការពិនិត្យបឋម លើស្ថានភាពប្រទេសអាហ្វហ្គានីស្ថាន ឆ្នាំ ២០១៤

  https://www.icc-cpi.int/sites/default/files/iccdocs/otp/OTP-Pre-Exam-2014.pdf
- របាយការណ៍ទាក់ទងនឹងស្ថានភាពប្រទេសកូតឌីវ័រ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ឆ្នាំ២០២១

  https://www.icc-cpi.int/sites/default/files/CaseInformationSheets/gbagbo-goudeEng.pdf
- អង្គជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ទាក់ទងនឹងស្ថានភាពនៅក្នុងសាធារណរដ្ឋហ្វីលីពីន ឆ្នាំ២០២៣

  https://www.icc-cpi.int/sites/default/files/CourtRecords/0902ebd18043e50f.pdf

## ២.សៀវភៅ

- សៀវភៅ ការអនុវត្តច្បាប់របស់តុលាការព្រហ្មអន្តរជាតិ បោះពុម្ពផ្សាយ ២០១៥ ដោយ មេធាវី Beth Van Schaack និងសាស្ត្រាចារ្យ Ronald Slye

  https://archive.org/details/internationalcri0000vans/page/144/mode/1up?view=theater

- សៀវភៅណែនាំអំពីការអនុវត្តមុនជំនុំជម្រះ ២០១៥ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

  https://www.icccpi.int/sites/default/files/iccdocs/other/PreTrial_practice_manual_(September_2015).pdf
- សៀវភៅក្រុមប្រឹក្សាសន្តិសុខ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ២០១៨,

  http://surl.li/qnlxt

- សៀវភៅ"មកដឹងអំពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ២០២១" បោះពុម្ពផ្សាយដោយស្ថាប័នតុលាការព្រហ្មអន្តរជាតិ

  https://www.icc-cpi.int/sites/default/files/Publications/understanding-the-icc.pdf

- សៀវភៅប្រវត្តិនយោបាយហិង្សារបស់សាធារណរដ្ឋអាហ្វ្រិកកណ្តាល ២០២៣

https://reliefweb.int/report/central-african-republic/conflict-diagnostic-central-african-republic-2023

### ៣.លិខិតបទដ្ឋានអន្តរជាតិ

- សន្និសីទការទូត ១៩៩៨ របស់អង្គការសហប្រជាជាតិ នៃអ្នកតំណាងពេញសមត្ថភាពលើការបង្កើតរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ
  https://www.legal-tools.org/doc/2c77c2/pdf/
- កិច្ចព្រមព្រៀងទំនាក់ទំនងដែលបានចរចារវាង តុលាការព្រហ្មទណ្ឌអន្តរជាតិ និងអង្គការសហប្រជាជាតិ ២០០៣
  https://legal.un.org/ola/media/UN-ICC_Cooperation/UN-ICC%20Relationship%20Agreement.pdf
- របាយការណ៍ពាក់ព័ន្ធ និងស្ថានភាពប្រទេសវេណេហ្ស៊ុយអេឡា ២០០៦
  https://t.ly/u8pZn
- សេចក្តីប្រកាសរបស់ប៉ាឡេស្ទីនទៅកាន់តុលាការព្រហ្មទណ្ឌអន្តរជាតិ ៖ ស្តីពីបញ្ហារដ្ឋ ២០០៩
  https://iccforum.com/media/background/gaza/2009-05-19_Quigley_Memo_on_Palestine_Declaration.pdf
- ដំណោះស្រាយក្រុមប្រឹក្សាសន្តិសុខក្នុងការស្វែងរកការពន្យាពេលការកាត់ក្តីរបស់មេដឹកនាំកេនយ៉ា ២០១៣
  https://shorturl.at/ikDZ8
- របាយការណ៍របស់អង្គមុនជំនុំជម្រះ ស្តីពីការជូនដំណឹងដល់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងសភានៃរដ្ឋភាគីអំពីការមិនសហការរបស់ ប្រទេសម៉ាឡាវី ក្នុងការចាប់ខ្លួន Omar Al Bashir ២០១១
  vhttps://www.icc-cpi.int/sites/default/files/CourtRecords/CR2011_21722.PDF
- សេចក្តីប្រកាសរដ្ឋាភិបាលអ៊ុយក្រែនស្តីពីការទទួលយកយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ២០១៤
  https://www.icccpi.int/sites/default/files/itemsDocuments/997/declarationRecognitionJuristiction09-04-2014.pdf
- ស្ថានភាពនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល ២ ជំពូកទី ៤ ចំណុច ៩ នៅក្នុងករណីរបស់រដ្ឋអាជ្ញា v. ALFRED YEKATOM និងPATRICE-EDOUARD NGAÏSSONA, ២០១៨
  https://icc-cpi.int/sites/default/files/CourtRecords/0902ebd1807def34.pdf

- របាយការណ៍ស្ដីពីស្ថានភាពប្រទេសអ៊ីរ៉ាក់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ២០២០
  https://shorturl.at/pX0mV
- កិច្ចព្រមព្រៀងរវាងការិយាល័យរបស់រដ្ឋអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិ និងប៉ូលិសឧក្រិដ្ឋកម្មអន្តរជាតិ
- http://surl.li/zalrbg

## ៤.គេហទំព័រ

- គេហទំព័រ គណកម្មាធិការអន្តរជាតិនៃកាកបាទក្រហម បោះផ្សាយ ១៩៩៧
  https://www.icrc.org/en/doc/resources/documents/article/other/57jp4m.htm
- គេហទំព័រ ការវិវត្តន៍នៃយុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ
  https://www.aba-icc.org/about-the-icc/evolution-of-international-criminal-justice/
- គេហទំព័រ សារមន្ទីរ រំលឹកការសម្លាប់សម្លាប់រង្គាល នៅសហរដ្ឋអាមេរិក បោះផ្សាយ ២០២៣
  https://rb.gy/027nop
- គេហទំព័រ បេសកកម្មអចិន្ត្រៃយ៍របស់ប្រទេសបារាំងទៅអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក ២០២៣
  https://t.ly/uc4-S
- គេហទំព័រផ្លូវការសម្ព័ន្ធសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ
  https://www.coalitionfortheicc.org/explore/20-icc-benefits
- គេហទំព័រផ្លូវការ របស់អង្គការសហប្រជាជាតិស្ដីពីតួនាទីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ  ក្នុងការបញ្ចប់និទណ្ឌភាព និងការបង្កើតនីតិរដ្ឋ
  https://shorturl.at/JH317
- គេហទំព័រសហព័ន្ធអន្តរជាតិសម្រាប់សិទ្ធិមនុស្ស
  https://t.ly/s00EI
- តារាងបញ្ជីឈ្មោះ ជនដែលត្រូវបានតុលាការចោទប្រកាន់ ថាបានប្រព្រឹត្តបទល្មើសស្ថិតក្នុងយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ
  Defendants | International Criminal Court (icc-cpi.int)។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## តារាងឧបសម្ព័ន្ធ៖

ឧបសម្ព័ន្ធទី ១៖ ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ២០០២

ឧបសម្ព័ន្ធទី ២៖ វិធាននៃនីតិវិធី និងភស្តុតាង ២០១៣

ឧបសម្ព័ន្ធទី ៣៖ សៀវភៅ៉មកដឹងអំពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ២០២១

ឧបសម្ព័ន្ធទី ៤៖ អនុសញ្ញាក្រុងវីយែនស្តីពីទំនាក់ទំនងការទូត ១៩៦៥

ឧបសម្ព័ន្ធទី ៥៖ រដ្ឋធម្មនុញ្ញអង្គការសហប្រជាជាតិ ១៩៤៥

ឧបសម្ព័ន្ធទី ៦៖ អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ១៩៥៣

ឧបសម្ព័ន្ធទី ៧៖ ឯកសារគោលនយោបាយស្តីពីការពិនិត្យបឋម តុលាការព្រហ្មទណ្ឌអន្តរជាតិឆ្នាំ ២០១៣

ឧបសម្ព័ន្ធទី ៨៖ ច្បាប់ស្តីពីការិយាល័យរដ្ឋអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ២០០៩

ឧបសម្ព័ន្ធទី ៩៖ សៀវភៅណែនាំអំពីការអនុវត្តមុនជំនុំជម្រះ ២០១៥ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

ឧបសម្ព័ន្ធទី ១០៖ របាយការណ៍របស់អង្គមុនជំនុំជម្រះ ស្តីពីការជូនដំណឹងដល់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងសភានៃរដ្ឋភាគីអំពីការមិនសហការរបស់ ប្រទេសម៉ាឡាវី ក្នុងការចាប់ខ្លួន Omar Al Bashir ២០១១

ឧបសម្ព័ន្ធទី ១១៖ សៀវភៅ ការអនុវត្តច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ២០១៥ ដោយ មេធាវី Beth Van Schaack និងសាស្ត្រាចារ្យ Ronald Slye

ឧបសម្ព័ន្ធទី ១២៖ តារាងបញ្ជីឈ្មោះ ជនដែលត្រូវបានតុលាការចោទប្រកាន់ ថាបានប្រព្រឹត្តបទល្មើសស្ថិតក្នុងយុត្តាធិការរបស់តុលាការ

ឧបសម្ព័ន្ធទី ១៖



# ព្រះរាជក្រម

នស/រកម/០១០២/០០៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល-កម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើលក្ខន្តិកៈទីក្រុងរ៉ូមស្តីពី តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យ ប្រជុំពេញអង្គលើក ទី ៦ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើលក្ខន្តិកៈទីក្រុងរ៉ូម
# ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ

មាត្រា ១.-

អនុម័តយល់ព្រមលើលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលធ្វើនៅទីក្រុងរ៉ូមប្រទេសអ៊ីតាលី នាថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តលក្ខន្តិកៈទីក្រុងរ៉ូមនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមករា ឆ្នាំ ២០០២

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

នស.០៧.០១-០០៦

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា

សុខ អាន

លេខ : ០៩ ច.ល

ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

-លក្ខន្តិកៈនីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ

- Rome Statute of the International Criminal Court

- Statut de Rome de la Cour Pénale Internationale

# លក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ

## បុព្វកថា

ដោយមានមនសិការថា មនុស្សទាំងអស់បានរួបរួមគ្នាជាផ្លុងមួយ វប្បធម៌របស់មនុស្សបានចូលរួមផ្សំគ្នានៅក្នុងកេរ្តិ៍ដំណែលរួម និងដោយមានការព្រួយបារម្ភថា បណ្តុំនៃរូបគំនូរតូចៗដែលមិនមានលក្ខណៈមាំមួននេះ អាចនឹងត្រូវបានបំបែក ចេញពីគ្នានៅពេលណាមួយ ។

ដោយយកចិត្តទុកដាក់ថា ក្នុងកំឡុងពេលនៃសតវត្សនេះ កុមារ ស្ត្រី និងបុរស រាប់លាននាក់បានរងគ្រោះ ដោយសារអំពើឃោរឃៅដែលមិនអាចស្មានដល់ ដែលធ្វើឱ្យមនសិការរបស់មនុស្សជាតិមានការតក់ស្លុតយ៉ាងខ្លាំង ។

ដោយទទួលស្គាល់ថា បទល្មើសព្រហ្មទណ្ឌដ៏ធ្ងន់ធ្ងរទាំងឡាយគំរាមកំហែងដល់សន្តិភាព សន្តិសុខ និងសុខមាលភាពពិភពលោក ។

ដោយមានការអះអាងថា បទល្មើសព្រហ្មទណ្ឌដ៏ធ្ងន់ធ្ងរបំផុតធ្វើឱ្យមានការព្រួយបារម្ភដល់សហគមអន្តរជាតិទាំងមូល មិនត្រូវរួចផុតពីការដាក់ទណ្ឌកម្មនឹងត្រូវតែធ្វើឱ្យប្រាកដថា មានការនាំយកមកជំនុំជំរះដែលមានប្រសិទ្ធភាព តាមរយៈការចាត់វិធានការនៅថ្នាក់ជាតិ និងតាមរយៈការធ្វើឱ្យកិច្ចសហប្រតិបត្តិការអន្តរជាតិ កាន់តែបានប្រសើរឡើង ។

ដោយមានការប្តេជ្ញាចិត្ត បញ្ចប់និទណ្ឌភាពចំពោះជនដៃដល់ដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌទាំងនោះ ហើយដូច្នេះ រួមចំណែកទប់ស្កាត់នូវបទល្មើសព្រហ្មទណ្ឌទាំងនេះ ។

ដោយចងចាំថា នេះជាភារកិច្ចរបស់រដ្ឋនីមួយៗក្នុងការអនុវត្តយុត្តាធិការព្រហ្មទណ្ឌរបស់ខ្លួនលើអ្នកទាំងឡាយទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌអន្តរជាតិទាំងនោះ ។

ដោយមានការបញ្ជាក់អះអាងឡើងវិញពីគោលបំណង និងគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ និងជាពិសេស រដ្ឋទាំងអស់ត្រូវទប់ខ្លួនពីការធ្វើការគំរាមកំហែង ឬពីការប្រើប្រាស់កម្លាំងប្រឆាំងនឹងបូរណភាពដែនដី ឬឯករាជ្យភាពខាងនយោបាយរបស់រដ្ឋណាមួយ ឬក្នុងឥរិយាបថណាផ្សេងទៀត ដែលមិនស្របទៅនឹងគោលបំណងរបស់អង្គការសហប្រជាជាតិ ។

ដោយការសង្កត់ធ្ងន់ក្នុងទំនាក់ទំនងនេះថា គ្មានអ្វីមួយនៅក្នុងច្បាប់លក្ខន្តិកៈនេះ ត្រូវបានចាត់ទុកជាការអនុវត្តឱ្យរដ្ឋភាគីណាមួយទៅធ្វើអន្តរាគមន៍ក្នុងជម្លោះប្រដាប់អាវុធ នៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋណាមួយឡើយ ។

ដោយមានការប្តេជ្ញាចិត្តបញ្ចប់អំពើទាំងនេះ និងសម្រាប់ជាគុណប្រយោជន៍ដល់ជនតាបច្ចុប្បន្ន និងអនាគត បង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ឯករាជ្យមួយ ដែលមានទំនាក់ទំនងជាមួយប្រព័ន្ធអង្គការសហប្រជាជាតិដែលមានយុត្តាធិការលើបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរបំផុត ដែលសហគមអន្តរជាតិទាំងមូលមានការព្រួយបារម្ភ ។ ដោយមានការសង្កត់ធ្ងន់ថា តុលាការព្រហ្មទណ្ឌអន្តរជាតិដែលបានបង្កើតឡើងតាមច្បាប់លក្ខន្តិកៈនេះត្រូវជាការបន្ថែមលើ យុត្តាធិការព្រហ្មទណ្ឌអន្តរជាតិ ។ បានសម្រេចចិត្តធានាការគោរពជារៀងរហូតតាមការដាក់ឱ្យអនុវត្តនូវយុត្តិធម៌អន្តរជាតិ ។

បានព្រមព្រៀងគ្នាដូចតទៅនេះ :

ឧបសម្ព័ន្ធទី ២៖


Cour
Pénale
Internationale
International
Criminal
Court
Rules
of
Procedure
and Evidence

ឧបសម្ព័ន្ធទី ៣៖


Cour
Pénale
Internationale
International
Criminal
Court
Helping build
a more just world
Understanding
the International
Criminal Court

ឧបសម្ព័ន្ធទី ៥៖



# ព្រះរាជក្រម

នស/រកម/០៤០៥/០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋា-ភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៥ នាសម័យ ប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល

**មាត្រា ១.-**

អនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ដែលធ្វើនៅទីក្រុងវីយែន នាថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៦៣ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស.០៥០៤.១៧៨

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង
សហប្រតិបត្តិការអន្តរជាតិ
ហត្ថលេខា
ហោ ណាំហុង

លេខ ៥២ ខ.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឧបសម្ព័ន្ធទី ៥៖

# ធម្មនុញ្ញសហប្រជាជាតិ

# Charter of the United Nations

បណ្ណាល័យច្បាប់-Law Library

lawlibrarysite.wordpress.com

ឧបសម្ព័ន្ធទី ៦៖


European Convention
on Human Rights
EUROPEAN COURT OF HUMAN RIGHTS
COUR EUROPÉENNE DES DROITS DE L'HOMME
COUNCIL OF EUROPE
CONSEIL DE L'EUROPE

ឧបសម្ព័ន្ធទី ៧៖

Cour
Pénale
Internationale

International
Criminal
Court

Le Bureau du Procureur
The Office of the Prosecutor

**Policy Paper on Preliminary Examinations**

**November 2013**

ឧបសម្ព័ន្ធទី ៨៖


Cour
Pénale
Internationale

International
Criminal
Court

Regulations
of the
Office of the
Prosecutor

ឧបសម្ព័ន្ធទី ៩៖

Cour
Pénale
Internationale

International
Criminal
Court

# PRE-TRIAL PRACTICE MANUAL

**September 2015**

ឧបសម្ព័ន្ធទី ១០៖



Cour
Pénale
Internationale

International
Criminal
Court

Original: English

No.: ICC-02/05-01/09
Date: 12 December 2011

**PRE-TRIAL CHAMBER I**

**Before:** Judge Sanji Mmasenono Monageng, Presiding Judge
Judge Sylvia Steiner
Judge Cuno Tarfusser

**SITUATION IN DARFUR, SUDAN**

***THE PROSECUTOR V. OMAR HASSAN AHMAD AL BASHIR***

**Public Document**

**Decision Pursuant to Article 87(7) of the Rome Statute on the Failure by the Republic of Malawi to Comply with the Cooperation Requests Issued by the Court with Respect to the Arrest and Surrender of Omar Hassan Ahmad Al Bashir**

ឧបសម្ព័ន្ធទី ១១៖


INTERNATIONAL
CRIMINAL LAW AND
ITS ENFORCEMENT
CASES AND MATERIALS
THIRD EDITION
BETH VAN SCHAACK
RONALD C. SLYE

ឧបសម្ព័ន្ធទី ១២៖

| ឈ្មោះ | ដីកា | បទល្មើស | ស្ថានភាព |
|---|---|---|---|
| Abu Garda, Bahar Idriss<br>តួនាទី៖ ប្រធាន និងជាអ្នកសម្របសម្រួលទូទៅនៃប្រតិបត្តិការយោធានៃរណសិរ្សតស៊ូរួបរួម | ដីកាកោះហៅឱ្យបង្ហាញខ្លួន៖<br>៧ ឧសភា ឆ្នាំ ២០០៩ | ឧក្រិដ្ឋកម្មសង្គ្រាម | ករណីបិទ<br>(អង្គមុនជំនុំជម្រះសម្រេចចិត្តមិនបញ្ជាក់ការចោទប្រកាន់) |
| Ag Abdoul Aziz, Al Hassan<br>តួនាទី៖ ជាប្រធានប៉ូលិសអ៊ិស្លាម | ដីកាចាប់ខ្លួន៖<br>២៧ មីនា ២០១៨ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | ស្ថិតក្នុងដំណាក់ជម្រះក្តី |
| Ag Ghaly, Iyad<br>តួនាទី៖ មេដឹកនាំឧទ្ទាមក្រុមអ៊ីស្លាមនិយម | ដីកាចាប់ខ្លួន៖<br>១៨ កក្កដា ឆ្នាំ ២០១៧ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ<br>ឧក្រិដ្ឋកម្មសង្គ្រាម | គេចខ្លួន |
| Al Bashir, Omar Hassan Ahmad<br>តួនាទី៖ ប្រធានាធិបតីនៃសាធារណរដ្ឋស៊ូដង់ | ដីកាចាប់ខ្លួន៖<br>៤ មីនា ឆ្នាំ ២០០៩ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | គេចខ្លួន |
| Al Faqi Al Mahdi, Ahmad<br>តួនាទី៖ សមាជិករបស់ Ansar Eddine | ដីកាចាប់ខ្លួន៖<br>២៨ កញ្ញា ឆ្នាំ ២០១៥ | ឧក្រិដ្ឋកម្មសង្គ្រាម | បានកាត់ទោស |
| Al-Senussi, Abdullah<br>តួនាទី៖ វរសេនីយ៍ឯកនៅក្នុងកងកម្លាំងប្រដាប់អាវុធលីប៊ី និងជាប្រធានផ្នែកស៊ើបការណ៍យោធា | ដីកាចាប់ខ្លួន៖<br>២៧ មិថុនា ឆ្នាំ ២០១១ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | ករណីបិទ<br>(តុលាការច្រានចោលសំណុំរឿង) |
| Al-Werfalli, Mahmoud Mustafa Busayf<br>តួនាទី៖ មេបញ្ជាការកងពលតូច Al-Saiqa | ដីកាចាប់ខ្លួន៖<br>១៥ សីហា ឆ្នាំ ២០១៧ | ឧក្រិដ្ឋកម្មសង្គ្រាម | ករណីបិទ<br>(មរណភាព) |

| | | | |
|---|---|---|---|
| Alekseyevna Lvova-Belova, Maria<br>តួនាទី៖ ស្នងការទទួលបន្ទុកសិទ្ធិកុមារនៅការិយាល័យប្រធានាធិបតីនៃសហព័ន្ធរុស្ស៊ី។ | ដីកាចាប់ខ្លួន៖ ១៧ មីនា ឆ្នាំ ២០២៣ | ឧក្រិដ្ឋកម្មសង្គ្រាម | គេចខ្លួន |
| Ali, Mohamed Hussein<br>តួនាទី៖ នាយកប្រតិបត្តិនៃសាជីវកម្មប្រៃសណីយ៍នៃប្រទេសកេនយ៉ា និងជាស្នងការប៉ូលិសកេនយ៉ា | ដីកាកោះហៅឱ្យបង្ហាញខ្លួន ៖ ៨ មីនា ២០១១ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | ករណីបិទ (ភស្តុតាងមិនគ្រប់គ្រាន់) |
| Ali Abd-Al-Rahman, Ali Muhammad<br>តួនាទី៖ មេដឹកនាំដែលត្រូវបានចោទប្រកាន់នៃកងជីវពល Janjaweed | ដីកាចាប់ខ្លួន៖ ២៧ មេសា ២០០៧ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ<br>ឧក្រិដ្ឋកម្មសង្គ្រាម | ស្ថិតក្នុងដំណាក់កាលជម្រះក្តី |
| Arido, Narcisse<br>តួនាទី៖ មេធាវី របស់ Jean-Pierre<br>Bemba Gombo | ដីកាចាប់ខ្លួន៖ ២០ វិច្ឆិកា ២០១៣ | ការផ្តល់សក្ខីកម្មមិនពិតរបស់សាក្សីក្នុងសំណុំរឿង Bemba | បានកាត់ទោស |
| Babala Wandu, Fidèle<br>តួនាទី៖ សមាជិកសភានៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ | ដីកាចាប់ខ្លួន៖ ២០ វិច្ឆិកា ២០១៣ | ការផ្តល់សក្ខីកម្មមិនពិតរបស់សាក្សីក្នុងសំណុំរឿង Bemba | បានកាត់ទោស |
| Banda Abakaer Nourain, Abdallah<br>តួនាទី៖ អគ្គមេបញ្ជាការនៃយុត្តិធម៌ និងសមភាព *Mouvement Collective-Leadership* | ដីកាកោះហៅឱ្យបង្ហាញខ្លួន៖ ២៧ សីហា ឆ្នាំ ២០០៩ | ឧក្រិដ្ឋកម្មសង្គ្រាម | គេចខ្លួន |

| | | | |
|---|---|---|---|
| Barasa, Walter Osapiri<br>តួនាទី៖ គឺជាអ្នកសារព័ត៌មាន និងជាអន្តរការីពីមុនរវាងការិយាល័យ ICC នៃរដ្ឋអាជ្ញា និងសាក្សីកេនយ៉ាក្នុងការស៊ើបអង្កេតលើស្ថានភាពនៅប្រទេសកេនយ៉ា។ | ដីកាចាប់ខ្លួន៖ ០២ សីហា ឆ្នាំ ២០១៣ | បទល្មើសចំនួនបីប្រឆាំងនឹងរដ្ឋបាលយុត្តិធម៌ | គេចខ្លួន |
| Jean-Pierre Bemba Gombo<br>តួនាទី៖ ប្រធានាធិបតី និងជាអគ្គមេបញ្ជាការនៃ *(Movement for the Liberation of Congo)* | ដីកាចាប់ខ្លួន៖ ២០ វិច្ឆិកា ឆ្នាំ ២០១៣ | បទល្មើសប្រឆាំងនឹងការគ្រប់គ្រងយុត្តិធម៌ រួមទាំងអំពើពុករលួយដែលមានឥទ្ធិពលលើសាក្សីនៅក្នុងសំណុំរឿង Bemba | បានកាត់ទោស |
| Bett, Philip Kipkoech<br>តួនាទី៖ មេធាវី ក្នុងសំណុំរឿង William Samoei Ruto និង Joshua Arap Sang | ដីកាចាប់ខ្លួន៖ ១០ មីនា ឆ្នាំ ២០១៥ | បទល្មើសប្រឆាំងនឹងការគ្រប់គ្រងយុត្តិធម៌ដែលមាននៅក្នុងអំពើពុករលួយដែលមានឥទ្ធិពលលើសាក្សីទាក់ទងនឹងករណីពីស្ថានភាពនៅក្នុងប្រទេសកេនយ៉ា | គេចខ្លួន |
| Blé Goudé, Charles<br>តួនាទី៖ អតីតរដ្ឋមន្ត្រីក្រសួងយុវជន<br>និងជាអ្នកនយោបាយ កូឌីវ័រ | ដីកាចាប់ខ្លួន ៖២១ ធ្នូ ឆ្នាំ ២០១១ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | កាត់ទោស សំណុំរឿងបិទ |
| Gaddafi, Muammar Mohammed Abu Minyar<br>តួនាទី៖ ប្រមុខរដ្ឋលីប៊ី ហើយជាមេបញ្ជាការនៃកងកម្លាំងប្រដាប់អាវុធនៃប្រទេសលីប៊ី និងកាន់តំណែងជាមេដឹកនាំបដិវត្តន៍ | ដីកាចាប់ខ្លួន៖ ២៧ មិថុនា ឆ្នាំ ២០១១ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | ករណីបិទ (មរណភាព) |

| | | | |
|---|---|---|---|
| Gaddafi, Saif Al-Islam<br>តួនាទី៖ ប្រធានកិត្តិយសនៃមូលនិធិសប្បុរសធម៌ និងអភិវឌ្ឍន៍អន្តរជាតិ Gaddafi និងដើរតួជានាយករដ្ឋមន្ត្រីលីប៊ី | ដីកាចាប់ខ្លួន៖<br>២៧ មិថុនា<br>២០១១ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | គេចខ្លួន |
| Gbagbo, Laurent<br>អតីតប្រធានាធិបតីរបស់ប្រទេសកូតឌីវ័រ<br>Charles Blé Goudé<br>មេដឹកនាំយុវជន កូតឌីវ័រ | ដីកាចាប់ខ្លួន៖<br>២៣ វិច្ឆិកា ឆ្នាំ<br>២០១១,<br>២១ វិច្ឆិកា ឆ្នាំ<br>២០១១ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | កាត់ទោស<br>រួចរាល់ |
| Simone Gbagbo<br>ជាប្រធានក្រុមសភានៃរណសិរ្សប្រជាប្រិយប្រទេសកូតឌីវ័រ | ដីកាចាប់ខ្លួន៖ថ្ងៃទី ២៩ កុម្ភៈ ឆ្នាំ<br>២០១១ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | អង្គមុនជំនុំជម្រះបដិសេធចោលដីការចាប់តាមសំណើរដ្ឋអាជ្ញា |
| Georgiyevich Sanakoev,<br>អតីតតំណាងប្រធានាធិបតីទទួលបន្ទុកសិទ្ធិមនុស្សនៃរដ្ឋបាលប្រទេសហ្សកហ្ស៊ី | ដីកាចាប់ខ្លួន៖<br>៣០ មិថុនា ឆ្នាំ<br>២០២២ | ឧក្រិដ្ឋកម្មសង្គ្រាម | គេចខ្លួន |
| Gicheru, Paul<br>មេធាវីមានមូលដ្ឋាននៅប្រទេសកេនយ៉ា ពាក់ព័ន្ធ និងករណីក្នុងការចោទប្រកាន់ប្រឆាំងលោក Philip Kipkoech Bett | ដីកាចាប់ខ្លួន៖<br>១០ មីនា ឆ្នាំ<br>២០១៥ | បទល្មើសប្រឆាំងរដ្ឋបាលយុត្តិធម៌ | អង្គជំនុំជម្រះដំបូង បានបញ្ចប់ដំណើរការនីតិវិធី បន្ទាប់ ពីការស្លាប់របស់គាត់ |

| | | | |
|---|---|---|---|
| Guchmazov, Gamlet<br>គាត់គឺជាប្រធានមន្ទីរឃុំឃាំងបឋម នៅ Tskhinvali ប្រទេសហ្សកហ្ស៊ី | ដីកាចាប់ខ្លួន៖ ៣០ មិថុនា ឆ្នាំ ២០២២ | ឧក្រិដ្ឋកម្មសង្គ្រាម | គេចខ្លួន |
| Harun, Ahmad Muhammad<br>រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនៃរដ្ឋាភិបាល ប្រទេសស៊ូដង់ | ដីកាចាប់ខ្លួន៖ ២៧ មេសា ឆ្នាំ ២០០៧ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | គេចខ្លួន |
| Hussein, Abdel Raheem Muhammad<br>រដ្ឋមន្ត្រីក្រសួងការពារជាតិ (អតីតរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាអតីតតំណាងពិសេសរបស់ប្រធានាធិបតីស៊ូដង់នៅដាហ្វួរ) | ដីកាចាប់ខ្លួន៖ ០១ មីនា ឆ្នាំ ២០១២ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម | គេចខ្លួន |
| Ivanovich Kobylash, Sergei<br>ឧត្តមសេនីយ៍ឯកនៅក្នុងកងកម្លាំងប្រដាប់អាវុធរុស្ស៊ី | ដីកាចាប់ខ្លួន៖ ៥ មីនា ឆ្នាំ ២០២៤ | ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | គេចខ្លួន |
| Jerbo Jamus, Saleh Mohammed<br>អគ្គមេបញ្ជាការនៃយុត្តិធម៌ និងសមភាព ប្រទេសស៊ូដង់ | ដីកាចាប់ខ្លួន៖ ១១ កញ្ញា ២០១៤ | ឧក្រិដ្ឋកម្មសង្គ្រាម | អង្គជំនុំជម្រះដំបូងបានបញ្ចប់ ថ្ងៃទី ៤ ខែតុលាឆ្នាំ ២០១៣ បន្ទាប់ពីគាត់បានស្លាប់ |
| Katanga, Germain<br>មេបញ្ជាការរងការចោទប្រកាន់នៃកងកម្លាំងការពារស្នេហាជាតិប្រទេសកុងហ្គោ (FRPI) | ដីកាចាប់ខ្លួន៖ ២ កក្កដា ឆ្នាំ ២០០៧ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម | កាត់ទោសរួចរាល់ |

| | | | |
|---|---|---|---|
| Kenyatta, Uhuru Muigai<br>ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ | ដីកាកោះហៅឱ្យបង្ហាញខ្លួន៖០៨ មីនា ឆ្នាំ ២០១១ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | អង្គជំនុំជម្រះដំបូងបដិសេធការចោទប្រកាន់ |
| Khaled, Al-Tuhamy Mohamed<br>អតីតឧត្តមសេនីយឯកនៃកងទ័ពលីប៊ី និងជាអតីតប្រធានទីភ្នាក់ងារសន្តិសុខផ្ទៃក្នុងលីប៊ី | ដីកាចាប់ខ្លួន៖ ១៨ មេសា ឆ្នាំ ២០១៣ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម | អង្គមុនជំនុំជម្រះបានបញ្ចប់ នីតិវិធីបន្ទាប់ពីការស្លាប់របស់គាត់ |
| Kilolo Musamba, Aimé<br>អតីតមេធាវីការពារក្តីរបស់ Jean-Pierre Bemba Gombo | ដីកាចាប់ខ្លួន៖ ២០ វិច្ឆិកា ឆ្នាំ ២០១៣ | បទល្មើសប្រឆាំងនឹងរដ្ឋបាលយុត្តធម៌នឹងការផ្តល់សក្ខីកម្មមិនពិត | កំពុងអនុវត្តទោស |
| Kony, Joseph<br>អគ្គមេបញ្ជាការរងនៃកងទ័ពតស៊ូរបស់ព្រះអង្គម្ចាស់ ប្រទេសអ៊ូហ្គង់ដា | ដីកាចាប់ខ្លួន៖ ៨ កក្កដា ឆ្នាំ ២០០៥ | ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | គេចខ្លួន |
| Jerbo Jamus, Saleh Mohammed<br>អគ្គមេបញ្ជាការនៃយុត្តិធម៌ និងសមភាព ប្រទេសស៊ូដង់ | ដីកាចាប់ខ្លួន៖ ១១ កញ្ញា ឆ្នាំ ២០១៤ | ឧក្រិដ្ឋកម្មសង្គ្រាម | អង្គជំនុំជម្រះដំបូងបានបញ្ចប់ ថ្ងៃទី ៤ ខែតុលាឆ្នាំ ២០១៣ បន្ទាប់ពីគាត់បានស្លាប់ |
| Kosgey, Henry Kiprono<br>រដ្ឋមន្ត្រីក្រសួងឧស្សាហូបនីយកម្មកេនយ៉ា សមាជិកសភាសម្រាប់មណ្ឌលបោះឆ្នោត Tinderet ប្រធាន ODM ប្រទេសកេនយ៉ា | ដីកាកោះហៅឱ្យចូលខ្លួន៖ ៨ មីនា ឆ្នាំ ២០១១ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | អង្គជំនុំជម្រះដំបូងបានច្រានចោលការចោទប្រកាន់ភស្តុតាងមិនគ្រប់គ្រាន់ |

| | | | |
|---|---|---|---|
| Kuzhugetovich Shoigu, Sergei<br>ជារដ្ឋមន្ត្រីក្រសួងការពារជាតិនៃសហព័ន្ធរុស្ស៊ី | ដីកាចាប់ខ្លួន៖ ២៤ មិថុនា ឆ្នាំ ២០២៤ | ឧក្រិដ្ឋកម្មសង្គ្រាម | គេចខ្លួន |
| Lubanga Dyilo, Thomas<br>អតីតប្រធានសហភាពអ្នកស្នេហាជាតិកុងហ្គោ | ដីកាចាប់ខ្លួន៖ ១០ កុម្ភៈ ឆ្នាំ ២០០៦ | ឧក្រិដ្ឋកម្មសង្គ្រាម | កាត់ទោសរួចរាល់ |
| Lukwiya, Raska<br>មេបញ្ជាការរងកងទ័ពនៃកងទ័ពតស៊ូរបស់ព្រះអង្គម្ចាស់ប្រទេសអ៊ូហ្គង់ដា | ដីកាចាប់ខ្លួន៖ ថ្ងៃទី៨ កក្កដា ឆ្នាំ ២០០៥ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម | អង្គមុនជំនុំជម្រះបានបញ្ចប់ នីតិវិធីបន្ទាប់ពីការស្លាប់របស់គាត់ |
| Mangenda Kabongo, Jean-Jacques<br>អតីតសមាជិកក្រុមការពារជាតិរបស់ប្រទេសកុងហ្គោ | ដីកាចាប់ខ្លួន៖ ២០ វិច្ឆិកា ឆ្នាំ ២០១៣ | បទល្មើសប្រឆាំងនឹងរដ្ឋបាលយុត្តធម៌នឹងការផ្តល់សក្ខីកម្មមិនពិត | កាត់ទោសរួចរាល់ |
| Mayramovich Mindzaev, Mikhail<br>ជាមន្ត្រីប៉ូលិសជាន់ខ្ពស់ជាមួយក្រសួងកិច្ចការផ្ទៃក្នុងនៃប្រទេសរុស្ស៊ី និង(២០០៨)រដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុងនៃរដ្ឋបាល South Ossetian | ដីកាចាប់ខ្លួន៖ ២៤មិថុនា ឆ្នាំ ២០២២ ; កំណែប្រែឡើងវិញ៖ ៣០ មិថុនា ឆ្នាំ ២០២២ | ឧក្រិដ្ឋកម្មសង្គ្រាម | គេចខ្លួន |
| Mbarushimana, Callixte<br>លេខាធិការប្រតិបត្តិនៃកងកម្លាំងប្រជាធិបតេយ្យ ប្រទេសរ៉ាន់ដា | ដីកាចាប់ខ្លួន៖ ២៥ កញ្ញា ឆ្នាំ ២០១០ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម | អង្គមុនជំនុំជម្រះបានសម្រេចដោយភាគច្រើន បដិសេធមិនបញ្ជាក់ពីការចោទប្រកាន់ |

| | | | |
|---|---|---|---|
| Mokom Gawaka, Maxime Jeoffroy Eli<br>អតីតអ្នកសម្របសម្រួលជាតិនៃប្រតិបត្តិការប្រឆាំងបាឡាកា នៃសាធារណរដ្ឋអាហ្វ្រិកកណ្តាល | ដីកាចាប់ខ្លួនៈ ១០ ធ្នូ ឆ្នាំ២០១៨ | ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | អង្គមុនជំនុំជម្រះបានបញ្ចប់ដំណើរការនីតិវិធីក្នុងសំណុំរឿងនេះ បន្ទាប់ពីការជូនដំណឹងពីអយ្យការអំពីការដកការចោទប្រកាន់ |
| Mudacumura, Sylvestre<br>មេបញ្ជាការកំពូលនៃកងកម្លាំងប្រជាធិបតេយ្យ ប្រទេសរវ៉ាន់ដា | ដីកាចាប់ខ្លួនៈ ១៣ កក្កដា ឆ្នាំ ២០១២ | ឧក្រិដ្ឋកម្មសង្គ្រាម | គេចខ្លួន |
| Muthaura, Francis Kirimi<br>ប្រធានសេវាសាធារណៈ និងជាលេខាធិការខុទ្ទកាល័យ និងជាប្រធានគណៈកម្មាធិការប្រឹក្សាសន្តិសុខជាតិប្រទេសកេនយ៉ា | ដីកាកោះហៅឱ្យចូលខ្លួនៈ ០៨ មីនា ២០១១ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | អង្គជំនុំជម្រះដំបូងបានសម្រេចចិត្តបញ្ចប់ការចោទប្រកាន់នេះ។ ដោយការដកខ្លួនរបស់អយ្យការលើការចោទប្រកាន់ |
| Ngaïssona, Patrice-Edouard<br>គឺជាអតីតរដ្ឋមន្ត្រីកីឡាអាហ្វ្រិកកណ្តាល ប្រធានសហព័ន្ធបាល់ទាត់អាហ្វ្រិកកណ្តាល និងជាអ្នកដឹកនាំ Anti-balaka | ដីកាចាប់ខ្លួនៈ ០៧ ធ្នូ ឆ្នាំ ២០១៨ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម | ស្ថិតក្នុងដំណាក់កាលជម្រះក្តី |
| Ngudjolo Chui, Mathieu<br>មេដឹកនាំនៃរណសិរ្សជាតិនិយម ប្រទេស កុងហ្គោ | ដីកាចាប់ខ្លួនៈ ០៦ កក្កដា ឆ្នាំ ២០០៧ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម | ដោះលែងដោយអង្គជំនុំជម្រះឧទ្ធរណ៍ |

| | | | |
|---|---|---|---|
| Nikolayevich Sokolov, Viktor<br>ឧត្តមនាវីឯកនៅក្នុងកងនាវាចររុស្ស៊ី | ដីកាចាប់ខ្លួន៖<br>០៥ មិនា<br>ឆ្នាំ២០២៤ | ឧក្រិដ្ឋកម្មសង្គ្រាម | គេចខ្លួន |
| Nouradine Adam, Mahamat<br>អតីតរដ្ឋមន្ត្រីក្រសួងសន្តិសុខ អន្តោប្រវេសន៍ អន្តោប្រវេសន៍ និង សណ្ដាប់ធ្នាប់សាធារណៈ សាធារណរដ្ឋអាហ្វ្រិកកណ្ដាល | ដីកាចាប់ខ្លួន៖<br>០៧ មករា<br>ឆ្នាំ ២០១៩ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ<br>និងឧក្រិដ្ឋកម្មសង្គ្រាម | គេចខ្លួន |
| Ntaganda, Bosco<br>អតីតអគ្គសេនាធិការរង និងជាមេបញ្ជាការប្រតិបត្តិការនៃកងកម្លាំងប្រទេសកុងហ្គោ | ដីកាចាប់ខ្លួន៖ ថ្ងៃទី ២២ ខែសីហា<br>ឆ្នាំ ២០០៦ | ឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | កំពុងអនុវត្តទោស |
| Odhiambo, Okot<br>មេបញ្ជាការរងកងទ័ពនៃកងទ័ពតស៊ូរបស់ព្រះអង្គម្ចាស់ ប្រទេសអ៊ូហ្គង់ដា | ដីកាចាប់ខ្លួន៖<br>០៨ កក្កដា<br>ឆ្នាំ២០០៥ | ឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | អង្គមុនជំនុំជម្រះបានបញ្ចប់ នីតិវិធីបន្ទាប់ពីការស្លាប់របស់គាត់ |
| Ongwen, Dominic<br>តួនាទី៖ មេបញ្ជាការកងពលតូចនៃកងពលតូច Sinia នៃកងទ័ពតស៊ូរបស់ព្រះអង្គម្ចាស់ (LRA) | ដីកាចាប់ខ្លួន៖<br>០៨ កក្កដា<br>ឆ្នាំ២០០៥ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ<br>និងឧក្រិដ្ឋកម្មសង្គ្រាម | កំពុងអនុវត្តទោស |
| Otti, Vincent<br>តួនាទី៖ មេបញ្ជាការទីពីរនៃកងទ័ពតស៊ូរបស់ព្រះអង្គម្ចាស់ (LRA) | ដីកាចាប់ខ្លួន៖<br>០៨ កក្កដា ឆ្នាំ<br>២០០៥ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ<br>និងឧក្រិដ្ឋកម្មសង្គ្រាម | សំណុំរឿងបិទបញ្ចប់<br>(មរណភាព) |

| | | | |
|---|---|---|---|
| Ruto, William Samoei<br>តួនាទី៖ រដ្ឋមន្ត្រីក្រសួងអប់រំឧត្តមសិក្សា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកេនយ៉ា | ដីកាកោះឱ្យចូលខ្លួន៖ ០៨ មីនា ឆ្នាំ ២០១១ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | អង្គជំនុំជម្រះដំបូងបដិសេធការចោទប្រកាន់ |
| Said Abdel Kani, Mahamat<br>តួនាទី៖ មេបញ្ជាកាជាតិនៃសាធារណរដ្ឋអាហ្វ្រិកកណ្តាល Seleka | ដីកាចាប់ខ្លួន៖ ០៧ មករា ឆ្នាំ ២០១៩ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម | កំពុងជម្រះក្តី |
| Sang, Joshua Arap<br>តួនាទី៖ ប្រធានប្រតិបត្តិការនៅ Kass FMin Nairobi ប្រទេសកេនយ៉ា | ដីកាកោះហៅឱ្យបង្ហាញខ្លួន៖០៨ មីនា ឆ្នាំ២០១១ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ | អង្គជំនុំជម្រះដំបូងបដិសេធការចោទប្រកាន់ |
| Vasilyevich Gerasimov, Valery<br>តួនាទី៖ ប្រធានអគ្គសេនាធិការនៃកងកម្លាំងប្រដាប់អាវុធនៃសហព័ន្ធរុស្ស៊ីនិងជាអនុរដ្ឋមន្ត្រីក្រសួងការពារជាតិទីមួយនៃសហព័ន្ធរុស្ស៊ី | ដីកាចាប់ខ្លួន៖ ២៤ មិថុនា ឆ្នាំ ២០២៤ | ឧក្រិដ្ឋកម្មសង្គ្រាម | គេចខ្លួន |
| Vladimirovich Putin, Vladimir<br>តួនាទី៖ ជាប្រធានាធិបតីសហព័ន្ធរុស្ស៊ី | ដីកាចាប់ខ្លួន៖ ១៧ មីនា ឆ្នាំ ២០២៣ | ឧក្រិដ្ឋកម្មសង្គ្រាម | គេចខ្លួន |
| Yekatom, Alfred<br>តួនាទី៖ អតីតមេបញ្ជាការនៅក្នុងចលនាប្រឆាំងបាឡាកា | ដីកាចាប់ខ្លួន៖១១ វិច្ឆិកា ឆ្នាំ ២០១៨ | ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម | ស្ថិតក្នុងដំណាក់កាលជម្រះក្តី |
| **ជនដែលត្រូវបាននាំមកជំនុំជម្រះសរុប** | **៥៨ នាក់** | | |